សាកលវិទ្យាល័យជាតិគ្រប់គ្រង
NATIONAL UNIVERSITY OF MANAGEMENT

# រដ្ឋបាលសាធារណៈ

បណ្ឌិត សេង ប៊ុនធឿន

ព.ស 2565-គ.ស 2021

លេខៈ ០៧២/២១ ស.ជ.គ.

# លិខិតឧទ្ទេសនាម

មន្ត្រីរាជការ និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការនិពន្ធ និងត្រួតពិនិត្យលើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅកម្រិតឧត្តមសិក្សា ដែលមានចំណងជើងថា "**ប្រវត្តិភូមិសមរលោរ សមរខ្មែរ និងសមរចិន**"៖

ក. គណៈកម្មការនិពន្ធ ឬអ្នកនិពន្ធ

១. លោកបណ្ឌិត សេង ប៊ុនធឿន

ខ. គណៈកម្មការត្រួតពិនិត្យ ៖

១. ឯកឧត្តមបណ្ឌិត ហោ ប៉េង ប្រធាន

២. លោកបណ្ឌិត លី សុខហេង អនុប្រធាន

៣. លោកស្រី ប៉ុក ភារុន សមាជិក

គ. ការអនុញ្ញាតឲ្យបោះពុម្ពផ្សាយ ៖

ឯកឧត្តមបណ្ឌិត ហោ ប៉េង ជាសាកលវិទ្យាធិការ។

គណៈកម្មការ និងអ្នកនិពន្ធ ដូចមានរាយនាមខាងលើ មានភារកិច្ច និងអនុវត្តតាមលិខិតឧទ្ទេសនាមនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

*រាជធានីភ្នំពេញ* ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

បណ្ឌិត ហោ ប៉េង

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្ដូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-

Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិ គឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ពិសេសគឺគ្រឹះស្ថានឧត្តមសិក្សា

ត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាន នៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្សនិងនិស្សិតអាចទទួលបានពីគ្រូ នៅគ្រឹះស្ថានសិក្សាដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន

៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ ដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើបចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹក

កិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែ មានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និង

ស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀតជាពិសេស ការលៃលកចំណាយនៅក្នុងគ្រួសារ សម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការ វិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្ម លើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះ ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាមានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀន និងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បី

បង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀននិងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិតត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# ឧទ្ទិសស្នាដៃ

សូមឧទ្ទិសស្នាដៃនេះថ្វាយ និងជូនចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធវីរជនខ្មែរស្នេហាជាតិពិតប្រាកដ គ្រប់ជំនាន់ គ្រប់សម័យដែលបានបូជាជីវិតចំពោះជាតិ សាសនា និងព្រះមហាក្សត្រ។

ចំពោះវិញ្ញាណក្ខន្ធរបស់លោកប៉ា *សេង អ៊ិន* និងបងប្រុស *សេង សុធន់ )អេង(* ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ និងផ្តល់ដំបូន្មានល្អៗដល់កូន និងប្អូនក្នុងការសិក្សា។

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះអ្នកម្តាយ *កាក់ ជួង* បងស្រី*សេង សុខហេង* បងប្រុស*សេង ឆេងលាង សេង ឆេងឡៃ (ជួក) លឹម សុខន* បងស្រី *សេង ម៉េងហ៊ាង* ប្អូនស្រី*សេង ស៊ាងហៃ* ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ផ្តល់ដំបូន្មានល្អៗ និងលើកទឹកចិត្តដល់កូន ប្អូន បងឱ្យប្រព្រឹត្តតែអំពើល្អ និងស្រឡាញ់ការសិក្សា។

ក្រសួងអប់រំ យុវជន និង កីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយឧបត្ថម្ភគាំទ្រមូលនិធិក្នុងការតែងនិពន្ធ និងបោះពុម្ពផ្សាយសៀវភៅសម្រាប់កម្មវិធីសិក្សានេះ។

ឯកឧត្តមបណ្ឌិត *ហោ ប៉េង* សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចំពោះការជំរុញ និងលើកទឹកចិត្តយ៉ាងខ្លាំងដល់ការសិក្សាស្រាវជ្រាវដើម្បីបានជាស្នាដៃ និងប្រយោជន៍ដល់សង្គមជាតិទាំងមូល។

សូមថ្លែងអំណរអរគុណចំពោះឯកឧត្តមបណ្ឌិត *កុល ផេង* អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោកជំទាវបណ្ឌិតសភាចារ្យ *ខ្លូត ធីតា* ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឯកឧត្តមបណ្ឌិតសភាចារ្យ *ស៊ិនសំណាង* ប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា ដែលបានផ្តល់ដំបូន្មាន និងគាំទ្រឲ្យខិតខំស្រាវជ្រាវ និងបង្កើតស្នាដៃផ្សេងៗ។

សូមថ្លែងអំណរគុណ និងកោតសរសើរដ៏ស្មោះចំពោះក្មួយប្រុស*សេង វិជ្ជូរ អ៊ិន វុទ្ធី អ៊ិន ឡុង សេង វុត្ថា សេង ជាប៉ សេង សាកល* ក្មួយស្រី*អ៊ិន គាម អ៊ិន ស៊ីណា សេង ឡៃហួយ សេង ណារី លោក វង្ស គឹមសាន* និងលោក*ដឹង ផេងស្រួយ* ដែលបានជួយគាំទ្រដើម្បីឱ្យកិច្ចការនេះឈានដល់ទីបញ្ចប់។

សូមថ្លែងអំណរអរគុណប្រកបដោយក្តីរំភើបចំពោះឧត្តមភរិយា *ហៃហម ពេជ្របញ្ញា* និងបុត្រាជាទីស្រឡាញ់ *សេង ពេជ្រពុទ្ធិខេមរិន្ទ្រ សេង ពេជ្រពុទ្ធិវឌ្ឍនៈ* និង *សេង ពេជ្រពុទ្ធិវីរធន* ដែលជានិច្ចកាលតែងតែជាកម្លាំងចិត្តដល់ការស្រាវជ្រាវ និងរៀបរៀងសៀវភៅនេះ។

# អារម្ភកថា

សៀវភៅរដ្ឋបាលសាធារណៈនេះជាស្នាដៃមួយត្រូវបានស្រាវជ្រាវ និងបោះពុម្ពផ្សាយជាផ្លូវការក្នុងកម្មវត្ថុចម្បងគឺបង្រៀននិស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្របន្តបន្ទាប់នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ សៀវភៅនេះ បានរៀបចំឡើងដោយអនុលោមទាំងស្រុងតាមកម្មវិធីសិក្សានៃគ្រឹះស្ថានសិក្សាផ្ទាល់។ ដោយសារតែមុខវិជ្ជារដ្ឋបាលសាធារណៈ ជាមុខវិជ្ជាមួយតម្រូវឲ្យអ្នកសិក្សាស្គាល់នូវគោលការណ៍សំខាន់ៗមានជាអាទិ៍ៈ របៀបដឹកនាំ របៀបគ្រប់គ្រង ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខភាពអនាម័យ ការអភិវឌ្ឍទាំងអស់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ដើម្បីឆ្លើយតបទៅនឹងកម្មវិធីសិក្សាក៏ដូចជាទីផ្សារ ការងាររបស់និស្សិត សៀវភៅនេះត្រូវបានចែកចេញជា៧ជំពូករួមមាន៖ សញ្ញាណទូទៅនៃរដ្ឋបាល រដ្ឋបាលសាធារណៈ អំពីរដ្ឋ អំពីរដ្ឋបាល គោលការណ៍គ្រប់គ្រងរដ្ឋ ការរៀបចំរដ្ឋ អំណាចសាធារណៈ សេវាសាធារណៈ តុលាការគ្រប់ជាន់ថ្នាក់ តួនាទីរបស់ភ្នាក់ងាររដ្ឋ តួនាទីរបស់ពលរដ្ឋ គ្រឹះស្ថានសាធារណៈ លទ្ធកម្មសាធារណៈ និងសវនកម្ម ជាដើម។ ដូចបានបញ្ជាក់ខាងដើមរួចហើយ យើងមិនអាចសរសេរគ្រប់បរិបទឲ្យស្របនឹងនិយមន័យ និងចំណងជើងសៀវភៅបានទេ ពីព្រោះថាពាក្យ រដ្ឋបាលសាធារណៈ ជាមុខវិជ្ជាមួយដែលប្រមូលផ្តុំដោយវិជ្ជាដឹកនាំ សមត្ថភាពវិជ្ជាជីវៈ មនសិកាការងារ អ្នកដឹកនាំក៏ត្រូវការចេះផ្តួចផ្តើមគំនិត ចេះលើកទឹកចិត្ត ចេះស្តីបន្ទោស ការរៀបចំការងារ ភាពឧស្សាហ៍ព្យាយាម និងការចេះទទួលខុសត្រូវ។ អ្នកដឹកនាំទោះបីស្ថានប័នតូចក្តីធំក្តី ទាំងសាធារណៈ និងឯកជន ប្រសិនបើប្រាថ្នាចង់បានបរិស្ថានការងារមួយប្រកបដោយសុក្រឹត្យភាព តម្លាភាព គណនេយ្យភាព ពោលគឺរដ្ឋ

បាលសាធារណៈមួយទំនើប មានសេវាកម្មល្អប្រសើរនោះ សៀវភៅនេះអាចជាប្រទីបមួយចំពោះប្រតិបត្តិករទាំងអស់។ ជាបញ្ចប់ខ្ញុំប្រាកដថា ស្នាដៃនេះនៅតែមានការខ្វះ ខាតនៅឡើយ អាស្រ័យហេតុនេះហើយ រាល់ការរិះគន់ប្រកបដោយការស្ថាបនាពីមិត្តអ្នកអាន និងនិស្សិតជាអាទិភាពគំនិតដើម្បីកែលម្អសម្រាប់ការបោះពុម្ពលើកក្រោយៗ។

*រាជធានីភ្នំពេញ* ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

**អ្នកនិពន្ធ**

**បណ្ឌិត សេង ប៊ុនធឿន**

# មាតិកា

សេចក្តីផ្តើម ........................................................................ 1
ជំពូកទី១ ........................................................................ 3
សញ្ញាណទូទៅរដ្ឋបាលសាធារណៈ ........................................ 3
១-សញ្ញាទូទៅរដ្ឋបាលសាធារណៈ ........................................ 4
២-ទ្រឹស្តីនៃរដ្ឋបាលសាធារណៈ ........................................ 13
២-ក-ទស្សនៈលោក Raul P. de Guzman ........................ 13
២-ខ-ទស្សនៈលោក Robert Presthus ........................ 16
៣-ធាតុផ្សំរបស់រដ្ឋបាលសាធារណៈ ........................................ 20
៣.ក. ប្រជាជន ( People ) ........................................ 21
៣.ខ. ស្ថាប័ន/ អង្គភាព ( Organization ) ........................ 22
៣.គ. គោលនយោបាយសាធារណៈ ( Public Policy ) ....... 23
៤. គោលការណ៍របស់អ្នករដ្ឋបាល ........................................ 28
៤-ក-អព្យាក្រឹតភាព ( Neutrality/ Equanimity ) ............... 29
៤-ខ-អចិន្ត្រៃយ៍ភាព ( Permanence ) ........................ 29
៤-គ-តម្លាភាព ( Transparency ) ........................................ 30
៥-តួនាទី និងលក្ខណៈសម្បត្តិរបស់អ្នករដ្ឋបាល .................... 31

៥-ក-ឧស្សាហ៍ព្យាយាម និង អំណត់ ( Commitment )........32
៥-ខ-តាមដានការងារជាប្រចាំ ( Work observation ) .........32
៥-គ-ឈ្វេងយល់ការងារនៅក្នុងអង្គភាព ( Work seeking out
......................................................................32
៥-ឃ-ចេះដកស្រង់បទពិសោធន៍ ( Experience exchange).33
៥-ច-សាកល្បងធ្វើការងារថ្មី (New work experiment).......34
៥-ឆ-សមត្ថភាព (Capacity) .........................................34
៥-ឈ-វិជ្ជាជីវៈ (Professional).......................................35
៥-ញ-ការទទួលខុសត្រូវ (Responsibility).......................35
៥-ដ-មនសិការ (Conscience).......................................36
៦. រដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន.........................37
៦-ក-រដ្ឋបាលសាធារណៈ(Public administration).............37
៦-ខ-រដ្ឋបាលឯកជន (Private administration) ................38
៧-តួនាទីរដ្ឋបាលសាធារណៈក្នុងសង្គមទំនើប ......................39
៨-សារៈសំខាន់នៃការសិក្សាមុខវិជ្ជារដ្ឋបាលសាធារណៈ ..........45
៨-ក-ចំពោះនិស្សិត ......................................................45
៨-ខ-ចំពោះអ្នកស្រាវជ្រាវ .............................................45

ជំពូកទី២ ........................................................................46
អំណាចសាធារណៈនៅកម្ពុជា ..............................................46
១-អ្វីទៅជាអំណាចសាធារណៈ ..........................................46
២-មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ ....................................48
**ក-ប្រជាធិបតេយ្យ** (Democracy) .................................49
៣-អំណាចនីតិបញ្ញត្តិ
៣-ក-១-ប្រវត្តិរបស់រដ្ឋសភា ..........................................59
ការបោះឆ្នោត នីតិកាលទី៥ ...............................................63
៣-ក-២-អាណត្តិ និងសមាជិកភាពនៃរដ្ឋសភា ..................65
៣-ក-៤-អគ្គលេខាធិការដ្ឋានរដ្ឋសភា ...............................66
៣-គ-អំពីព្រឹទ្ធសភា .......................................................71
៣-គ-៣-ព្រឹទ្ធសភានីតិកាលទី៣(២០១២-២០១៨).........78
៤. ព្រឹទ្ធសភានីតិកាលទី៤ (២០១៨-២០២៤)................81
៥-អំណាចនីតិប្រតិបត្តិ ....................................................85
៦-អំណាចតុលាការ .........................................................99
៦-ក-ប្រវត្តិ និងការកកើតតុលាការនៅកម្ពុជា.....................99
ជំពូកទី៣ ......................................................................127

គោលការណ៍ទូទៅនៃការរៀបចំរដ្ឋបាលរបស់រដ្ឋ ..................... 127
១-ការរៀបចំរដ្ឋបាលរបស់រដ្ឋ ........................................ 127
**ក-ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ** ........................................ 130
**ខ-ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ** ........................................ 135
២-ប្រព័ន្ធគ្រប់គ្រងបែបវិសហមជ្ឈការ ........................... 145
**២-៣-គុណវិបត្តិ** ........................................................ 148
៣-សហត្ថិភាពរវាងវិមជ្ឈការ និងវិមជ្ឈការ.......................... 149
**លក្ខណៈដូចគ្នា** ........................................................ 152
**លក្ខណៈខុសគ្នា** ........................................................ 152
៤-សេចក្ដីសន្និដ្ឋាន ........................................................ 154
ជំពូកទី៤ ......................................................................... 156
ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា ................. 156
១-ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា......... 156
ជំពូកទី៥ ......................................................................... 166
សហគ្រាសសាធារណៈ..................................................... 166
១-អ្វីទៅជាសហគ្រាសសាធារណៈ .................................. 167
២-ក្រុមហ៊ុនរដ្ឋ .............................................................. 168

៣-ក្រុមហ៊ុនចម្រុះ ........ 174
៤-គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ........ 179
៥-ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល ........ 186
៦-ការត្រួតពិនិត្យសហគ្រាសសាធារណៈ ........ 188
៧-សេចក្តីសន្និដ្ឋាន ........ 190
ជំពូកទី៦ ........ 191
សញ្ញាណទូទៅនៃលទ្ធកម្មសាធារណៈ ........ 191
១-សញ្ញាណទូទៅនៃលទ្ធកម្មសាធារណៈ ........ 191
២-ប្រសិទ្ធភាពនៃការគ្រប់គ្រងការធ្វើលទ្ធកម្ម ........ 195
៥-សេចក្តីសន្និដ្ឋាន ........ 241
ជំពូកទី៧ ........ 242
សវនកម្ម ........ 242
១-ទិដ្ឋភាពទូទៅនៃសវនកម្ម ........ 242
**ខ-គោលបំណងនៃការធ្វើសវនកម្ម** ........ 246
**២-គ-គោលបំណង** ........ 249
ឯកសារយោង ........ 257

# សេចក្ដីផ្ដើម

តាំងពីអតីតកាលមក ពោលគឺក្រោយសង្គ្រាមលោកលើកទី១ រដ្ឋាភិបាលនានា(ភាគច្រើនប្រទេសលើកខាងលិច)បានចាប់ផ្ដើមពង្រឹងកាតព្វកិច្ច និងករណីយកិច្ចរបស់ខ្លួនចំពោះប្រជាពលរដ្ឋ និង ប្រជាជាតិទាំងអស់ពីមួយថ្ងៃទៅមួយថ្ងៃ។ ជាមួយគ្នានេះ បទបញ្ញា គោលនយោបាយ ច្បាប់សេដ្ឋកិច្ច និងវិធានការផ្សេងៗទៀតក៏ចាប់ផ្ដើមគិតគូរដាក់ឲ្យអនុវត្តជាបន្តបន្ទាប់ដើម្បីធ្វើយ៉ាងណាឲ្យប្រសិទ្ធភាពការងារកាន់តែប្រសើរឡើងៗឥតឈប់ឈរ។ ដោយសារពេលវេលាមិនអនុញ្ញាតឲ្យយើងច្រើន ដូច្នេះហើយសៀវភៅនេះមិនបានបរិយាយឲ្យទូលំទូលាយគ្រប់ជ្រុងជ្រោយតាមការចង់បាននោះទេ។ នៅផ្នែកដំបូងបង្អស់ យើងបាននិយាយអំពីសញ្ញាណខ្លះៗដែរពាក់ព័ន្ធនឹងនិយមន័យ សមាសភាព និងខ្លឹមសារសំខាន់ៗនៃសៀវភៅនេះ។ រចនាសម្ព័ន្ធទូទៅនៃសៀវភៅនេះមានជាអាទិ៍៖

សញ្ញាណទូទៅនៃរដ្ឋបាលរដ្ឋបាលសាធារណៈ ប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋការគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណា ចក្រកម្ពុជា អំណាចសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចម្រុះ លទ្ធកម្មសាធារណៈ និងសវនកម្ម ជាដើម។ ប្រាកដណាស់ នៅក្នុងសៀវភៅនេះយើងមិនបានធ្វើការបកស្រាយបានក្បោះក្បាយស៊ីជម្រៅនូវខ្លឹមសារនៃជំពូកនីមួយៗឲ្យបានទូលំទូលាយនោះទេ ប៉ុន្តែ យើងសង្ឃឹមថា លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យនឹងធ្វើការបកស្រាយយ៉ាងក្បោះក្បាយនៅក្នុងថ្នាក់សិក្សា។ រួមសេចក្ដីមក សៀវភៅនេះបានរួមចំណែកមួយ

ភាគធំនូវបញ្ហាទាក់ទងនឹងច្បាប់ នយោបាយ គោលនយោបាយសាធារណៈ កិច្ចសហប្រតិបត្តការ គោលដៅ និងទំនាក់ទំនងកិច្ចការសាធារណៈ សេវាកម្មសាធារណៈទាំងមូលតែម្តង។ យើងមានជំនឿយ៉ាងមុតមាំថា បន្ទាប់ពីប្រិយមិត្តបានអាន សិក្សាសៀវភៅនេះចប់ លោកអ្នកនឹងទទួលបានចំណេះដឹងថ្មីៗទៀតដើម្បីចូលរួមក្នុងបុព្វហេតុអភិវឌ្ឍសង្គមជាតិមួយឲ្យកាន់តែស៊ីវិល័យ និងការទទួលខុសត្រូវខ្ពស់។

*សម្រាប់អ្នករដ្ឋបាល សូមកុំនិយាយថាអ្នកនេះ ឬអ្នកនោះមិត្ត និងសត្រូវខ្ញុំ ប៉ុន្តែយើងជាអ្នកបម្រើគាត់។*

# ជំពូកទី១

# សញ្ញាណទូទៅរដ្ឋបាលសាធារណៈ

ការសិក្សាមុខវិជ្ជារដ្ឋបាលសាធារណៈសម្រាប់ជំពូកដំបូងនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

១- សញ្ញាណទូទៅរដ្ឋបាលរដ្ឋបាលសាធារណៈ
២- ទ្រឹស្តីនៃរដ្ឋបាលសាធារណៈ
៣- ធាតុផ្សំរបស់រដ្ឋបាលសាធារណៈ
៤- គោលការណ៍របស់អ្នករដ្ឋបាល
៥- តួនាទី និងលក្ខណៈសម្បត្តិរបស់អ្នករដ្ឋបាល
៦- រដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន
៧- តួនាទីរដ្ឋបាលសាធារណៈក្នុងសង្គមទំនើប
៨- សារៈសំខាន់នៃការសិក្សាមុខវិជ្ជារដ្ឋបាលសាធារណៈ

## ១-សញ្ញាណទូទៅរដ្ឋបាលសាធារណៈ

ដើម្បីងាយយល់នូវអត្ថន័យនៃពាក្យ **"រដ្ឋបាលសាធារណៈ"** គេចាំបាច់ត្រូវយល់ដឹងនូវពាក្យគន្លឹះទាំងនេះជាមុនសិនគឺ រដ្ឋ បាល រដ្ឋបាល និង សាធារណៈ។

រដ្ឋបាល < រដ្ឋ + បាល

-រដ្ឋ = នគរ ប្រទេស បុរី

-បាល = គ្រប់គ្រង / ថែរក្សាដោយយកចិត្តទុកដាក់។

***រដ្ឋ*** ឬអាចហៅថា នគរ ប្រទេស ឬ បុរី តាមអត្ថន័យរបស់ប្រទេសលោកខាងលិច គឺជាសង្គមមនុស្ស ដែលរស់នៅជាប់លាប់លើទឹកដីមួយដោយមានអំណាចនយោបាយគ្រប់គ្រងយ៉ាងទៀងទាត់។

ចំណែកតាមទ្រឹស្តីកុម្មុយនីស្តវិញ រដ្ឋជាក្បាលម៉ាស៊ីនដឹកនាំ ដែលក្នុងនោះមានអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។

ស្ទើរតែគ្រប់ អ្នកនយោបាយទាំងអស់លើសកលលោកយើងនេះ កាលណាគេធ្វើនយោបាយ ឬអ្នកដឹកនាំនយោបាយ គេតែងតែភ្ជាប់ប្រយោជន៍ទូទៅ[1]។ ក្នុងន័យនេះ ដើម្បីក្លាយទៅជារដ្ឋមួយត្រូវមានធាតុផ្សំ(Elements of State)សំខាន់ៗបួនគឺ៖

---

[1]តាមន័យនីតិរដ្ឋធម្មនុញ្ញ កាលណាគេនិយាយថា ប្រយោជន៍ទូទៅ គឺគេនិយាពីប្រយោជន៍របស់ប្រជាជាតិមួយទាំងមូលតែម្តង ហើយខុសពីប្រយោជន៍រួម ដែលមានអត្ថន័យក្តោបតែលើប្រយោជន៍មនុស្សមួយក្រុមប៉ុណ្ណោះ។ មនុស្សមួយក្រុមនេះ អាចមនុស្សក្រុមខ្លួនឯង ឬក្រុមណាមួយ។

-ទឹកដី (Territory)

-ប្រជាជន (Population)

-អំណាចនយោបាយ/រដ្ឋាភិបាល( Political Power /Government)

-អធិបតេយ្យភាព (Sovereignty)

សូមបញ្ជាក់ថា **ទឹកដី** (Territory) បង្កើតនូវព្រំដែនសមត្ថកិច្ចរបស់រដ្ឋ (ទោះតូច ឬធំប៉ុនណាក៏ដោយ)។ កាលណាគេនិយាយពីទឹកដី នៅក្នុងទស្សនៈនៃបរិបទវិទ្យាសាស្ត្រនយោបាយ គេសំដៅដល់ការកំណត់ព្រំដែននៃដែនដីគោក ដែនទឹក និងដែនអាកាស។ ជាមួយគ្នានេះ **ប្រជាជន** មានន័យខុសគ្នា នឹងពាក្យថា ប្រជារាស្ត្រ និងប្រជាពលរដ្ឋ។ **ប្រជាជន** (Population) ជាសមាជិកសង្គមដែលមានទំនាក់ទំនងផ្សារភ្ជាប់គ្នាដោយសារវប្បធម៌ ភាសា សាសនា ពូជអំបូរ....។ **ប្រជាពលរដ្ឋ** សំដៅលើកម្លាំងរបស់រដ្ឋពលរបស់រដ្ឋ(labor/force of state)។ ចំពោះពាក្យ ប្រជារាស្ត្រ គេសំដៅដល់ពលរដ្ឋនៃប្រទេសមួយដែលរស់នៅក្រោមបារមីនៃព្រះជារា ឬព្រះមហាក្សត្រសោយរាជ្យ។

នៅទីនេះ កាលណាយើងនិយាយពីពាក្យថា ប្រជាជន ប្រជាពលរដ្ឋ ឬប្រជារាស្ត្រ យើងត្រូវយល់ដឹងពីពាក្យថាសញ្ជាតិផងដែរ។ **សញ្ជាតិ** យើងត្រូវដឹងថា គឺជាអត្តសញ្ញាណរបស់បុគ្គលម្នាក់ ឬច្រើននាក់ដែលច្បាប់ប្រទាន។

មនុស្ស ម្នាក់អាចមានសញ្ជាតិច្រើនលើសពីមួយ ហើយការផ្ដល់សញ្ជាតិការដកសញ្ជាតិពីបុគ្គលណាម្នាក់ វាអាស្រ័យទាំងស្រុងលើច្បាប់ និងនីតិវិធីផ្សេងៗនៃប្រទេសណាមួយនោះ។

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ។ ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។ ការទទួលសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់[2]។ រីឯពាក្យ **ជនជាតិ** វិញជាអត្តសញ្ញាណរបស់បុគ្គលម្នាក់តាំងពីកំណើតហើយមានតែមួយគត់។ ឧទាហរណ៍ ប្រជាពលរដ្ឋខ្មែរ ជាជនជាតិខ្មែរ មានសញ្ជាតិខ្មែរជាស្វ័យប្រវត្តិ ឬសញ្ជាតិនៃប្រទេសណាមួយ ឬច្រើនទៀតអាស្រ័យលើការប្រព្រឹត្ត ឬស្ថានភាពគតិយុត្តនៃបុគ្គលម្នាក់ៗនោះ។ **អំណាចយោបាយ/រដ្ឋាភិបាល** (Political power/Government)

គ្រប់គ្រងលើទឹកដី និងប្រជាជន។ នៅលើលោកនេះ គ្មានរដ្ឋណាមួយមិនមានអំណាចនយោយបាយត្រួតត្រាឬក្រុមមេដឹកនាំនយោបាយឡើយ។

ទោះបីអំណាចនោះបានមកពីការដណ្ដើមពីគេ អំណាចបានពីការជឿការគោរព អំណាចបានពីការបោះឆ្នោត។ល។ តាមន័យរបស់លោក ម៉ាក្យាវ៉ែល ត្រូវបានគេ(អ្នកវិទ្យាសាស្ត្រនយោបាយ អ្នកនយោបាយ) បកស្រាយថា ធ្វើយ៉ាងម៉េចក៏ដោយឲ្យតែបានអំណាច

---

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣៣។

ទោះបីជណ្ដើមគេក៏ដោយ កុំគិតរឿងសីលធម៌ ឬអសីលធម៌អ្វីទាំងអស់ នៅពេលមានអំណាចក្នុងដៃរួចហើយ គេនឹងគោរព គេនឹងខ្លបខ្លាចអ្នកមានអំណាចក្នុងដៃមិនខានឡើយ។ ប៉ុន្តែអ្វីដែលគាត់ចង់និយាយមិនដូច្នេះទេ ខ្ញុំសូមលើកយកពាក្យពេចន៍ និងទស្សនវិជ្ជារបស់គាត់ខ្លះមកលាតត្រដាងបន្តិច៖

សូមចងចាំនូវទ្រឹស្ដីរបស់លោក Machiavel ដែលបានលើកឡើងថាការប្រយុទ្ធមានពីរ ទី១គឺការប្រយុទ្ធដោយយកច្បាប់មកធ្វើជាអាវុធ និងទី២ គឺការប្រើប្រាស់កម្លាំង។ ករណីទី១ ជាអ្វីដែលគេហៅថា ជាចរិកលក្ខណៈនៃមនុស្ស និងទី២ជាទង្វើមួយដែលដូចនឹងការប្រព្រឹត្តរបស់សត្វតិរិច្ឆានដែរ។ លោកយល់ថា វិធីទី១ មិនអាចបំពេញបំណងមនុស្សបានទេ ដូច្នេះក្នុងករណីខ្លះគេចាំបាច់ត្រូវប្រើប្រាស់វិធីទី២[3]។ នៅក្នុងសតវត្សទី១៦ មានឥទ្ធពលនៃគំនិតរបស់អ្នកនយោបាយជនជាតិអ៊ីតាលីម្នាក់ឈ្មោះ នីកូឡូ ម៉ាគីយ៉ាវ៉ែលី(Niccolo Machiaveli) ឬហៅតាមភាសាបារាំងថា នីកូឡា ម៉ាគីយ៉ាវ៉ែល (Nicolas Machiavel)បានមកគ្របដណ្ដប់ប្រទេសអឺរ៉ុបផងដែរជាមួយនឹងជំនឿគ្រីស្ដសាសនានេះ[4]។ លោក Machiaveli បានប្រសូត្រនៅឆ្នាំ១៤៦៩ នៅក្នុងតំបន់មួយឈ្មោះ Florence ដែលសម័យនោះជារដ្ឋតូចមួយគ្រប់គ្រងដោយរបបសាធារណរដ្ឋ។ តាមសាស្ត្រាចា

[3] Serge Velley : Droit administratif, 2017-2018, page 3

[4] សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ២២

រៀបណ្ឌិតសាយ បូរី Florence គ្រាន់តែជាក្រុងមួយដែលមានស្វ័យភាពគេចចេញពីការបែកបាក់ប្រទេសអ៊ីតាលី។ រចនាសម្ព័ន្ធរដ្ឋបាលនៅតែជាទីក្រុងមួយដដែល។ អាស្រ័យហេតុនេះហើយទើបគេហៅថា រដ្ឋ-បុរី (Ville-Etat)។ ពេលនោះ រដ្ឋ-បុរី ធំៗមានបីគឺ Venise, Milan និង Florence ។ជាមួយនោះរដ្ឋ-បុរី ធំបន្ទាប់មានបីទៀតគឺ Gênes, Ferrare និង Bologne។ ក្នុងន័យនេះ លោក Machiavel គាត់ចង់បង្រួបបង្រួម" រដ្ឋ-បុរី" ទាំង៦នេះឲ្យចូលវង្សត្រកូលគ្នាជាប្រទេសអ៊ីតាលីតែមួយដូចអតីតកាលឡើងវិញ ប៉ុន្តែ ខ្លួនគាត់មិនមានលទ្ធភាព និងសមត្ថភាពផ្ទាល់ទេ ពីព្រោះទោះបីគាត់ជា " លេខាធិការសាធារណរដ្ឋ" ក៏ដោយក៏គាត់មិនមានអំណាចសម្រេចអ្វីឡើយ។ គាត់ត្រូវការឲ្យមាន " បុរសខ្លាំង" សម្រាប់ធ្វើការបង្រួបបង្រួមនេះ។ គាត់គិតទៅឃើញថា ក្នុងកាលៈទេសៈនាសម័យនោះ គឺមានតែស្តេចទេទើបអាចធ្វើបាន ប៉ុន្តែត្រូវធ្វើតាមគំនិតរបស់គាត់។ ថ្វីបើគាត់មានឋានៈជាលេខាធិការនៃសាធារណរដ្ឋតែគាត់ហ៊ានសរសេរថា " អត់ស្តេច អត់ឯកសមោធាន(អត់មានកាឯកភាព)"(Pas de Prince pas d'unification/ No Prince no unificatication)។ ដូចសុភាសិតបារាំងមួយនិយាយថា ចង់បានដល់ទីដៅទាមតារឲ្យមានមធ្យោបាយ (vouloir la fin exige le moyens)។ មធ្យោបាយនោះគឺ " ស្តេច" ។ គាត់ក៏បានសរសេរសៀវភៅតូចមួយក្រោមចំណងជើងថា" ស្តេ

ច”(Le Prince) អស់រយៈពេលតែពីរឆ្នាំ(១៥១៣-១៥១៤)[5] ហើយបានផ្សព្វផ្សាយរបៀបចង្អៀត(មិនសាធារណៈ)នៅក្នុងឆ្នាំ១៥១៥។

មនោគមវិជ្ជា Machiaveli ជាមនោគមវិជ្ជានៃ “ បុរសខ្លាំង ” (L'homme fort/ The strong man)ដែលត្រូវបានលើកយកខ្លឹមសារមករៀបរាប់ដោយសង្ខេបដូចទៅ៖

-ធ្វើស្តេចត្រូវតែមនុស្សប្រាកដនិយម មិនត្រូវឆាប់ជឿគេ និងមិនត្រូវឆាប់ភ័យ។

-ធ្វើស្តេចត្រូវតែប្រកាន់អញ្ញនិយម ហើយមិនត្រូវធ្វើល្អក្នុងចំណោមមនុស្សអាក្រក់។

-ធ្វើស្តេចត្រូវតែឲ្យគេខ្លាច ជាជាងឲ្យគេស្រឡាញ់ ពីព្រោះបើចង់ឲ្យគេស្រឡាញ់ ស្តេចគ្មានធ្វើអ្វីកើតទេដោយខ្លួនឯង ហើយមុខជាខំយកចិត្តគេជានិច្ច។ ប៉ុន្តែបើធ្វើឲ្យគេខ្លាច គឺមានតែគេទេដែលខំយកចិត្តស្តេច ហើយពេលនោះ ស្តេចចង់ធ្វើអ្វីក៏កើតទាំងអស់[6]។

-ធ្វើស្តេចធម្មតា គឺធ្វើល្អ ប៉ុន្តែកុំញញើតនឹងធ្វើអាក្រក់ បើមានការចាំបាច់ កុំខ្លាចនឹងបំពានពាក្យសម្បថ ពីព្រោះអ្នកចាញ់គេ គឺអ្នកគោរពពាក្យសម្បថ។

-គុណសម្បត្តិចម្បងធំជាងគេដែលស្តេចត្រូវមានគឺមិនមែន

---

[5] សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ២៣

[6] ឯកសារដដែល ទំព័រ២៤

គុណធម៌(Lavertu)ទេ ប៉ុន្តែគឺល្បិច គុណ(La virtu)។ ល្បិចគុណ ជាការប៉ិនប្រសប់ ឈ្លាសវៃ ឋាមពលខ្លាំង ការប្តេជ្ញាចិត្តខ្ពស់ ហ៊ានពុះពារជានិច្ចរហូតបានសម្រេចទិសដៅ។

-ស្តេចគឺមិនត្រូវធ្វើដូចគេដូចឯងជនសាមញ្ញបានឡើយ។ ត្រូវនៅឲ្យខ្ពស់ដាច់ស្រឡះពីគេ ពីសាមញ្ញភាព ពីកម្ពស់សីលធម៌ ឬពីអ្វីដែលជាល្អ និងអ្វីដែលជាអាក្រក់ គឺមានតែឧត្តមប្រយោជន៍ជាតិ និងឧត្តមប្រយោជន៍រដ្ឋដែលតម្រូវឲ្យធ្វើយ៉ាងម៉េចស្តេចត្រូវធ្វើអញ្ចឹង។ ឲ្យតែស្តេចបានសម្រេចលទ្ធផល ចុងក្រោយដែលជាឧត្តមប្រយោជន៍នេះ វាគ្មានមធ្យោបាយណាដែលគេត្រូវគិតថា មិនសមរម្យឡើយ។
-ស្តេចត្រូវតែសំដែងមហិទ្ធិឫទ្ធិជាមេទ័ពកំពូល ក្លាហាន អង់អាច។

-ស្តេចត្រូវតែចេះឆក់ឱកាស និងស្គាល់ឱកាស ពីព្រោះខ្លួនជាសហការីរបស់ព្រះអាទិទេពដ៏ធ្នើម។ ចេះធ្វើពុត និងចេះលាក់ពុត។ វិលមកនិយាយពីរដ្ឋប្រជាធិបតេយ្យវិញ។ ក្នុងរបបប្រជាធិបតេយ្យក្តី ឬកុម្មុនីស្តក្តីសុទ្ធតែមានអំណាចនយោបាយដឹកនាំទាំងអស់។
**អធិបតេយ្យភាព** (Sovereignty) ការទទួលស្គាល់ដោយអន្តរ ជាតិ។ យើងមិនអាចប្រកាសខ្លួនថា ជារដ្ឋមួយបានឡើយ ប្រសិនបើយើងមិនមានការទទួលស្គាល់ជាអន្តរជាតិនោះ។ អ្នកនយោបាយ ឬអ្នកដឹកនាំនយោបាយបានទន្ទេញចាំដោយរត់មាត់ថា ខ្លួននឹងធ្វើអ្វីៗទាំងអស់ដើម្បីប្រជាពលរដ្ឋ ដើម្បីទឹកដី និងអធិបតេយ្យជាតិ។

ប្រវត្តិសាស្ត្រនយោបាយបង្ហាញថា រដ្ឋមានពីរទម្រង់គឺ រដ្ឋ

ទោល (Single State) និងរដ្ឋសហព័ន្ធ(Federal State)។ ការបែងចែកនេះ ជាលទ្ធផលនៃភូមិសាស្ត្រនយោបាយ ច្បាប់ ទំនៀមទម្លាប់ សេដ្ឋ-កិច្ច អាកាសធាតុ និងប្រជាសាស្ត្រផងដែរ។ រដ្ឋទោល (Single State) បានសេចក្តីថា គ្រប់បុគ្គលនៅក្នុងរដ្ឋស្ថិតនៅក្រោមច្បាប់តែមួយ។

ឧទាហរណ៍ ៖ បារាំង កម្ពុជា ចិន អេស្ប៉ាញ...។ ចំណែករដ្ឋសហព័ន្ធ (Federal State)ជារដ្ឋដែលប្រមូលផ្តុំរដ្ឋនានាជាសមាជិក មួយផ្នែកស្ថិតនៅក្រោមអំណាច តែមួយ ហើយមួយផ្នែកនៃរដ្ឋជាសមាជិកមានស្វ័យភាព។ ឧទាហរណ៍៖ សហរដ្ឋអាមេរិក អូស្ត្រាលី ម៉ាឡេស៊ី ឥណ្ឌា ភូមា...។

លោក Barry M. Richman and Melvyn Copen "រដ្ឋបាលជាដំណើរការនៃការរៀបចំចាត់ចែងមួយពាក់ព័ន្ធទៅនឹងការអនុវត្តគោលដៅ ផែនការ និងប្រសិទ្ធភាពនៃប្រតិបត្តិការផ្ទៃក្នុង"។ វាតែងតែបង្កប់នូវរចនាសម្ព័ន្ធ និងអាកប្បកិរិយារបស់រដ្ឋទាក់ទិនទៅនឹងការសម្រេចចិត្តប្រចាំថ្ងៃ។

ទស្សនៈតាមពាក្យខ្មែរយើង "រដ្ឋបាល" ត្រូវបានយល់ថា ជាកិច្ចការរបស់រដ្ឋ ពីព្រោះមានពាក្យ"រដ្ឋ"ក្នុង"រដ្ឋបាល"។ ប៉ុន្តែពាក្យ "រដ្ឋបាល" ក៏ត្រូវបានគេប្រើនៅក្នុងសហគ្រាសឯកជនផងដែរដូចជា "ការិយាល័យរដ្ឋបាល"ឬ "កិច្ចការរដ្ឋបាល" ដែលជួយឲ្យប្រត្តិបត្តិការរបស់សហគ្រាស ឬក្រុមហ៊ុននោះដើរបានល្អ។ល។

យើងមិនអាចសន្និដ្ឋានបានភ្លាមៗថា "រដ្ឋបាល" ជារឿងឯកជន ឬជាកិច្ចការរដ្ឋការ ឬរាជការបានភ្លាមៗទេ ប្រសិនបើគ្មានអ្វីមកបញ្ជាក់អំពីអង្គភាព។ ដូច្នេះ បើនិយាយតែពីសកម្មភាពយើងមិនអាចឱ្យន័យពាក្យ "រដ្ឋបាល" បានត្រឹមនេះឡើយ។

សរុបមក "រដ្ឋបាល" មានន័យថា គឺជាការគ្រប់គ្រងរដ្ឋ ឬការគ្រប់គ្រងប្រទេសដោយការយកចិត្តទុកដាក់ខ្ពស់ដើម្បីសម្រេចឲ្យបាននូវគោលបំណង ឬទិសដៅរួមមួយ។ ចំណែកឯការគ្រប់គ្រងអង្គភាពសហគ្រាស អង្គការសមាគម ក្រុមហ៊ុន ការរៀបចំ និងថែរក្សាដោយការយកចិត្តទុកដាក់ក៏ជា "រដ្ឋបាល" ដែរ។ ដូចនេះ "រដ្ឋបាល" ពុំមែនមានន័យត្រឹមតែជាអ្នកធ្វើលិខិត ឬធ្វើកិច្ចការការិយាល័យតែមួយមុខនោះទេ។

Administration comes from two Latin words. Ad means to, ***ministiare'****= to serve, to care for or to look after people,* and *to manage affairs.* ***<u>Administration</u>*** *may be defined as "<u>group activity</u> which involves <u>cooperation</u> and <u>coordination</u> for the purpose of achieving desired goals or objectives".*

មានអត្ថន័យស្រដៀងគ្នាដែរពាក្យថា **រដ្ឋបាល** ត្រូវបានគេផ្តល់អត្ថន័យថា **បម្រើ**។..វាក្យស័ព្ទ រដ្ឋបាល អាចមានន័យថាជាសកម្មភាពគ្រប់គ្រងរបស់រាជការ ឬរដ្ឋការ[7]។សកម្មភាពជាក្រុមដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលដើម្បីសម្រេចបាននូវគោលដៅ ឬគោលបំណងដ៏ចាំបាច់ណាមួយ។

---

[7] Serge Velley : Droit administratif, 2017-2018, page 8

ចំពោះពាក្យ **សាធារណៈ ឬសាធារណ៍** ត្រូវបានពន្យល់ថា ជាកណ្តាល ដែលទូទៅ ដែលប្រើបានទាំងអស់គ្នា ដែលមិនចំពោះ មួយៗ..ភារដែលប្រើបានទាំងអស់គ្នា[8]។

## ២-ទ្រឹស្តីនៃរដ្ឋបាលសាធារណៈ

ពាក្យរដ្ឋបាលសាធារណៈបកប្រែជាភាសាបារាំងថា (Administration publique) ហើយប្រសិនបើបកប្រែទៅជាភាសាអង់គ្លេសថា (Public administration)នោះ វាមានអត្ថន័យខុសពីភាសាបារាំងទៅវិញ។ អ្នកអក្សរសាស្ត្រអាចបកប្រែខុសអត្ថន័យនៃពាក្យបច្ចេកទេសមួយចំនួន។ តាមលោកសាស្ត្រាចារ្យបណ្ឌិត សាយ បូរី ពាក្យ (Public administration) ត្រូវបកប្រែថា **វិទ្យាសាស្ត្ររដ្ឋបាល** ដែលភាសាបារាំងហៅថា (science administration) ទៅវិញទើបត្រឹមត្រូវ[9]។

### ២-ក-ទស្សនៈលោក Raul P. de Guzman

លោកបានលើកឡើងថា “នៅទីណាមានរដ្ឋាភិបាល នៅទីនោះមានរដ្ឋបាលសាធារណៈ ពោលគឺវាសំដៅដល់សកម្មភាពសហប្រតិបត្តិការរបស់ពលរដ្ឋដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់រដ្ឋាភិ-បាល” ។ តាមន័យនេះ ក្នុងប្រទេសមួយ ទោះបីទៅដល់កន្លែងក៏រដ្ឋត្រូវមានកាតព្វកិច្ចរៀបចំហេដ្ឋារចនាសម្ព័ន្ធដែរ ប៉ុន្តែត្រូវបត់បែនទៅ

---

[8] សម្តេចព្រះសង្ឃរាជ ជួន ណាត ៖ វចនានុក្រមខ្មែរ ឆ្នាំ១៩៦៧ ទំព័រ៨២៧

[9] បណ្ឌិត សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ២

តាមភូមិសាស្ត្រ អាកាសធាតុ ប្រជាសាស្ត្រ និងការប្រែប្រួលផ្សេងៗទៀត។ បានសេចក្តីថា រដ្ឋាភិបាលត្រូវចាប់ផ្តើមគិតគូរគ្រប់បញ្ហារបស់ប្រទេសជាតិ បើទីក្រុងស្អាត ជន បទត្រូវតែស្អាតតាមបែបជនបទ។ ជាមួយគ្នានេះ ពលរដ្ឋជាភាគីមួយត្រូវតែសហការជាមួយរដ្ឋាភិបាលតាមរយៈភ្នាក់ងាររបស់ខ្លួន។ ឧទាហរណ៍ រដ្ឋាភិបាលតម្រូវឲ្យភូមិមួយមានបរិស្ថានស្អាត មានប្រព័ន្ធទឹកស្អាត គ្មានសំរាមពង្រាយក្នុងទីធ្លាផ្ទះសម្បែង គ្មានក្លិនស្អុយ និងទីធ្លាសារធារណៈ គ្មានខ្សែភ្លើងរយីងរយោងលើដើមឈើតាមដងផ្លូវ គ្មានចោរកម្ម មានសណ្តាប់ធ្នាប់នៃការរស់នៅរបស់ប្រជាពលរដ្ឋល្អប្រសើរ។ ដើម្បីឆ្លើយតបនឹងគោលនយោបាយខាងលើ រដ្ឋាភិបាលត្រូវមានបទបញ្ជា ត្រូវមានមូលនិធិគាំទ្រគ្រប់គ្រាន់ ជាពិសេស ត្រូវមានផែនការមេមួយច្បាស់លាស់ ហើយចុងក្រោយពលរដ្ឋត្រូវចូលរួមសហការឲ្យបានគ្រប់ជ្រុងជ្រោយនៃផែនការសកម្មភាពរបស់រដ្ឋ។ ក្នុងករណីនេះ ផែនការសកម្មភាពមួយចំនួនមិនគួររង់ចាំមូលនិធិរបស់រដ្ឋ ឬដៃគូអភិវឌ្ឍទេទើបអនុវត្តបាននោះទេ ដូចជាគ្រាន់តែដាំដើមឈើតាមទីសាធារណៈ ធ្វើសួនលម្អ ធ្វើអនាម័យ ធ្វើសួនបន្លែនៅក្នុងបរិវេណផ្ទះ។ល។ ផ្តើមចេញពីទស្សនៈខាងលើ នៅរាជធានី និងទីក្រុងផ្សេងៗ បុរីនីមួយៗមិនត្រូវស្អាតតែក្នុងប្លង់ឃោសនាលក់នោះទេ ប៉ុន្តែត្រូវចាប់អនុវត្តម៉ឺងមាត់ឲ្យស្រេច បាច់យើងអាចនិយាយថា ត្រូវខិតខំបង្រួមការងារឲ្យនៅតូច បាន សេចក្តីថា ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធចាស់យើងមិនឆ្លើយតបនឹងសម័យកាលទំនើបទៅហើយ ៗមិនទាន់អាចមានលទ្ធភាពធ្វើបច្ចុប្បន្នភាព

អគារចាស់ៗ កែលម្អផ្លូវថ្នល់ បង្គោលខ្សែភ្លើង និងខ្សែភ្លើងឲ្យបានល្អ ទេ សំណង់ថ្មីត្រូវតែស្អាតឲ្យហើយតែម្តងទៅ។ ក្នុងន័យនេះ បុរី នីមួយៗ ត្រូវមានផ្លូវធំទូលាយ(៨ម៉ែត្រទៅ១២ម៉ែត្រ)នៅតូចណាស់ ប្រសិនបើម្ចាស់លំនៅដ្ឋានចតរថយន្តម្នាក់មួយតាមមុខផ្ទះរៀងខ្លួន ម្ខាងម្នាក់នោះ។ ខ្សែភ្លើង ឬបណ្តាញទូរគមនាគមន៍ផ្សេងៗ កាប៏ត្រូវ បង្កប់នៅក្រោមដីឲ្យហើយស្រេចទៅចៀសវាងការរុះរើពេលអនាគត។ នេះមិនទាន់និយាយដល់គុណភាពសំណង់ផង។ ចំពោះនៅជនបទ ស្រែចំការវិញ ហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋាន និងគួរចាប់ផ្តើមពីទីប្រជុំ ជន មានជាអាទិ៍ សាលាស្រុក សាលាឃុំ សាលារៀន ផ្សារ និងវត្ត អារាមទាំងអស់។ ជាមួយគ្នានេះ រមណីយដ្ឋានទេសចរណ៍ទាំងអស់ទូ ទាំងប្រទេសយ៉ាងហោចណាស់ក៏ត្រូវមានប្លង់ស្លាបត្យករមួយលើក បង្ហាញ សាធារណៈជនឲ្យបានឃើញដែរ។

រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមាន សមត្ថកិច្ច និងស្ថានប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផល ប្រយោជន៍សាធារណៈគឺជាសេវាសាធារណៈ។ ស្ថាប័នមានសមត្ថកិច្ច នៅក្នុងន័យនេះ គឺសំដៅដល់ស្ថាប័នរដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន[10]។ ស្ថានប័នទទួលសមត្ថកិច្ច ក្នុងន័យនេះគឺសំដៅដល់ផ្នែកឯកជន និង

---

[10] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនៃរាជរដ្ឋាភិបាលកម្ពុជា៖ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ឆ្នាំ២០០៦ ទំព័រ៦ និង៧

សង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងការត្រួតពិនិត្យ ពីរដ្ឋ ឬភ្នាក់ងាររដ្ឋ។ ការគ្រប់គ្រងការត្រួតពិនិត្យពីរដ្ឋ ឬភ្នាក់ងាររដ្ឋទៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឲ្យត្រូវធ្វើឡើងផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងសេចក្ដីសម្រេច កិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលបានប្រគល់ភារកិច្ចក្នុងវង្វង់ដែនសមត្ថកិច្ចមួយច្បាស់លាស់ និងពិនិត្យទៅលើសកម្មភាពការងារលទ្ធផលសម្រេចបានគោលដៅទៅអនាគត និងផលប៉ះពាល់ផ្សេងៗដោយថា ហេតុដែលអាចកើតមានចំពោះសង្គមជាតិ[11]។ ដូច្នេះយើងឃើញថា គ្រប់សកម្មភាពរបស់ស្ថាប័ន រដ្ឋក្ដី ឯកជនក្ដីសុទ្ធតែត្រូវបានត្រួតពិនិត្យដោយផ្ទាល់ ឬដោយប្រយោលពីរដ្ឋទាំងអស់។

**២-ខ-ទស្សនៈលោក** Robert Presthus

លោក **Robert Presthus** បានឱ្យនិយមន័យថា "រដ្ឋបាលសាធារណៈពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌស្ថាប័នរបស់រដ្ឋាភិបាលមជ្ឈដ្ឋានសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងអាកប្បកិរិយានៃបុគ្គលគ្រប់រូបដែលកាន់កាប់ក្បាលម៉ាស៊ីនរបស់រដ្ឋ"។ លើសពីនេះទៀត ប្រសិនបើយើងមើលទៅលើរដ្ឋបាលសាធារណៈបង្ហាញថាវាចាំបាច់ត្រូវពាក់ព័ន្ធជាមួយនឹងការដាក់ចេញនូវគោលនយោបាយសាធារណៈ និងការអនុ

---

[11] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនៃរាជរដ្ឋាភិបាលកម្ពុជា៖ គោលនយោបាយស្ដីពីការផ្ដល់សេវាសាធារណៈ ឆ្នាំ២០០៦ ទំព័រ៦ និង៧

វត្តកម្មវិធីនយោបាយរបស់រដ្ឋាភិបាល។លោកក៏បានបញ្ជាក់ថែមទៀតថា "រដ្ឋបាលសាធារណៈ គឺជាទិដ្ឋភាពនៃការគ្រប់គ្រងដែលធ្វើឡើងដោយភ្នាក់ងារផ្លូវការរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់" ។

ឃ្លាប្រយោគខាងលើ ប្រសិនបើយើងក្រឡេកមើលពាក្យបុរាណខ្មែរ សំដីសជាតិមានយាទសពូជ ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន ឃើញផ្លែស្គាល់ស្លឹក ឬឃើញស្លឹកស្គាល់ផ្លែ។ ស្រដៀងនឹងសុភាសិតបារាំងដែរ ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់(Tel père tel fils) លទ្ធផលបង្ហាញពីការងារ(Le résultat indique le moyen)។ លទ្ធផលនៃការងាររបស់យើងនឹងបង្ហាញថា តើយើងបានគិត បានធ្វើ បានអនុវត្តផែនការ ឬទេ?

**២-ខ-ទស្សនៈលោក** Jean Rivero **និង** Jean Waline DALLOZ

ក្នុងច្បាប់បារាំង វិធានគតិយុត្តដែលគ្រប់គ្រងសកម្មភាពរដ្ឋបាលនៃនីតិបុគ្គលសាធារណៈ (personne publique) មិនដូចវិធានគតិយុត្តនៃនីតិឯកជនទេ ពីព្រោះរដ្ឋការមានបុព្វសិទ្ធិនៃអំណាចសាធារណៈ ដែលនាំឲ្យរដ្ឋការមានឧត្តមភាពជានិច្ចលើរាស្ត្រ។ ទោះបីឥឡូវរដ្ឋការត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក៏ដោយ ក៏ការទទួលខុសត្រូវនោះមានចរិកលក្ខណៈខុសគ្នាពីការទទួលខុសត្រូវរបស់ឯកជន។ ហេតុដូច្នេះហើយបានជាសាស្ត្រាចារ្យ Jean Rivero et Jean Waline DALLOZ សរសេរថា នីតិរដ្ឋបាលជាសារព័ន្ធនៃវិធានគតិយុត្តទាំងឡាយណាដែលប្លែកពីវិធានការគតិយុត្តនៃនីតិឯកជន

ដែលគ្រប់គ្រងសកម្មភាពរដ្ឋបាលនៃនីតិបុគ្គលសាធារណៈ (Le droit administrative est l'ensemble des règles juridiques distinctes de celle du droit privé qui régissent l'activité administrative des personnes publiques)[12]។

សរុបសេចក្តីមក **រដ្ឋបាលសាធារណៈ** ត្រូវបានឱ្យនិយមន័យជា“សកម្មភាពគ្រប់គ្រងរបស់រដ្ឋ។

(the Management of Public Programs)” ។

តាមអត្ថន័យខាងលើ អាជ្ញាធរប្រទេសណាក៏ដោយក្នុងលោកនេះពិបាកគេចផុតចំពោះការសរសើរ ការរិះគន់ ការស្រឡាញ់ និងការថ្នាំងស្នាក់ពីសំណាក់ប្រជាពលរដ្ឋរបស់ខ្លួនណាស់។ ដូច្នេះហើយបានជាយើងតែងតែសង្កេតឃើញរដ្ឋាភិបាលនានា ជាពិសេសរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋបានខិតខំធ្វើការងារយ៉ាងខ្លាំងទៅតាមកិច្ចសន្យារបស់ខ្លួនដែលបានថ្លែងសន្យាមុនក្នុងពេលយុទ្ធនាការបោះឆ្នោត។ ប្រទេសមួយចំនួន ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិតនៅឡើយ ដូចជា បញ្ហាវប្បធម៌ សាសនា សណ្តាប់ធ្នាប់សាធារណៈ ចរាចរណ៍ សន្តិសុខ សុខភាពសាធារណៈ ទូរគមនាគមន៍ បញ្ហាអប់រំ ផ្លូវថ្នល់ អគ្គិសនី បង្គន់អនាម័យ ទឹកស្អាត និងបញ្ហានានាទៀត តែងតែមានការរិះគន់ពីប្រជាពលរដ្ឋជារឿយៗ។ ដូច្នេះ អ្នករាជការមិនអាចបន្ទោស ឬខឹងសម្បារប្រជាពលរដ្ឋដែលមិន

---

[12] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ២០

សប្បាយចិត្តនឹងយើងទេ នេះជាកាតព្វកិច្ច នៃសេវាសាធារណៈដែលអ្នកដឹកនាំ និងរាជការយើងខិតខំបម្រើឲ្យបានកាន់តែប្រសើរឡើងៗ។ កត្តាសំខាន់មួយទៀត ដោយសារតែជាកាតព្វកិច្ច និងតួនាទីរបស់រាជការនេះហើយ ដូច្នេះរាជការត្រូវដានការងារជាប្រចាំ និងខិតខំបំពេញចន្លោះការងារដែលខ្វះខាត។ ជាមួយគ្នានេះ យើងអាចបកស្រាយពន្យល់ ឆ្លើយតប និងណែនាំពីនិតិវិធី វិធានការចាំបាច់ផ្សេងៗដល់ពលរដ្ឋរបស់យើង។

របបសភានិយម ជារបបមួយដែលយកសភាជាធំ។ របបសភានិយមនេះ គឺចេញពីប្រទេសអង់គ្លេសដែលមានបែបបទជ្រើសរើសនាយករដ្ឋមន្ត្រីត្រូវបានអនុវត្តតាមដោយប្រទេសនានាលោក។ ចំពោះរបបសភានិយម[13]គឺគោលនយោបាយជាតិដែលបេក្ខជននាយករដ្ឋ មន្ត្រីបានថ្លែងនៅចំពោះមុខតំណាងរាស្ត្រក្នុងរដ្ឋសភា។ ក្នុងប្រទេសជឿនលឿនទាំងអស់ រដ្ឋាភិបាលដែលជាប់ឆ្នោតមួយអាណត្តិ ហើយមួយអាណត្តិទៀតជារដ្ឋាភិបាលដែលប្រជាពលរដ្ឋវាយតម្លៃខ្ពស់ដោយសារតែរដ្ឋាភិបាលចាស់នេះបានបំពេញការងារបានល្អ ដូច្នេះប្រជាពលរដ្ឋបន្តបោះឆ្នោតគាំទ្រសាជាថ្មី។

[13] A parliamentary system or parliamentary democracy is a system of democratic governance of a state (or subordinate entity) where the executive derives its democratic legitimacy from its ability to command the confidence of the legislature, typically a parliament, and is also held accountable to that parliament.

ចំពោះរបបប្រធានាធិបតីនិយម[14] ប្រជាពលរដ្ឋបានវាយតម្លៃទៅលើកិច្ចការរបស់ប្រធានាធិបតី សហរដ្ឋអាមេរិកប្រធានាធិបតីក្នុងមួយអាណត្តិមានរយៈពេលបួន(៤)ឆ្នាំ ហើយអាចឈរឈ្មោះធ្វើប្រធានាធិបតីបានតែពីរអាណត្តិទេ។ ប្រទេសហ្វីលីពីន ប្រធានាធិបតីមានអាណត្តិប្រាំមួយ(៦)ឆ្នាំ ហើយឈរឈ្មោះបានតែមួយអាណត្តិប៉ុណ្ណោះ។ ប្រទេសបារាំងជារបបចម្រុះ ប្រធានាធិបតីមានអាណត្តិប្រាំ(៥)ឆ្នាំ រដ្ឋធម្មនុញ្ញប្រទេសនេះអនុញ្ញាតឲ្យឈរឈ្មោះបានតែពីរអាណត្តិដូចសហរដ្ឋអាមេរិកដែរ ពោលគឺទោះបីប្រធានាធិបតីចាស់ធ្វើកិច្ចការល្អឥតខ្ចោះយ៉ាងណាក៏ដោយចុះ ប្រសិនបើកាន់អំណាចបានពីរអាណត្តិហើយ(សហរដ្ឋអាមេរិក បារាំង) លោកត្រូវតែចូលនិវត្តន៍ហើយ។

### ៣-ធាតុផ្សំរបស់រដ្ឋបាលសាធារណៈ

ប្រសិនបើយើងពិនិត្យលើនិយមន័យនៃរដ្ឋបាលសាធារណៈខាងលើ កិច្ចការនេះមានលក្ខណៈ ជាប្រព័ន្ធ ដែលទាមទារឲ្យអ្នកប្រតិបត្តិយល់ឲ្យច្បាស់លាស់អំពីតួនាទី និងភាគីពាក់ព័ន្ធទាំងអស់ ហើយចេះធ្វើសហប្រតិបត្តិការជាមួយគ្នាឲ្យស្អិតរមួតទើបបំណងប្រាថ្នារបស់យើងអាចទទួលបានលទ្ធផលល្អ។ ធាតុផ្សំរបស់រដ្ឋបាល

---

[14] A presidential system, or single executive system, is a form of government in which a head of government (president) leads an executive branch that is separate from the legislative branch. This head of government is in most cases also the head of state.

សាធារណៈ **(Elements of Public Administration/ Public Management)**

៣.ក. ប្រជាជន (People)

៣.ខ. ស្ថាប័ន/ អង្គភាព (Organization)

៣.គ. គោលនយោបាយសាធារណៈ (Public Policy)

៣.ឃ. ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ (Laws and Regulations)

៣.ង. ហិរញ្ញវត្ថុសាធារណៈ (Public Finance)

៣.ច. មន្ត្រីរាជការស៊ីវិល(Public Servants)

ធាតុផ្សំខាងលើបញ្ជាក់ជាថ្មីថា នៅក្នុងរដ្ឋបាលសាធារណៈ យើងមិនអាចចាប់ច្បិចយកតែ បញ្ហាណាមួយឲ្យដាច់ដោយឡែកបានទេ ផ្ទុយទៅវិញប្រាំមួយករណីខាងលើសុទ្ធតែមានសារៈសំខាន់ ហើយពាក់ព័ន្ធគ្នាជានិច្ច។

**៣.ក. ប្រជាជន**( People )

ក្នុងប្រទេសមួយ ស្ថាប័នមួយ( ទាំងសាធារណៈ និងឯកជន ) ការងារទាំងអស់វាដំណើរការ ដើម្បីបម្រើប្រជាជន និងអតិថិជនរបស់ខ្លួន។ យើងអាចសួរខ្លួនឯងថា ចុះប្រសិនបើគ្មានប្រជាជន តើយើងបង្កើតរាជការមកដើម្បីអ្វី? ជាការពិតណាស់ មនុស្សរាប់លាននាក់រង់ចាំទទួលសេវកម្មពីយើង។

វិស័យអប់រំ គ្រូបង្រៀនរាប់ម៉ឺននាក់បម្រើ( បង្រៀន )កូនចៅប្រជាជន? ប្រសិនបើប្រទេសមួយគ្មានគ្រូបង្រៀន គ្មានសាលារៀន តើកូនចៅយើងបានអ្នកណាបង្រៀន? ប្រជាជនខំចំណាយថវិកាដ៏

ច្រើនដើម្បីវិនិយោគអប់រំកូនរបស់គាត់ឲ្យមានចំណេះដឹង ចំណេះជំនាញ នៅពេលកូនចៅគាត់ទាំងអស់ចេះដឹងរួចហើយ ពួកគេជាធនធានជាតិដោយមិនអាចប្រកែកបានឡើយ។ យើងអាចសញ្ជឹងគិតថា ប្រទេសមួយខ្វះធនធានមនុស្ស តើប្រទេសនោះអាចរឹងមាំកើតទេ? កូនចៅប្រជាជនដែលទទួលបានការអប់រំ មានការចេះដឹងហើយក៏ដើម្បីបម្រើរដ្ឋវិញដដែល។ ដូច្នេះ លទ្ធផលនៃការអប់រំត្រូវរដ្ឋប្រមូលយកវិញទាំងអស់។ ករណីដូចគ្នា វិស័យឯកជន តើក្រុមហ៊ុននឹងដំណើរការផលិត និងលក់ផលិតផលយ៉ាងដូចម្តេច ប្រសិនបើពួកគេគ្មានអតិថិជន? នៅពេលក្រុមហ៊ុនរកស៊ីចំណេញ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ ដូច្នេះកាលណាគេនិយាយពីរដ្ឋបាលសាធារណៈមិនអាចអវត្តមានធាតុចូល(ប្រជាពលរដ្ឋ និងវិស័យឯកជនបានទេ)។

### ៣.ខ. ស្ថាប័ន/ អង្គភាព (Organization)

ស្ថាប័នគឺអ្វីៗដែលគេបង្កើតឡើងដើម្បីបម្រើប្រយោជន៍ទូទៅតាមន័យនៃនីតិរដ្ឋធម្មនុញ្ញ ប្រយោជន៍ទូទៅខុសពីប្រយោជន៍រួម។ ប្រយោជន៍ទូទៅគេសំដៅលើប្រយោជន៍នៃប្រជាជនប្រទេសមួយ ចំណែកប្រយោជន៍រួម សំដៅដល់មនុស្សក្រុមណាមួយ ឬកន្លែងណាមួយ។ ស្ថាប័ន ឬអង្គភាពគឺជាអ្នកទទួលខុសត្រូវអនុវត្តផែនការទៅតាមផ្នែកនីមួយៗ។ ដូច្នេះហើយបានជាយើងឃើញមានវត្តមាននៃស្ថាប័នជាច្រើនបានកើតឡើងស្របគ្នា និងការទទួលខុសត្រូវរៀងៗខ្លួន។

### ៣.គ.គោលនយោបាយសាធារណៈ Public Policy

កាលណាយើងនិយាយពីគោលនយោបាយសាធារណៈ យើងនិយាយពីភារកិច្ចរបស់អាជ្ញាធរ មានសមត្ថកិច្ចដែលមានតួនាទីសម្របសម្រួលអនុវត្តឲ្យបានម៉ឺងម៉ាត់បំផុត។ការចេញបទបញ្ជា ប្រជាពលរដ្ឋមិនមានសិទ្ធិអ្វីទេ ពោលគឺជាអ្នកអនុវត្ត និងសហការតាមណែនាំរបស់អាជ្ញាធរ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ឲ្យបានត្រឹមត្រូវតែប៉ុណ្ណោះ។ អ្នកធ្វើគោលនយោបាយសាធារណៈ ត្រូវពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ ហើយរាល់សេចក្ដីសម្រេចទាំងអស់ត្រូវឲ្យស្របរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

### ៣.ឃ. ច្បាប់និងបទប្បញ្ញត្តិផ្សេងៗ (Laws and Regulations)

យើងសាកល្បងធ្វើការសង្កេតមើលពីសកម្មភាពការងាររបស់ស្ថាប័នជាតិយើងនាសម័យកូវីដ (COVID)-១៩ នេះ។ ទាំងនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងស្ថាប័នពាក់ព័ន្ធទាំងអស់ខិតខំតាមដានសភាពការណ៍ វិវត្តនៃរោគរាតត្បាត ហើយចេញច្បាប់បទបញ្ជា និងសេចក្ដីសម្រេចជាច្រើនផងដើម្បីធ្វើយ៉ាងណាការពារបាននូវរោគឆ្លងដ៏កាចសាហាវនេះ រលត់រលាយបាត់ទៅវិញ ពោលគឺចៀសវាងរាល់គ្រប់គ្រោះមហន្តរាយរបស់ប្រជាពលរដ្ឋតែម្ដង។ សេចក្ដីសម្រេចលេខ ៤៩សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្ដីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាលដើម្បីទប់ស្កាត់ការ

ឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងសេចក្តីសម្រេចលេខ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ កន្លងទៅនេះស្តីពីការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញនិងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ រួមទាំងវិធានការរបស់អាជ្ញាធរថ្នាក់ក្រោមជាតិជាច្រើនទៀត បើគិតពីបញ្ហាសិទ្ធិមនុស្ស បញ្ហាសេដ្ឋកិច្ចសុទ្ធតែមានការប៉ះពាល់ទាំងអស់ ជាពិសេសសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប៉ុន្តែរដ្ឋាភិបាលគ្មានជម្រើសល្អណាក្រៅពីការធ្វើដើម្បីប្តូរយកការសុខសាន្តត្រាណ និងសុខភាពសាធារណៈរបស់ប្រជាពលរដ្ឋនាពេលអនាគតជាជាងទុក្ខឲ្យប្រជាពលរដ្ឋបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់របស់ខ្លួន។ ទាំងនេះជាឯកសារគតិយុត្តដ៏សំខាន់មួយដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះ ដំណើរការចាក់វ៉ាក់សាំងក៏រដ្ឋាភិបាលខិតខំដុតដៃដុតជើងរកថវិកាដើម្បីទិញវ៉ាក់កូវីដ-១៩មកចាក់ជូនប្រជាពលរដ្ឋដែរ។

### ៣.ខ. ហិរញ្ញវត្ថុសាធារណៈ ( Public Finance )

ក្នុងរបបទីផ្សារសេរី ថវិកាដើរតួនាទីសំខាន់ណាស់ មានតែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេដែលថវិកាជាក្រដាស់មួយសន្លឹក។ ថ្វីបើថវិកា ជាឧបករណ៍ដ៏សំខាន់សម្រាប់ធ្វើការដោះដូរទំនិញ ប៉ុន្តែប្រភពថវិកាចំណាយ និងចំណាយត្រូវតែមានតម្លាភាព និងស្របតាមគោលនយោបាយ និយាមនៃរបបសេដ្ឋកិច្ច និងរូបិយវត្ថុ រូបិយប័ណ្ណដែរ។ និយាយឲ្យខ្លីត្រូវគ្រប់គ្រងឲ្យបានល្អចៀសវាងអតិផរណាទឹកប្រាក់នៅលើទីផ្សារដែលនាំឲ្យមានការដួលរលំសេដ្ឋកិច្ចជាតិទាំងមូល

ហិរញ្ញវត្ថុសាធារណៈ ជាថវិកា បម្រុងរបស់រដ្ឋដើម្បីទ្រទ្រង់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងរដ្ឋបាលសាធារណៈឲ្យមានប្រសិទ្ធភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

### ៣.ច. មន្ត្រីរាជការស៊ីវិល ( Public Servants )

ជាការពិតណាស់ស្ទើរតែគ្រប់អ្នកប្រាជ្ញនៃរដ្ឋបាលសាធារណៈ គ្មានអ្នកណាម្នាក់បដិសេធន៍នូវវត្តមានមន្ត្រីរាជការស៊ីវិលនៅក្នុងក្របខ័ណ្ឌនៃរដ្ឋបាលសារធារណៈឡើយ។ អញ្ចឹងហើយ ទើបយើងតែងតែឃើញមតិរិះគន់ពីប្រជាពលរដ្ឋពីសាធារណៈជនចំពោះរាជការ និងរដ្ឋាភិបាល។ ពួកគេយល់យ៉ាងច្បាស់ថា សណ្តាប់សាធារណៈ និងការអភិវឌ្ឍលើវិស័យនានាទាំងអស់ជាភារកិច្ចរបស់មន្ត្រីរាជការដែរជាភ្ជាក់ងារយ៉ាងសកម្មរបស់រដ្ឋាភិបាល។ ដូច្នេះហើយទើបរដ្ឋាភិបាលនីមួយយកទឹកទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញ លើកទឹកចិត្ត ម្លើងថ្នាក់ និងដាក់ទណ្ឌកម្មផ្សេងៗទៅលើមន្ត្រីរាជការយើងដែលបំពេញកិច្ចការបានល្អ ដែលប្រព្រឹត្តកំហុស និងអសកម្មផ្សេងៗ។

ឆ្លៀតឱកាសនេះ យើងសូមច្បិចយកច្បាប់ត្រីនេត្រដែលជាបុរាណច្បាប់និពន្ធចងក្រងដោយកវីរាជជូនជាគតិខ្លះដូចតទៅ។ ត្រីនេត្រជាច្បាប់ប្រកបដោយអង្គបីនៃការទូន្មានជាបីៗបទ។ កវីរាជសំដៅ ការអប់រំទៅលើការរស់ ការទាក់ទងជាបច្ច័យរវាងគ្នានៃនរកជនដែលជារាជមាត្យ ជាមន្ត្រី ជាសេនា ជាកវីបណ្ឌិត ជាអ្នករាជការបម្រើ

ព្រះមហាក្សត្រ[15] ជាប្រជារាស្ត្រ និងប្រទេសជាតិមានសេចក្តីដូចតទៅ ៖

នរូអ្នកណា នឹងចូលទៅជា វររាជអាមាត្យ
សេនាមន្ត្រី កវីជាអាទិ៍ រៀនច្បាប់ជាខ្នាត
តែងទុករៀងទៅ ។

ដ្បិតមុខមន្ត្រី សេនាបតី ពុំដោយគន្លង
លោភោបង់បាន បំពានរាស្ត្រផង រាស្ត្ររឹងក្តៅហោង
អង្គឥតអាស្រ័យ ។

រាស្ត្រដូចមច្ឆា មន្ត្រីសេនា ដូចគង្គានៃ
បើប្រែជាក្តៅ ក្រែក្រៅវិស័យ រាស្ត្ររឹងកើតភ័យ
អង្គឥតពុំនាក់ ។

មន្ត្រីយោធា បីដូចព្យគ្ឃា និពស់ពញ្លាក់
រីអស់រាស្ត្រផង ចរចូលពឹងពាក់ ក្សិណប្រែជាយក្ស
យល់ឥតករុណា[16] ។

លោកពន្យល់ន័យសេចក្តីល្អិតល្អន់ច្រើនប្រការ តែយើងសូមលើកយកមកបញ្ជាក់ដូចតទៅ ៖

**ក-កូនកាចកំណាច វិនាសសន្តាន (ហៅកុបុត្តំ)**

[15] លាង ហាប់អាន ៖ ព្រះរាជសម្ភារ កវីសតវត្សទី១៧ ឆ្នាំ១៩៦៦ ទំព័រ៦៨

[16] លាង ហាប់អាន ៖ ព្រះរាជសម្ភារ កវីសតវត្សទី១៧ ឆ្នាំ១៩៦៦ ទំព័រ៦៩-៧០

-នៅភូមិអាក្រក់ កើតមានព្យាធិ ពុំប្រពៃ (ហៅកុភូមំ)

-នៅផ្ទះអាក្រក់ កើតហិនហោច អាប់ឥតមង្គល (ហៅកុគេហំ)។

**ខ-មន្ត្រីល្អមានប្រាជ្ញាដឹងអស់អធ្យាស្រ័យ ធ្វើឲ្យក្សេមក្សាន្តនគររាស្ត្រមណ្ឌល (ហៅសុមន្ត្រី)**

-កូនមានគំនិតល្អ នាំចម្រើនបងប្អូនសាច់សន្តាន (ហៅសុបុត្តំ)

-ភូមិស្ថាន ផ្ទះសម្បែងល្អ នាំចម្រើនធនធាន ចម្រើនប្រាជ្ញាដល់អ្នករស់នៅ (ហៅសុភូមិ និង សុគហំ)។

**គ-លក្ខណះអសារឥតការមកអំពី**

-មានទ្រព្យ ពុំធ្វបុណ្យសងគុណគេ

-ពុំកាន់សីល គ្មានពាក្យទៀងត្រង់ ពុំចង់បានបុណ្យ ពុំប្រណិប័តន៍សង្ឃ ពុំឧស្សាហ៍

-ពុំស្តាប់ធម៌ ពុំកាន់ក្រឹត្យក្រមច្បាប់ ពុំធ្វើបរិសុទ្ធ។

**ឃ-លក្ខណះផ្តង់បីយ៉ាង**

-ស្នេហាកុំភ្លេចសំណេះសំណាលសាកសួរស្នេហ៍ស្នង

-ភរិយាដោយការឲ្យរក្សានូវទ្រព្យធន ផ្ទះសម្បែង

-បុត្រដោយឲ្យរៀនសាស្ត្រសិល្ប៍ ច្បាប់រិះរកកិរិយាល្អឲ្យ[17]។

ជាថ្មីម្តងទៀត ការប្រព្រឹត្តរបស់មន្ត្រីរាជការ ជាការឆ្លុះបញ្ចាំង

---

[17] លាង ហាប់អាន៖ ព្រះរាជសម្ភារ កវីសតវត្ស៍ទី១៧ ឆ្នាំ១៩៦៦ ទំព័រ៦៩-៧០

នូវអាកប្បកិរិយារបស់រដ្ឋនីមួយៗនោះ។ មន្ត្រីរាជការជាខ្នងបង្អែករបស់ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល។

មន្ត្រីរាជការមានបុព្វសិទ្ធិ(prerogative) ដែលជាអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធររដ្ឋបាល គឺជាអំណាចដែលមានជាប់ចំណងដោយវិធានច្បាប់ ហើយដែលអាជ្ញាធរអាចប្រើប្រាស់បានដោយសេរីដើម្បីប្រសិទ្ធភាពនៃការបំពេញបេសកកម្មរបស់ខ្លួន។ ប៉ុន្តែអំណាចឆន្ទានុសិទ្ធិតម្រូវស្ថិតនៅក្នុលក្ខខណ្ឌពីរជាចាំបាច់ដើម្បីឲ្យស្របនឹងតម្រូវការនីត្យានុកូលភាពគឺ

១-លក្ខខណ្ឌសមត្ថកិច្ច

២-លក្ខខណ្ឌផលប្រយោជន៍សាធារណៈ

អាជ្ញាធរអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយធ្វើ ឬមិនធ្វើអន្តរាគមន៍ ដោយយោងទៅលើលក្ខខណ្ឌទាំងពីរខាងលើនេះ។ ការជ្រើសរើសមធ្យោបាយធ្វើអន្តរាគមន៍ ក៏ត្រូវថ្លឹងឲ្យសមរម្យ និងសភាពការណ៍ ហើយនឹងកាលៈទេសៈ[18]។ ដូច្នេះអំណាចឆន្ទានុសិទ្ធិ ជាអំណាចស្របច្បាប់ រីឯអំណាច តាមទំនើងចិត្តព្រៃផ្សៃខុសច្បាប់[19]។

## ៤. គោលការណ៍របស់អ្នករដ្ឋបាល

គោលការណ៍របស់អ្នករដ្ឋបាលរួមាន៖

[18] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ២០១

[19] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ២០១

### ៤-ក-អព្យាក្រឹតភាព ( Neutrality/ Equanimity )

អ្នករដ្ឋបាលមិនត្រូវមាននិន្នាការប្រកាន់បក្សពួកនិយមឡើយ។ ត្រូវធ្វើកិច្ចការសព្វសារពើទៅតាមតួនាទីនិងភារកិច្ចរបស់ខ្លួនដោយគោរពតាមគោលការណ៍ច្បាប់កំណត់។ជាគោលការណ៍មួយតម្រូវ ឲ្យអ្នករដ្ឋបាលប្រកាន់ឲ្យខ្ជាប់ខ្លួននៅពេលដែលខ្លួនបំពេញការងារ ជាអ្នកបម្រើរាស្ត្រ និងបម្រើសេវាសាធារណៈផ្សេងៗ។ នេះជាទស្សនៈប្រកបដោយបទពិសោធន៍ និងការគិតគូរគ្រប់ជ្រុងជ្រោយបំផុត ពីព្រោះថា ប្រសិនមន្ត្រីសាធារណៈប្រកាន់បក្សពួក រើសអើងមានឥរិយាបថលម្អៀងហើយ ប្រជាពលរដ្ឋអស់សង្ឃឹមថានឹងទទួលបានសេវាពេញលេញហើយ។ ភាពអព្យាក្រឹត្យនេះមានប្រជាប្រិយភាពណាស់ និងត្រូវបានដាក់ឲ្យអនុវត្តយ៉ាងទូលំទូលាយនៅក្នុងពិភពលោកយើង។ ព្រះពុទ្ធព្រះបរមគ្រូនៃយើងក៏ទ្រង់សម្រេចដោយផ្លូវកណ្តាល( មជ្ឈិមបដិបទា )នេះដែរ។

### ៤-ខ-អចិន្ត្រៃយ៍ភាព ( Permanence )

អ្នករដ្ឋបាលត្រូវធ្វើការងារជាប្រចាំដោយគោរពពេលវេលាធ្វើការងារឱ្យបានទៀងទាត់។ ជាវាក្យស័ព្ទមួយទៀតរបស់អ្នករដ្ឋបាលនិយម ដែលប្រកាន់គោលការណ៍មិនចេះគេចវេសពីការទទួលខុសត្រូវរបស់ខ្លួន។ អ្នករដ្ឋបាលមានវិជ្ជាជីវៈពិតប្រាកដ មិនដែលដើរចោល ឬចេញក្រៅការិយាល័យក្នុងពេលវេលាធ្វើការទេ ពីព្រោះក្នុងម៉ោងបំពេញការងារ ប្រជាពលរដ្ឋ ឬសហការីតែងតែ មកទំនាក់ទំនង

ការងារជាប្រចាំ។ អ្នករដ្ឋបាលប្រៀបដូចជាមេផ្ទះមួយរូបដែលតែងតែដឹងពីសុខទុក្ខគ្រប់បែបយ៉ាងនៅក្នុងផ្ទះ ក្នុងការិយាល័យ ក្នុងស្ថាប័ន។ ប្រសិនបើមានការអ្វីកើតឡើង អ្នករដ្ឋបាលមិននៅក្នុការិយាល័យទូរសព្ទមិនចូលទូរសព្ទចូលហើយមិនលើក តើឲ្យយើងទៅសួរអ្នកណា? ដូច្នេះរាល់ម៉ោងការងារត្រូវតែមានវត្តមាននៅការិយាល័យជានិច្ច។

**៤-គ-តម្លាភាព** ( Transparency )

ភាពថ្លាភ្លឺច្បាស់ធ្វើអ្វីមួយមានហេតុផលត្រឹមត្រូវ។ ការនេះមិនសំដៅតែលើបញ្ហាពុករលួយ លុយកាក់ មាសប្រាក់ ត្រូវតែស្អាតស្អំប៉ុណ្ណោះទេ ប៉ុន្តែការងារក្រដាស់ស្នាម រាល់ឯកសារនានាត្រូវតែដឹងឮទាំងអស់គ្នា។ គ្មានអ្វីត្រូវលាក់លៀមក្នុងចំណោមបុគ្គលិកគ្នាឯងទេ។

នៅក្នុងឆ្នាំ១៩៥៥ គឺសម័យសង្គមរាស្ត្រនិយម។ ពេលនោះព្រះករុណាទ្រង់បានដាក់រាជ្យមក ជាព្រះបិតាឯករាជ្យ ជាសម្តេចឪ។ រហូតដល់ឆ្នាំ១៩៦៨ សម្តេចឪទ្រង់បានលើកពាក្យស្លោកថា ធ្វើឲ្យប្រទេសកម្ពុជាទៅជាផ្ទះ" កញ្ចក់" (Maison de verre/ Mirrow house)ដូច្នេះយើងឃើញថា ក្នុងគំនិតតម្លាភាពនេះមានតាំងពីសម័យសម្តេចឪមកម្ល៉េះ[20]។ តាមព្រះបន្ទូលខាងលើ ទ្រង់ចង់ឲ្យសង្គមខ្មែរស្អាតស្អំ កុំពុករលួយមិនមែនបើទ្វារបង្អួចការិយាល័យធ្វើការដើម្បីកុំ

[20] មជ្ឈមណ្ឌលអភិវឌ្ឍសង្គម៖ អំពើពុករលួយ និងឥទ្ធិពលរបស់វាមកលើការបង្រួបបង្រួមជាតិ និងការស្តាបនាជាតិឡើងវិញ សុន្ទរកថាបណ្ឌិត សាយ បូរី ថ្ងៃទី២-៣ ខែមីនា ឆ្នាំ ១៩៩៥

ឲ្យមន្ត្រីជួបជុំហើយសុំគ្រលំការងារលុយកាក់ខុសច្បាប់នោះទេ។ ប៉ុន្តែក្នុងន័យនេះ អ្នករដ្ឋបាលត្រូវមានភាពស្អាតស្អំប្រកបដោយមនសិការវិជ្ជាជីវៈ។ សូមបញ្ជាក់ថា តម្លាភាពនេះមិនសំដៅតែបញ្ហាហិរញ្ញវត្ថុប៉ុណ្ណោះទេប៉ុន្តែក៏ចង់សំដៅផងដែរទៅលើកិច្ចការទូទៅនការិយាល័យរបស់ខ្លួន ករណីចុងក្រោយនេះ នៅប្រទេសបារាំង គេមានវិធានច្បាប់តឹងតែងចំពោះអ្នកធ្វើឲ្យបែកធ្លាយកិច្ចការសំខាន់ៗ។ នៅប្រទេសស៊ុយអែត ប្រទេស ហ្វាំងឡង់ និងប្រទេសដាណឺម៉ាក ។ល។សុទ្ធតែមានការបើកទូលាយណាស់ដើម្បីឲ្យប្រជារាស្ត្របានដឹង កិច្ចការដែលរាជការ ឬរដ្ឋការបានអនុវត្ត។ ចំណែកនៅសហរដ្ឋអាមេរិក អតីតប្រធាធិបតីលោក ទ្រូម៉ាន់ បានបញ្ជាឲ្យមានការបើកចំហរកិច្ចការទាំងឡាយ តែដោយសារការបើកទូលាយខ្លះវាបានធ្វើឲ្យខូចប្រយោជន៍ជាតិទាំងមូលទើបក្រោយមកកែប្រែឲ្យមានបិទបាំងនូវរឿងរ៉ាវសំខាន់ៗដែលប៉ះពាល់ដល់ ប្រយោជន៍របស់ប្រទេសជាតិ។ ទោះបីយ៉ាងណាបញ្ហាហិរញ្ញវត្ថុនៅសហរដ្ឋអាមេរិកនៅតែបើកចំហរដដែល[21]។

## ៥-តួនាទី និងលក្ខណៈសម្បត្តិរបស់អ្នករដ្ឋបាល

ថ្វីបើប្រេកសម្រាប់អ្នករដ្ឋបាលបំពេញការងារទូលំទូលាយ ប៉ុន្តែអ្នករដ្ឋបាលក៏ត្រូវតែមានលក្ខណៈសម្បត្តិ និង ចំណេះដឹង (Qualified Administrator)សំខាន់ៗមួយចំនួនដែរ។

[21] ឯកសារដដែល ទំព័រ៤១-៤៣

**៥-ក-ឧស្សាហ៍ព្យាយាម និង អំណត់** ( Commitment )

អ្នករដ្ឋបាលត្រូវតែជាមនុស្សឧស្សាហ៍ព្យាយាម និងមានសេចក្ដីអំណត់ទោះបីក្នុងកាលៈទេសៈពិបាកជាមួយនឹងតួនាទីដ៏មមារញឹកការងារ និងលំបាកយ៉ាងណាក្ដី។ ការអនុវត្តតាមគោលគំនិតនេះ នឹងជំរុញឲ្យការងារគ្រប់គ្រងរបស់យើងកាន់តែមានប្រសិទ្ធភាព និងអនុញ្ញាតឲ្យអ្នកទទួលសេវាកម្មទទួលបានលទ្ធផលជាទីពេញចិត្ត។

**៥-ខ-តាមដានការងារជាប្រចាំ** ( Work observation )

អ្នករដ្ឋបាលត្រូវតែមានការតាមដានការងាររបស់ខ្លួនទៅតាមភារកិច្ច និងតួនាទីជាប្រចាំដែលកំណត់ដោយច្បាប់ និងបទបញ្ជារបស់ស្ថាប័នទាំងអស់។ អវត្តមាននៃការតាមដានការងារក៏ដូចជាការបង្កើតការងារ ឬទទួលការងាររួចហើយយកមកទុកចោល បង្កើតជាទម្លាប់មិនល្អហើយឆ្ពោះទៅរកការបរាជ័យរបស់ស្ថាប័ន និងក្នុងអាជីពដោយចៀសមិនផុតឡើយ។

**៥-គ-ឈ្វេងយល់ការងារនៅក្នុងអង្គភាព** ( Work seeking out

ជាធម្មតាមនុស្សយើងរស់នៅឬធ្វើការកន្លែងណាមួយត្រូវតែមានការឈ្វេងយល់ពីកន្លែងនោះ។ អ្នករដ្ឋបាលត្រូវតែជាមនុស្សរហ័សរហួន ឆ្លាតវាងវៃ ចេះស្វែងយល់ស្វែងដឹងអំពីប្រវត្តិ ឬទស្សនវិជ្ជានៃកន្លែងធ្វើការរបស់ខ្លួនឲ្យបានច្បាស់លាស់។ ថ្វីបើកន្លែងខ្លះ អ្នករដ្ឋបាលជាមនុស្សថ្មីយ៉ាងណាក៏ដោយក៏យើងត្រូវតែដឹងត្រូវសួរនាំស្វែងរកព័ត៌មានសិក្សាបន្ថែមលៃយ៉ាងណាឲ្យព័ត៌មានទាំងអស់នៃអនាគត

កិច្ចការរបស់យើងស្ថិតនៅក្នុងដៃរបស់យើងទាំងស្រុង។ តើយើងធ្វើសេចក្ដីសម្រេចម្ដេចទៅបើយើងមិនដឹងទាំងលំហូរការងារនេះពីណាទៅណាផងនោះ? ដាងនេះទៅទៀតច្បាប់បទបញ្ជា និងវិធានផ្សេងៗ ត្រូវតែអាន ត្រូវតែរៀនសូត្រជាប្រចាំ។

**៥-ឃ-ចេះដកស្រង់បទពិសោធន៍** ( Experience exchange )

ការងារខ្លះទទួលបានចំណេះដឹងទាំងស្រុងពីបទពិសោធន៍ដែលយើងធ្លាប់ជួបប្រទះ និងការសាកល្បងធ្វើ( ក្នុងក្របខ័ណ្ឌអំពើល្អស្របច្បាប់ )។ អ្នករដ្ឋបាលខ្លះគិតថាខ្លួនចេះទាំងអស់មិនចាំបាច់សាកល្បង ឬធ្វើអ្វីមុននាំតែខាតពេលទេ។ ប្រសិនបើគិតដូច្នេះ វាអាចបង្កើតជាកំហុសមួយ បុគ្គលលិកមួយចំនួនយើងមិនស្គាល់អារម្មណ៍គាត់ទេ គាត់អាចស្ដាប់បញ្ជាយើង ហើយក៏អាចប្រកែកមិនទទួលបញ្ជាដែរ។ សូមសិក្សាអក្សរសិល្ប៍ខ្មែររឿង តេជោយ៉ត ត្រង់ឈុតមួយដែល តេជោមាស ស្លាប់ទៅ ព្រះករុណាព្រះបាទ ជ័យជេស្ដា ទ្រង់តែងតាំង តេជោយ៉ត ឲ្យក្លាយជាមេទ័ពបន្តពីគ្រូរបស់គាត់បន្តទៅទៀត តើការងារអ្វីដែល តេជោយ៉ត ចាប់ផ្ដើមមុនគេបង្អស់មុននឹងដឹកនាំទ័ពទៅសមរភូមិ? បញ្ហាឲ្យអូសបួស្សីបញ្ច្រាស់ចុង !

**៥-ខ-ពង្រីកចំណេះដឹង** ( Knowledge enpension )

ជាថ្មីម្ដងទៀត ចំណេះដឹងសំខាន់ខ្លាំងណាស់សម្រាប់មនុស្សទូទៅទាំងអស់មិនចាំតែរាជការ អ្នកដឹកនាំនោះទេ។ ជាអ្នករដ្ឋបាលម្នាក់ដែលដើរតួសំខាន់ក្នុងការបំពេញការងារជាមេផ្ទះត្រូវរ៉ាប់រងការ

ងារសន្តិសុខ លិខិតស្នាម អនាម័យ សម្ភារបរិក្ខា សណ្តាប់ធ្នាប់ កន្លែងខ្លះហិរញ្ញវត្ថុទៀតផង។ អាស្រ័យហេតុនេះ យើងមិនអាចឆ្លើយដោះសារថា មិនដឹង មិនយល់ពីអ្វីដែលស្ថាប័នពាក់ព័ន្ធស្នើមក ឬដាក់មកសុំយោបល់នោះទេ។

**៥-ច-សាកល្បងធ្វើការងារថ្មី** New work experiment

ករណីនេះមិនខុសឆ្ងាយពីគោលការណ៍ខាងលើប៉ុន្មានទេ តើការងារថ្មីណាខ្លះដែលអ្នករដ្ឋបាលគួរសាកល្បងទទួលយក? ឧទាហរណ៍ អ្នករដ្ឋបាលធ្លាប់ទទួលភារកិច្ចតែលើការងារគ្រប់គ្រងបុគ្គលិក សរសេរលិខិតស្នាម គ្រប់គ្រងលិខិតចេញចូល ការងារសន្តិសុខ។ល។ ចុះប្រសិនបើថ្នាក់ដឹកនាំចាត់តាំងអនុវត្តលើការងារសវនកម្ម(សកម្មភាពការងារនិងហិរញ្ញវត្ថុ) ការងារលទ្ធកម្មថែមទៀត? តើអ្នករដ្ឋបាល អាចប្រកែកថា មិនទទួលយក ពីព្រោះតែហេតុថា ខ្លួនមិនចេះលើជំនាញហិរញ្ញវត្ថុ និងការងារដេញថ្លៃឬទេ?

**៥-ជ-សមត្ថភាព** (Capacity)

តាមសម្តេចព្រះសង្ឃរាជ សមត្ថភាព មកពីពាក្យថា (ន)បាន សេចក្តីថា សេចក្តីអាច ការអាចហាន ការហ៊ាន ដំណើរធ្វើកើត។ សមត្ថកាល វេលាដែលខ្លួននៅប្រឹងប្រែងបាន,វេលាដែលធ្វើការការកើតនៅឡើយ(វេលាកំពុងពេញកម្លាំង)[22]។ មនុស្សមានសមត្ថភាពជាមនុស្សមានប្រាជ្ញាច្រើន មានការយល់ដឹងរហ័ស ឆាប់យល់នូវបញ្ហា

---

[22] សម្តេចព្រះសង្ឃរាជ ជួន ណាត៖ វចនានុក្រមខ្មែរ ឆ្នាំ១៩៦៧ ទំព័រ៧៩៤

ដែលជួបប្រទះ ហើយជាមនុស្សដែលធ្លាប់បានរៀន បានឆ្លងកាត់ អ្នកមានវ័យចាស់ជាងក៏អាចរាប់ថាមានសមត្ថភាពជាងមនុស្សដែលមានវ័យក្មេងជាងដែរ។ ឧទាហរណ៍ អ្នករៀនចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិទៅនិយាយអំពីកម្មវិធីសិក្សាបឋមភូមិងាយយល់ អ្នករៀនថ្នាក់ ឬចប់ថ្នាក់បរិញ្ញាបត្រទៅនិយាយអំពីកម្មវិធីសិក្សាទុតិយភូមិមិនសូវពិបាកពន្យល់ទេ អ្នកបានរៀនជា មួយអ្នកមិនបានរៀន និងដូចគ្នាដែរ អ្នកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។

**៥-ឈ-វិជ្ជាជីវៈ** ( Professional )

ករណីនេះមានការផ្សេងគ្នានឹងលក្ខណៈទី៧ត្រង់ថា អ្នកមានវិជ្ជាជីវៈអាចមិនមានសមត្ថភាព ពីព្រោះអ្នកចេះវិជ្ជាណាមួយដើម្បីរកស៊ីចិញ្ចឹមជីវិតបានទាល់តែអ្នកនោះមានរបបរកស៊ីមួយ។ មុខរបរអាចជាជាងកាត់សក់ ជាងម៉ាស៊ីន ជាងចម្លាក់ ជាងជួសជុសរថយន្ត អ្នកបើកបររថយន្ត ជាងដេរប៉ាក់ ពួកគាត់មិនប្រាកដថា មានសមត្ថភាពទូលំទូលាយ ឬសញ្ញាបត្រខ្ពស់ទេ។ ប៉ុន្តែអ្នករដ្ឋបាលត្រូវមានទាំងសមត្ថភាព និងវិជ្ជាជីវៈសម្រាប់ធ្វើការក្នុងការិយាល័យផងដែរ។

**៥-ញ-ការទទួលខុសត្រូវ** ( Responsibility )

ការទទួលខុសត្រូវសំខាន់ណាស់ មនុស្សរាល់រូប គ្មានអ្នកណាចង់ឈរ ឬជ្រើសរើសខាងខុសទេ ប៉ុន្តែខាងត្រូវជានិច្ច។ ជាកំហុសមួយធំណាស់ណាស់ ប្រសិនបើជាមេដឹកនាំម្នាក់ បុគ្គលិកម្នាក់ស្គាល់ និងប្រកាន់យកតែខាងត្រូវមួយមុខនោះ។ អ្នករដ្ឋបាលដែលល្អជាមនុស្សដែលចេះទទួលយកការងារដែលខ្លួនប្រព្រឹត្តរួចហើយហើយ

ទាំងខុសផងទាំងត្រូវផង។ ប្រសិនបើខ្លួនទទួលតែខាងត្រូវទាំងអស់ ដូច្នេះ តើទុកការខុសឲ្យអ្នកណា?

មាតាបិតាទាំងឡាយត្រូវខិតខំអប់រំកូន គ្រប់គ្រងកូនឲ្យបាន ល្អ។ អសន្តិសុខគឺខ្លួនយើងបង្កខ្លួន យើង។ ក្រុមបងតូចបងធំ អុក លូកសាលារៀន ជាកូនចៅរបស់យើង។ មន្ត្រីអ្នកមានអំណាច គ្រប់គ្រងកូនឲ្យបានល្អ។ អសន្តិសុខ គឺខ្លួនយើងជាអ្នកបង្កឡើង ដោយខ្លួនយើង មន្ត្រីអ្នកមានអំណាច កូនចៅអ្នកមាន។ បើពពកទៅ បាំងព្រះចន្ទ គង់បាត់បង់ពន្លឺនៅលើភពផែនដីដែរ ទីភ្លឺវាក្លាយទៅទីង ងឹត។ បើចៅហ្វាយខេត្ត ចៅហ្វាយក្រុង ចៅហ្វាយស្រុក មេប៉ូលី សខេត្ត មេប៉ូលីសស្រុកធ្វើមិនកើត ឲ្យបងធំបងតូចធ្វើម្តងទៅ។ តើ ទុកឲ្យសង្គមស្ថិតក្នុងភាពភ័យខ្លាចឬ? វិធានការរដ្ឋបាល ត្រូវប្រកាន់ យកដោយម៉ឺងម៉ាត់ បើបណ្តោយកូន ឪសក្តិ៥ កូនធ្វើផ្តេសផ្តាស ធ្លាក់ សក្តិអន្តរាគមន៍កូន ដកសក្តិ។ បញ្ហាស៊ីរ៉ែន និងការពារសម្បុរបែប ដេកមិនបានស៊ីរ៉ែនពីមុខផងពីក្រោយផង កុំបានអំណាចហើយឈ្លក់ ទឹកម៉ាស៊ីនអំណាច យកមហិទ្ធិរិទ្ធិ បង្ហួតស្រីស្អាតម៉ូតូអម[23]។

**៥-៨-មនសិការ** ( Conscience )

ជាចិត្តសាស្ត្រ និងឧត្តមគតិមួយរបស់អ្នកបម្រើសេវាកម្មទាំង អស់លើលោកនេះ។ គ្រប់បុគ្គលណាក៏ដោយ ធ្វើការអ្វីមួយត្រូវមាន មនសិការការងារនោះ ទោះបីការងារនោះយើងមិនពេញចិត្តនឹងធ្វើក៏

[23] សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៥

ត្រូវតែបណ្តុះឆន្ទៈស្រឡាញ់ និងយកចិត្តទុកដាក់លើការងារនោះដែរ ពោលគឺមិនទុកការងារចោលកណ្តាលទី ឬមិនសូវយកចិត្តទុកដាក់ការងារដែលខ្លួនកំពុងតែបំពេញរាល់ថ្ងៃ។

## ៦. រដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន

រដ្ឋបាលសាធារណៈត្រូវបានបែងចែកជាមែកធាងទៅតាមប្រភេទនៃការគ្រប់គ្រង ការទទួលខុសត្រូវ និងស្ថាប័នផ្សេងៗគ្នា។

**៦-ក-រដ្ឋបាលសាធារណៈ**(Public administration)

គឺជាប្រភេទរដ្ឋបាលគ្របដណ្តប់ទៅលើការគ្រប់គ្រងរដ្ឋការ (រាជការ)បម្រើផលប្រយោជន៍ទូទៅ។ រដ្ឋបាលទាំងនោះត្រូវ ចេះគោរព និងស្តាប់បង្គាប់ថ្នាក់លើ។ សេចក្តីសម្រេចរបស់ថ្នាក់លើត្រូវតែអនុវត្តឲ្យបានម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់។ ត្រូវចាំថា រាជការជាកិច្ចជាអ្នកទទួលប្រាក់បៀវត្សន៍ពីប្រជាពលរដ្ឋដែលបង់ពន្ធ ដូច្នេះការងារទាំងអស់ស្របនឹងឆន្ទៈរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិ។ ជាពិសេស មន្ត្រីរាជការជាមនុស្សដែលចេះផ្តួចផ្តើម និងមានទទួលខុសត្រូវខ្ពស់លើតួនាទីរបស់ខ្លួន។ ក្លាយខ្លួនទៅជាមន្ត្រីជើងពីរ កុំទៅជាមន្ត្រីជើងដប់។ ត្រូវឲ្យនៅជិតប្រជាពលរដ្ឋ ដាក់ខ្លួនឲ្យទាប អង្គុយឲ្យខ្ពស់ ដាក់ខ្លួនឲ្យកាន់តែទាប[24]។

---

[24] សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ថ្លែងក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រដល់សិស្សមន្ត្រីក្រមការ ជំនាន់ឈ្នះ ឈ្នះ និងវិញ្ញាបនបត្រដល់កម្មសិក្សាការី មន្ត្រីជាន់ខ្ពស់ និងមធ្យម នៅសាលាភូមិន្ទរដ្ឋបាល ថ្ងៃចន្ទ ទី២៩ ខែធ្នូ ឆ្នាំ២០០៣

**៦-ខ-រដ្ឋបាលឯកជន** ( Private administration )

គឺជាប្រភេទរដ្ឋបាលដែលគេប្រើប្រាស់នៅក្នុងអង្គភាពឯកជន ដូចជា រោងចក្រ សហគ្រាស ក្រុមហ៊ុន អង្គការឯកជន សមាគម...។ ក្នុងសង្គមប្រជាធិបតេយ្យ វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយរដ្ឋាភិបាលដើម្បីលើកតម្កើងសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងជាពិសេស ជំរុញការលូតលាស់ឆាប់រហ័សនៃវិស័យសេដ្ឋកិច្ចជាតិ។

លោក Nigro ជាអ្នកនិពន្ធជនជាតិអាមេរិកកាំង បានលើកឡើងថា “រដ្ឋាភិបាល គឺមិនដូចគ្នាទៅនឹងក្រុមហ៊ុនឯកជនទេទាំងទំហំ និងទាំងវិសាលភាពនៃការងារ។ សកម្មភាពរបស់រដ្ឋាភិបាលប៉ះពាល់ដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសទាំងមូល” ។

**តារាងសង្ខេបអំពីភាពខុសគ្នារវាងរដ្ឋបាលសាធារណៈ និងរដ្ឋបាលឯកជន**

| **រដ្ឋបាលសាធារណៈ** | **រដ្ឋបាលឯកជន** |
| --- | --- |
| - ការគ្រប់គ្រងមានលក្ខណៈទូលំទូលាយ | - ការគ្រប់គ្រងមានកម្រិតកំណត់ |
| - សកម្មភាពរបស់មន្ត្រីរាជការ គឺផ្អែកលើមូលដ្ឋាននៃទំនុកចិត្តពីសាធារណៈជន ពោល គឺការទទួលខុសត្រូវខាងផ្លូវច្បាប់ | សកម្មភាពរបស់បុគ្គលិក គឺផ្អែកលើមូលដ្ឋាននៃទំនុកចិត្តពីអតិថិជន ហើយការទទួលខុសត្រូវខាងផ្លូវច្បាប់មានកំណត់ |

| | |
|---|---|
| - នីតិវិធីក្នុងការចេញសេចក្តីសម្រេចមានលក្ខណៈជាប្រចាំ និងជាក់លាក់ | -នីតិវិធីក្នុងការចេញសេចក្តីសម្រេចគ្មានកំណត់ព្រំដែន |
| - ទទួលរងនូវការរិះគន់ពីសាធារណៈជន | - មិនសូវមានការរិះគន់ពីសាធារណៈជន |

## ៧-តួនាទីរដ្ឋបាលសាធារណៈក្នុងសង្គមទំនើប

រដ្ឋបាលសាធារណៈមានតួនាទីសំខាន់ណាស់នៅក្នុងរដ្ឋមួយ។ ការផលិត និងផ្គត់ផ្គង់ទំនិញសាធារណៈ ការការពារ និងការថែរក្សាសណ្តាប់ ធ្នាប់សង្គម ការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ គឺជាតួនាទី និងភារកិច្ចរបស់រដ្ឋាភិបាលដែលត្រូវធ្វើតាមរយៈរដ្ឋបាលសាធារណៈ។

ចាប់តាំងពីទសវត្សទី៤០មក រដ្ឋាភិបាលកាន់តែគិតគូយ៉ាងខ្លាំងអំពីការអភិវឌ្ឍន៍ជាតិរបស់គេទាក់ទងនឹងសេដ្ឋកិច្ច សង្គមកិច្ច លើសពីអ្វីដែលរដ្ឋាភិបាលធ្លាប់ធ្វើពីមុន គឺថែរក្សាសន្តិសុខជាតិ ផ្តល់ និងផលិតនូវទំនិញសាធារណៈ។ នេះជាដំណាក់កាលមួយដែលប្រទេសជាច្រើនទើបនឹងបានងើបផុតពីសង្គ្រាមលោក។ រដ្ឋបាលសាធារណៈមានតួនាទីមួយទៀតគឺ Executive Leadership តួនាទី នេះមានសំខាន់ៗដូចតទៅ៖

### ៧-ក-តួនាទីពិសេសចំពោះរដ្ឋ៖

-ថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម

-ផ្តល់នូវយុត្តិធម៌សង្គម

-ការពារនូវសិទ្ធិលើកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ និង របស់រដ្ឋ

-ដាក់ចេញនូវគោលនយោបាយគ្រប់គ្រងរដ្ឋបាល និងគោលនយោបាយការបរទេស

**៧-ខ-តួនាទីទ្រទ្រង់ដល់សុខមាលភាពរបស់រដ្ឋ៖**

-ថែរក្សានូវធនធានធម្មជាតិ

-ផលិត និងផ្គត់ផ្គង់នូវទំនិញសាធារណៈ ដល់ប្រជាពលរដ្ឋ

-ថែរក្សានូវទ្រព្យសម្បត្តិសាធារណៈ ដូចជា សួនច្បារ បឹងបួរ ទន្លេ សមុទ្រ សាលារៀន មន្ទីរពេទ្យ សារៈមន្ទីរ .....ៗលៗ

-ថែរក្សានូវប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ សីលធម៌ បេតិកភ័ណ្ឌជាតិ

តួនាទីសំខាន់មួយទៀតរបស់រដ្ឋ គឺការរៀបចំបង្កើតឡើងនូវគោលនយោបាយទូទៅក្នុងការគ្រប់គ្រងរដ្ឋ។ សង្គមដែលមានការរៀបចំឲ្យទៅជាប្រទេសមួយបាន លុះត្រាតែគេចេះធ្វើយ៉ាងម៉េចឲ្យសង្គមនោះរស់នៅបានដោយមានសណ្តាប់ធ្នាប់សាធារណៈរៀបរយល្អគឺមានសន្តិសុខ សុវត្ថិភាព ភាពសុខសាន្ត និងអនាម័យល្អ[25]។ ចាប់ពីសតវត្សទី១៥មក នៅប្រទេសអឺរ៉ុប ជាពិសេសបារាំង និងអាឡឺម៉ង់

[25] សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ១៨

មានប្រើពាក្យថា **ប៉ូលីស** (Police)។ ពាក្យ **ប៉ូលីស** សំដៅលើសណ្តាប់ធ្នាប់សាធារណៈល្អនេះហើយ។ រហូតមកដល់សតវត្សទី១៦ បារាំងបន្ថែមន័យនៃពាក្យ **ប៉ូលីស** នេះនូវពាក្យ **សុខមាលភាព** ដែលមានន័យថា សេចក្តីសុខកាយសប្បាយចិត្ត(le bien-être)។ ចំណែកអាឡឺម៉ង់បានបន្ថែមលើសពីបារាំងដោយបានបញ្ចូលគំនិតថា **សណ្តាប់ធ្នាប់សាធារណៈខាងសីលធម៌ ខាងមាយាទក្នុងសង្គមដើម្បី**ថែរក្សាទំនៀមទម្លាប់ល្អ។ ចំពោះប្រទេសអាឡឺម៉ង់ សណ្តាប់ធ្នាប់ល្អគឺទាំងផ្លូវកាយ ផ្លូវសម្ភារៈ ផ្លូវសីលធម៌ និងផ្លូវចិត្តគំនិត[26]។

លោកស្រី ម៉ាហ្គារ៉េត ថាច់ឈ័រ (Margaret Thacher[27]) អតីតនាយករដ្ឋមន្ត្រីអង់គ្លេស (១៩៧៩)ស្ត្រីដំបូងបានធ្វើឱ្យប្រទេសនេះមានទំនើបកម្មខាងរដ្ឋបាលតាមបែបគ្រប់គ្រងថ្មី (New Public Management-NPM)។ លោកស្រីត្រូវបានគេប្រសិទ្ធនាមថា ជាស្រីដែដែក ហើយបានបង្កើតទ្រឹស្តីដ៏ល្បីល្បាញដើម្បីគ្រប់គ្រងនៅប្រទេសអង់គ្លេសគឺ3Es :

---

[26] ឯកសារដដែលទំព័រ ១៩

[27] Margaret Hilda Thatcher, Baroness Thatcher, LG, OM, DStJ, PC, FRS, HonFRSC was a British stateswoman who served as Prime Minister of the United Kingdom from 1979 to 1990 and Leader of the Conservative Party from 1975 to 1990.
Wikipedia
Born: October 13, 1925, Grantham, United Kingdom
Died: April 8, 2013, The Ritz London, London, United Kingdom
Spouse: Denis Thatcher (m. 1951–2003)
Children: Mark Thatcher, Carol Thatcher
Nicknames: Attilla the Hen, Iron Lady, Maggie

១- សេដ្ឋកិច្ច ឬសន្សំសំចៃ (Economy)

២-សមត្ថភាពក្នុងការបំពេញការងារឬប្រសិទ្ធផល(Efficiency) និង

៣- ប្រសិទ្ធភាពការងារ (Effectiveness)

ចំណែកលោក ប៊ីល គ្លីនតុន (Bill Clinton[28]): ជាអតីតប្រធានាធិបតីកាន់តំណែងពីរអាណត្តិជាប់គ្នានៃសហរដ្ឋអាមេរិកដ៏មានប្រជាប្រិយភាពបានដាក់ចេញនូវគោលការណ៍៤យ៉ាងដើម្បីធ្វើឲ្យការងារកាន់តែមានប្រសិទ្ធភាព និងជោគជ័យ។

១-កាត់បន្ថយនូវរបៀបរបបធ្វើការងារដ៏ស្មុគ្រស្មាញ (Cutting the red tap)

២-ចាត់ទុកអតិថិជនជាធំ (Putting customers first)

៣-ផ្តល់សិទ្ធិឱ្យអ្នកធ្វើការឱ្យគេដើម្បីឱ្យមានលទ្ធផល (Empowering employees to get results)

---

28 William Jefferson Clinton is an American lawyer and politician who served as the 42nd president of the United States from 1993 to 2001. Prior to his presidency, he served as governor of Arkansas and as attorney general of Arkansas.Wikipedia
Born: August 19, 1946 (age 74 years), Hope, Arkansas, United States
Height: 1.88 m
Presidential term: January 20, 1993 – January 20, 2001
Spouse: Hillary Rodham Clinton (m. 1975)
Vice president: Al Gore (1993–2001)
Education: Yale Law School (1970–1973), MORE

ទី៤-កាត់បន្ថយចំណាយមិនចាំបាច់ដើម្បីធ្វើឱ្យរដ្ឋាភិបាលមានភាពប្រសើរឡើង(Cutting back to basics and producing better government for less)

តាមរយៈទ្រឹស្តីទាំងពីរខាងលើនេះ អ្នកប្រតិបត្តិទាំងអស់រកឃើញថាជាទ្រឹស្តីទាន់សម័យទំនើប និងអាចអនុវត្តបានក្នុងការពង្រឹងកិច្ចការឲ្យបានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីយ៉ាងនេះក្តី សម្រាប់លោកស្រី ម៉ាហ្គេរ៉េតថាច់ឈ័រ គួរតែត្រូវលើកទឹកចិត្តឲ្យបុគ្គលិកបម្រើការងារកាន់តែមានភាពកក់កៅជាងនេះ ដោយបន្ថែម E=Embrace ការឪបក្រសោប ឬភាពសុខដុមរមនាមួយទៀត ទើបកាន់តែល្អប្រសើរ។ ដូច្នេះប្រសិនបើយើងទទួលបាន 4E ដែលជាគ្រឿងផ្សំដ៏វិសេសវិសាលដើម្បីជំរុញលទ្ធផលការងារមួយកាន់តែល្អប្រសើរ និងពេញចិត្ត។

ក្នុងរដ្ឋបាលសាធារណៈជំនឿជាកត្តាមួយក្នុងការគ្រប់គ្រងប្រជាពលរដ្ឋ និងសណ្តាប់ធ្នាប់សាធារណៈ។ អ្នករដ្ឋបាល ដែលជាមន្ត្រីរាជការត្រូវចេះកសាងជំនឿក្នុងស្រទាប់ប្រជាពលរដ្ឋ ទើបអាចធ្វើកិច្ចការទាំងឡាយបានប្រកបដោយជោគជ័យ[29]។

នៅប្រទេសបារាំង អ្នកផ្តើមសិក្សារដ្ឋបាលសាធារណៈក្នុងគំនិតស្វែងរកគោលការណ៏វិទ្យាសាស្ត្រមុនគេ គឺលោក Charles Jean Bonnin ។ គាត់គិតថា ការប្រមូលចងក្រងឯកសាររដ្ឋបាលជា ក្រមប៉ូ

[29] សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ៣៧

លីស និងជាវចនានុក្រមរដ្ឋបាលមិនអាចកសាងក្បួនវិទ្យាសាស្ត្រក្នុងការសិក្សារដ្ឋបាលសាធារណៈបានឡើយ[30]។

តាមផ្រ្នុងទស្សនៈវិទ្យាសាស្ត្រគ្រប់គ្រង គេនឹងទទួលបានលទ្ធផលជាវិទ្យាសាស្ត្ររដ្ឋបាលតាមបែបវិទ្យាសាស្ត្រគ្រប់គ្រង។គេអាចរាប់ ដំបូងបង្អស់ សាស្ត្រាចារ្យជនជាតិអាមេរិកកាំងជាអតីតប្រធានាធិបតី និងជាជ័យលាភីរង្វាន់ណូបែលសន្តិភាព (Nobelarate of Peace) ឆ្នាំ១៩១៩ផងដែរ គឺលោក Thomas Woodrow WILSON ។ គាត់បាននិយាយថា ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាលសាធា- រណៈគេត្រូវផ្ដាច់ឲ្យជ្រះស្រឡះពីគ្នារវាងនយោបាយ និងរដ្ឋបាល។នៅឆ្នាំ១៨៨៤ សៀវភៅរបស់លោកមានចំណងជើងថា ការសិក្សាអំពីវិទ្យាសាស្ត្ររដ្ឋបាល (The study of Public administration)បានចេញផ្សាយ[31]។ ចំណែកអ្នកសង្គមវិទូដែលគិតអំពីរដ្ឋបាលសាធារណៈមុនគេគឺលោក Max Weber។ គាត់សិក្សារដ្ឋបាលសាធារណៈដូចជាបាតុភូមតសង្គម(social phenomenon) មួយដែរ។ គាត់ប្រើផ្រុងទស្សនៈសង្គមវិជ្ជា (sociological approaches) ដើម្បីបើកផ្លូវថ្មីសម្រាប់ស្រាវ ជ្រាវវិទ្យាសាស្ត្ររដ្ឋបាល[32]។

---

30 ឯកសារដដែល ទំព័រ៣១

31 ឯកសារដដែល ទំព័រ៤១-៤២

32 ឯកសារដដែល ទំព័រ៤៣

## ៨-សារៈសំខាន់នៃការសិក្សាមុខវិជ្ជារដ្ឋបាលសាធារណៈ

### ៨-ក-ចំពោះនិស្សិត

និស្សិតដែលបានសិក្សាមុខវិជ្ជានេះចប់ ពួកគេនឹងទទួលបានចំណេះដឹង ចំណេះធ្វើដើម្បីយកទៅប្រតិបត្តិ ឬចែកចាយបន្តទៅទៀត ក៏ដូចជាទន់មួយសម្រាប់ពិចារណា ផ្ទៀងផ្ទាត់ និងវាយតម្លៃកិច្ចការសង្គមដែមគេធ្លាប់បាន នឹងបានជួបប្រទះនាពេលខាងមុខ។

### ៨-ខ-ចំពោះអ្នកស្រាវជ្រាវ

ឯកសារនេះពិតជាមានប្រយោជន៍ខ្លាំងណាស់ចំពោះការស្រាវជ្រាវផ្នែកបណ្ឌិតសភា (Academic research) ពីព្រោះថាប្រសិនបើការសិក្សារបស់ពួកគាត់ពុំមានឯកសារបង្អែកត្រឹមត្រូវទេ នោះលទ្ធផលនៃការស្រាវជ្រាវនេះនឹងមិនមែនតម្លៃដែលអាចផ្តល់បានឡើយ។ ជាការពិតណាស់ មិនមានការសិក្សាណាមួយចេះគ្រប់សព្វគ្រប់ទេ យ៉ាងហោចណាស់ឯកសារនេះក៏នឹងក្លាយជាមូលដ្ឋានបង្អែកតូចមួយស្រាប់បញ្ញវន្តជំនាន់ក្រោយដែរ។

### ៨-គ-ចំពោះប្រតិបត្តិករ

អ្នកនយោបាយ អ្នកដឹកនាំ មន្ត្រីរាជការ ភ្នាក់ងារវិស័យឯកជន និងអ្នកពាក់ព័ន្ធនានាប្រាកដជា អាចប្រមូលបានជាទុនខ្លះមិនខានឡើយដើម្បីប្រសិទ្ធភាពការងារ និងជោគជ័យតាមផែនការដែលបានគ្រោងទុករួចហើយ។ សៀវភៅនេះ ជាបណ្តុំដោយព័ត៌មានអាជីពមួយដែលអ្នកសិក្សា អ្នកស្រាចវជ្រាវ និងអ្នកដឹកនាំទាំងឡាយទន្ទឹងរង់ចាំថ្វីបើវាមិនបាននិយាយឲ្យបានក្បោះក្បាយទាំងអស់ក៏ដោយ។

# ជំពូកទី២

# អំណាចសាធារណៈនៅកម្ពុជា

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១- អ្វីទៅជាអំណាចសាធារណៈ*

*២- មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ*

*៣- អំណាចនីតិបញ្ញត្តិ*

*៤- អំណាចនីតិប្រត្តិបត្តិ*

*៥- អំណាចតុលាការ*

*៦-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*

*៧-ក្រុមប្រឹក្សាធម្មនុញ្ញ*

## ១-អ្វីទៅជាអំណាចសាធារណៈ

ជាការរំលឹកដល់អ្នកមានគំនិតសេរីនិយមមុនដំបូងទាំងអស់ គឺទស្សនវិទូអង់គ្លេសម្នាក់ឈ្មោះ ចន ឡុក (John Locke[33]) យល់ថា

33 John Locke FRS was an English philosopher and physician, widely regarded as one of the most influential of enlightenment thinkers and commonly known as the "Father of Liberalism". Wikipedia

រដ្ឋត្រូវមានអំណាចដែលកំណត់ព្រំដែនច្បាស់លាស់។ លោកមានកូនសិស្សម្នាក់ជាសាសន៍បារាំងឈ្មោះ ម៉ុង តេស្សគីយើ(Montesquieu[34]) ដែលបានបញ្ចេញទ្រឹស្តីអំពីការបែងចែកអំណាចរដ្ឋជាបីដាច់ពីគ្នា គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងនិងអំណាចតុលាការ[35]។

នៅទីនេះ កាលណាគេនិយាយអំពី **អំណាចសាធារណៈ** គឺគេសំដៅភ្លាមដល់"**អំណាចនានាសម្រាប់គ្រប់គ្រងរដ្ឋ**"។ ជាទូទៅរដ្ឋដែលប្រកាន់យកនូវលទ្ធិប្រជាធិបតេយ្យសេរី អំណាចនេះមាន៣ធំៗគឺ៖

១-អំណាចនីតិបញ្ញត្តិ៖ គ្រប់គ្រងដោយ រដ្ឋសភា និង ព្រឹទ្ធសភា

២-អំណាចនីតិប្រតិបត្តិ៖ គ្រប់គ្រងដោយរដ្ឋាភិបាល

៣-អំណាចតុលាការ៖ គ្រប់គ្រងដោយតុលាកាគ្រប់ជាន់ថ្នាក់

---

Born: August 29, 1632, Wrington, United Kingdom
Died: October 28, 1704, High Laver, United Kingdom
Notable ideas: Liberty, State of nature, Property, Tabula rasa
Influenced by: Thomas Hobbes, René Descartes, Aristotle, Plato, MORE

34 Montesquieu

French philosopher
Charles-Louis de Secondat, Baron de La Brède et de Montesquieu, generally referred to as simply Montesquieu, was a French judge, man of letters, and political philosopher. He is the principal source of the theory of separation of powers, which is implemented in many constitutions throughout the world. Wikipedia
Born: January 18, 1689, La Brède, France
Died: February 10, 1755, Paris, France
Notable ideas: Separation of powers
Influenced by: John Locke, Thomas Hobbes, Aristotle, MORE

35 សាយ បូរី៖ វិទ្យាសាស្ត្ររដ្ឋបាល ឆ្នាំ២០០៧ ទំព័រ៤៣-៤៤

សម្គាល់៖

អង្គការនៃអំណាចនីមួយៗត្រូវបានគេឱ្យឈ្មោះ និងមានលក្ខណៈខុសៗគ្នាពីរដ្ឋមួយទៅរដ្ឋមួយដោយផ្អែកលើប្រវត្តិសាស្ត្រ និងរបបនយោបាយដែលរដ្ឋនោះប្រកាន់យក។

## ២-មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ

**អត្ថន័យប្រជាធិបតេយ្យ**

**« ប្រជាធិបតេយ្យមានន័យថា កូនចៅមានទឹកធ្វើស្រែ»**



**នរោត្តម សីហនុ**

ព្រះបន្ទូលរបស់សម្តេចព្រះ នរោត្តម សីហនុ តែងតែបង្កប់យ៉ាងជ្រៅ។ ព្រះអង្គទ្រង់ជ្រាបថា ប្រជារាស្ត្រខ្មែរ(កាលនោះ)ស្ទើរតែជាង៩០%ទៅទៅហើយជំនាន់នោះជាកសិករ។ រាល់អ្នកដឹកនាំដែលឡើងកាន់អំណាច ត្រូវតែធ្វើការឲ្យឆ្លើយតបនឹងផលប្រយោជន៍នៃអ្នកបោះឆ្នោតគាំទ្រ។ ក្នុងករណីនេះ ប្រសិនបើអ្នកដឹកនាំណាលោកមិនមានសមត្ថភាពដឹកនាំរកទឹកធ្វើស្រែមិនបាន រកទីផ្សារឲ្យកសិករមិនបាន(មាន់ ទា ជ្រូក គោ ក្របី ត្រី ស្រូវ ពោត សណ្តែក ល្ង ស្វាយ ស្វាយចាន់ទី ក្រចៅ កប្បាស កៅស៊ូ ម្រេច...)។ល។ នោះកសិករច្បាស់មិន

ជ្រើសរើសគាត់មកបម្រើទៀតទេ។ រដ្ឋាភិបាលត្រូវយកប្រជាជនជាម្ចាស់ មិនមែនធ្វើម្ចាស់លើប្រជាជនទេ[36]។ តម្លៃប្រជាធិបតេយ្យ មានទៅបានលុះត្រាប្រជាធិបតេយ្យនោះ មានការប្រកួតប្រជែង តែត្រូវបែងចែកឲ្យដាច់រវាងការរិះគន់ជាមួយការជេរប្រមាថ ប្រការដែលគួរឲ្យខ្លាច គឺភាពក្រីក្រមិនមែនបក្សប្រឆាំងទេ ទន់បន្តិចទៅ ខ្មែរឈ្នះទាំងអស់គ្នា[37]។ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាវិញ្ញាសាដែលត្រូវថែទាំ ជុសខាត់ ការពារ និងអភិវឌ្ឍជារៀងរហូត[38]។

**ក- ប្រជាធិបតេយ្យ** ( Democracy )

គឺ ប្រជា *(រាស្ត្រ/ប្រជាជន)* + ធិបតេយ្យ *(ធំ/ឧត្តមានុភាព)* មានន័យដោយខ្លីថា ប្រជាពលរដ្ឋជាធំ។

**ខ-ចរិតលក្ខណៈនៃប្រជាធិបតេយ្យ**

-រដ្ឋាភិបាលរបស់ប្រជាជន

-បោះដោយសេរី ស្មើភាព ចំពោះ សម្ងាត់ ជាសកល ពហុបក្ស

---

[36] សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅខេត្តកណ្តាល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០២

[37] សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦

[38] សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងឱកាសបើកសន្និសីទអន្តរជាតិ ខេមរសិក្សា លើកទី២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០០ និងក្នុងសៀវភៅ សម្តេច ហ៊ុន សែន កម្ពុជាឆ្នាំ២០០០ ខែសីហា ឆ្នាំ២០០០ ភាគ៣ ទំព័រ៩៥

-មានអាណត្តិ ជាក់លាក់ចំពោះរដ្ឋាភិបាល

-រដ្ឋធម្មនុញ្ញ

-មានការបែងចែកអំណាច។

**គ-ការបែងចែកអំណាចក្នុងសង្គមប្រជាធិបតេយ្យ**




**ឃ-ប្រព័ន្ធត្រួតពិនិត្យ តុល្យភាពអំណាច**

ដូចបានរៀបរាប់ខាងលើរួចហើយ អំណាចរដ្ឋទាំងបីនេះត្រូវបានចែកដាច់ពីគ្នា ហើយត្រូវតែកាន់កាប់ដោយមនុស្សខុសគ្នា។ ក្នុងន័យនេះមិនត្រឹមតែស្ថាប័ន និងមនុស្សមិនលាយឡំគ្នាទេ ប៉ុន្តែរបៀប

ធ្វើការក៏គេមិនអនុញ្ញាតឲ្យមានការពាក់ព័ន្ធគ្នាក្នុងសមត្ថកិច្ចនៃអំណាចនីមួយៗដែរ។ ពោលគឺមនុស្សដែលធ្វើការនៅក្នុងកន្សោមអំណាចនីមួយត្រូវមានឯករាជ្យភាពពីគ្នា[39]។ ទោះបីជាយ៉ាងនេះក៏ដោយ ការគាំទ្រគ្នា ការគាបសង្កត់គ្នាត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងដើម្បីជានាឲ្យមានយុត្តិធម៌ពិតប្រាកដជូនប្រជាពលរដ្ឋ និងសង្គមប្រជាធិបតេយ្យមួយបាន។ តាមច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ចែងថាដោយសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្គូរផ្គងឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណរដ្ឋមន្ត្រីទាំងមូល[40]។ តាមខ្លឹមសារនៃមាត្រានេះ បង្ហាញឲ្យឃើញការសហការគ្នាយ៉ាងស្អិតរមួតរវាងអង្គការនីតិបញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ រៀវលែងតែក្នុងករណីដែលរដ្ឋាភិ

[39] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា១២៨ថ្មី(មាត្រា១០៩ចាស់) វាក្យខណ្ឌទី១

[40] ឯកសារដដែល មាត្រា១២៨ថ្មី(មាត្រា១០៩ចាស់)

បាលត្រូវបានទម្លាក់ពីរដេងក្នុងរយៈ១២ខែ[41]។

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅរបស់រដ្ឋាភិបាល។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត[42]។ តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខអក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយដោយផ្ទាល់ខ្លួន។ ចម្លើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខអក្សរ។ ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីបានទទួលសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមានឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។ បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រី អាចជជែក

[41] ឯកសារដដែល មាត្រា៧៨ វាក្យខណ្ឌទី២

[42] ឯកសារដដែល មាត្រា១២១ថ្មី (មាត្រា១០២ចាស់)

ប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំ ឡើយ។ រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការឆ្លើយសំណួរ។ ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយឡើយ[43]។ គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន[44]។ រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋ-មន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន[45]។ អត្ថន័យដូចបានលើកមកបញ្ជាក់តាមមាត្រានានាខាងលើនេះបាន សបញ្ជាក់ឲ្យឃើញថា រាជរដ្ឋាភិបាលមានការទទួលខុសចំពោះមុខរដ្ឋសភា ជាងនេះទៅទៀត វាក៏បង្ហាញឲ្យឃើញពីការគាបសង្កត់របស់រដ្ឋសភាទៅលើអង្គការនីតប្រតិបត្តិផងដែរ។ បានសេចក្តីថា ទាំងនាយករដ្ឋមន្ត្រី ទាំងរដ្ឋមន្ត្រីដែលជាសមាជិករាជរដ្ឋាភិបាលមិនអាចបំពេញការងាររបស់ខ្លួនតាមទំនើងចិត្តចង់បានខុសពីគោក

---

[43] ឯកសារដដែល មាត្រា៩៦

[44] ឯកសារដដែល មាត្រា៩៧

[45] ឯកសារដដែល មាត្រា៩៨ថ្មី

នយោបាយដែលខ្លួនបានសន្យានៅចំពោះមុខរដ្ឋសភានៅពេលសុំសេចក្តីទុកចិត្ត ឡើយ។

ដូច្នេះរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិមានតុល្យការអំណាចរៀងៗខ្លួនដែលស្ថាប័នទាំងពីរមានលទ្ធភាពគាបសង្កត់គ្នាទៅវិញទៅមកទៅតាមច្បាប់រដ្ឋធម្មនុញ្ញជាធរមាន។ ម៉្យាងវិញទៀត តើរដ្ឋសភា និងរាជរដ្ឋាភិបាលមានការពាក់ព័ន្ធជាមួយនឹងអង្គការតុលារ ឬទេ?

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្រណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាចន្លោះសម័យប្រជុំនៃរដ្ឋសភាវៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវ ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បី អនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ករណីទាំងងស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបញ្ចេញមតិឲ្យផ្អាកតាមមតិ

ភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល[46]យើងអាចធ្វើ សេចក្ដីសន្និដ្ឋានបានច្បាស់លាស់ហើយ ប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាច ( Check and Balance ) ជាបានត្រូវចែងលំអិតក្នុងមាត្រា ផ្សេងៗនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នសព្រះរាជណាចក្រកម្ពុជា




---

46 ឯកសារដដែល មាត្រា៨០

**ង-តើការបែងចែកអំណាចសាធារណៈនៅប្រទេសកម្ពុជាមានលក្ខណៈដូចម្តេច?**

របបនយោបាយប្រទេសកម្ពុជា

- រាជាណាចក្រអាស្រ័យ រដ្ឋធម្មនុញ្ញ
- របបទ្វិកសភានិយម ឬរបបសភាពីរជាន់ (ព្រឹទ្ធសភា និង រដ្ឋសភា)

(Parliamentary bicameral/ Two-Chamber System)



ព្រះបាទ **នរោត្តម សីហមុនី**
ជាបុត្ររបស់ព្រះបាទ**នរោត្តម សីហនុ**
បានឡើងគ្រងរាជសម្បត្តិឆ្នាំ ២០០៤។

# រដ្ឋធម្មនុញ្ញ ១៩៩៣

**Constitution 1993**



## ៣-អំណាចនីតិបញ្ញត្តិ

### ៣-ក-អំពីរដ្ឋសភាជាតិ

ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ ភាគីជម្លោះខ្មែរទាំង៤(ភាគីរដ្ឋកម្ពុជាភាគីហ៊្វុនស៊ិនប៉ិច ភាគីរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ និងភាគីកម្ពុជាប្រជាធិបតេយ្យ)ព្រមទាំងមានការគាំទ្រពីបណ្តាប្រទេសចំនួន១៩ មាន ជាអាទិ៍៖ ប្រទេសសមាជិកអាស៊ាន(កាលនោះមាន០៦ប្រទេស លើកលែងតែ កម្ពុជា វៀតណាម ឡាវ និងភូមា) ប្រទេសមហាអំណាចទាំង៥(ចិន បារាំង សហរដ្ឋ អាមេរិក សហភាពសូវៀត និងអង់គ្លេស) ប្រទេសមិនចូលបក្សសម្ព័ន្ធ១ (យូហ្គោស្លាវី) ប្រទេសជាមិត្តរបស់កម្ពុជា៤(កាណាដា ជប៉ុន ឥណ្ឌា អូស្ត្រាលី) និងប្រទេសនៅឥណ្ឌូចិន៣(កម្ពុជា វៀតណាម ឡាវ) អង្គការសហប្រជាជាតិដែលមានលោក ហ្សង់វីយេ ប៉េរ៉េដឺគួអេឡា(Janvier Perez De Cuellar)ជាអគ្គលេខាធិការ។

ការបោះឆ្នោតជ្រើសរើសសមាជិកសភាធម្មនុញ្ញត្រូវបានរៀបចំដោយអាជ្ញាធរបណ្តោះសាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាអ៊ុនតាក់/UNTAC(United Nations Transitional Authority in Cambodia) ចាប់ពីថ្ងៃទី២៣ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ជាលទ្ធផល គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៥១អាសនៈ គណបក្សប្រជាជនកម្ពុជា៥១អាសនៈ គណបក្សសេរីនិយមព្រះពុទ្ធសាសនា ១០អាសនៈ និងគណបក្សម៉ូលីណាកា១អាសនៈសរុប១២០អាសនៈ

សមាជិកសភាធម្មនុញ្ញទាំង១២០រូបនេះបានពង្រាង និងអនុម័តរដ្ឋធម្មនុញ្ញមួយនៅថ្ងៃទី២១ និងប្រកាសឲ្យប្រើដោយព្រះប្រមុខរដ្ឋសម្ដេចព្រះ នរោត្តម សីហនុ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

សមាជិកសភាធម្មនុញ្ញបានក្លាយជា សមាជិកសភាជាតិចាប់ពីពេលនោះមក[47]។

**៣-ក-១-ប្រវត្តិរបស់រដ្ឋសភា**

យើងសូមងាកទៅក្រោយបន្តិចទាក់ទងនឹងប្រវត្តិពង្សាវតារបស់សភាខ្មែរ ពីព្រោះថារឿងរ៉ាវទាំងអស់នេះនិស្សិតតែងតែលើកជាសំណួរមកកាន់សាស្ត្រាចារ្យរបស់គេ។ ព្រះរាជាណាចក្រកម្ពុជាត្រូវបានអាណានិគមនិយមបារាំងត្រួតត្រាពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣។

ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មានព្រះរាជបញ្ញត្តិមួយ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩១៣ សម្រេចបង្កើតសភាពិគ្រោះយោបល់ដែលមាន សមាជិក៣៩រូប តំណាងឱ្យ១០ ខេត្ត-ក្រុង ។ នេះជាសញ្ញាដំបូងនៃការកកើតសភា។

-ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤០ សភាពិគ្រោះយោបល់បានកែប្រែទៅជាសភាតំណាងប្រជាជនកម្ពុជាក្រោមរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស។

[47] សេង ប៊ុនធឿន៖ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្ដូររបបនយោបាយនៅកម្ពុជា ឆ្នាំ២០១៥ ទំព័រ ១៥៩-១៦០

-ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៤៥ មានការបង្កើតសភាពិគ្រោះយោបល់ដែលមានសមាជិក៣៣រូប តំណាងឱ្យ១៤ខេត្ត-ក្រុង[48]។

-ខែវិច្ឆិកា ឆ្នាំ១៩៤៥ ការបង្កើតគណៈកម្មការបារាំង-ខ្មែរមួយដើម្បីរៀបរៀងសេចក្តីព្រាងរដ្ឋធម្មនុញ្ញដំបូង។

-ឆ្នាំ១៩៤៦មានព្រះរាជក្រម៤ សម្រេចផ្តល់សេរីភាពសារព័ត៌មាន សេរីភាពបង្កើតសមាគម សេរីភាពបង្កើតគណបក្សនយោបាយ និងឱ្យប្រើច្បាប់បោះឆ្នោតសកលជ្រើសតាំងរដ្ឋសភាបណ្តោះអាសន្ន (សភាធម្មនុញ្ញ)។

-ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ ការបោះឆ្នោតសកលលើកដំបូងនៅកម្ពុជាជ្រើសតាំងសមាជិកសភាធម្មនុញ្ញ៦៧រូប មានបេសកកម្មតាក់តែងរដ្ឋធម្មនុញ្ញទី១ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧[49]។

ខាងក្រោមនេះ គឺជាតារាងស្តីពីប្រវត្តិរបស់រដ្ឋសភាកម្ពុជា ពីការកកើតមកដល់បច្ចុប្បន្ន[50] ៖

---

48 https://km.wikipedia.org/wiki/ May 3, 2021
49 https://km.wikipedia.org/wiki/ May 3, 2021
50 https://km.wikipedia.org/wiki/ May 3, 2021

| ល.រ | រដ្ឋសភា រយៈកាល | ចំនួនគណបក្ស | ចំនួនអាសនៈ | កាលបរិច្ឆេទបោះឆ្នោត |
|---|---|---|---|---|
| ១ | -សភាធម្មនុញ្ញ ឆ្នាំ១៩៤៦-១៩៤៧ | ពហុបក្ស | ៦៧ | ០១/០៩/៤៦ |
| ២ | -រដ្ឋសភា ឆ្នាំ១៩៤៧-១៩៥១ | ពហុបក្ស | ៧៥ | ២១-១២-១៩៤៧ |
| ៣ | -រដ្ឋសភា ឆ្នាំ១៩៥១-១៩៥៣ | ពហុបក្ស | ៧៨ | ០៩/០៩/៥១ |
| ៤ | -រដ្ឋសភា ១៩៥៥-១៩៥៨ | បក្សតែមួយ | ៩១ | ១១/០៩/៥៥ |
| ៥ | -រដ្ឋសភា១៩៥៨-១៩៦២(១) | បក្សតែមួយ | ៦១ | ២៣-០៩-១៩៥៨ |
| ៦ | -រដ្ឋសភា ១៩៦២-១៩៦៦ | បក្សតែមួយ | ៧៧ | ១០/០៦/៦២ |
| ៧ | -រដ្ឋសភា ១៩៦៦-១៩៧២ | បក្សតែមួយ | ៨២ | ១១/០៩/៦៦ |

| | | | | |
|---|---|---|---|---|
| ៨ | -សភាជាតិនៃសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២-១៩៧៥ | បក្សតែមួយ | ១២៦ | ០៣/០៩/៧២ |
| ៩ | -សភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ(២) | បក្សតែមួយ | ២៥០ | ២០-០៣-១៩៧៦ |
| ១០ | -រដ្ឋសភាសាធារណរដ្ឋប្រជាមានិតកម្ពុជា -រដ្ឋកម្ពុជា ឆ្នាំ១៩៨១-១៩៩៣ | បក្សតែមួយ | ១១៧ | ០១/០៥/៨១ |
| ១១ | -សភាធម្មនុញ្ញ ១៩៩៣ | ពហុបក្ស | ១២០ | ២៣-២៨/០៥/១៩៩៣ |
| ១២ | -រដ្ឋសភានីតិកាលទី១ ១៩៩៣-១៩៩៨ | ពហុបក្ស | ១២០ | ២៣-២៨/០៥/១៩៩៣ |
| ១៣ | -រដ្ឋសភានីតិកាលទី២ ១៩៩៨-២០០៣ | ពហុបក្ស | ១២២ | ២៦/០៧/១៩៩៨ |
| ១៤ | -រដ្ឋសភានីតិកាលទី៣ ២០០៣-២០០៨ | ពហុបក្ស | ១២៣ | ២៧/០៧/២០០៣ |

| | | | | |
|---|---|---|---|---|
| ១៥ | -រដ្ឋសភានីតិកាលទី៤ ១៩៩៨-២០០៣ | ពហុបក្ស | ១២៣ | ២៦/០៧/២០០៨ |
| ១៦ | -រដ្ឋសភានីតិកាលទី៥ ២០១៣-២០១៨ | ពហុបក្ស | ១២៣ | ២៨/០៧/២០១៣ |

**កំណត់សម្គាល់**

(១) ជាលើកដំបូងដែលស្ត្រីខ្មែរមានសិទ្ធិសេរីភាពទៅបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

(២) ជាសម័យកម្ពុជាប្រជាធិបតេយ្យ លទ្ធផលស្រាវជ្រាវរកឃើញត្រឹមសមាសភាពគណៈកម្មាធិការ អចិន្ត្រៃយ៍តែប៉ុណ្ណោះ[51]។

ការបោះឆ្នោត នីតិកាលទី៥

| | | | | |
|---|---|---|---|---|
| គណបក្សប្រជាជនកម្ពុជា | ៣,២៣៥,៩៦៩ | ៤៨,៨៣ | ៦៨ | –២២ |
| គណបក្សសង្គ្រោះជាតិ | ២ ៩៤១ ១៣៣ | ៤៤,៤៥ | ៥៥ | +២៦ |
| គណបក្សហ្វ៊ុនស៊ិនប៉ិច | ២៤១ ៨៦៦ | ៣,៦៦ | ០ | –២ |

[51] https://km.wikipedia.org/wiki/ May 3, 2021

| | | | | |
|---|---|---|---|---|
| គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៦៩ ៦៦៧ | ១,០៥ | ០ | ០ |
| គណបក្សសញ្ជាតិកម្ពុជា | ៣៧ ៩៦៣ | ០,៥៧ | ០ | ថ្មី |
| គណបក្សខ្មែរឈប់ក្រ | ៤៣ ៣១២ | ០,៦៥ | ០ | ០ |
| គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ៣៤ ៥៦៩ | ០,៥២ | ០ | ថ្មី |
| គណបក្សសាធារណរដ្ឋប្រជាធិzតេយ្យ | ១៩ ៨៧១ | ០,៣០ | ០ | ថ្មី |
| អសុពលភាព/សំឡេងឆ្នោតទទេ | | – | – | – |
| **សរុប** | ៦ ៦១៦ ១១០ | | **១២៣** | **០** |
| អ្នកបោះឆ្នោតចុះបញ្ជី/អ្នកមិនបានបោះឆ្នោត | | | – | – |
| ប្រភព: គណៈកម្មាការជាតិរៀបចំការបោះឆ្នោត | | | | |

រដ្ឋសភានីតិកាលទី៥

រដ្ឋសភានីតិកាលទី៥ កើតចេញពីការបោះឆ្នោតសកល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ តាមប្រព័ន្ធសមាមាត្រមាន២៤មណ្ឌល រាជធានី-ខេត្ត មានគណបក្សនយោបាយចំនួន៨ចូលរួម។ ប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតចំនួន៩.៦៧៥.៤៥៣នាក់

ប្រជាជនបានទៅបោះឆ្នោតចំនួន៦.៧៣៥.២៤៤នាក់ ស្មើនឹង ៦៩,៦១%។ អាសនៈដែលទទួលបាន: គណបក្សប្រជាជនកម្ពុជា ៦៨ អាសនៈ ស្មើនឹង៥៥,២៨% គណបក្សសង្គ្រោះជាតិ ៥៥ អាសនៈ ស្មើនឹង៤៤,៧១%។ តំណាងរាស្ត្រសរុបចំនួន១២៣រូប ក្នុងនោះ តំណាងរាស្ត្រស្ត្រី២៥រូប ស្មើនឹង២០,៣២% តំណាងរាស្ត្រជនជាតិភាគតិចចំនួន២រូប ក្រុមស្ត្រីសមាជិករដ្ឋសភាត្រូវបានបង្កើត[52]។

## ៣-ក-២-អាណត្តិ និងសមាជិកភាពនៃរដ្ឋសភា

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប។ តំណាងរាស្ត្រ ត្រូវជ្រើសរើសដោយការ បោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

ប្រជាពលរដ្ឋដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្របានលុះត្រាតែ៖

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិច២៥ឆ្នាំ[53]។

ក្រៅពីនោះ បេក្ខជនម្នាក់ៗត្រូវតែជាអ្នកមានសិទ្ធិបោះឆ្នោតបានសេចក្តីថា បេក្ខជនម្នាក់ណានោះ ត្រូវស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងតិចមួយឆ្នាំមុនថ្ងៃបោះឆ្នោត។ ជាមួយគ្នានេះដោយ

---

[52] https://km.wikipedia.org/wiki/ May 3, 2021

[53] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៧៦

ព្រះរាជាណាចក្រកម្ពុជាប្រកាន់យកប្រព័ន្ធបោះឆ្នោតសមាមាត្រ ដូច្នេះ បេក្ខជនឈរឈ្មោះម្នាក់ៗត្រូវ មានការតែងតាំងពីគណបក្សនយោបាយដែលបានការចុះបញ្ជីឈរឈ្មោះបោះឆ្នោតតំណាងរាស្ត្រក្នុងរយៈពេល៥ឆ្នាំម្តង។

### ៣-ក-៣-គណៈកម្មាធិការអចិន្ត្រៃយ៍

ដើម្បីដំណើរការអង្គការរដ្ឋសភាក្នុងការអនុម័តច្បាប់ ក៏ដូចជាការតាមដានសកម្មភាពការងាររាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាពខ្ពស់ រដ្ឋសភាមានក្បាលម៉ាស៊ីនដឹកនាំរបស់ខ្លួន គេឲ្យឈ្មោះថា គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដែលមានមុខងារធ្វើការនៅចន្លោះសម័យប្រជុំនីមួយៗនឹងសម្រេចពីរបៀបវារៈប្រជុំពេញអង្គ និងសម្រេចកិច្ចការធំៗរបស់រដ្ឋសភា។ សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅ៖

-ប្រធានរដ្ឋសភា(ប្រធាន)

-អនុប្រធានទាំងពីរ

-ប្រធានគណៈកម្មការនានានៃរដ្ឋសភា។

### ៣-ក-៤-អគ្គលេខាធិការដ្ឋានរដ្ឋសភា

ទទួលបន្ទុករៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភាគណៈកម្មការនានា និងទទួលរ៉ាប់រងផងដែរនូវគ្រប់កិច្ចការរដ្ឋបាលរបស់រដ្ឋសភា និងទំនាក់ទំនងផ្សេងៗទៀតក្រៅរដ្ឋសភា។ អគ្គលេខាធិការដ្ឋានរដ្ឋសភា ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយ

រូបជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច១០ឆ្នាំ ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**៣-ខ-មុខងារ និងអំណាចរបស់រដ្ឋសភា**

**៣-ខ-១-អំណាចផ្នែកច្បាប់**

រដ្ឋសភាជាអង្គការដែលមាអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការ ឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត ការកែប្រែឬការលុបចោលពន្ធដារ។

-មុខងារផ្តួចផ្តើម និងអនុម័តច្បាប់

-ការសើរើ និងវិសោធនកម្មច្បាប់

-ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

-ការស្នើសុំឱ្យត្រួតពិនិត្យធម្មនុញ្ញភាព

-រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីយរដ្ឋបាល

-រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែទោសជាទូទៅ

-រដ្ឋសភាអនុម័តយល់ព្រមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ[54]

-រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។

រដ្ឋសភាមានភារកិច្ចធ្វើសេចក្តីព្រាងច្បាប់ដែលគេហៅថា សេចក្តីច្បាប់(proposed Law)។ ចំណែករាជរដ្ឋាភិបាលក៏មានសិទ្ធិ

[54] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មាត្រា៩០ថ្មី(ពីរ)

នេះដែរ ប៉ុន្តែគេហៅថាគេហៅថាសេចក្តីព្រាងច្បាប់(draft of law)។ ជាមួយគ្នានេះសិទ្ធិស្នើរើឬវិសោធនកម្មច្បាប់ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវអនុម័តដោយមតិភាគច្រើន២/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

### ៣-ខ-២-អំណាចផ្នែកនយោបាយ

តាមមាត្រា១១៩ថ្មី មាត្រា១០០ចាស់ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ជាតួនាទីយ៉ាងសំខាន់របស់រដ្ឋសភាដែលអនុញ្ញាតឲ្យស្ថាប័នជាតិមួយនេះបង្កើត និងត្រួតពិនិត្យរាជរដ្ឋាភិបាលតាមរយៈគណ កម្មាធិការអចិន្ត្រៃយ៍ និងសមាជិករបស់ខ្លួន។

### ៣-ខ-៣-មុខងារទម្លាក់រដ្ឋាភិបាល

ដូចបានបរិយាយរួចហើយនៅក្នុងមាត្រា៧៨នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានបង្ហាញឲ្យឃើញថា មានតែអង្គរដ្ឋសភាមួយគត់ដែលមានសិទ្ធិកោះហៅរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីទៅសួរនាំទាក់ទងនឹងនយោបាយដឹកនាំរបស់ខ្លួន ហើយឈានទៅដល់ការបោះឆ្នោតលើញត្តិបន្ទោស និងទម្លាក់រដ្ឋាភិបាលចេញពីតំណែងតែម្តង។

### ៣-ខ-៤-ការធ្វើញត្តិបន្ទោសរាជរដ្ឋាភិបាល

មិនខុសពីករណីខាងលើទេនៅពេលដែលរដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រីមិនអាចឆ្លើយដោះសារនូវសំណួរផ្សេងៗរបស់រដ្ឋសភាដែលទាក់ទងនឹងនយោបាយរបស់ខ្លួនបានឬមិនមានតម្លាភាពគណនេយ្យភាពគ្រប់គ្រាន់រដ្ឋាភិបាលអាចទទួលរងនូវការដាក់ញត្តិបន្ទោសពីរដ្ឋសភា ប៉ុន្តែ រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋា

ភិបាលពីតំណែងអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន[55]។ ក្នុងរបបសភានិយមរដ្ឋសភាអាចធ្វើញត្តិបន្ទោសដើម្បីទម្លាក់រាជរដ្ឋាភិបាលពីតំណែង។ អំពើនេះជាការបង្ហាញឱ្យឃើញយ៉ាងពិតប្រាកដពីការទទួលខុសត្រូវនយោបាយរបស់រដ្ឋាភិបាលចំពោះមុខរដ្ឋសភាពោលគឺ ការមិនចុះសម្រុងគ្នាខាងនយោបាយទូទៅរបស់ស្ថាប័នទាំងពីរ។

### ៣-ខ-៥-ការចោទប្រកាន់សមាជិករាជរដ្ឋាភិបាល

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។ ក្នុងករណីនេះ និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួនរដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល[56]។

### ៣-ខ-៦-អំណាចផ្នែកនយោបាយ

---

[55] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៩៨ថ្មី

[56] ឯកសារដដែល មាត្រា ១២៦ថ្មី (មាត្រា១០៧ចាស់)

បន្ថែមលើការកំណត់ឱ្យទទួលការខុសត្រូវផ្នែកនយោបាយរបស់រដ្ឋាភិបាលចំពោះមុខស្ថាប័ននីតិបញ្ញត្តិមានកាតព្វកិច្ចធំៗពីរគឺ៖

-ការផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល

-ការត្រួតពិនិត្យកិច្ចការនយោបាយរបស់រដ្ឋាភិបាល

**៣-ខ-៧-គណៈកម្មការពិសេស**

រដ្ឋសភាអាចចាត់តាំងឱ្យមានគណៈកម្មការពិសេសដែលមានសមាជិកច្រើន ឬតិចទៅតាមតម្រូវការចាំបាច់ដើម្បីបំពេញបេសកកម្មចំពោះកិច្ចលើការងារអ្វីមួយដែលអាចមានសមាជិកចម្រុះពីច្រើនស្ថាប័ន ឬគណៈកម្មការជំនាញណាមួយ ជាដើម។

**៣-ខ-៨-គណៈកម្មការជំនាញនានាចំនួន១០**

ជាសមាភាពគណៈកម្មការ( Commission )ដ៏សំខាន់បំផុតរបស់រដ្ឋសភាដើម្បីតាមដានយន្តការការងារនយោបាយ ឬជំនាញដើម្បីឲ្យប្រាកដថា តើក្រសួងនានាទាំងអស់របស់រដ្ឋាភិបាលបានបំពេញការងារមានប្រសិទ្ធភាពដែរឬទេ ? ។ល។ គណៈកម្មការជំនាញទាំងអស់នោះមានដូចតទៅ៖

១-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេត និងទំនាក់ទំនង រដ្ឋសភា និងព្រឹទ្ធសភា

២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣- គណៈកម្មការផែនការវិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៩- គណៈកម្មការសាធារណការដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១០-គណៈកម្មការប្រឆាំងអំពើពុករលួយ។

## ៣-គ-អំពីព្រឹទ្ធសភា

ជាថ្មីម្តងទៀតដោយសារនេះជាឯកសារបង្រៀន វាពិតជាមានសារៈសំខាន់ណាស់ដើម្បីឲ្យអ្នកស្រាវជ្រាវអ្នកសិក្សាទូទៅ និងនិស្សិតបានយល់ដឹងកាន់តែទូលំទូលាយ ដូច្នេះខ្ញុំសូមដកស្រង់អំពីប្រវត្តិព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាមកបញ្ចូលក្នុងសៀវភៅនេះតែ ម្តង។ ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២តាមរយៈកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សនយោបាយធំៗទាំងពីរដែលទទួលបានអាសនៈនៅរដ្ឋសភា គឺគណបក្សប្រជាជន

កម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច នាថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា នៅព្រះបរមរាជវាំងក្នុងស្មារតីលើកកម្ពស់ការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិពង្រឹងស្ថិរភាពនយោបាយ និងបន្តប្រវត្តិសាស្ត្រព្រឹទ្ធសភានៅព្រះរាជាណាចក្រកម្ពុជាដោយបានឯកភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ដើម្បីបង្កើតឱ្យមានព្រឹទ្ធសភាឡើងវិញ។

ការបង្កើតព្រឹទ្ធសភា គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រដោយបានបង្ហាញនូវពន្លឺថ្មីមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជាតាមរយៈការពង្រឹងពង្រីកស្មារតីបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ស្ថិរភាពនយោបាយ និងការប្តេជ្ញាចិត្តក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ[57]។ អនុលោមតាមច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលជាធរមាននាថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ព្រឹទ្ធសភាត្រូវបានបង្កើតឡើង និងបានបើកសម័យប្រជុំលើកទី១ នីតិកាលទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

### ៣-គ-១-ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៦)

ព្រឹទ្ធសភានីតិកាលទី១កើតឡើងដោយការតែងតាំងសម្រាប់រយៈពេល៥ឆ្នាំមានសមាជិកចំនួន៦១រូបក្នុងនោះសមាជិកព្រឹទ្ធសភា

[57] https://senate.gov.kh/about-senate/senate-history/ May 2, 2021

ចំនួន០២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ រីឯប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានរដ្ឋសភា។ ដោយឡែក សមាជិកដទៃទៀត ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមសមាជិក សមាជិកានៃគណបក្សនយោបាយទាំងបី (គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម រង្ស៊ី) ដែលមានអាសនៈនៅរដ្ឋសភា ហើយត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមសំណើរបស់ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភាដែលក្នុងនោះមាន ៖

-គណបក្សប្រជាជនកម្ពុជា (CPP) ៣១រូប

-គណបក្សហ៊្វុនស៊ិនប៉ិច (FUN) ២១រូប

-គណបក្សសមរង្ស៊ី (SRP) ០៧រូប ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភានីតិកាលទី១សរុបទាំង៦១រូប មានសមាជិកាចំនួន១០រូប។ ការរៀបចំការប្រព្រឹត្តទៅ និងដំណើរការការងារព្រឹទ្ធសភាត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្តនានារបស់ព្រឹទ្ធសភា និងច្បាប់ពាក់ព័ន្ធព្រមទាំងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។ ក្នុងនីតិកាលទី១ ព្រឹទ្ធសភាដែលកើតឡើងដោយការតែងតាំង ការបែងចែកអាសនៈនៅក្នុងគណៈកម្មការនានាអនុវត្តដូចរដ្ឋសភានីតិកាលទី២ដែរ គឺយករូបមន្ត ៤+៤+១ មានន័យថា គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន៤(គណៈកម្មការ ទី៣, ៤, ៥, ៦)គណបក្សហ៊្វុនស៊ិនប៉ិចទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន៤ (គណៈកម្មការទី

១, ២, ៨, ៩) និងគណបក្សសមរង្ស៊ីទទួលជាប្រធានគណៈកម្មការចំនួន១ គឺគណៈកម្មការទី៧។ ដោយឡែក អនុប្រធានគណៈកម្មការនានា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន០៥(គណៈកម្មការទី១,២,៧, ៨, ៩) និងគណបក្សហ្វ៊ុនស៊ិនប៉ិចទទួលបានអាសនៈចំនួន០៤ (គណៈកម្មការទី៣, ៤, ៥, ៦)។

ព្រឹទ្ធសភា មានគណៈកម្មាធិការអចិន្ត្រៃយ៍មួយសម្រាប់ដឹកនាំចាត់ចែង និងពិនិត្យសម្រេចរាល់ការងារផ្សេងៗ ក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុង។ ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ អនុប្រធានទាំងពីរ និងប្រធានគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាសមាជិក[58]។ ព្រឹទ្ធសភានីតិកាលទី១ មានគណៈកម្មការចំនួន០៩ ជាសេនាធិការអនុវត្តមុខងាររបស់ខ្លួនដែលត្រូវបានបែងចែកទៅតាមវិស័យជាសមត្ថកិច្ចដូចខាងក្រោម៖

**១**-គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង។

**២**- គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ។

**៣**-គណៈកម្មការសេដ្ឋកិច្ចផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍ ន៍ជនបទ និងបរិស្ថាន។

**៤**- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសម្អាត។

---

[58] https://senate.gov.kh/about-senate/senate-history/ May 2, 2021

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន។

៦- គណៈកម្មការនីតិកម្ម។

៧- គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍។

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី។

៩-គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាល ចំនួន២ដង(ម្តង១ឆ្នាំ) តាមព្រះរាជក្រឹត្យ ៖

-**លើកទី១** : ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣០ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៤ (គិតចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥)។

-**លើកទី២** : ព្រះរាជក្រឹត្យ នស/រកត/១២០៥/០៧០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ (គិតចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ រហូតដល់ព្រឹទ្ធសភានីតិកាលទី២ចូលកាន់តំណែង)។

**កំណត់សម្គាល់៖** សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី១ មានសម្តេច **ជា ស៊ីម** ជាប្រធាន (CPP) ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ៉នមុនីរ័ក្ស** ជាអនុប្រធានទី១ (FUN) និងឯកឧត្តម **ញឹក ប៊ុនឆៃ** ជាអនុប្រធានទី២(FUN)។ មកដល់ខែសីហា ឆ្នាំ២០០៤ ឯកឧត្តម **ញឹក ប៊ុនឆៃ** បានលាលែងទៅបំពេញការងារក្នុងរាជរដ្ឋាភិបាល ហើយ

គណបក្សហ្វ៊ុនស៊ិនប៉ិចបានស្នើតែងតាំងឯកឧត្តម **ប៉ោ ប៊ុនស្រ៊ឺ** ត្រូវបានតែងតាំងជំនួសតួនាទីនេះ។ ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភាបានផ្តួចផ្តើមគំនិតស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំលើកទី៩ នីតិកាលទី១ ព្រមទាំងក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ : ០៧០/០០២/ ២០០៥/ កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥។ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៦០៥/០២០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥[59]។ អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចាប់ពីនីតិកាលទី២ និងនីតិកាលបន្តបន្ទាប់ ព្រឹទ្ធសភាកើតឡើងដោយការបោះឆ្នោតជាអសកលផង ជ្រើសតាំងផង និងចាត់តាំងផង សម្រាប់រយៈពេល៦ឆ្នាំ។

### ៣-គ-២-ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦។ ព្រឹទ្ធសភានីតិកាលទី២ មានសមាជិកចំនួន៦១រូប ក្នុងនោះ៥៧រូប ត្រូវបានបោះ

---

59 https://senate.gov.kh/about-senate/senate-history/ May 2, 2021

ឆ្នោតជាអសកល០២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង ០២រូបទៀតត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើន ដោយប្រៀប។ ព្រឹទ្ធសភានីតិកាលទី២ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងចំណោមសមាជិកព្រឹទ្ធសភា៥៧រូប ដែលបានជាប់ឆ្នោតមានសមាសភាពមកពី ៖

១- គណបក្សប្រជាជនកម្ពុជា (CPP)ចំនួន៤៥រូប

២- គណបក្សហ៊្វុនស៊ិនប៉ិច (FUN) ចំនួន ១០រូប

៣- គណបក្សសមរង្ស៊ី (SRP) ចនួន ០២រូប ។

ក្នុងចំណោមសមាជិកព្រឹទ្ធសភាសរុបទាំង៦១រូបនេះ ព្រឹទ្ធសភានៃនីតិកាលទី២មានគណៈកម្មការចំនួន០៩ ដែលក្នុងនោះតាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំងស្របតាមនីតិវិធីកំណត់នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណក្សប្រជាជនកម្ពុជា ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៥ (គណៈកម្មការទី២, ៣, ៤, ៥, ៦) គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០៣ (គណៈកម្មការទី១, ៨, ៩) និងគណបក្សសមរង្ស៊ី ទទួលបានអាសនៈជាប្រធានគណៈកម្មការចំនួន០១ គឺ គណៈកម្មការទី៧។ ដោយឡែក អនុប្រធានគណៈកម្មការ គណបក្ស

ប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន០៤ (គណៈកម្មការទី១, ៦, ៨, ៩) និងគណបក្សហ៊្វុនស៊ិនប៉ិចទទួលបានអាសនៈចំនួន០៥ (គណៈកម្មការទី២, ៣, ៤, ៥, ៧)។

**កំណត់សម្គាល់៖** ថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី២មានសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ជាប្រធាន(CPP) សម្តេច ស៊ី សុវត្ថិ ជីវ៉ែនមុនីរ័ក្ស ជាអនុប្រធានទី១(FUN)និងឯកឧត្តម ទេព ងន ជាអនុប្រធានទី២ (CPP)។

**៣-គ-៣-ព្រឹទ្ធសភានីតិកាលទី៣(២០១២-២០១៨)**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។ ជាលទ្ធផលក្នុងចំណោមសមាជិក៥៧រូប ដែលជ្រើស តាំងដោយការបោះឆ្នោតមានសមាសភាពមកពី៖

- គណបក្សប្រជាជនកម្ពុជា(CPP)ចំនួន៤៦រូប
- គណបក្សសមរង្ស៊ី(SRP)ចំនួន១១រូប[60]។

ក្នុងចំណោមសមាជិកព្រឹទ្ធសភានីតិកាលទី៣សរុបទាំង៦១រូប មានសមាជិកាចំនួន១០រូប។ ព្រឹទ្ធសភានីតិកាលទី៣ បានបើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ

---

[60] https://senate.gov.kh/about-senate/senate-history/ May 2, 2021

**នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**កំណត់សម្គាល់ :** ថ្នាក់ដឹកនាំព្រឹទ្ធសភាមាន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ជាប្រធាន (CPP) **ឯកឧត្តម សាយ ឈុំ** ជាអនុប្រធានទី១ (CPP) និង**ឯកឧត្តម ទេព ងន** ជាអនុប្រធានទី២ (CPP)[61]។ ចាប់ពីដំណើរការសម័យប្រជុំដំបូង និងបន្តរហូតមកដល់ពាក់កណ្តាលនីតិកាលទី៣ គណៈកម្មការនានា នៃព្រឹទ្ធសភាមានចំនួន០៩ ហើយសមាសភាពក្នុងគណៈកម្មការដែលបានជាប់ឆ្នោតតាមរយៈការបោះឆ្នោតជ្រើសរើស និងជ្រើសតាំងស្របតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺមកពីគណបក្សប្រជាជនកម្ពុជាទាំងអស់ ទាំងប្រធាន អនុប្រធាន លេខាធិការ និងសមាជិកគណៈកម្មការ។ ដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា និងក្រុមការងាររបស់គណបក្សសមរង្ស៊ី បានឯកភាពចុះកិច្ចព្រមព្រៀងស្តីពីការរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤។ តាមរយៈកិច្ចព្រមព្រៀងខាងលើ ព្រឹទ្ធសភាបានធ្វើវិសោធនកម្មប្រការ១៥នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ប្រការ១៥ថ្មីនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាគណៈកម្មការនានារបស់ព្រឹទ្ធសភា

---

61 https://senate.gov.kh/about-senate/senate-history/ May 2, 2021

មានដូចខាងក្រោម ៖

១- គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេត។

២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។

៣- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន។

៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ។

៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការ អន្តរជាតិ ឃោសនាការ និងព័ត៌មាន។

៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌។

៧- គណៈកម្មការអប់រំ យុវជន កីឡាធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍។

៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងកិច្ចការនារី។

៩-គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១០- គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំង អំពើពុករលួយ។ទន្ទឹមនឹងនេះសមាសភាពក្នុងគណៈកម្មការទាំង១០ ត្រូវបានរៀបចំកែសម្រួលបោះឆ្នោតជ្រើសរើសនិងជ្រើសតាំងឡើងវិញ។ សមាជិកព្រឹទ្ធសភាពីគណបក្សសមរង្ស៊ីទាំង១១រូបត្រូវបានបញ្ចូល

ទៅក្នុងគណៈកម្មការទាំងអស់ ក្នុងនោះមានអាសនៈប្រធានគណៈកម្មការចំនួន២ គឺគណៈកម្មការទី១ និងទី១០ អនុប្រធានគណៈកម្មការចំនួន២ គឺគណៈកម្មការទី៣ និងទី៧ លេខាធិការគណៈកម្មការចំនួន២ គឺគណៈកម្មការទី១ និងទី១០ ព្រមទាំងសមាជិក៥រូបទៀតបញ្ចូល១រូបៗ ទៅក្នុងគណៈកម្មការទី១,៣,៧,៨ និងទី១០[62]។

**កំណត់សម្គាល់** : ព្រឹទ្ធសភានីតិកាលទី៣ មានសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ជាប្រធាន ឯកឧត្តម **សាយ ឈុំ** ជាអនុប្រធានទី១ និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភាបានទទួលមរណភាព។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានព្រឹទ្ធសភា និងឯកឧត្តម **នៃ ប៉េណា** ជាអនុប្រធានទី១ ព្រឹទ្ធសភានីតិកាលទី៣[63]។

### ៤. ព្រឹទ្ធសភានីតិកាលទី៤ (២០១៨-២០២៤)

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៤ ប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។ ជាលទ្ធផល គណបក្សប្រជាជនកម្ពុជាទទួលបាននូវអាសនៈទាំងអស់ចំនួន៥៨

[62] https://senate.gov.kh/about-senate/senate-history/ May 2, 2021
[63] https://senate.gov.kh/about-senate/senate-history/ May 2, 2021

សម្រាប់៨ភូមិភាគនៃព្រះរាជាណាចក្រកម្ពុជា។ សម្រាប់នីតិកាលទី៤ សមាជិកព្រឹទ្ធសភាសរុបមានចំនួន៦២រូប បង្កើន០១អាសនៈនៅមណ្ឌល ភូមិភាគទី៧( ៥៨រូប ជ្រើសតាំងដោយការបោះឆ្នោត ០២រូបចាត់តាំងដោយព្រះមហាក្សត្រ០២រូបជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប) ស្របគ្នានឹងរដ្ឋសភាបង្កើន២អាសនៈនៅមណ្ឌលខេត្តព្រះសីហនុ (រដ្ឋសភានីតិកាលទី៦ មានសមាជិក សរុបចំនួន១២៥រូប)។ ព្រឹទ្ធសភានីតិកាលទី៤ បានបើកសម័យប្រជុំដំបូងនាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងចំណោមសមាជិកព្រឹទ្ធសភា នីតិកាលទី៤ទាំង៦២រូប មានសមាជិកាចំនួន១០រូប[64]។

**កំណត់សម្គាល់** : សមាសភាពថ្នាក់ដឹកនាំព្រឹទ្ធសភា មានសម្តេចវិបុល សេនាភក្តី **សាយ ឈុំ** ជាប្រធាន ឯកឧត្តម **នៃ ប៉េណា** ជាអនុប្រធានទី១ និងឯកឧត្តម **ទេព ងន** ជាអនុប្រធានទី២។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បានទទួលមរណភាព។ ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនាថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តម ស៊ឹម កា ត្រូវបានព្រឹទ្ធសភាធ្វើការបោះឆ្នោតជ្រើសរើសជាអនុប្រធានទី១

[64] https://senate.gov.kh/about-senate/senate-history/ May 2, 2021

ព្រឹទ្ធសភា[65]។ ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ មានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ពីររូបចាត់តាំងដោយព្រះមហាក្សត្រពីររូបទៀតជ្រើសតាំងដោយសមាជិករដ្ឋសភាតាម**មតិភាគច្រើនដោយប្រៀប** ក្រៅពីនេះតាមរយៈការត្រូវបោះឆ្នោតជ្រើសតាំងដោយ**អសាកល** អ្នកដែលមានសិទ្ធិបោះឆ្នោត គឺសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ និងសមាជិករដ្ឋសភាដែលធ្វើឡើងតាមប្រព័ន្ធសមាមាត្រ និងតាមភូមិភាគ)។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែល៖

-មានសិទ្ធិបោះឆ្នោត

-មានអាយុយ៉ាងតិច ៤០ឆ្នាំ

-មានសញ្ជាតិខ្មែរតាំងពីកំណើត។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសតាំងសារជាថ្មីបាន[66]។

### ៤-ក-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នៅរៀងរាល់ដើមនីតិកាលនីមួយៗ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំព្រឹទ្ធសភាបានហើយប្រធានព្រឹទ្ធសភា ដោយមានការឯកភាពពីអនុប្រធានទាំងពីររបស់ខ្លួនស្នើសុំទៅព្រះមហា

---

65 https://senate.gov.kh/about-senate/senate-history/ May 2, 2021

66 https://senate.gov.kh/about-senate/senate-history/ May 2, 2021

ក្សត្រតែងតាំងឥស្សរជនជាន់ខ្ពស់មួយរូបជាអគ្គលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដើម្បីដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា។ អគ្គលេខាធិការដ្ឋាននេះ ទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាល សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភាព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ប្រធានព្រឹទ្ធសភា[67]។

## ៤-៦-តួនាទី និង អំណាចព្រឹទ្ធសភា

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល។ ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យព្រឹទ្ធសភាពិនិត្យ។ ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន[68]។

---

[67] បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ប្រការ២៧

[68] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៩៩ថ្មីដល់មាត្រា១១៧ ថ្មី

# ៥-អំណាចនីតិប្រតិបត្តិ



**៥-ក-អំពីព្រះមហាក្សត្រ**

លក្ខណៈវិនិច្ឆ័យបេក្ខភាពព្រះមហាក្សត្រកម្ពុជា ជាសមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ

១-ព្រះជន្មយ៉ាងតិច៣០ព្រះវស្សា

២-ជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គឌួងឬព្រះមហាក្សត្រ នរោត្តម ឬព្រះមហាក្សត្រ ស៊ីសុវត្ថិ 69។

ក-១-តួនាទី និងអំណាច

-អំណាចទាក់ទងនឹងរដ្ឋាភិបាល

-អំណាចចេញបទបញ្ជា

-អំណាចទាក់ទងនឹងកិច្ចការយោធា

-អំណាចទាក់ទងនឹងកិច្ចការការទូត

-អំណាចទាក់ទងនឹងអង្គការនីតិបញ្ញត្តិ

-អំណាចទាក់ទងនឹងតុលាការ

-អំណាចផ្សេងៗ

ក-២-ការជ្រើសរើសព្រះមហាក្សត្រ

ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ70។

---

69 សូមស្វែងរកអានបន្ថែមនូវព្រះរាជជីវប្រវត្តិអតីតព្រះមហាក្សត្រកម្ពុជា ព្រះបាទ អង្គឌួង ព្រះបាទ នរោត្តម និងព្រះបាទ ស៊ីសុត្ថិ។

70 រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១៣ថ្មី

សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ

១-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

២-ប្រធានព្រឹទ្ធសភា

៣-ប្រធានរដ្ឋសភា

៤-នាយករដ្ឋមន្ត្រី

៥-អនុប្រធានទាំងពីរនៃព្រឹទ្ធសភា

៦-អនុប្រធានទាំងពីរនៃរដ្ឋសភា

ឆ្លៀតឱកាសនេះ គួររំលឹកថាទាក់ទងនឹងព្រះមហាក្សត្រទ្រង់គ្រងរាជហើយមិនកាន់អំណាចនេះ គឺបានសេចក្តីថា ព្រះអង្គទ្រង់មិនមានព្រះរាជអំណាចដើម្បីសម្រេចកិច្ចការនៃអំណាចសាធារណៈទាំងបីឡើយ។ ប្រសិនបើរដ្ឋធម្មនុញ្ញកម្ពុជាអនុញ្ញាតឲ្យអង្គព្រះមហាក្សត្រមានព្រះរាជអំណាចដឹកនាំរាជរដ្ឋាភិបាល ដឹកនាំអង្គការនីតិបញ្ញត្តិ ឬអង្គការតុលាការ តើរដ្ឋធម្មនុញ្ញនេះនឹងថ្វាយព្រះមហាក្សត្រនូវការសោយរាជអស់មួយជីវិតម្តេចបាន? ពីព្រោះជាសត្យានុម័ត អ្នកមានអំណាចដឹកនាំម្នាក់ណាដែលមិនចេះខុសនោះ។ ការចាត់ចែងដឹកនាំកុំថាឡើយដល់អំណាចរដ្ឋ សូម្បីតែសង្គមគ្រួសារ សហគមន៍ តូច និងដែនដីណាមួយក៏គង់តែធ្វើឲ្យមានការស្អប់ ការស្រឡាញ់ពីអ្នកក្រោមបង្គាប់បាន។ បានសេចក្តីថា មិនមានទេអ្នកស្រឡាញ់ទាំងអស់ និងអ្នកស្អប់ទាំងអស់។

ហេតុដូច្នេះហើយ ក្នុងជំពូកទី១៦ថ្មី(ពីរ)អំពីអានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ និងប្រកដ

ដោយការទទួលខុសត្រូវចំពោះវាសនាប្រជាជាតិមួយនេះថា ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងករណីដែលព្រះមហាក្សត្រទ្រង់សោយរាជ្យ ហើយមិនកាន់អំណាចដែលត្រូវបានលើកបញ្ជាក់ជាថ្មីក្នុងមាត្រា១៧នៃរដ្ឋធម្មនុញ្ញនេះ[71]។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយចុះ ព្រះមហាក្សត្រត្រូវបានរដ្ឋធម្មនុញ្ញថ្វាយព្រះរាជតួនាទីថា ព្រះមហាក្សត្រព្រះអង្គទ្រង់និមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសិទ្ធិសញ្ញាអន្តរជាតិ[72]។

---

[71] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១៥៥ថ្មី(ពីរមាត្រា១៥៣ថ្មី)

[72] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៨

## ៥-ខ-អំពីរាជរដ្ឋាភិបាល

## ដ្យាក្រាមនៃរចនាសម្ព័ន្ធសមាសភាពរាជរដ្ឋាភិបាលកម្ពុជា



ដ្យាក្រាមនៃដំណើរការការបង្កើតរាជរដ្ឋាភិបាលកម្ពុជា




រដ្ឋាភិបាល
ចាត់តាំងរដ្ឋ
តែងតាំងជា
រដ្ឋសភា
បង្កើត
តំណាងរាស្ត្រ
បោះឆ្នោតជ្រើសរើស
របបសភានិយម
ប្រជាពលរដ្ឋ
ប្រធាន/អនុប្រធានទាំង២
នៃរដ្ឋសភាប្រធានគណៈកម្ម
ការទាំងដប់នៃរដ្ឋសភា
នាយករដ្ឋមន្ត្រី(បង្កើតគណៈ
រដ្ឋមន្ត្រី)(មាត្រា៤ នៃរដ្ឋធម្ម
នុញ្ញបន្ថែម)
សម្គាល់៖ ច្បាប់ធម្មនុញ្ញប
ន្ថែម សំដៅជានាដំណើរការ
ជាប្រក្រតីនៃស្ថាប័នជាតិ។

### ៥-គ-ការបង្កើតរដ្ឋាភិបាល

#### ៥-គ-១-ការបង្កើតរដ្ឋាភិបាលតាមរដ្ឋធម្មនុញ្ញ

តាមសេចក្តីស្នើប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តួរផ្តងឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល[73]។

#### ៥-គ-២-ការបង្កើតរដ្ឋាភិបាលតាមរដ្ឋធម្មនុញ្ញបន្ថែម

ការរៀបចំបញ្ជីរាយនាមបេក្ខជនដើម្បីបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តអនុវត្តដូច តទៅ៖

-បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភាក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភាត្រូវរៀបចំនិងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នាដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាតាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រ

---

[73] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១១៩ថ្មី(មាត្រា១០០ចាស់)

ត្រូវចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំតំណែងផ្សេងៗក្នុងរាជរដ្ឋា-ភិបាលរួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភាក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋរដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត[74]។

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់នេះដែរ។ សមាជិករដ្ឋសភាត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬមិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ[75]។

តាមខ្លឹមសារនេះ យើងអាចយល់បានថា ករណីនេះត្រូវបានអនុវត្តឡើងបានតែក្នុងករណីសំដៅជានានូវដំណើរការជាប្រក្រតីនៃ

[74] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ច្បាប់ធម្មនុញ្ញបន្ថែម មាត្រា៤

[75] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ច្បាប់ធម្មនុញ្ញបន្ថែម មាត្រា៥

ស្ថាប័នជាតិ ជាងនេះទៅទៀត រាល់ការពិភាក្សាផ្សេងៗលើបញ្ហានេះ ត្រូវបានមាត្រានៃធម្មនុញ្ញបន្ថែមនេះហាមឃាត់។

យើងអាចកត់សម្គាល់ដែរនៅក្នុងចំណុចទី១ខាងលើ គឺការបោះឆ្នោតជាកញ្ចប់ត្រូវស្នើឡើងដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នាដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។ សំណួរសួរថា ចុះប្រសិនបើករណីផ្ទុយពីនេះ តើត្រូវធ្វើតាមលក្ខខណ្ឌរដ្ឋធម្មនុញ្ញបន្ថែមបានចែងនេះដែរទេ? តើក្នុងករណីណាខ្លះដែលយើងកំណត់ថា សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិនោះ? បានសេចក្តីថា តើប្រទេសជាតិស្ថិតនៅក្នុងលក្ខខណ្ឌបែបណាខ្លះទើបតម្រូវឲ្យមានការបោះឆ្នោតកញ្ចប់នេះ? ចម្លើយនៃករណីខាងលើអាចមានច្រើនដូចនឹងការឲ្យនិយមន័យនៃពាក្យ **សណ្តាប់ធ្នាប់សាធារណៈ** ដែរ។

### ៥-គ-៣-សមាសភាព និងតួនាទីរបស់រាជរដ្ឋាភិបាល

#### ៥-គ-៣-១-នាយករដ្ឋមន្ត្រី

សមាសភាពរបស់រាជរដ្ឋាភិបាលរួមមាន៖ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី[76]។ នាយករដ្ឋមន្ត្រីជាប្រមុខនៃរាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវរួមគ្នា ជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និង

---

[76] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ១១៨ថ្មី(មួយ) ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ មាត្រា៨

អំពីសកម្មភាពរួមរបស់រាជរដ្ឋាភិបាលទាំងមូល។ នាយករដ្ឋមន្ត្រីដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រីចាត់ចែងនិងរាល់សកម្មភាពរបស់រដ្ឋាភិបាលលើគ្រប់វិស័យ។ នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្សេងៗមានដូចជា វិស័យពាណិជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស ការពារជាតិ និងលើវិស័យផ្សេងៗទៀត[77]។ នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្ដីសម្រេច និងសារាចរផ្សេងៗរបស់គណៈរដ្ឋមន្ត្រី លើលិខិតបទដ្ឋានទាំងឡាយដែលមានអានុភាពគតិយុត្តទូទៅរបស់រាជរដ្ឋាភិបាលត្រូវតែចុះក្នុងព្រះរាជកិច្ច។ នាយករដ្ឋមន្ត្រីត្រូវលើកសំណើថ្វាយព្រះមហាក្សត្រដើម្បីតែងតាំងផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវ មន្ត្រីជាន់ខ្ពស់ស៊ីវិល នគរបាល និងយោធាដូចតទៅ៖

-ទេសាភិបាល ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា។

-ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី/រដ្ឋាភិបាល។

-អគ្គលេខាធិការរាជរដ្ឋាភិបាល។

-អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង។

-ប្រតិភូរាជរដ្ឋាភិបាល។

-អភិបាលខេត្ត-រាជធានី។

-ឯកអគ្គរាជទូត។

-ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។

---

[77]ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ មាត្រា១៧

-អគ្គមេបញ្ជាការ អគ្គបញ្ជាការរង នាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ។

-អគ្គស្នងការនគរបាលជាតិ[78]។

**៥-គ-៣-២-ឧបនាយករដ្ឋមន្ត្រី៖**

ឧបនាយករដ្ឋមន្ត្រីជួយការពារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី[79] លើកិច្ចការដែលទាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ។ ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រីទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។ នៅពេលនោះឧបនាយករដ្ឋមន្ត្រីមានតួនាទីជានាយករដ្ឋមន្ត្រីស្ដីទី។ ឧបនាយករដ្ឋមន្ត្រី ជាសមាជិករាជរដ្ឋាភិបាលដែលមានអាសនានុក្រមខ្ពស់ជាងសមាជិករាជរដ្ឋាភិបាលដទៃទៀត។

**៥-គ-៣-៣-ទេសរដ្ឋមន្ត្រី៖**

ទេសរដ្ឋមន្ត្រីមួយចំនួនមានតួនាទីដឹកនាំក្រសួង(ទេសរដ្ឋ-មន្ត្រី និងជារដ្ឋមន្ត្រីទើបមានតំណែងជាប្រធានស្ថាប័នពិតប្រាកដ) និងទេសរដ្ឋមន្ត្រីមួយចំនួនទៀតមិនដឹកនាំក្រសួងទេ ប៉ុន្តែទទួលបន្ទុក

---

[78] ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ មាត្រា២៣

[79] ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ មាត្រា៣០

បេសកកម្មពិសេសអាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី។ ទេសរដ្ឋមន្ត្រីមានសិទ្ធិអំណាចមិនខុសប្លែកអ្វីពីរដ្ឋមន្ត្រីទេ ប៉ុន្តែមានងារជាទេសរដ្ឋមន្ត្រី នេះគឺតាមរយៈនាយករដ្ឋមន្ត្រីផ្តល់ជូនដើម្បីបញ្ជាក់អំពីការគោរពជាអ្នកនយោបាយដែលមានវ័យចំណាស់ និងមានបទពិសោធន៍ការងារច្រើនឆ្នាំ ក្នុងឋានៈជាអតីតរដ្ឋមន្ត្រីដែលនៅក្នុងគណៈរដ្ឋមន្ត្រីយូរឆ្នាំជាងគេប៉ុណ្ណោះ ហើយអាចដឹកនាំកិច្ចប្រជុំអន្តរក្រសួងបាន។

**៥-គ-៣-៤-រដ្ឋមន្ត្រី**

រដ្ឋមន្ត្រីមានពីរប្រភេទ គឺរដ្ឋមន្ត្រីមិនគ្រប់គ្រងក្រសួង និងរដ្ឋមន្ត្រីគ្រប់គ្រងក្រសួង។ រដ្ឋមន្ត្រីទាំងឡាយណាដែលមិនដឹកនាំក្រសួងអាចទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី ដែលមានរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីដែលជាសមាជិកនៃរាជរដ្ឋាភិបាលដែលដឹកនាំគ្រប់គ្រងក្រសួង ឬរដ្ឋលេខាធិការដ្ឋានហៅថាប្រធានស្ថាប័ន។ រដ្ឋមន្ត្រីដែលជាសមាជិករាជរដ្ឋាភិបាល ជាប្រធានស្ថាប័នមានសិទ្ធិតែងតាំងផ្លាស់ប្តូរនិងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីច្បាប់ជាធរមានចាប់ពីនាយកដ្ឋាន វរសេនីយ៍ឯក និងថ្នាក់ប្រហាក់ប្រហែល[80]។ ប្រធានស្ថាប័នមានសិទ្ធិតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានដោយប្រកាសចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន(អនុ

[80] មាត្រា៤៦ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

ប្រធាននាយកដ្ឋាន )និងថ្នាក់ប្រហាក់ប្រហែល។ ជាទូទៅរដ្ឋមន្ត្រីអាច មានទីប្រឹក្សាបច្ចេកទេសមួយរូប ឬច្រើនរូប និងមានជំនួយការជាច្រើនរូបទៀតដែលត្រូវទទួលបន្ទុក ផ្សេងៗគ្នា រដ្ឋមន្ត្រីដឹកនាំការងារស្នូលក្នុងក្រសួង និងការគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ក្រោមស្ថាប័នខ្លួន[81]។ ដោយឡែក រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្ដីសម្រេចសារាចរ និងសេចក្ដីណែនាំនានាស្ថិតក្នុងដែនសមត្ថកិច្ចខ្លួន[82]។

រដ្ឋមន្ត្រីទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភា។ ចំណែករដ្ឋលេខាធិការចាប់ពី អាណត្តិ៦តទៅមិនមែនជាសមាជិករដ្ឋាភិបាលទៀតឡើយ។ អនុរដ្ឋលេខាធិការក៏មានភារកិច្ច តួនាទីដូចរដ្ឋលេខាធិការដែរ ប៉ុន្តែមានអាសនានុក្រមតូចជាងរដ្ឋលេខាធិការ។ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការជាអ្នកនយោបាយដូចសមាជិករាជរដ្ឋាភិបាលដែរ បានសេចក្តីថា អ្នកទាំងពីរអាចត្រូវបានផ្លាស់ប្តូរទៅតាមអាណត្តិរបស់រដ្ឋាភិបាល ឬរដ្ឋមន្ត្រី។

[81] មាត្រា ៤០ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

[82] មាត្រា ៤៧ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

## ៦-អំណាចតុលាការ

ដ្យាក្រាមរចនាសម្ព័ន្ធប្រព័ន្ធតុលាការកម្ពុជា




## ៦-ក-ប្រវត្តិ និងការកកើតតុលាការនៅកម្ពុជា

ធម្មជាតិបង្កើតផែនដី និងជីវិតទាំងអស់នៅលើផែនដីមានមនុស្ស សត្វ និងរុក្ខជាតិទាំងឡាយ តែងតែមានជម្លោះ ឬទំនាស់នឹងគ្នាមិនចេះចប់មិនចេះហើយ ។ជម្លោះ ឬទំនាស់នេះមានតាំងពីយូរ

លង់ណាស់មកហើយ។ គ្មានអ្វីដែលមានមានទំនាស់ និងគ្មានអ្វីដែលគ្មានដំណោះស្រាយដែរ ក្នុងសង្គមមួយ សហគមន៍មួយ ប្រជាជាតិជាតិមួយ ត្រូវតែកើតមាននូវទំនាស់ជាមួយគ្នាជាសត្យានុម័ត សូម្បីតែធម្មជាតិ ក៏បង្ហាញនូវទំនាស់រវាងគ្នាដែរ។ ទំនាស់មានក៏ច្រើនប្រភេទដែរ ដូចជាទំនាស់បង្កប់ ទំនាស់ស្ដែងចេញភ្លាមៗ និងទំនាស់ចំហ[83]។ ប៉ុន្តែដោយសារមនុស្សមានសតិសម្បជ្ជញ្ញៈ និងមានការគិតពិចារណាខ្ពស់ជាងសត្វទើបមនុស្សអាចរស់នៅភាពថ្លៃថ្នូរ និងភាពសុខដុមរមនាបាន។

ដោយហេតុនេះ ហើយទើបមនុស្សមានវិធីដោះស្រាយជម្លោះដោយសន្តិវិធីមិនដូចសត្វដែលដោះស្រាយបញ្ហាដោយកម្លាំងនោះទេ។ការដោះស្រាយជម្លោះដោយសន្តិវិធីនេះ ហើយដែលនាំឲ្យមនុស្សបង្កើតបានជាស្ថាប័នតុលាការដល់សព្វថ្ងៃនេះ។

កាលពីសម័យអាណាចក្រភ្នំ សម័យចេន្លា និងសម័យអង្គរ សម័យក្រោយអង្គរ។ល។ ការដាក់ទោស ឬការដាក់ពិន័យទៅលើជនណាម្នាក់ បានប្រព្រឹត្តទៅដោយការបើកសវនការក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ ពោលគឺអំណាចវិនិច្ឆ័យទោសស្ថិតនៅលើព្រះមហាក្សត្រ ដែលព្រះអង្គទ្រង់ជាអ្នកកាន់កាប់អំណាចគ្រប់

---

[83] សេង ប៊ុនធឿន៖ ការដោះស្រាយវិវាទពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា(និក្ខេបបទថ្នាក់បណ្ឌិត) ឆ្នាំ២០១២ ទំព័រ១២

វិស័យទាំងអស់[84]។ នាសម័យនោះព្រះរាជាមានព្រះរាជតួនាទីខ្ពង់ខ្ពស់ណាស់ និយាយជារួមគឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ គឺព្រះអង្គទ្រង់ជាអ្នកសម្រេច និងក្តោបក្តាប់ទាំងអស់។ របបរាជានិយមផ្តាច់ការ( Absolute monarchy /Monarchie absolue )។ ប៉ុន្តែនេះគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ចំពោះការអនុវត្តវិញរបបរាជានិយម ឬរាជាធិបតេយ្យខ្មែរនាសម័យនោះ ព្រះមហាក្សត្រមានទសពិធរាជធម៌( ធម៌របស់អ្នកដឹកនាំទាំង១០ )ពុំនោះសោត និយាយដោយឡែករបបរាជានិយមខ្មែរមិនមានអត្ថិភាពរហូតដល់សព្វថ្ងៃនេះទេ[85]។ ដូច្នេះហើយ បានស្ថាប័នតុលាការកម្ពុជានាសម័យនោះមិនទាន់មានវត្តមាននៅឡើយទេ គឺទើបតែមាននៅពេលប្រទេសបារាំងមកដាក់លើអាណានិគមមកលើប្រទេសខ្មែរថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ តែប៉ុណ្ណោះ។ ពេលនោះបារាំងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្ថាប័នតុលាការពីរដាច់ពីគ្នា គឺតុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក និងតុលាសហភាពបារាំង[86]។

តុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក ជាសាលាវិនិច្ឆ័យតែលើករណីវិវាទដែលបង្កឡើងដោយជនជាតិខ្មែរ និងជនជាតិខ្មែរដូចគ្នា។

---

[84] https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

[85] សេង ប៊ុនធឿន៖ រដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា ឆ្នាំ២០១៥ ទំព័រ ១៥។

[86] https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

តុលាការសហភាពបារាំង ជាតុលាការដែលវិនិច្ឆ័យចំពោះវិវាទដែលបង្កដោយជនជាតិបារាំង ឬជនបរទេស។ ប្រសិនបើមានអំពើល្មើសណាមួយដែលពិរុទ្ធជនច្រើននាក់ត្រូវជាប់ទោសពីបទផ្សំគំនិតដែលក្នុងនោះមានទាំងជនជាតិខ្មែរ ឬជនជាតិបារាំង ឬជនជាតិបរទេសផងនោះ នីតិវិធីអាណានិគមនិងធ្វើការបំបែកសំណុំរឿងព្រមទាំងជនល្មើសដោយឡែកពីគ្នាទៅតាមសមត្ថកិច្ចតុលាការផ្សេងៗពីគ្នា។ប្រសិនបើជនល្មើសជាជនជាតិខ្មែរ នោះសមត្ថកិច្ចរបស់តុលាការក្នុងស្រុកជាអ្នកមានសមត្ថកិច្ចវិនិច្ឆ័យ ប្រសិនបើជនជាប់ចោទជាជាតិបារាំង ឬជាជនបរទេសវិញនោះ គឺជាសមត្ថកិច្ចរបស់តុលាការសហភាពបារាំង[87]។ នៅសម័យនោះប្រទេសកម្ពុជាមានសាលាជំនុំជំរះក្តីតិចតួចណាស់។លុះក្រោយថ្ងៃទី៩ខែវិច្ឆិកាឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានរៀបចំប្រទេសខ្លួនឡើងវិញ ធ្វើវិសោធនកម្មជាបន្តបន្ទាប់ ហើយសាលាជំនុំជំរះក្តីជាន់ទី១ ឬសាលាដំបូងត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តមួយចំនួនដែលមានសមត្ថកិច្ចគ្របដណ្តប់លើវិសាលភាពនៃដែនដីដែលសាលាជំនុំជំរះក្តីនោះស្ថិតនៅ។

សាលាលហុ សាលាដំបូង ឬសាលាជំនុំជំរះក្តីលើកដំបូងសាលាទាំងពីរនេះ មានទីតាំងនៅស្ទើរតែគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា។

---

[87] https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

-សាលាឧទ្ធរណ៍

-សាលាឧក្រិដ្ឋ

-សាលាវិនិច្ឆ័យ

សាលាជម្រះក្តីទាំងបីនេះមានទីតាំងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចគ្រប់ដណ្តប់លើដែនដីនៃប្រទេសទាំងមូល។ ប្រព័ន្ធតុលាការសម័យសាធារណៈរដ្ឋខ្មែរ១៩៧០-១៩៧៥ បន្ទាប់ពីធ្វើការផ្លាស់ប្តូររបបមកជារបបសាធារណៈរដ្ឋខ្មែរ របបនេះនៅតែបានបន្តអនុវត្តប្រព័ន្ធតុលាការអតីតព្រះរាជាណាចក្រកម្ពុជាទី១រហូតដល់រដ្ឋធម្មនុញ្ញថ្មីរបស់របបសាធារណៈរដ្ឋខ្មែរបានចូលជាធរមាននៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧២ ពេលនោះប្រព័ន្ធយុត្តាធិការត្រូវបានកែប្រែ និងវិវត្តបន្ថែមទៀត។ តុលាការកំពូល និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់នៃរបបសាធារណៈរដ្ឋខ្មែរត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញថ្មីដោយកំណត់ថាអំណាចតុលាការត្រូវតែរក្សានូវអនាគតិការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ តុលាការកំពូលមានឧត្តមមន្ត្រីតុលាការចំនួន៩រូប គឺប្រធាន១រូប និងចៅក្រមប្រឹក្សាចំនួន០៨រូប។

តុលាការកំពូលអាចផ្តើមគំនិតបង្កើតច្បាប់ទាក់ទងនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃអំណាចតុលាការ និងមានសិទ្ធិប្រកាស

រំសាយគណបក្សនយោបាយយកតាមមតិពីរភាគបីចំពោះគណបក្សនយោបាយណាដែលធ្វើសកម្មភាពបំផ្លាញរបបសាធារណៈរដ្ឋ[88]។

នៅក្នុងសម័យសាធារណៈរដ្ឋខ្មែរ យើងសង្កេតឃើញមានតុលាការធម្មនុញ្ញ និងតុលាការជាន់ខ្ពស់។ តុលាការធម្មនុញ្ញមានសមត្ថកិច្ចសម្រេចអំពីនិយ័តភាពនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណៈខ្មែរ ហើយប្រកាសពីលទ្ធផលនៃការបោះឆ្នោតនោះ និងមានសមត្ថកិច្ចសម្រេចពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសមាជិកសភា។ តុលាការជាន់ខ្ពស់មានអំណាចជំនុំជំរះរឿងក្តីរបស់ប្រធានាធិបតី និងអនុប្រធានាធិបតីនៃរបបសាធារណៈរដ្ឋខ្មែរសមាជិករដ្ឋាភិបាល សមាជិកសភា សមាជិកតុលាការធម្មនុញ្ញ និងសមាជិកតុលាការកំពូលពីបទឧក្រិដ្ឋ និងបទមជ្ឈឹមដែលស្ថិតនៅក្នុងពេលបំពេញការងាររៀងៗខ្លួន[89]។

ទោះបីជារចនាសម្ព័ន្ធដូចបានរៀបរាប់ខាងលើដោយ ដោយសង្រ្គាមបេះតែបន្ត និងមូលហេតុផ្សេងៗទៀតនោះជាហេតុធ្វើឲ្យស្ថាប័នយុត្តាធិការនាសម័យសាធារណៈរដ្ឋខ្មែរពុំបានដំណើរការរហូត

---

88 https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

89 https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលរបបសាធារណៈរដ្ឋខ្មែរបាន ដួលរលំទាំងស្រុង។

សម័យកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៥-១៩៧៩ មានរដ្ឋធម្មនុញ្ញថ្មីមួយដែលមាន១៦ជំពូក និង២១មាត្រា ក្នុងនោះក៏មានចែងផងដែរអំពីស្ថាប័នតុលាការ និងតួនាទីរបស់ស្ថាប័ននេះក្នុងការការពារយុត្តិធម៌របស់ប្រជាជនតំណាងឲ្យយុត្តិធម៌ ប្រជាជនការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យប្រជាជន ហើយផ្តន្ទាទោសចំពោះអំពើដែលប្រឆាំងរដ្ឋប្រជាជន។ ប៉ុន្តែអ្វីដែលចែងក្នុងរដ្ឋធម្មនុញ្ញនេះផ្ទុយស្រឡះពីការអនុវត្តជាក់ស្តែង ពីព្រោះភាពយុត្តិធម៌ ឬអយុត្តិធម៌ សម្រេចលើមតិអង្គការទាំងអស់។ ប្រជាពលរដ្ឋស្លូតត្រង់ត្រូវគេសម្លាប់ដោយមិនដឹងពីទោសកំហុសរបស់ខ្លួនដោយគ្មានការតវ៉ា និងមិនឆ្លងការជំនុំជំរះអ្វីទាំងអស់[90]។

ប្រព័ន្ធតុលាការសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩-១៩៨៩ និងរដ្ឋកម្ពុជាពីឆ្នាំ១៩៨៩-១៩៩១ ប្រព័ន្ធបង្កើតឡើងដោយច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនិងអយ្យការដែលប្រកាសឲ្យប្រើដោយក្រឹត្យច្បាប់០២ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋ។ តុលាការនេះជាតុលាការប្រជាជនខេត្ត-ក្រុង ដែលជាតុលាការជាន់ដំបូងនៅកម្ពុជា។

---

[90] https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

នៅឆ្នាំ១៩៨៥ តុលាការកំពូលក៏ត្រូវបានបង្កើតឡើង (ដោយច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការកំពូលដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ២៨ក្រចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ)។

អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាអ៊ុនតាក់(UNTAC)បានរៀបចំប្រព័ន្ធតុលាការដោយបានបន្ថែមសាលាជំរះក្តីមួយថ្នាក់ទៀតគឺ សាលាឧទ្ធរណ៍ និងនិតិវិធីព្រហ្មទណ្ឌនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល[91]១៩៩១-១៩៩៣។

សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជារួមមាន៖

-សាលាដំបូង

-សាលាឧទ្ធរណ៍

-តុលាកំពូល។

សាលាដំបូងជាសាលាជម្រះក្តីជាន់ទាប។ សាលាឧទ្ធរណ៍ តុលាកំពូល ជាសាលាជម្រះក្តីជាន់ខ្ពស់។ យោងតាមសេចក្តីត្រូវការចាំជាក់ស្តែង ការបង្កើតសាលាជម្រះក្តីណាមួយ ឬសាលាជម្រះក្តីវិសាមញ្ញត្រូវធ្វើឡើងដោយច្បាប់[92]។

### ៦-ក-១-អំពីតុលាការជាន់ទាប

អំណាចតុលាការខេត្ត-ក្រុង ជាអំណាចឯករាជ្យ។ អំណាច

---

[91] https://wi1234567.blogspot.com/2016/07/blog-post_14.html May 3, 2021

[92] ច្បាប់ស្តីពីការរៀបចំអង្គការតុការ ឆ្នាំ២០១៤ មាត្រា៣

តុលាការគ្រប់ដណ្តប់លើរឿងក្តីទាំងអស់រួមទាំរឿងក្តីរដ្ឋបាលផង។ នៅព្រះរាជាណាចក្រកម្ពុជាតុលាការជាន់ទាបនេះទទួលដោះស្រាយរឿងក្តីដំបូងគេបំផុត។ សាលាដំបូងនេះមានតុលាការពីរប្រភេទទៀត គឺតុលាការខេត្ត-ក្រុង និងតុលាការយោធា។ ដោយឡែកតុលាការយោធាមានសមត្ថកិច្ចលើកងទ័ពទូទាំងប្រទេស និងចំពោះតែបទល្មើសយោធាប៉ុណ្ណោះ។

**៦-ក-១-១-១-តុលាការខេត្ត/រាជធានី**

-តុលាការរាជធានី-ខេត្ត មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើទឹកដីនៃរាជធានី-ខេត្តដែលខ្លួនតាំងនៅ។

សេចក្តីសម្រេចរបស់សាលាដំបូងគេហៅថាសាលក្រម។ អាជ្ញាយុកាលនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាមានរយៈពេល១ (មួយ)ខែ។ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីក្រោយពេលប្រកាសសាលក្រម។

**៦-ក-១-១-២-ចំណែករឿងរដ្ឋប្បវេណី**

១-បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេល១(មួយ)ខែ ដោយគិតចាប់តាំងពីថ្ងៃដែលទទួលបានទទួលការបញ្ជូនសាលក្រម ឬថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចប្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។ ប៉ុន្តែករណីនេះ មិនមែនជាការរាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាង

លើ មិនអាចពន្យារបានឡើយ។ តាមគោលការណ៍ តុលាការរាជធានី-ខេត្ត ត្រូវចែកចេញជាផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី។ សាលាជម្រះក្តីជាន់ទាប ត្រូវបែងចែកជា តុលាការជំនាញ។ ការបង្កើតការលុបចោល និងការកែប្រែតុលាការជំនាញត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ សាលាដំបូងនីមួយៗបែងចែកជាតុលាការជំនាញដូចខាងក្រោម៖

-តុលាការរដ្ឋប្បវេណី

-តុលាការព្រហ្មទណ្ឌ

-តុលាការពាណិជ្ជកម្ម

-តុលាការការងារ។

ផ្នែកព្រហ្មទណ្ឌមានចៅក្រម និងក្រឡាបញ្ជី។ ចៅក្រមមានភារកិច្ចធ្វើការស៊ើបអង្កេតតាមសេចក្តីសន្និដ្ឋានស្នើឲ្យស៊ើបអង្កេតរបស់អយ្យការ និងធ្វើការជំនុំជម្រះរឿងព្រហ្មទណ្ឌនៅរឿងទាំងឡាយដែលខ្លួនពុំបានធ្វើការស៊ើបអង្កេត។ ការបំពេញនាទីស៊ើបអង្កេតគេហៅថា“ចៅក្រមស៊ើបអង្កេត” កាលណាបំពេញនាទីក្នុងការជំនុំជម្រះគេហៅថា“ចៅក្រមជំនុំជម្រះ”ក្រឡាបញ្ជីមានតួនាទីជាអ្នកជំនួយចៅក្រមនៅក្នុងការកត់ត្រាកំណត់ហេតុនានារៀបចំទុកដាក់ឯកសារ និងសេវាកម្មប្រគល់ដីកា និងលិខិតស្នាមផ្សេងៗ។

**៦-ក-១-១-៣-តុលាការយោធា**

តុលាការយោធាមានទីតាំងស្ថិតនៅរាជធានីភ្នំពេញជាប្រភេទ

តុលាការជាន់ទាបដែលមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលទាក់ទងទៅនឹងបទល្មើសមានលក្ខណៈយោធា ឬបទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធដែលប្រព្រឹត្តដោយយោធិន។ ចំពោះយោធាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការរាជធានី-ខេត្ត។ រាល់សកម្មភាពទាំងអស់ដែលប្រព្រឹត្តដោយតុលាការយោធាត្រូវរាយការណ៍ទៅក្រសួងការពារជាតិដូចជាស្ថិតិនៃការស៊ើបអង្កេត និងការជំនុំជម្រះ ជាដើម។ ស្ថាប័នអយ្យការយោធាដែលអមតុលាការយោធាក៏ស្ថិតនៅក្រោមក្រសួងការពារជាតិដែរ។ បើផ្អែកតាមច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជំរះក្ដីរដ្ឋកម្ពុជាឆ្នាំ១៩៨៩ គេមិនបានចែងអំពីតំបន់ភូមិសាស្ត្រដែលតុលាការយោធាមានសមត្ថកិច្ចគ្របដណ្ដប់ឡើយ ប៉ុន្តែគេអាចយល់ថា គឺគ្របដណ្ដប់លើដែនដីកម្ពុជាទាំងមូល។ តុលាការយោធានៅក្នុងខ្លឹមសារនៃក្រឹត្យច្បាប់លេខ០៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១ ដែលសមត្ថកិច្ចមិនត្រឹមតែលើបុគ្គលិកយោធាប៉ុណ្ណោះទេ តែថែមទាំងរហូតដល់សមាជិកមិនមែនយោធាដែលស្ថិតក្រោមការរបស់ក្រសួងការពារប្រទេស និងជនស៊ីវិលដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួមជាមួយយោធាផងដែរ។ តុលាការយោធាចែកចេញជាការិយាល័យក្រឡាបញ្ជីនាយក ការិយាល័យស៊ើបអង្កេត ការិយាល័យចៅក្រមជំនុំជម្រះ និងលេខាធិការដ្ឋាន (ជាការិយាល័យរដ្ឋបាល)។ តុលាការយោធា មានបុគ្គលិកទាំងអស់ជាសមាជិយោធាដែលមានដូចតទៅគឺ ប្រធានម្នាក់ អនុប្រធាន០៣នាក់ ចៅក្រម

សមាជិក និងអ្នកការពារយោធា។ ចៅក្រមទាំងអស់ត្រូវតែងតាំងដោយក្រសួងការពារប្រទេស ចំពោះអ្នកការពារក្តីយោធាត្រូវបានតែងតាំងដោយប្រធានតុលាការ ក្រោយពីបានបញ្ចប់ការហ្វឹកហ្វឺននៅក្រសួងយុត្តិធម៌។ នៅអមតុលាការយោធាមានតំណាងខាងអយ្យការយោធា មានព្រះរាជអាជ្ញាយោធាម្នាក់ និងព្រះរាជអាជ្ញារងច្រើននាក់។ ស្របតាមខ្លឹមសារនៃក្រឹត្យលេខ០៦ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានផ្តល់អំណាចឲ្យតុលាការយោធាជម្រះតែរឿងមានបទល្មើសយោធាដែលប្រព្រឹត្តដោយយោធានៃកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះ។ ជាការសំខាន់គេត្រូវយល់ថា តើអ្វីទៅជាបទល្មើសយោធា? ច្បាប់នោះបានឲ្យនិយមន័យយ៉ាងខ្លីអំពីបទល្មើសយោធាថាជាអំពើដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ពហើយដែលពាក់ព័ន្ធទៅនឹងវិស័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។ចំណែកក្រឹត្យច្បាប់លេខ០៤ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបានរៀបរាប់លំអិតអំពីប្រភេទបទល្មើសយោធា និងទណ្ឌកម្មសម្រាប់បទល្មើស នីមួយៗ។

-មានតែមួយគត់តាំងនៅរាជធានីភ្នំពេញ

-មានសមត្ថកិច្ចលាតសន្ធឹងលើផ្ទៃប្រទេសទាំងមូល

-ដោះស្រាយតែរឿងក្តីទាំងឡាយដែលបង្កឡើងដោយយោធិនប៉ះពាល់ដល់កងទ័ព ឬទ្រព្យសម្បត្តិ ឬវិន័យរបស់កងទ័ព។

-នីតិវិធីដូចគ្នានឹងនីតិវិធីរបស់តុលាការខេត្ត-រាជធានីដែរតែ

គ្រប់ចៅក្រមទាំងអស់គឺជាសមាជិកឃោជាដែលតែងតាំងដោយក្រសួងការពារជាតិ។

**៧-ក-២-អំពីតុលាការជាន់ខ្ពស់**

**៧-ក-២-១-សាលាឧទ្ធរណ៍**

-ជុំនុំជំជម្រះទាំងអង្គហេតុ និងអង្គច្បាប់ដែលមានបណ្ដឹងឧទ្ធរណ៍ពីសាលក្រមរបស់តុលាការជាន់ទាបដោយបើកផ្លូវឱ្យប្ដឹងសារទុក្ខ។

-នីតិវិធីជំនំជម្រះមានភាពស្រដៀងគ្នានឹងតុលាការជាន់ទាបដែរ អ្វីដែលខុសគ្នាគឺចៅក្រមដែលជំនុំជំជម្រះគេហៅថា “ ក្រុមប្រឹក្សាវិនិច្ឆ័យទោស ”។

-ផ្លូវនៃបណ្ដឹងមានពីរដូចនៅក្នុងនីតិវិធីរបស់តុលាការរាជធានី-ខេត្តដែរ គឺបណ្ដឹងជំទាស់ និងបណ្ដឹងសារទុក្ខ។

-សេចក្ដីសម្រេចចុងក្រោយហៅថា “ សាលដីកា” ។ ការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល៣(បី)ខែ។ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីក្រោយពេលប្រកាសសាលក្រម[93]។

**៧-ក-២-២-តុលាការកំពូល**

-មានតែមួយគត់នៅភ្នំពេញ

-មានសមត្ថកិច្ចលាតសន្ធឹងលើផ្ទៃប្រទេសទាំងមូល

-មានសមត្ថកិច្ចដោះស្រាយបណ្ដឹងសារទុក្ខលើកទី១ និង២

---

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៨១

-ការដោះស្រាយបណ្តឹងសារទុក្ខលើកទី១ តុលាការកំពូលពិនិត្យតែអង្គច្បាប់ទេ តែលើកទី២ទាំងអង្គហេតុ និងអង្គច្បាប់។

-សេចក្តីសម្រេចរបស់តុលាការកំពូលហៅថា “សាលដីកា*។ រយៈពេលដើម្បីធ្វើបណ្តឹងសារទុក្ខបណ្តឹងសារទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចតទៅ៖

-១(មួយ)ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

-១៥(ដប់ប្រាំ)ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

-៥(ប្រាំ)ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។ កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខរយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា។ កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខរយៈពេលត្រូវផ្តើមពីការពីការឲ្យដំណឹង។ កាលណាសាលដីកាសម្រេចដោយកំបាំងមុខរយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់[94]។

## ៨-អំពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

---

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤២០

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ[95]។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ[96]។

**ក-សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួមមាន៖

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២-ប្រធានតុលាការកំពូល

៣-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

៤-សមាជិក១រូបជ្រើសរើសដោយព្រឹទ្ធសភា

៥-សមាជិក១រូបជ្រើសរើសដោយរដ្ឋសភា

៦-សមាជិក១រូបជ្រើសរើសដោយក្រុមប្រឹក្សាធម្មនុញ្ញ

៧-សមាជិក១រូប ជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៨-សមាជិក១រូប ជាចៅក្រម ដែលជ្រើសរើសចៅក្រមសាលាជំរះក្តីជាន់ខ្ពស់

៩-សមាជិក១រូបជាព្រះរាជអាជ្ញា ដែលជ្រើសរើសព្រះរាជអាជ្ញាអមសាលាជម្រះក្តីជាន់ខ្ពស់ ឬព្រះរាជអាជ្ញា

---

[95] រដ្ឋធម្មនុញ្ញ ១៩៩៣ មាត្រា ១៣២ថ្មី

[96] រដ្ឋធម្មនុញ្ញ ១៩៩៣ មាត្រា ១៣៤ថ្មី

បម្រើការងារនៅក្រសួងយុត្តិធម៌

១០-សមាជិក១រូបជាចៅក្រមពេញសិទ្ធិ នៅសាលាដំបូងដែលជ្រើសរើសតាមការបោះឆ្នោតដោយចៅក្រមសាលាដំបូងទូទាំងប្រទេស

១១-សមាជិក១រូប ជាព្រះរាជអាជ្ញាពេញសិទ្ធិ នៃអយ្យការអមសាលាដំបូងដែលជ្រើសរើសតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាអមសាលាដំបូងទូទាំងប្រទេស។

**ខ-មុខងារ និងសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

**ខ-១-មុខងារក្នុងការតែងតាំងចៅក្រម**

ការតែងតាំង ការតម្លើងថ្នាក់ ការតម្លើងឋានន្តរសក្តិ ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការហូតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។

**ខ-២-មុខងារក្នុងការដាក់ទណ្ឌកម្មវិន័យ**

ចំពោះចៅក្រម និងព្រះរាជអាជ្ញាទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញតិច្បាប់។

**ខ-៣. មុខងារប្រឹក្សាយោបល់**

ផ្តល់យោបល់ទៅលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។

# ៧-អំពីក្រុមប្រឹក្សាធម្មនុញ្ញ

## ៧-១-ប្រវត្តិនៃក្រុមប្រឹក្សាធម្មនុញ្ញ

ជាស្ថាប័នកំពូលមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ សម្រាប់ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ តាមការឲ្យដឹងពីគេហដ្ឋទំព័ររបស់ក្រុមប្រឹក្សាធម្មនុញ្ញថា ក្រុមប្រឹក្សាធម្មនុញ្ញចាប់ដំណើរការពេញលក្ខណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨[97]។ កាលពីសម័យសង្គមរាស្ត្រនិយម ស្ថាប័នត្រូវបានគេស្គាល់ថាជា ក្រុមប្រឹក្សារាជាណាចក្រ ដែលមានតួនាទីស្រដៀងគ្នានឹងស្ថាប័នក្រុមប្រឹក្សារដ្ឋធម្មនុញ្ញដែរ បានសេចក្តីថា ស្ថាប័នទាំងពីរប្រសិនបើមានមួយណាហើយមួយទៀតមិនចាំបាច់បង្កើតទេ។

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ។ មានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួននិងតំណាងរាស្ត្រមួយភាគដប់ ឬតុលាការប៉ុណ្ណោះ ដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាន។

---

[97] https://www.ccc.gov.kh/

ប្រជារាស្ត្រ និងគណបក្សនយោបាយអាចលើកសំណើ ឬប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមលក្ខខណ្ឌដែលមានចែងខាងក្រោយ[98]។

### ៧-២-ព្រះមហាក្សត្រ និងក្រុមប្រឹក្សាធម្មនុញ្ញ

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្ដីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។ ការផ្ដើមគំនិតសើរើ ឬការផ្ដើមគំនិតធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភាតាមសេចក្ដីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។

### ៧-៣-សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកទាំងអស់ចំនួន៩រូបដែលមានប្រធាន១រូប និងសមាជិកចំនួន៨រូប។ ប្រធានត្រូវបាជ្រើសតាំងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតរៀងរាល់បីឆ្នាំម្ដង ក្រោយពីសមាជិកថ្មី៣រូបចូលកាន់តំណែង។ ប្រធានមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា។ សមាជិកមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។

ជាធម្មតាអាណត្តិរបស់សមាជិកគឺ៩ឆ្នាំ ប៉ុន្តែសមាជិកចំនួន៣រូបត្រូវបានជ្រើសតាំង ឬតែងតាំងរាល់បីឆ្នាំម្ដង។ ក្នុងអាណត្តិទី១ ត្រូវបានតែងតាំង ឬជ្រើសតាំងសមាជិក៣រូបសម្រាប់បីឆ្នាំ ៣រូបសម្រាប់

---

[98] https://www.ccc.gov.kh/

ប្រាំមួយឆ្នាំ និង៣រូបសម្រាប់ប្រាំបួនឆ្នាំ។ សមាជិក៣រូបតែងតាំងដោយព្រះមហាក្សត្រផ្ទាល់ ៣រូបជ្រើសតាំងដោយរដ្ឋសភា និង៣រូបទៀត ជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[99]។ សមាជិកទាំងអស់ត្រូវបានតែងតាំង ឬជ្រើសតាំងពីចំណោមឥស្សរជនមានសញ្ជាតិខ្មែរពីកំណើតមានអាយុយ៉ាងតិច៤៥ឆ្នាំ មានបទពិសោធន៍ការងារយ៉ាងតិច១៥ឆ្នាំ និងមានសញ្ញាបត្រឧត្តមសិក្សាឡើងទៅក្នុងវិស័យច្បាប់ រដ្ឋបាល ការទូត និងសេដ្ឋកិច្ច[100]។ ស្ថាប័នដែលមានអំណាចតែងតាំង និងជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ៖

-ព្រះមហាក្សត្រតែងតាំង៣រូបតាមព្រះរាជក្រឹត្យ

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បោះឆ្នោតជ្រើសតាំង៣រូបដែលបន្ទាប់មកត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ

-រដ្ឋសភាបោះឆ្នោតជ្រើសតាំង៣រូបដែលបន្ទាប់មកត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល បន្ទាប់ពីសមាជិកថ្មី ៣រូប

---

[99] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជំពូកទី១២ថ្មី មាត្រា១៣៧ថ្មី (មាត្រា១១៨ចាស់)

[100] https://www.ccc.gov.kh/

ចូលកាន់តំណែង។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវបានជ្រើសតាំងជាថ្មីបាន[101]។

**៧-៤-លក្ខណៈសម្បត្តិរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ**

សមាជិកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសរើសក្នុងចំណោមឥស្សរជនដែល ៖

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិច៤៥ឆ្នាំ

-មានបទពិសោធន៍ក្នុងកាងារយ៉ាងតិច១៥ឆ្នាំ

-មានសញ្ញាប្រតចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់រដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច។

**៧-៥-មុខងារ និងវិសមិតភាព**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពជាមួយសកម្មភាពទាំងអស់នៅក្នុងមុខងារសាធារណៈ និងមុខងារជា ៖

-សមាជិកព្រឹទ្ធសភា

-តំណាងរាស្ត្រ

-សមាជិករាជរដ្ឋាភិបាល

-ប្រធាន និងអនុប្រធានគណបក្សនយោបាយ

-ប្រធាន និងអនុប្រធានសហជីព

-ចៅក្រមក្នុងមុខតំណែង

---

[101] https://www.ccc.gov.kh/

នៅក្នុងអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបំពេញតំណែង ឬមុខរបរណាមួយផ្សេងទៀតឡើយ។

**៧-៦-អភ័យឯកសិទ្ធិ**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ចំពោះការសម្រេចដែលបានធ្វើឡើងនៅពេលបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ[102]។

**៧-៧-ឋានៈ និងបុព្វសិទ្ធិ**

-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈ និង បុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា[103]។

**៧-៨-ការដកចេញពីតំណែង**

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាម្នាក់ពីតំណែង តម្រូវឱ្យមានការយល់ព្រមពីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន២ភាគ៣នៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូលក្នុងសវនាការមិនសាធារណៈ និងដោយមានវត្តមានរបស់សាមីខ្លួន។ ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពីតំណែងនូវសមាជិកណាដែលមានវិសមិតភាពមុខតំណែងឬដែលមិនបានមកប្រជុំលើសពី៣ដង

[102] https://www.ccc.gov.kh/
[103] https://www.ccc.gov.kh/

ផ្ទួនៗគ្នាដោយឥតបានជូនដំណឹងជាមុន ឬដែលមិនអាចបំពេញមុខងារជារៀងរហូតបានដោយបាត់បង់សមត្ថភាព ខាងបញ្ញា ឬ រូបកាយជាអចិន្ត្រៃយ៍ [104]។

## ៧-៩-សមត្ថកិច្ចនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចដូចតទៅ៖

-ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ

-ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព។

-ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា[105]។

-ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ។

-ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះ

---

[104] https://www.ccc.gov.kh/

[105] [105] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជំពូកទី១២ថ្មី មាត្រា១៣៦ថ្មី

រាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោ-បាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអាសាសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ[106]។

-ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាព នៃច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រចំនួនមួយភាគដប់។

-បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាព នៃបទប្បញ្ញត្តិណាមួយនៃច្បាប់ឬសេចក្តីសម្រេចរបស់ស្ថាប័ននានាដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន។ អ្នកមានសិទ្ធិដាក់សំណើ ឬបណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ

-ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិនិត្យដោះស្រាយសំណើ ឬបណ្តឹងជានិច្ចជាកាលតាមរយៈនៃការស្នើសុំពីខាងក្រៅមិនមែនក្រុមប្រឹក្សាធម្មនុញ្ញខ្លួនឯងចាប់យកមកពិនិត្យវិនិច្ឆ័យដោយឯកឯងនោះទេ។ អ្នកដែលមានសិទ្ធិក្នុងការធ្វើបណ្តឹង ឬលើកសំណើត្រូវបានបែងចែកដោយឡែកៗ ទៅតាមប្រភេទ និងកម្មវត្ថុនៃបណ្តឹង ឬសំណើដូច

[106] https://www.ccc.gov.kh/

មានខាងក្រោម៖

ក-អ្នកមានសិទ្ធិដាក់សំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ឬព្រឹទ្ធសភា។

| **ប្រភេទ កម្មវត្ថុនៃសំណើ** | **សមាសភាព អ្នកមានសិទ្ធិដាក់សំណើ** |
|---|---|
| **១-ពិនិត្យធម្មនុញ្ញ ជាអតិកាល** (មុនពេលដែលច្បាប់ប្រកាសឱ្យប្រើ)<br>**ក-មិនដាច់ខាត**<br>-ច្បាប់ស្ដីពីការផ្ដល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ អនុសញ្ញាអន្តរជា<br>-ច្បាប់ធម្មតា | -ព្រះមហាក្សត្រ<br>-ប្រធានព្រឹទ្ធសភា<br>-ប្រធានរដ្ឋសភា<br>-នាយករដ្ឋមន្ត្រី<br>-តំណាងរាស្ត្រ ចំនួន ១ ភាគ ១០<br>-សមាជិកព្រឹទ្ធសភា ចំនួន ១ ភាគ ៤<br>-ប្រធានព្រឹទ្ធសភា<br>-ប្រធានរដ្ឋសភា<br>-ប្រធានរដ្ឋសភា |
| **ខ-ជាដាច់ខាត**<br>-បទបញ្ជាផ្ទៃក្នុង វិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា<br>-បទបញ្ញាផ្ទៃក្នុង វិសោធនកម្មបទបញ្ញាផ្ទៃក្នុងរបស់រដ្ឋសភា<br>-ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការ | -ប្រធានព្រឹទ្ធសភា<br><br>-ប្រធានរដ្ឋសភា<br><br>-ប្រធានរដ្ឋសភា |

| | |
|---|---|
| **២.ពិនិត្យធម្មនុញ្ញភាព ជាបច្ឆាកាល** (ក្រោយពេលដែលច្បាប់ប្រកាសឱ្យប្រើ)<br>-ព្រះរាជក្រម ក្រឹត្យ-ច្បាប់ដែលនៅជាធរមាន -បទបញ្ញាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និង រដ្ឋសភា<br><br>**៣-បកស្រាយ**<br>-រដ្ឋធម្មនុញ្ញ<br>-ព្រះរាជក្រម ក្រឹត្យ-ច្បាប់ដែលនៅជាធរមាន<br>-បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា និង រដ្ឋសភា | -ព្រះមហាក្សត្រ<br>-ប្រធានព្រឹទ្ធសភា<br>-ប្រធានរដ្ឋសភា<br>-នាយករដ្ឋមន្ត្រី<br>-តំណាងរាស្ត្រចំនួន១ភាគ១០<br>-សមាជិកព្រឹទ្ធសភាចំនួន១ភាគ៤<br>-តុលាការ<br>-ប្រជារាស្ត្រធ្វើសំណើ ប៉ុន្តែពុំដោយផ្ទាល់ទេ ត្រូវឆ្លងតាមរយៈប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភា១ភាគ៤តំណាងរាស្ត្រ ១ ភាគ១០[107] |

ខ-អ្នកមានសិទ្ធិដាក់បណ្តឹងតវ៉ាដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ាពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប)តែប៉ុណ្ណោះលើកលែងតែករណីប្តឹងអំពីលទ្ធផលបណ្តោះអាសន្ន ទើប

[107] https://www.ccc.gov.kh/

បុគ្គលគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតអាចដាក់បណ្តឹងដោយផ្ទាល់មកក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល៧២ម៉ោងបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ក្នុងករណីដែលបណ្តឹងនេះមិនបានដាក់ប្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ[108]។

| **ប្រភេទកម្មវត្ថុនៃបណ្តឹង** | **សមាសភាពអ្នកមានសិទ្ធិដាក់បណ្តឹង** |
|---|---|
| **១-ការចុះបញ្ជី គណបក្សនយោបាយនៅក្រសួងមហាផ្ទៃ** | គណបក្សនយោបាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា(៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពីក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេចក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបណ្តឹង) |
| **២-ការតវ៉ាពីបេក្ខភាព បញ្ជីរាយនាមបេក្ខជន** | សាមីខ្លួន សាមីគណបក្សនយោបាយ(៥ថ្ងៃយ៉ាងយូរ |

108 https://www.ccc.gov.kh/

| | |
|---|---|
| | បន្ទាប់ពីថ្ងៃទទួល លិខិតជូនដំណឹងបដិសេធពីគជប។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេចក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបណ្តឹង) |
| **៣-ការសុំចុះឈ្មោះបោះឆ្នោត**<br>-ការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត<br>-ជំទាស់នឹងការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត<br>-ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត | សាមីខ្លួនអ្នកតំណាងឱ្យសាមីខ្លួន (៥ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពីគជប។ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចក្នុងរយៈពេល១០ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលបណ្តឹង) |
| **៤-លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត**<br>-បណ្តឹងតវ៉ាដោយផ្ទាល់៧២ម៉ោងយ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់គជប<br>-បណ្តឹងជំទាស់នឹងសេចក្តី | គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេចក្នុងរយៈពេល១០ថ្ងៃទៅ២០ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលបណ្តឹង[109] ។ |

[109] https://www.ccc.gov.kh/

| | |
|---|---|
| សម្រេចរបស់គជប ៧២ម៉ោង យ៉ាងយូរបន្ទាប់ពីការជូនដំណឹងរបស់ គជប។ | |

ជារួមស្ថាប័នជាតិសំខាន់ៗត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងនយោបាយ សិទ្ធិ សេរីភាព និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌជារដ្ឋឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដី។ ស្ថាប័នជាតិសំខាន់ៗខាងលើ កន្លងមកបានដើរតួយ៉ាងសំខាន់ក្នុងការជំរុញឲ្យនាវាកម្ពុជាមួយនេះធានានូវក្របខណ្ឌនីតិរដ្ឋ។ ថ្វីបើតំណាក់កាលខ្លះ ការអនុវត្តខ្លះ យើងមិនអាចបំពេញន័យឲ្យបានពេញលេញនូវពាក្យថា **នីតិរដ្ឋ** យ៉ាងណាក្តី ប៉ុន្តែស្ថាប័នទាំងនោះ ពិតជាមានសារសំខាន់ណាស់ដែលអាចចាត់ទុកជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយឆ្លើយតបបាន និងទាន់បេលវេលាចំពោះស្ថានការនយោបាយ និងការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាលើឆាកអន្តរជាតិ។

# ជំពូកទី៣

# គោលការណ៍ទូទៅនៃការរៀបចំរដ្ឋបាលរបស់រដ្ឋ

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១- ការរៀបចំរដ្ឋបាលរបស់រដ្ឋ*

*២- ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ*

*៣- ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ*

*៤- ប្រព័ន្ធគ្រប់គ្រងបែបវិសហមជ្ឈការ*

*៥- សហគ្គិភាពរវាងវិមជ្ឈការ-វិសហមជ្ឈការ*

*៦-សេចក្តីសន្និដ្ឋាន*

## ១-ការរៀបចំរដ្ឋបាលរបស់រដ្ឋ

### ១-សេចក្តីផ្តើមប្រព័ន្ធគ្រប់គ្រងរដ្ឋបាល

ការគ្រប់គ្រងរដ្ឋបាលបែបមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ ជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិ-បាលដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មក និងបានបង្កើតនូវ

សមិទ្ធផលជាច្រើនពាក់ព័ន្ធនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងនិងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ តាមរយៈការអនុវត្តកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានបំពេញតួនាទី និងការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានាឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋាន ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

កំណែទម្រង់មជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំអនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានា ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា និងផ្អែកតាមគោលនយោបាយច្បាប់ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ រហូតមកដល់ពេលនេះ កំណែទម្រង់នេះបានឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅ ដោយតម្រូវឱ្យមានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនានា ដែលកំពុងមានការ

កើនឡើងយ៉ាងគំហុក ស្របពេលដែលស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ជាតិកំពុងមានការរីចម្រើនកាន់តែខ្លាំង ។

ក្នុងដំណាក់កាលដ៏សំខាន់នេះ តម្រូវឱ្យក្រសួង ស្ថាប័ននៅថ្នាក់ជាតិត្រូវផ្ទេរមុខងារ និងធនធានកាន់តែច្រើនឡើងបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមគ្នានេះ ក៏តម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតការទទួលខុសត្រូវឱ្យបានកាន់តែសកម្មបន្ថែមទៀតក្នុងការគ្រប់គ្រង ចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលនយោបាយលិខិតបទដ្ឋាន និងស្តង់ដារដែលបានកំណត់ជាធរមានក្នុងវិស័យនីមួយៗ។

រដ្ឋបាលកណ្តាល គឺជាការប្រមូលផ្តុំនៃអាជ្ញាធររួមចូលគ្នាបានជា **អំណាចនីតិប្រតិបត្តិ**។ អាជ្ញាធររដ្ឋបាល គឺជាអាជ្ញាធរដែលជំរុញការងារនៅក្នុងក្រសួង ឬក្រុមរដ្ឋការមួយ។ អំណាចកណ្តាលមានសមត្ថកិច្ចទូទៅលើដែនដីនៃប្រទេសជាតិ។ បានសេចក្តីថា រដ្ឋបាលកណ្តាលមានតួនាទីបំពេញមុខងាររដ្ឋបាលនៅលំដាប់ថ្នាក់លើ និងស្ថិតនៅក្នុងក្របខ័ណ្ឌជាតិទាំងមូល។ បើនិយាយអំពីសកម្មភាពរបស់រដ្ឋ គឺអាជ្ញាធរកណ្តាលជាអ្នកដឹកនាំដោយផ្ទាល់ ឬតាមរយៈតំណាងទាំងឡាយរបស់រាជរដ្ឋាភិបាលនៅបណ្តាខេត្តនានា។ ដើម្បីអនុវត្តនូវ

សកម្មភាពរបស់ខ្លួន  អាជ្ញាធររដ្ឋបាលកណ្តាលអាចធ្វើការជ្រើសរើស នូវរូបមន្ត៣ ៖

ក- គ្រប់គ្រងតាមបែបមជ្ឈការ Centralization

ខ- គ្រប់គ្រងតាមបែបវិមជ្ឈការ Decentralization

គ- គ្រប់គ្រងតាមបែបវិសហមជ្ឈការ ( De-concentration)

**ក-ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ**

ស្ថាប័ននីតិប្រតិបត្តិ  ជាអ្នកគ្រប់គ្រងនូវអំណាចសំខាន់ពីរ  គឺ អំណាចនយោបាយ  និងអំណាចរដ្ឋបាល។កាលណាអំណាចរដ្ឋបាល ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ឬថ្នាក់កណ្តាល ឬមនុស្សមួយក្រុម ឬមនុស្សណាម្នាក់ គេហៅថាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនោះថា មជ្ឈការ។

យើងអាចនិយាយបានថា ប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការ ជាប្រព័ន្ធគ្រប់គ្រងដែលអាជ្ញាធរកណ្តាលមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចគ្រប់កិច្ចការទាំងឡាយ។ បានសេចក្តីថា រដ្ឋាភិបាលជាអ្នកដឹកនាំការងាររដ្ឋបាលដោយផ្ទាល់  តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ចំណែកអាជ្ញាធរមូលដ្ឋាន(ថ្នាក់ក្រោមជាតិ) គ្រាន់តែជាអ្នកបញ្ជូននូវរាល់សំណូមពរ  ឬជាអ្នកលើកបញ្ហារបស់ប្រជាជនទៅឲ្យអាជ្ញាធរកណ្តាលដើម្បីពិនិត្យ និងសម្រេច ហើយអាជ្ញាធរថ្នាក់មូលដ្ឋានជាអ្នកទទួលនូវបទបញ្ជាពីថ្នាក់កណ្តាលយកទៅឲ្យប្រជាជនអនុវត្តតាមផងដែរ។

ប្រព័ន្ធគ្រប់គ្រងនេះ មានតែអាជ្ញាធរថ្នាក់កណ្តាលទេដែលមានអំណាចសម្រេច និងចេញបទបញ្ជាបាន។ អំណាចកណ្តាលជាអំណាចរបស់រដ្ឋាភិបាលដែលកាន់កាប់ដោយប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នដែលជាអ្នកមានឋានៈ និងឋានានុក្រមខ្ពស់ជាងគេមានសិទ្ធិអំណាចតែងតាំង ដកហូត ឬផ្លាស់ប្តូរមន្ត្រីក្រោមឱវាទរបស់ខ្លួន ចេញបទបញ្ជាឲ្យថ្នាក់ក្រោមអនុវត្តតាម ការកែប្រែសេចក្តីសម្រេចរបស់ថ្នាក់ក្រោម និងក៏ដូចគ្នាដែរមានសិទ្ធិបដិសេធន៍ ឬលុបចោលសេចក្តីសម្រេចថ្នាក់ក្រោមបានគ្រប់ពេល។

ប្រព័ន្ធគ្រប់គ្រងបែបនេះ គេច្រើនប្រើប្រាស់នៅក្នុងបណ្តាប្រទេសដែលមានបូរណៈភាព ដែនដីតូចតាច និងមានចំនួនប្រជា

ជនតិចតួច ដូចជានៅប្រទេសសឹង្ហបុរី[110] រាជាចក្រម៉ូណាកូ[111] បុរីវ៉ាទីកង់[112] ជាដើម។

### ក-១-និយមន័យ

#### *តាមនិរុត្តិសាស្ត្រ ( Etymology )

---

[110] Singapore, Country in Asia

Singapore, officially the Republic of Singapore, is a sovereign island city-state in maritime Southeast Asia. Wikipedia
Area: 728.3 km²
Population: 5.704 million (2019) World Bank
National language: Malay
President: Halimah Yacob
Gross domestic product: 372.1 billion USD (2019) World Bank

[111] Monaco, Country in Europe

Monaco, officially the Principality of Monaco, is a sovereign city-state and microstate on the French Riviera close to the Italian region of Liguria, in Western Europe. Bordered by France to the north, east and west, it is lapped by the Mediterranean Sea to the south. Wikipedia
Area: 202 ha
Population: 38,964 (2019) World Bank
Gross domestic product: 7.188 billion USD (2018) World Bank
Continent: Europe

[112] **Vatican City,** Country in Europe

Vatican City, a city-state surrounded by Rome, Italy, is the headquarters of the Roman Catholic Church. It's home to the Pope and a trove of iconic art and architecture. Its Vatican Museums house ancient Roman sculptures such as the famed “Laocoön and His Sons” as well as Renaissance frescoes in the Raphael Rooms and the Sistine Chapel, famous for Michelangelo’s ceiling. — Google
Capital: Vatican City
Area: 44 ha
Population: 825 (2019)
President: Giuseppe Bertello
Continent: Europe

ពាក្យ **មជ្ឈការ**មកពីបន្សំរវាងពាក្យពីរម៉ាត់« **មជ្ឈ**» + **« ការ»** ។ « **មជ្ឈ**» (សំ-មធ្យ )— មានន័យថា « កណ្តាល ឬមជ្ឈឹម» ចំណែក **« ការ»** សំដៅដល់ « កិច្ច ឬអំពើ» ។ **សរុបមក មជ្ឈការ គឺជាកិច្ចការកណ្តាល ឬមជ្ឈឹម**[113]។

***តាមវិស័យច្បាប់**

ការប្រមូលផ្តុំអំណាច (Centration of authority) របស់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់លើ(**រដ្ឋបាលកណ្តាល**) ក្នុងការធ្វើសេចក្តីសម្រេចរដ្ឋបាលទាំងឡាយហៅថា **មជ្ឈការ** (Centration)។ ជាគោលការណ៍អំណាចនីតិប្រតិបត្តិអាចចែកចេញជាពីរយ៉ាងសំខាន់ៗ គឺ៖ **អំណាចនយោបាយ** និង**អំណាចរដ្ឋបាល**។ ដូច្នេះកាលណាអំណាចរដ្ឋបាលទាំងអស់ប្រមូលផ្តុំមកនៅតែក្នុងកណ្តាប់ដៃរដ្ឋបាលកណ្តាលតែម្នាក់ឯងគេហៅថា **មជ្ឈការ**។

នៅក្នុងប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ រដ្ឋាភិបាល(**អាជ្ញាធររដ្ឋបាលកណ្តាល**)ដឹកនាំគ្រប់រដ្ឋបាល ដោយផ្ទាល់ចាប់តាំងពីរដ្ឋបាលថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ(**ថ្នាក់មូលដ្ឋាន**)។ ក្នុងរបបសភានិយម អំណាចកណ្តាលនេះកាន់កាប់ដោយ**នាយករដ្ឋមន្ត្រី** និង**រដ្ឋមន្ត្រី** ដែលជាប្រធានស្ថាប័នរដ្ឋ ខណៈនៅក្នុងរបបប្រធានាធិបតីនិយម អំណាចរដ្ឋបាលកណ្តាលគឺស្ថិតនៅលើប្រធានាធិតីជាប្រធាន។

---

[113] សម្តេចព្រះសង្ឃរាជ ជួន ណាត ៖ វចនានុក្រមខ្មែរ ឆ្នាំ១៩៦៧ ទំព័រ៥២៨-៥២៩

រាល់សេចក្ដីសម្រេចរដ្ឋបាលទាំងឡាយ ត្រូវបានធ្វើឡើងចេញតែពីមជ្ឈមណ្ឌលតែមួយគត់គឺ **អាជ្ញាធររដ្ឋបាលកណ្ដាល** នេះឯង។ ក្នុងន័យនេះ អាជ្ញាធរនៅថ្នាក់ក្រោម ឬហៅថា **ថ្នាក់មូលដ្ឋាន** មិនអាចធ្វើសេចក្ដីសម្រេចរដ្ឋបាល ឬអនុវត្តការងារតាមគំនិតរបស់ខ្លួនដោយផ្ទាល់បានទេ។

អាជ្ញាធរថ្នាក់មូលដ្ឋានមានតួនាទីត្រឹមតែជាអ្នកប្រតិបត្តិតែប៉ុណ្ណោះ។

**ក-២-គុណសម្បត្តិរបស់ប្រព័ន្ធមជ្ឈការ**

ត្បិតតែអំណាចស្ថិតនៅក្នុងដៃថ្នាក់កណ្ដាលជាអ្នកសម្រេចក៏ពិតមែន តែវាក៏មានគុណសម្បត្តិមួយចំនួនផងដែរ ដែលមានដូចខាងក្រោម ៖

-រដ្ឋអំណាចកណ្ដាលជាអ្នកប្រើប្រាស់អំណាច និងបុព្វសិទ្ធិពិសេសដែលមានទាំងអស់

-ការប្រមូលផ្ដុំរដ្ឋបាលធានាឲ្យមានការស្មើភាពគ្នារវាងពលរដ្ឋនិងពលរដ្ឋ

-មធ្យោបាយសកម្មសម្រាប់គាបសង្កត់ទាំងឡាយ គឺស្ថិតនៅក្នុងដៃរដ្ឋបាលកណ្ដាល

-កាត់បន្ថយការចំណាយធនធានហិរញ្ញវត្ថុនិងសម្ភារៈ

-ពង្រឹងការឯកភាពជាតិដោយសារការណែនាំដូចគ្នាក្នុងដែនដីទាំងមូល

-រដ្ឋអាចក្តាប់ស្ថានការណ៍ទាំងអស់នៅទូទាំងប្រទេសទាំងនយោបាយ និងសន្តិសុខជាតិ។

**ក-៣-គុណវិបត្តិរបស់ប្រព័ន្ធមជ្ឈការ**

នៅក្នុងការគ្រប់គ្រងតាមបែបមជ្ឈការវាផ្តល់ផលវិបាកមួយចំនួនផងដែរដូចជា៖

-ធ្វើឲ្យដំណើរការរដ្ឋបាលកណ្តាលមានការលំបាក និងបន្ទុកធ្ងន់ធ្ងរពេក

-ជាមធ្យោបាយសម្រាប់គាបសង្កត់ខាងនយោបាយ

-គម្រោងផែនការអភិវឌ្ឍនានាមិនអាចឆ្លើយតបនឹងតម្រូវការរបស់ថ្នាក់មូលដ្ឋាន

-របបគ្រប់គ្រងបែបមជ្ឈការនេះអាចនាំមកនូវអំពើផ្តាច់ការកាន់តែច្រើននៅគ្រប់ទីកន្លែង។

**ខ-ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ**

ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ គឺជាប្រព័ន្ធគ្រប់គ្រងមួយដែលរដ្ឋបាលកណ្តាលធ្វើការផ្ទេរអំណាច និងការទទួលខុសត្រូវមួយចំនួនឲ្យទៅអាជ្ញាធរមូលដ្ឋានចាត់ចែងបម្រើផលប្រយោជន៍ផ្ទាល់ របស់មូលដ្ឋាននោះ។

វិមជ្ឈការមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់គុណភាពនៃជីវភាពរស់នៅ និងការផ្តល់ជូនឱកាសកាន់តែច្រើនឡើងដល់

ប្រជាពលរដ្ឋដើម្បីសម្រេចលើជោគវាសនាអនាគតរបស់ខ្លួន ដោយខ្លួនឯងនិងថែមទាំងជានាឲ្យមានការអភិវឌ្ឍមួយប្រកប ដោយនិរន្តភាពព្រមទាំងការផ្តល់សេវាកម្មនានាជាមូលដ្ឋាន។

អំណាចរដ្ឋបាលក្នុងប្រព័ន្ធនេះ មានការទទួលស្គាល់ នៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ ដូចជាអំណាចរបស់ក្រុមប្រឹក្សារាជ ធានី ខេត្ត ក្រុង ស្រុក ខណ្ឌសុទ្ធតែជាអំណាចស្វ័យសម្រេចក្នុង ដែនសមត្ថកិច្ចរបស់ខ្លួនហើយមានការទទួលស្គាល់ដោយច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។

ចំណែកសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មាន ការទទួលស្គាល់ដោយច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ដែរ។ មានលក្ខខណ្ឌមួយចំនួនដើម្បីចាត់ទុកជាប្រព័ន្ធវិមជ្ឈការបានលុះ ត្រាតែ៖

-មានក្រុមប្រឹក្សាតំណាងឲ្យអាជ្ញាធរនៃអំណាចនៅថ្នាក់ ក្រោមជាតិ។ ក្រុមប្រឹក្សានេះកើតឡើងដោយការបោះឆ្នោតជាសាកល ឬអសាកល។

-មានថវិកាស្វ័យ័តសម្រាប់បម្រើការអភិវឌ្ឍមូលដ្ឋាន

-មានសិទ្ធិ និងអំណាចស្វយ័តក្នុងការសម្រេចលើបញ្ហា អ្វីមួយក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន។ ការផ្តល់ស្វ័យភាពដោយ អំណាចរដ្ឋបាលកណ្តាលនេះ នៅតែអមទៅដោយការត្រួតពិនិត្យ មើលខ្លាំង ឬតិចពីរដ្ឋអំណាចកណ្តាលដែលការត្រួតពិនិត្យនេះគេហៅ

ថាអាណាព្យាបាលដែលប្រែប្រួលទៅតាមស្ថានការណ៍នៃពេលវេលា។ ការត្រួតពិនិត្យមានពីរ គឺការត្រួតពិនិត្យតាមឋានានុក្រម និងការត្រួតពិនិត្យកាលានុភាព។

**ខ-១-និយមន័យ**

***តាមនិរុត្តិសាស្ត្រ**

ពាក្យ **វិមជ្ឈការ**កើតចេញមកពីពាក្យ« **វិ**» បូកនឹង« **មជ្ឈការ**» ។ « **វិ**» មានន័យថា « **មិន មិនមែន ឥត ពុំ**» ឯ « **មជ្ឈការ**» មានន័យថា « **អំណាចកណ្តាល**» ។ សរុបមក **វិមជ្ឈការ** មានន័យថា ការរំលែកអំណាច គឺជាប្រព័ន្ធអភិបាលកិច្ច សំដៅអនុញ្ញាតឲ្យចំពោះសមូហភាពមនុស្សជាតិមួយ (**ការរំលែកអំណាចខាងដែនដី**) ឬចំពោះកិច្ចការណាមួយ (**ការរំលែកខាងកិច្ចការបច្ចេកទេស**) ដើម្បីអភិបាលដោយខ្លួនឯង ក្រោមការត្រួតពិនិត្យរបស់រដ្ឋ ដោយផ្តល់នូវបុគ្គលិកលក្ខណៈគតិយុត្ត អំណាចផ្ទាល់ខ្លួន និងធនធាន។ រដ្ឋបាលវិមជ្ឈការនៅកម្ពុជាធ្លាប់មានប្រវត្តិ និងបទពិសោធន៍ក្នុងប្រព័ន្ធនេះជិត៨៥ឆ្នាំ គឺពីឆ្នាំ ១៨៨៩ ដល់ឆ្នាំ១៩៧៤[114]។

***តាមវិស័យច្បាប់៖**

ប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ( Decentralization )គឺជាប្រព័ន្ធមួយដែលរដ្ឋបាលកណ្តាលធ្វើការផ្ទេរអំណាចនិងផ្ទេរការទទួល

114 សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ៤២៩

ខុសត្រូវលើកិច្ចការមួយចំនួនឲ្យដល់ថ្នាក់មូលដ្ឋានចាត់ចែងបម្រើផលប្រយោជន៍ផ្ទាល់របស់មូលដ្ឋាននោះ។

វិមជ្ឈការមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់គុណភាពជីវភាពរស់នៅ និងជាការផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសកាន់តែច្រើនដើម្បីសម្រេចលើជោគវាសនាអនាគតរបស់ខ្លួនដោយខ្លួនឯង ព្រមទាំងជានាំឲ្យមានកិច្ចអភិវឌ្ឍន៍មួយប្រកប ដោយនិរន្តភាពរួមទាំងការផ្តល់សេវានានាជាមូលដ្ឋាន។

**ដើម្បីធ្វើឲ្យមានវិមជ្ឈការពិតប្រាកដនោះ ចាំបាច់ត្រូវឲ្យមាន៖**

ឯករាជ្យភាពនៃអំណាចមូលដ្ឋានចំពោះអំណាចកណ្តាល ប៉ុន្តែគេក៏មិនត្រូវឲ្យមានឯករាជ្យពេញលេញពេកនោះទេ ព្រោះប្រសិនបើមានឯករាជ្យភាពពេញលេញបណ្តាលឲ្យធ្លាក់ចូលទៅក្នុងសម្ព័ន្ធភាពនិយមពោលគឺការផ្តាច់ខ្លួនដើម្បីទាមទារយកឯករាជ្យក្នុងមណ្ឌលរបស់ខ្លួន។ ហេតុនេះ ការកាត់បន្ថយអំណាចរដ្ឋបាលកណ្តាលច្រើនតែអមទៅដោយការត្រួតពិនិត្យខ្លាំង ឬតិចពីរដ្ឋអំណាចកណ្តាល។ ការត្រួតពិនិត្យនេះគេឈ្មោះថា **អាណាព្យាបាលរដ្ឋបាល** វាប្រែប្រួលទៅតាមស្ថានការនៃពេលវេលា។

ទាក់ទងនឹងការអនុវត្តវិធានការទប់ស្កាត់ជំងឺឆ្លងកូវីដ-១៩ (COVID-19)ខ្ញុំសូមកាត់ត្រាទាំងស្រុងនូវសារសំឡេងសម្តេចនាយករដ្ឋរដ្ឋមន្ត្រីដើម្បីទុកជាឧទាហរណ៍មួយចំពោះអ្នកសិក្សា។..ជូនឯកឧត្តមលោកជំទាវអភិបាលខេត្ត-រាជធានីរាជរដ្ឋាភិបាលបានបិទបញ្ចប់

ក្នុងការបិទទីក្រុងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ក៏ដូចជាការបិទបញ្ចប់សម្រាប់ការធ្វើដំណើរឆ្លងខេត្តតាំងពីរយៈពេលមុនមកម្ល៉េះ។ ក្នុងពេលបិទបញ្ចប់នេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់អំណាចដល់អភិបាលខេត្ត-រាជធានីដើម្បីគ្រប់គ្រងសភាពការណ៍តាមការជាក់ស្តែង។ ប៉ុន្តែខ្ញុំបែរជាពិនិត្យឃើញថា នៅក្នុងខេត្តខ្លះបានដាក់បំរាមរហូតទៅដល់កម្រិតប្រជាពលរដ្ឋកម្ពុជាខ្លួនឯងដែលចូលទៅកាន់ខេត្តខ្លួនចាំបាច់ត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ នេះមិនខុសពីការដែលយើងបង្កើតរដ្ឋនៅក្នុងរដ្ឋនោះទេដែលដូចជាខ្ញុំត្រូវធ្វើដំណើរទៅឥណ្ឌូនេស៊ីត្រឡប់មកវិញត្រធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ បើធ្វើយ៉ាងដូច្នេះ វាស្មើនឹងការបិទរដ្ឋឡើងវិញ បិទប្រទេសឡើងវិញ។ ឧទាហរណ៍ ប្រជាជនត្រូវឆ្លងកាត់នៅខេត្តនោះ ចាំបាច់ត្រូវតែធ្វើចត្តាឡីស័កនៅខេត្តមួយនោះតែម្តង។ យើងត្រូវបន្តគ្រប់គ្រង និងការធ្វើចត្តាឡីស័កចំពោះអ្នកដែលសង្ស័យថាមានហានីភ័យអាចនឹងមានកូវីដ-១៩ ដើម្បីទៅយកសំណាក ហើយឲ្យធ្វើចត្តាឡីស័ក ប៉ុន្តែមិនមែនធ្វើគ្រប់មនុស្សទាំងអស់ដែលឆ្លងកាត់ខេត្តរបស់ខ្លួននោះទេ។ បើធ្វើយ៉ាងដូច្នេះ ប្រជាជនហាក់បីដូចជានៅក្នុងទ្រុងដដែល អញ្ជើងសុំឲ្យឯកឧត្តម លោកជំទាវអភិបាលខេត្តណា ដែលបានចេញសេចក្តីសម្រេចហួសទៅហើយត្រូវកែប្រែនូវសេចក្តីសម្រេចនោះវិញជាបន្ទាន់ដើម្បីសម្រួលឲ្យមានការចរាចរណ៍សម្រាប់ប្រជាពលរដ្ឋ ហើយខ្ញុំនិយាយនេះមិនមែនសំដៅមិនឲ្យទប់ស្កាត់ចំពោះអ្នកដែលមានករណីសង្ស័យដែលយើងតម្រូវឲ្យយកសំណាក និងនាំទៅដល់ការធ្វើចត្តា

ឡីស័កដែលជៀសវាងមិនបាននោះទេ។ ក៏ប៉ុន្តែការធ្វើនេះគឺសំដៅ ដើម្បីឲ្យកែសម្រួលសេចក្ដីសម្រេចដើម្បីបើកឲ្យប្រជាពលរដ្ឋអាចធ្វើ ដំណើរបាន បើមិនដូច្នេះទេគ្រប់ខេត្តនីមួយៗដាក់ធ្វើចត្តាឡីស័ក១៤ ថ្ងៃ វាមិនខុសពីចែកកម្ពុជាទៅជា២៥ប្រទេសឆ្លងពីខេត្តមួយចូលខេត្ត មួយធ្វើចត្តាឡីស័ក ចេញពីខេត្តនោះមកខេត្តនេះវិញធ្វើចត្តាឡីស័ក បើដូច្នោះតើយើងរស់របៀបម៉េច?អញ្ចឹងខ្ញុំសុំស្នើឲ្យឯកឧត្ដម អភិបាលខេត្ត-រាជធានីឯកឧត្ដម លោកជំទាវអភិបាលខេត្ត-រាជធានី ត្រូវធ្វើការកែសេចក្ដីសម្រេចជាបន្ទាន់របស់ខ្លួន បើមិនដូច្នោះ យើង គ្រប់គ្រងប្រជាជននៅក្នុងតែខេត្តរបស់ខ្លួន ហើយប្រជាជនខេត្តដទៃ ដែលទៅរកស៊ី ធ្វើការចូលទៅក្នុងខេត្តរបស់ខ្លួនត្រូវតែធ្វើចត្តាឡីស័ក តើប្រជាជនខ្លួនត្រូវចេញទៅខេត្តដទៃក៏ត្រូវធ្វើចត្តាឡីស័កបើដូច្នោះ ប្រជាជនត្រូវធ្វើចត្តាឡិស័កតូទាំងប្រទេសតែម្ដង វាមិនខុសពីការ ដែលបិទប្រទេស បិទក្រុងបិទស្អីរយៈពេលកន្លងទៅទេ។ ហ្នឹងធ្វើឲ្យ គាំងទៅដល់ក្បាលម៉ាស៊ីននៃដំណើរការសេដ្ឋកិច្ចសង្គមរបស់ប្រជា ជនតែម្ដង។ ខ្ញុំគាំទ្រឲ្យអនុវត្តនូវវិធានការដូចជាខាងភ្នំពេញៗគឺជា តំបន់ក្ដៅត្រូវអនុវត្តនូវវិធានការទន់ភ្លន់ ម៉ឺងម៉ាត់ តែទន់ភ្លន់ ខេត្តព្រះ សីហនុក៏ម៉ឺងម៉ាត់ទន់ភ្លន់ ក៏ប៉ុន្តែដូចជាខាងខេត្ត ដូចជាមានរត់អក្សរ នៅតាមនេះ គឺមានខេត្តព្រៃវែង ហើយខេត្តត្បូងឃ្មុំ ខ្ញុំបានជួបឯក ឧត្ដមអភិបាលខេត្តត្បូងឃ្មុំបានសួរបញ្ជាក់ ហើយមិនចាំបាច់ករណី លើកលែង មិនលើកលែងអីទេ យើងយកករណីតែអ្នកដែលសង្ស័យ បានហើយដើម្បីទៅយកសំណាក និងធ្វើចត្តាឡីស័ក។ ពួកគាត់ពិត

ជាចង់បានការធ្វើយ៉ាងដូច្នេះ ប៉ុន្តែបែរជាយើងថា ត្រូវធ្វើចត្តាឡីស័ក ហើយលើកលែងករណីដូចជាអ្នកចាក់ថ្នាំបានពីរដង ឬក៏ករណីនេះករណីនោះ យើងមិនអាចធ្វើអញ្ចឹងបានទេ យើងបើកឲ្យការធ្វើដំណើរធម្មតា ប៉ុន្តែត្រូវតែត្រួតពិនិត្យធ្វើវិធានការសុខាភិបាលទៅលើអ្នកដែលមានករណីសង្ស័យឬក៏ករណីមួយចំនួនផ្សេងទៀតទៅតាមការប្រគល់សិទ្ធិអំណាចឲ្យអភិបាលខេត្ត-រាជធានី។ បើមិនដូច្នោះ ប្រជាពលរដ្ឋរបស់យើង បើកដូចជាមិនបើក រឿងនេះគឺត្រូវតែកែសម្រួលជាចាំបាច់ហើយសុំរាយការណ៍ជូនតាមគ្រុប(ក្រុម)របស់រាជរដ្ឋាភិបាលត្រឡប់មកវិញហើយរបស់គ្រុបរវាងនាយករដ្ឋមន្ត្រីជាមួយនិងអភិបាលខេត្ត-រាជធានី ឲ្យខ្ញុំត្រឡប់មកវិញ តើខេត្តណាខ្លះបានធ្វើ និងខេត្តណាខ្លះដែលមិនបានធ្វើ ប៉ុន្តែខ្ញុំដូចជានៅឃើញថា មានតែខេត្តព្រៃវែង ហើយនិងខេត្តត្បូងឃ្មុំតែប៉ុណ្ណោះដែលចេញ ប៉ុន្តែខ្ញុំមិនដឹងថា តើខេត្តព្រៃវែងធ្វើប៉ុណ្ណា? ឯខេត្តត្បូងឃ្មុំ ខ្ញុំបានជួបអភិបាលខេត្តរួចហើយ។ អញ្ចឹងសរុបមក ឯកឧត្តម លោកជំទាវចាត់វិធានការជាបន្ទាន់ដើម្បីកែសម្រួលសម្រេចរបស់ខ្លួនដើម្បីកុំឲ្យសេចក្តីសម្រេចនោះជ្រុលហួសនាំទៅដល់ការរំខានទៅដល់ជីវភាពរបស់ប្រជាពលរដ្ឋទៅវិញ ដែលវាសម្លាប់សេដ្ឋកិច្ចតែម្តង។ ដល់ពេលវេលាដែលប្រជាជនធ្វើស្រែចំការធ្វើដំណើរទៅនេះដល់នោះ យើងបានទប់ស្កាត់អស់រយៈពេលបីអាទិត្យរួចមកហើយៗមិនមែនទូទៅៗទៀត។ ក៏ប៉ុន្តែវាមានការលំបាកណាស់ទៅហើយ។ អញ្ចឹងសុំឯកឧត្តមលោកជំទាវមេត្តាមើលព្រៃទាំងមូលប្រសើរជាងមើលឈើមួយដើមៗដើម្បីដោះស្រាយបញ្ហាកូវីដនៅ

ក្នុងខេត្តរបស់ខ្លួន។ សុំមើលឲ្យបានគ្រប់ជ្រុងជ្រោយ គ្រប់ទិដ្ឋភាពសេដ្ឋកិច្ច សង្គម និងបញ្ហានយោបាយទូទៅ។សូមអរគុណ[115]។ ការនេះ សបញ្ជាក់ឲ្យឃើញថា វិមជ្ឈការក្តី វិសហមជ្ឈការក្តី ថ្នាក់ទទួលបញ្ជា ឬថ្នាក់ក្រោមជាតិមិនអាចធ្វើកិច្ចការអ្វីមួយតាមតែការយល់ឃើញរបស់ខ្លួនក៏ដូចជាដើម្បីតែប្រយោជន៍ក្នុងតំបន់របស់ខ្លួន គ្រប់គ្រងដាច់ដោយឡែកដោយកាត់ផ្តាច់ទាំងស្រុងផលប្រយោជន៍ជាតិទាំងមូលនោះទេ។ ផ្ទុយទៅវិញត្រូវធ្វើអ្វីៗគ្រប់យ៉ាងគិតទាំងប្រយោជន៍រួម និងប្រយោជន៍ទូទៅ ជាពិសេសឲ្យស្របនឹងសេចក្តីសម្រេចរបស់ថ្នាក់លើពុំនោះសោតសេចក្តីសម្រេចរបស់ថ្នាក់ក្រោមនោះមិនបានរឹងមាំទេ។ បន្ថែមពីលើនេះទៀត កិច្ចការបីយ៉ាងដែលរដ្ឋកណ្តាលមួយមិនអនុញ្ញាតឲ្យអំណាចវិមជ្ឈការ ឬវិសហមជ្ឈការធ្វើដោយឯករាជ្យបានគឺទី១ ការផលិត ឬទិញអាវុធជាតិផ្ទុះ និងការកេណ្ឌកម្លាំងកងទ័ពដែលមិនមានបទបញ្ជាពីអំណាចកណ្តាល ទី២ ការបោះពុម្ពរូបិយវត្ថុ និងទី៣ការពុម្ពលិខិតឆ្លងដែនដើម្បីប្រជាពលរដ្ឋក្នុងតំបន់ប្រើប្រាស់។

### ខ-២-គុណសម្បត្តិរបស់ប្រព័ន្ធវិមជ្ឈការ

[115] ប្រសាសន៍ដ៏ខ្លង់ខ្លស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថ្លែងទៅកាន់ឯកឧត្តម លោកជំទាវអភិបាលខេត្តតាមបណ្តាញសង្គមតេឡេក្រាមទាក់ទងនឹងវិធានការទប់ស្កាត់ការឆ្លងជំងឺរាតត្បាតកូវីដ១៩ កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១។

ប្រព័ន្ធវិមជ្ឈការ ធ្វើឲ្យមានតម្លៃនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យកម្រិតថ្នាក់ជាតិដោយអនុញ្ញាតឲ្យមានការចូលរួមពីប្រជាជន ឬអ្នកតំណាងរបស់មូលដ្ឋានក្នុងកិច្ចការនយោបាយ។ ប្រព័ន្ធនេះ បានផ្តល់ផលប្រយោជន៍ជាច្រើនទៀតដូចជា៖

-ពង្រឹងការឆ្លើយតបឲ្យបានរហ័សរបស់ស្ថាប័នរដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ

-បង្កើននូវលំហូរព័ត៌មានរវាង  រដ្ឋាភិបាល និងប្រជាពលរដ្ឋ

-ធ្វើឲ្យសម្រេចបាននូវកិច្ចប្រឹងប្រែងថ្មីផ្នែកនយោបាយ

-ជំរុញការទទួលខុសត្រូវឲ្យកាន់តែប្រសើរឡើងព្រមទាំងទប់ស្កាត់បានច្រើននូវភាពលំអៀង

-ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-កាត់បន្ថយការចំណាយដែលមិនចំទិសដៅ

-ជំរុញការទទួលខុសត្រូវឲ្យកាន់តែប្រសើរឡើងព្រមទាំងទប់ស្កាត់បាននូវភាពលំអៀង

-មានការចូលរួមពីប្រជាពលរដ្ឋក្នុងការសម្រេចអ្វីមួយដែលជាប្រយោជន៍រាស្ត្រតាមទីកន្លែង

-នាំឲ្យមានការអភិវឌ្ឍរីកចម្រើនជីវភាពរស់នៅតាមទីកន្លែង។

**ខ-៣-គុណវិបត្តិរបស់ប្រព័ន្ធវិមជ្ឈការ**

-ធ្វើឲ្យបាត់បង់នូវឯកភាពជាតិ និងសាមគ្គីភាពណែជាតិទាំងមូល

-ធ្វើឲ្យបែកខ្ញាយនូវឯកភាពដ៏ចាំបាច់របស់រដ្ឋបាលដោយសារការអនុវត្តវិធានការរដ្ឋបាលខុសៗគ្នាទៅតាមមណ្ឌលនៃមូលដ្ឋាន

-ការប្រគួតប្រជែងគ្នារវាងមូលដ្ឋាននាំឲ្យប៉ះពាល់ដល់សមូហភាពដែលដីមួយ

-អាជ្ញាធរតាមមូលដ្ឋានខ្វះខាតនូវសមត្ថកិច្ចបច្ចេកទេស ហើយនិងបទពិសោធន៍

-អំណាចកណ្តាលអាចចុះខ្សោយដោយសារតែរដ្ឋក្តាប់ស្ថានការណ៍មិនបានទាំងស្រុង

-មានភាពមិនស្មើរគ្នាខ្លះក្នុងរឿងដូចគ្នាពីកន្លែងមួយទៅកន្លែងមួយប្រព័ន្ធវិមជ្ឈការនេះ ត្រូវបានចែកចេញជាពីរប្រភេទគឺ៖

**ខ-៣-១-វិមជ្ឈការដែនដី**

វិមជ្ឈការដែនដី យើងឃើញមានការអនុវត្តអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាដើម។

**ខ-៣-២-វិមជ្ឈការបច្ចេកទេស**

អាជ្ញាធរស្វ័យតសម្រាប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាលក្រុមហ៊ុនរដ្ឋក្រុមហ៊ុនចម្រុះរដ្ឋជាដើមជាស្ថាប័នអនុវត្តនៃប្រព័ន្ធខាងលើ។

## ២-ប្រព័ន្ធគ្រប់គ្រងបែបវិសហមជ្ឈការ

### ២-១-និយមន័យ

ប្រព័ន្ធគ្រប់គ្រងតាមបែប**វិសហមជ្ឈការ**( De-concentration ) គឺជាប្រព័ន្ធមួយដែលរដ្ឋបាល កណ្តាលធ្វើការរំលែកអំណាច និង រំលែកការទទួលខុសត្រូវមួយផ្នែកលើកិច្ចការរដ្ឋឲ្យទៅអាជ្ញាធរថ្នាក់ក្រោមអនុវត្តក្នុងនាមជាភ្នាក់ងារមួយរបស់រដ្ឋបាលកណ្តាលដើម្បី បម្រើផលប្រយោជន៍របស់ជាតិ។ គោលការណ៍ទូទៅនៃការគ្រប់គ្រងតាមបែបវិសហមជ្ឈការ គឺការរំលែកអំណាចខ្លះទៅឲ្យរដ្ឋអំណាចថ្នាក់ក្រោមជាតិដែលស្ថិតនៅជិតប្រជាពលរដ្ឋ។ ការបែងចែកអំណាចនេះ ជាវិធានការមួយ ដែលអាចធ្វើឲ្យរដ្ឋបាលកាន់តែនៅជិតប្រជាពលរដ្ឋ ហើយធ្វើការសម្រេចចិត្ត។ ប្រពន្ធ័គ្រប់គ្រងវិសហម្ឈការជាប្រពន្ធ័មួយដែលរដ្ឋបាលកណ្តាលធ្វើការបែងចែកអំណាច និងការទទួលខុសត្រូវខ្លះទៅឲ្យថ្នាក់ក្រោមជាតិអនុវត្តកិច្ចការក្នុងនាមជាភ្នាក់ងាររបស់រដ្ឋបាលកណ្តាលដើម្បីបម្រើផលប្រយោជន៍របស់ជាតិទាំងមូល។ ប្រពន្ធ័នេះជួយសម្រួលលបន្ទុកការងាររបស់រដ្ឋបាលកណ្តាល ហើយផ្តល់ភារកិច្ចរបស់ថ្នាក់លើទៅឲ្យអាជ្ញាធរមូលដ្ឋានជាអ្នកជួយដោះស្រាយរាល់បញ្ហាជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងរបបគ្រប់គ្រងតាមបែបវិសហមជ្ឈការនេះ គេធ្វើឡើងគ្រាន់តែរំលែកការងារមួយចំនួនដែលថ្នាក់លើធ្វើមិនទាន់ ឬមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីដោះស្រាយ ទៅថ្នាក់ក្រោមជួយធ្វើ

ជំនួសតាមការបញ្ជា ឬកំណត់ឲ្យយ៉ាងច្បាស់លាស់ដែលហៅថា ប្រតិភូកម្មអំណាច។ ទោះបីយ៉ាងណា អំណាចនៅតែស្ថិតក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើជានិច្ច។

ប្រតិភូកម្ម សំដៅទៅលើការបែងចែកអំណាចកណ្តាលតាមរយៈលិខិតផ្ទេរសិទ្ធិពីមន្ត្រីថ្នាក់លើឲ្យទៅមន្ត្រីថ្នាក់ក្រោមធ្វើជំនួស និងត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើ។ ជាគោលការណ៍ការធ្វើប្រតិភូកម្មនេះ ផ្តល់ឲ្យតែអ្នកដែលមានឋានៈធំជាងគេនៃស្ថាប័ន ឬអង្គការក្រោមបង្គាប់តែប៉ុណ្ណោះ។

ដើម្បីបន្ថយផលអាក្រក់របស់ការប្រមូលផ្តុំរដ្ឋបាលរដ្ឋជាច្រើននៅលើពិភពលោកបានអនុវត្តរូបមន្តការពង្រាយអំណាចរដ្ឋបាលពោលគឺ **វិសហមជ្ឈការ**។ វិសហមជ្ឈការ មានគោលបំណងកែលំអរការអនុវត្តមុខងាររបស់ជាតិដោយនាំយកមុខងារនេះ និងកិច្ចការទាំងឡាយរបស់រដ្ឋឲ្យកាន់តែជិតប្រជាពលរដ្ឋ។ ដើម្បីធ្វើឲ្យបានសម្រេចជាក់ស្តែងនូវការរំលែកអំណាចត្រូវមានលក្ខណៈសម្បត្តិបី៖

ក-ការទទួលស្គាល់បុគ្គលិកលក្ខណៈភាពជាគត្តិយុត្តដោយឡែកៗពីគ្នា ដើម្បីជាប្រយោជន៍ឲ្យអាជ្ញាធររំលែកអំណាចបង្កបង្កើតឡើង ព្រោះថាបើមិនយ៉ាងដូច្នេះទេ អាជ្ញាធរដែលបង្កបង្កើតនោះ នឹងត្រូវបញ្ចេញមកពីអាជ្ញាធរកណ្តាលមិនខាន។

ខ. ភាពចាំបាច់ត្រូវមានអាជ្ញាធរឯករាជ្យពីអំណាចកណ្តាល។

គ. អាជ្ញាធរវិសហមជ្ឈការត្រូវតែមានស្វ័យភាពមួយចំនួននូវអំណាចចេញសេចក្ដីសម្រេច។

**២-២-គុណសម្បត្តិ**

វិសហមជ្ឈការក្រៅពីមានផលប្រយោជន៍ល្អដូចប្រព័ន្ធ វិមជ្ឈការ ប្រព័ន្ធនេះនៅមានប្រយោជន៍ដោយឡែកៗផ្សេងគ្នាទៀតដូចជា៖

-ប្រព័ន្ធនេះបានជួយសម្រួលកិច្ចការអនុវត្តការងាររបស់រដ្ឋអំណាចកណ្ដាល ដោយបន្ធូរបន្ថយការងាររបស់រដ្ឋបាលកណ្ដាល ហើយធ្វើការណែនាំការងារបានឆាប់រហ័ស។

-ការរំលែកអំណាចមានលទ្ធភាពច្រើនក្នុងកិច្ចការតំបន់ដើម្បីត្រិះរិះរកដំណោះស្រាយឲ្យសម្រេចជាស្ថាពរក្នុងលំដាប់លំដោយរបស់មូលដ្ឋាន។ ដូច្នេះអំណាចមានភាពងាយស្រួលដោយមិនបាច់លំបាកដោះស្រាយកិច្ចការមូលដ្ឋានដែលគេក្ដាប់មិនបានសព្វគ្រប់។

-ប្រព័ន្ធនេះបង្កើតប្រកបដោយផលប្រយោជន៍នូវអំណាចតាមមូលដ្ឋាន ហើយបើកលទ្ធភាពឲ្យតំណាងទាំងនោះដោះស្រាយបណ្ដាបញ្ហាដោយពិចារណាទៅតាមភាពជាក់ស្ដែងទៅតាមកន្លែង។

-ការរំលែកអំណាចនេះជាវិធីធ្វើឲ្យការគ្រប់គ្រងដែនដីបានល្អប្រសើរ។ ប្រព័ន្ធនេះអាចជួយសម្រួលកិច្ចការអនុវត្តការងាររបស់រដ្ឋអំណាចកណ្ដាល ហើយបន្ធូរការងាររបស់រដ្ឋអំណាចកណ្ដាល ដោយអាចធ្វើការណែនាំការងារបានឆាប់រហ័ស។

-ការបែកចែកអំណាច ធ្វើឲ្យមានលទ្ធភាពច្រើនក្នុងកិច្ចការតំបន់ ដើម្បីរិះរកដំណោះស្រាយឲ្យបានសម្រេចជាស្ថាពរក្នុងលំដាប់លំដោយរបស់មូលដ្ឋាន។ ដូចច្នេះអំណាចនេះមានភាពងាយស្រួលដោយមិនចាំបាច់ពិបាកដោះស្រាយកិច្ចការមូលដ្ឋានដែលគេក្តាប់ការមិនបានសព្វគ្រប់។

-ប្រពន្ធ័នេះក៏បង្កើតនូវអំណាចមូលដ្ឋាន បើកលទ្ធភាពឲ្យតំណាងទាំងនោះ ដោះស្រាយបញ្ហាដោយការពិចារណាទៅតាមទីកន្លែងជាក់ស្តែងនីមួយៗ។

-ការបែកចែកអំណាចនេះជាវិធីមួយដែលធ្វើឲ្យការគ្រប់គ្រងដែនដីបានល្អប្រសើរ ទទួលខុសត្រូវ និងមានគុណភាពការងារល្អ។

**២-៣-គុណវិបត្តិ**

-ធ្វើឲ្យរដ្ឋបាលកណ្តាល ក្តាប់មិនបានល្អនូវអំណាចរបស់ខ្លួនការងារខ្លះពិនិត្យតាមការតែរបាយការណ៍របស់ថ្នាក់ក្រោមដែលបានផ្តល់ឲ្យ ដោយពុំបានជ្រាបពីភាពពិតប្រាកដនៅមូលដ្ឋាន។

-ភ្នាក់ងាររាជការដែលតំណាងឲ្យរដ្ឋ មិនអាចមានទស្សនៈវិស័យក្នុងការអភិវឌ្ឍន៍ឲ្យលើសពីអ្វីដែលថ្នាក់លើប្រគល់ជូនឡើយ គឺត្រូវធ្វើតាមតែបញ្ជារពីថ្នាក់លើប្រគល់ឲ្យតែប៉ុណ្ណោះ។

-នាំឲ្យមានការអនុវត្តពុំចំទិសដៅទៅ និងតម្រូវការរបស់ពលរដ្ឋតំបន់នីមួយៗនោះ។

## ៣-សហគ្គិភាពរវាងវិមជ្ឈការ និងវិមជ្ឈការ

វិមជ្ឈការមិនប៉ះពាល់ឲ្យខូចអំណាចរដ្ឋទេ។ ផ្ទុយទៅវិញវាបន្ត អនុវត្តអំណាចគ្រប់គ្រងព្រមទាំងពង្រឹងបានប្រសិទ្ធភាពរដ្ឋផ្សេងៗ។ ប្រព័ន្ធរដ្ឋបាលមួយដែលប្រមូលផ្តុំពេកមិនអាចស្ថិតស្ថេរបានទេ។ប្រសិនបើអ្វីៗទាំងអស់ត្រូវតែសម្រេចដោយថ្នាក់កណ្តាល ម៉ាស៊ីនរដ្ឋបាលត្រូវរាំងស្ទះយ៉ាងឆាប់។

រដ្ឋទំនើបមួយ ទោះបីខ្លាំងហើយប្រមូលផ្តុំត្រូវតែទុកកន្លែងឲ្យវិសហមជ្ឈការដែរដោយរំលែកអំណាចមួយចំនួនទៅឱ្យថ្នាក់រដ្ឋបាលផ្សេងៗទៀតដែលត្រូវសម្រេចក្រៅអំណាចកណ្តាល។

ដូចនេះ វិសហមជ្ឈការជាបែបបទមួយនៃមជ្ឈការ ដែលចាំបាច់សម្រាប់កែសម្រួលការខ្វះខាតរបស់មជ្ឈការ។ រដ្ឋបាលកណ្តាលលែងទើសទែង និងការងារប្រមូលផ្តុំគ្រប់ជំពូកនោះនឹងទទួលផលល្អពីបែបបទប្រតិបត្តិការងារនេះដោយមិនមានកង្វល់។

វិសហមជ្ឈការ និងវិមជ្ឈការមិនដូចគ្នាទាំងស្រុងទេ។ ភាពខុសគ្នានៅត្រង់ថា វិសហមជ្ឈការ ទោះបីបានទទួលការងារពីអាជ្ញាធរកណ្តាល និងមានស្វ័យភាពថវិកា( budget autonomy ) មែន ក៏ប៉ុន្តែវាមិនមានស្វ័យភាពក្នុងការគ្រប់គ្រង( administrative autonomy ) ទេ។

ចុងក្រោយនេះមានន័យថា អាជ្ញាធរគ្រប់គ្រងនៅក្នុងរដ្ឋបាលវិសហមជ្ឈការត្រូវបានតែងតាំងឡើងដោយអាជ្ញាធររដ្ឋបាលកណ្តាល ចំណែកឯអាជ្ញាធរគ្រប់គ្រងនៅក្នុងរដ្ឋបាលវិមជ្ឈការត្រូវតែងតាំង

ដោយការបោះឆ្នោតជ្រើសតាំងពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ហេតុអ្វីចាំបាច់ធ្វើវិសហមជ្ឈការ?**

មូលហេតុចាំបាច់ដែលនាំឲ្យមានការធ្វើវិសហមជ្ឈការគឺ៖

**ក-ដោះស្រាយបញ្ហា៖** ដើម្បីដោះស្រាយបញ្ហាដែលកើតមកពីគុណវិបត្តិនៃមជ្ឈការសុទ្ធសាធពេករូបមន្តមួយថ្មី គឺធ្វើយ៉ាងណាឱ្យមានសហត្ថិភាពវិមជ្ឈការនៅគ្រប់ទីកន្លែង។ និយាយឲ្យងាយយល់ គឺថាអំណាចរាស្ត្រ និងអំណាចរដ្ឋត្រូវនៅជាមួយគ្នាដើម្បីជួយគ្នាទៅវិញទៅមក។ ឧទាហរណ៍ ដូចជារដ្ឋជួយឃុំ ឃុំជួយរដ្ឋ។

**ខ-ជួយគ្នាទៅវិញទៅមក៖** រដ្ឋជួយឃុំក្នុងរឿងបច្ចេកទេសគ្រប់វិស័យ (ពន្យល់ច្បាប់ ផ្តល់បច្ចេកទេស និងមធ្យោបាយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស) និងក្នុងរឿងទំនាស់រវាងឃុំ និង ឃុំ ឬរវាងឃុំ និងអង្គការវិមជ្ឈការណាមួយ។ រដ្ឋដើរតួនាទី ជាអ្នកសម្របសម្រួល និងសម្រុះសម្រួល។ ឃុំជួយរដ្ឋ ក្នុងបញ្ហាទាំងឡាយដែលនៅក្នុងវិស័យរបស់រដ្ឋតាមការស្នើសុំពីរដ្ឋ (ជួយទារពន្ធជាឲ្យរដ្ឋ ឬធ្វើការសហការជាមួយរដ្ឋក្នុងគម្រោងអភិវឌ្ឍផ្សេងៗ)។

**គ-ទស្សនៈវិស័យ៖** ពេលណាគេជំរុញ វិមជ្ឈការឲ្យកាន់តែខ្លាំង(គឺថាអំណាចវិមជ្ឈការកាន់តែទូលំទូលាយ) គេត្រូវពង្រីកប្រព័ន្ធអំណាចវិសហមជ្ឈការឱ្យកាន់តែរីកសុះសាយ ទូលំទូលាយខ្លាំងឡើង

ជាមួយគ្នាដែរក្នុងគោលដៅសហត្ថិភាពមិនមែនដើម្បីជាមធ្យោបាយគាបសង្កត់ទេ[116]។

ប្រទេសបារាំងបានធ្វើពិសោធនូវគំនិតនេះរួចមកហើយ តាំងពីឆ្នាំ១៩៨២មកម្ល៉េះ។ ច្បាប់ចុះថ្ងៃទី២ ខែមីនា ១៩៨២ ពង្រីកអំណាច វិមជ្ឈការកាន់តែខ្លាំងធំឡើង ដោយបានលុបបំបាត់អំណាចអាណាព្យាបាលរបស់រដ្ឋលើសមូហវិមជ្ឈការទុកឱ្យតុលាការរដ្ឋបាលត្រួត ពិនិត្យជាបច្ឆាកាល( Posteriorité ) លើនីត្យានុកូលភាព។ ប៉ុន្តែ ទន្ទឹមនឹងច្បាប់នេះមានបទបញ្ញាចេញតាម “ ដេក្រេ” ចុះថ្ងៃទី១ ខែកក្កដា ១៩៩២ស្តីពី“ រដ្ឋធម្មនុញ្ញនៃវិសហមជ្ឈការ ” ដែលបានប្រគល់តួនាទីយ៉ាងសំខាន់ដល់លោក(អភិបាលខេត្ត)“ ប្រេហ្វេ” ក្នុងឋានៈជាតំណាងរដ្ឋក្នុងសមូហភាពដែនដី។

ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការគឺ**ភាពជាម្ចាស់**។ វិមជ្ឈការមានភាពជាម្ចាស់ចំណែកឯ វិសហមជ្ឈការ គ្មានភាពជាម្ចាស់ទេ គឺធ្វើអ្វីៗជាតំណាង ឬក្នុងនាមរាជរដ្ឋាភិបាលថ្នាក់លើ ដែលបានធ្វើប្រតិភូកម្មឱ្យ(ប្រតិភូកម្មគឺជាការផ្ទេរមុខងារការទទួលខុសត្រូវអំណាច និងធន្ធានុសិទ្ធិដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ)។ ការងារបែបវិសហមជ្ឈការមានដូចជា ការធ្វើបញ្ជីអត្រានុកូលដ្ឋាន (សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព) ជា

---

[116] សាយ បូរី៖ រដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ៤០៩

សមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលការងារនេះធ្វើឡើងក្នុងនាមក្រសួងមហាផ្ទៃ។ រីឯការងារចុះឈ្មោះបោះឆ្នោត ជាសមត្ថកិច្ចរបស់ឃុំ សង្កាត់ ដែលធ្វើឡើងក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្នុងករណីនេះ ភាពជាម្ចាស់ គឺជាអំណាច (អំណាចសំដៅលើមុខងារ បុគ្គលិក និងហិរញ្ញវត្ថុ) ពេញលេញដែលរដ្ឋបាលវិមជ្ឈការមានសិទ្ធិក្នុងការបំពេញការងាររបស់ខ្លួនឯងផ្ទាល់។ ប៉ុន្តែទាំងវិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយដើម្បីសម្រេចបាននូវគោលដៅរបស់រដ្ឋ ដែលចាំបាច់ត្រូវកំណត់អំពីវិសាលភាព ធនធាន និងមុខងារឱ្យបានច្បាស់លាស់។

**លក្ខណៈដូចគ្នា**

លក្ខណៈដូចគ្នានិងខុសគ្នារវាង វិមជ្ឈការ និង សហវិមជ្ឈការ គឺរដ្ឋបាលកណ្តាលត្រូវតែចែករំលែកអំណាចរបស់ខ្លួនទៅឲ្យរដ្ឋបាលមូលដ្ឋាន។

**លក្ខណៈខុសគ្នា**

លក្ខណៈខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ ៖

**ក-វិមជ្ឈការ**

-គ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ

-អង្គភាពអនុវត្ត គឺជានីតិបុគ្គលដាច់ដោយឡែក

-មានតំណាងចេញពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ

-ធ្វើជាអ្នកតំណាងឲ្យអ្នកបោះឆ្នោត

-ទទួលខុសត្រូវផ្ទាល់ចំពោះអ្នកបោះឆ្នោត និងប្រយោលចំពោះរាជរដ្ឋាភិបាល

-តម្រូវឲ្យមានការចូលរួមពីប្រជាពលរដ្ឋ ថវិកា ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិដាច់ដោយឡែក

-ទទួលអំណាយតាមរយៈការផ្ទេរពីថ្នាក់ជាតិ

-មានភាពជាម្ចាស់ការក្នុងការអនុវត្ត។

**ខ-វិសហមជ្ឈការ**

-ការទទួលខុសត្រូវរបស់រដ្ឋឲ្យទៅជិតប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋកាន់តែរហ័ស និងមានប្រសិទ្ធភាព

-អង្គភាពអនុវត្តមិនមែនជានីតិបុគ្គលដោយឡែកពីអង្គភាពថ្នាក់ជាតិទេ

-មន្ត្រីអនុវត្តកើតចេញពីការតែងតាំង

-ធ្វើជាអ្នកតំណាងឲ្យរដ្ឋាភិបាល

-ទទួលខុសត្រូវផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាលថ្នាក់ជាតិ

-មិនតម្រូវឲ្យមានការចូលរួមពីប្រជាពលរដ្ឋជាតិ

-ទទួលអំណាចតាមរយៈការធ្វើប្រតិភូកម្មពីថ្នាក់ជាតិ

-អនុវត្តក្នុងនាមស្ថាប័នដែលធ្វើប្រតិភូកម្មឱ្យ។

## ៤-សេចក្ដីសន្និដ្ឋាន

យោងតាមលទ្ធផលសិក្សាស្រាវជ្រាវ ពីដំណើរការគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ គឺមានដំណើរការល្អប្រសើរ ព្រោះសកម្មភាព សេវារបស់រដ្ឋបាលនេះ បានឆ្លុះបញ្ចាំងពីដំណើរការអភិវឌ្ឍស្ទើគ្រប់ផ្នែក(វិស័យ)ទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើឲ្យកាន់តែប្រសើរឡើងនូវវឌ្ឍនភាព និងភាពរីកចម្រើនទៅថ្ងៃអនាគតនៃជីវភាពប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដោយសារតែនយោបាយមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការបានធ្វើឲ្យប្រជាពលរដ្ឋ និងសហគមន៍ទាំងមូលមានភាពប្រសើរឡើងតាមរយៈការអនុវត្តកិច្ចការនៅថ្នាក់មូលដ្ឋាន និងជាភ្នាក់ងារតំណាងរដ្ឋ ដែលសកម្មភាពទាំងនេះផ្ដោតសំខាន់ទៅលើផ្នែកជាច្រើនដូចជា ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ និងបរិស្ថាន ផ្នែករដ្ឋបាល និងសន្តិសុខ ផ្សេងៗទៀត។

ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការពិតជាប្រព័ន្ធគ្រប់គ្រងដ៏ល្អប្រសើរបំផុតសម្រាប់ប្រទេសកម្ពុជាជាពិសេសសម្រាប់ប្រជាពលរដ្ឋតាមមូលដ្ឋានតែម្ដង ដោយហេតុថាប្រព័ន្ធដឹកនាំតាមបែបវិមជ្ឈការមានគោលដៅជាចម្បងឆ្ពោះទៅរកការធ្វើឲ្យមានការទទួលខុសត្រូវនៅកម្រិត ថ្នាក់ក្រោមជាតិឲ្យកាន់តែច្រើន និងមានភាពជិតស្និទ្ធជាមួយប្រជាពលរដ្ឋនៅក្នុងដែនដីមូលដ្ឋាន។

ម្យ៉ាងទៀតអ្វីដែលសំខាន់ទៅទៀតនោះ គឺការធ្វើឲ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានដូចជា អាជ្ញាធរដែនដីអង្គការស្ថាប័ននិងវិស័យ

ឯកជននានា ជាពិសេស គឺការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានផងដែរពីព្រោះថាប្រព័ន្ធគ្រប់គ្រងនេះនឹងធ្វើឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពកាន់តែខ្លាំងក្នុងការឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំកាន់តែប្រសើរ។

# ជំពូកទី៤

# ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១- ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា*

*២- ប្រវត្តិនៃការគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា*

*៣- រចនាសម្ព័ន្ធថ្នាក់ជាតិ*

*៤- រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ/មូលដ្ឋាន*

## ១-ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា

ការគ្រប់គ្រងរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនៅមានការស្រពិចស្រពិលមិនទាន់ច្បាស់លាស់នៅឡើយទេ។ ការគ្រប់គ្រងរដ្ឋបាលបានធ្វើតាមទម្លាប់មុនខ្លះ និងមានការកែសម្រួលខ្លះដើម្បីឆ្លើយតបទៅនឹងសភាពការជាក់ស្តែងនៃស្ថានភាពប្រទេសជាតិ។

ជាទូទៅគេសង្កេតឃើញថាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជាមានប្រព័ន្ធចម្រុះ **គឺមជ្ឈការ វិមជ្ឈការ** និង**វិសហមជ្ឈការ**នៅជាមួយគ្នា។ ចាប់ពីរបបប្រល័យពូជសាសន៍បានដួលរលំមក ក្នុងកំឡុងទស-

វត្សទី៨០ ការគ្រប់គ្រងរដ្ឋបាលគឺធ្វើតាមបែប**មជ្ឈការ**។ រហូតមកដល់ទសវត្សទី៩០ ការគ្រប់គ្រងរដ្ឋបាលត្រូវបានធ្វើការកែទម្រង់ ដោយបានអនុវត្តតាមបែប**វិសហមជ្ឈការ** ពោលគឺបានផ្តល់អំណាចឲ្យទៅរាជធានីខេត្តមួយចំនួន។

**១-១-រដ្ឋបាលថ្នាក់ជាតិ/រដ្ឋបាលកណ្តាល**

**១-១-១-ថ្នាក់រាជរដ្ឋាភិបាល**

ក្នុងវិស័យរចនាសម្ព័ន្ធរដ្ឋបាល រាជរដ្ឋាភិបាលមានទីស្តីការ គណៈរដ្ឋមន្ត្រីមួយដែលជាទីតាំងការិយាល័យរដ្ឋបាលរបស់រាជរដ្ឋាភិបាល។ មាត្រា១៧ នៃព្រះរាជក្រមលេខ០២.នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចែងថា៖ “ នាយករដ្ឋមន្ត្រីដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី” ហើយមាត្រា៣១បញ្ជាក់ថា៖ “ រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីអមដោយរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការព្រមទាំងអគ្គលេខាធិការរដ្ឋាភិបាលផង គ្រប់គ្រងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រីសម្របសម្រួលការងារប្រចាំថ្ងៃនៃគណៈរដ្ឋមន្ត្រីក្រោមការទទួលខុសត្រូវរបស់នាយករដ្ឋមន្ត្រី។

ចំពោះតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការនឹងត្រូវបញ្ជាក់ដោយអនុក្រឹត្យស្តីពីការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី” ។ កិច្ចប្រជុំថ្នាក់រាជរដ្ឋាភិបាលមានពីរសំខាន់ៗគឺ៖

-អង្គប្រជុំអន្តរក្រសួង

-អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

**១-១-២- អង្គប្រជុំអន្តរក្រសួង**

ព្រះរាជក្រមលេខ ០២.នស.៩៤ ខាងលើនេះ បានចែងក្នុងមាត្រា១១ថា៖ អង្គប្រជុំអន្តរក្រសួង “ **គ្មានសិទ្ធិសម្រេចកិច្ចការតាងនាមរាជរដ្ឋាភិបាលបានឡើយ”** ។ ដូច្នេះការប្រជុំអន្តក្រសួងគ្រាន់តែជា ការប្រុងប្រៀបរៀបចំសម្រាប់ដាក់ជូនអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីសម្រេច។ នាយករដ្ឋមន្ត្រីអាចជាអធិបតីនៃអង្គប្រជុំអន្តរក្រសួងក៏បានឬប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់ក៏បាន។

ប្រសិនបើមានអង្គប្រជុំខ្លះដែលគេឲ្យឈ្មោះថា “ **អង្គប្រជុំអន្តរក្រសួង”** ប៉ុន្តែក្រោមអធិបតីភាពរបស់អគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រី (រាជរដ្ឋាភិបាល) ដែលមិនមែនជាសមាជិករដ្ឋាភិបាលតាមច្បាប់ ការប្រជុំនេះមិនមែនជាអង្គប្រជុំអន្តរក្រសួងទេគឺគ្រាន់តែជា *អង្គប្រជុំការងារ* មួយប៉ុណ្ណោះ ដែលមានតំណាងក្រសួងជាច្រើនចូលរួម។

នៅអមទីស្តីការគណៈរដ្ឋមន្ត្រីមានក្រុមការងារមួយឈ្មោះថា “ **ក្រុមប្រឹក្សាអ្នកច្បាប់”** បង្កើតដោយអនុក្រឹត្យតាំងពីឆ្នាំ១៩៩៤ ហើយដែលរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជាប្រធាន។

“ **ក្រុមប្រឹក្សាអ្នកច្បាប់”** ជួយមើល និងឲ្យយោបល់ក្នុងវិស័យច្បាប់លើរាល់គម្រោងនៃសេចក្តីព្រាងច្បាប់សេចក្តីព្រាងអនុក្រឹត្យ ឬលើកិច្ចការខាងផ្លូវគតិយុត្តតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

កន្លងមកការប្រជុំរបស់“ ក្រុមប្រឹក្សាអ្នកច្បាប់” ជាការប្រជុំការងារមួយដែរ។ ក្នុងការប្រតិបត្តិសព្វថ្ងៃនេះការប្រជុំរបស់ “ ក្រុមប្រឹក្សាអ្នកច្បាប់” ពុំសូវមានភាពទៀងទាត់ទេ ហើយហាក់ដូចជាមកធ្វើការប្រជុំដែលគេឱ្យឈ្មោះថា “អន្តរក្រសួង” នោះច្រើនជាងទៅវិញ។

**១-១-៣- អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

ក្រោយមានប្រជុំអន្តរក្រសួងរួចហើយ រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីលើកបញ្ហាទាំងឡាយស្នើដាក់ក្នុងរបៀបវារៈនៃអង្គប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី។

## ២-ថ្នាក់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

មាត្រា៣៣ នៃព្រះរាជក្រមចែងថា ៖ “ ការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវកំណត់ដោយច្បាប់” ។ បទប្បញ្ញត្តិនេះ នាំឲ្យមានការចង្អៀតចង្អល់ក្នុងការត្រូវលុប ឬត្រូវបន្ថែមក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ដែលរាជរដ្ឋាភិបាលនីមួយៗចង់ធ្វើ។ រដ្ឋាភិបាលចេញពីគណបក្សដែលឈ្នះឆ្នោតតែងតែមានកម្មវិធីនយោបាយ ដែលតម្រូវឲ្យបង្កើតក្រសួងថ្មី ឬលុបចោលក្រសួងចាស់ ដូច្នេះ គួរណាស់ទុកលទ្ធភាពនេះជូនរាជរដ្ឋាភិបាលតាមរយៈការបង្កើតដោយព្រះរាជក្រឹត្យដំណាលជាមួយគ្នានឹងការតែងតាំងរាជរដ្ឋាភិបាលថ្មីវិញ។ តាមច្បាប់ដែលបង្កើតក្រសួង ការរៀបចំរចនាសម្ព័ន្ធនៃក្រសួង និងរដ្ឋលេខធិការដ្ឋានត្រូវធ្វើអនុក្រឹត្យ។

**២-១-រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដ្ឋានប្រធានស្ថាប័ន**

រដ្ឋមន្ត្រី ជាសមាជិករាជរដ្ឋាភិបាល គឺមានន័យថាជាអ្នកនយោបាយ។ អ្នកនយោបាយ ជាអ្នកដាក់ទិសឲ្យមន្ត្រីរាជការដើរតាម ដើម្បីបម្រើនយោបាយរបស់រាជរដ្ឋាភិបាលតាមកម្មវិធី ដែលគេប្រកាសជូនរដ្ឋសភានៅពេលសុំសេចក្តីទុកចិត្ត។ ក្រៅអំពីមុខងារនយោបាយ រដ្ឋមន្ត្រី មានមុខងាររដ្ឋបាលថែមទៀត។ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន គឺជានាយថៅហ្វាយលើគ្រប់មន្ត្រីភ្នាក់ងាររាជការទាំងអស់នៅក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋានដែលខ្លួនត្រួតត្រា។

រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការចេញសេចក្តីសម្រេចគ្រប់បែបយ៉ាងសម្រាប់ធ្វើឲ្យមានដំណើរការល្អក្នុងក្រសួងចេញសារាចរណែនាំបំភ្លឺការអនុវត្តច្បាប់និងបទបញ្ជារៀបចំ គម្រោងដំបូងនៃសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ហើយជាតំណាងរដ្ឋក្នុងការគ្រប់គ្រងសម្បត្តិរដ្ឋដែលមានក្នុងក្រសួងក្នុងការចុះកិច្ចសន្យា ឬក្នុងការប្តឹងទៅតុលាការ។ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការប្រធានស្ថាប័នជាអាណាប័កដើមខ្សែនៃចំណាយ។ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការធ្វើការត្រួតពិនិត្យអាណាព្យាបាលលើគ្រឹះស្ថានសាធារណៈដែលចំណុះខ្លួន។

រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការចេញសេចក្តីសម្រេចរបស់ខ្លួនតាម “ ប្រកាស” ដែលអាចជា“ ប្រកាសក្រសួង” ឬជា“ ប្រកាសអន្តរក្រសួង” ។

**២-២-រដ្ឋបាលកណ្តាលនៃក្រសួង ឬនៃរដ្ឋលេខាធិការដ្ឋាន**

*រដ្ឋបាលកណ្តាលនៃក្រសួង ឬនៃរដ្ឋលេខាធិការដ្ឋានគេឃើញមាន៤ក្រុមសំខាន់គឺ៖

ក-ក្រុម “ ខុទ្ទកាល័យ”

ខ-ក្រុម “ រដ្ឋបាលកណ្តាលមែនទែន”

គ-ក្រុម “ អធិការកិច្ច និងត្រួតពិនិត្យ”

ឃ-ក្រុម “ ទីប្រឹក្សា” របស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ

រដ្ឋបាលកណ្តាលនៃក្រសួង ឬនៃរដ្ឋលេខាធិការដ្ឋានក្រុម “ **ខុទ្ទកាល័យ**” ជាពួកមនុស្សផ្ទាល់របស់ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ។ ពួកនេះ ជួនកាលជាមន្ត្រីរាជការ ជួនកាលមិនមែនជាមន្ត្រីរាជការក្របខ័ណ្ឌ ហើយត្រូវផ្លាស់ប្តូរទៅតាមការផ្លាស់ប្តូររបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលជាអ្នកយកខ្លួនមកប្រើ។

ក្រុម “ **រដ្ឋបាលកណ្តាល** ” គេហៅថា “ **ពួកប៊ុយរ៉ូ** ” គឺពួកមន្ត្រីភ្នាក់ងាររាជការក្របខ័ណ្ឌនៃក្រសួង ដែលនៅធ្វើការជាអចិន្ត្រៃយ៍នៅក្នុង“ ប៊ុយរ៉ូ ” ដូចជា ក្នុងនាយកដ្ឋាន ឬការិយាល័យ។ ពួកនេះសុទ្ធតែជាអ្នកបច្ចេកទេស ឬឯកទេស ដែលចេះស្គាល់កិច្ចការរដ្ឋបាលយ៉ាងស្ទាត់ជំនាញសម្រាប់រៀបចំគម្រោងការឱ្យរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការសម្រេច។ ពួកក្រុម“ **រដ្ឋបាលកណ្តាល**” នេះ ធ្វើឱ្យរដ្ឋការមានស្ថិរភាព ទោះបីមានការផ្លាស់ប្តូររដ្ឋាភិបាលយ៉ាងណាក៏ដោយ។ រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការមិនអាចដកចេញក្រុម ” រដ្ឋបាលកណ្តាល ” ដោយគ្មានមូលហេតុត្រឹមត្រូវ និងដោយមិនគោរពនីតិវិធីដែលមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលបានឡើយ។ ក្រុម “ រដ្ឋបាល កណ្តាល” ជាសសរទ្រូងរបស់ក្រសួង ឬរដ្ឋលេខាធិការដ្ឋាន បើគេដក“ **សសរ**” ចេញវាត្រូវតែរលំផ្ទះ។

ក្នុងក្រុមនេះ **អគ្គនាយកក្រសួង** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅត្រូវធ្វើការតែងតាំងដោយអនុក្រឹត្យ ហើយចាប់ពីក្រោមនេះ ដោយ**ប្រកាសរបស់ក្រសួង** ឬ **រដ្ឋលេខាធិការដ្ឋាន**។ ជារួមក្នុងរដ្ឋបាលកណ្ដាលមានការិយាល័យដែលបម្រើសេវាគ្រប់គ្រងផ្ទៃក្នុងក្រសួង ហើយនិងការិយាល័យដែលបម្រើសេវាសម្រាប់សាធារណៈជនដែលគេហៅថា" **សេវាអន្តរាគមន៍" សេវាគ្រប់គ្រងផ្ទៃក្នុងក្រសួង** គឺសំដៅការងារខាងបុគ្គលិកហិរញ្ញវត្ថុ ឬវិវាទផ្ទៃក្នុង។ល។ **សេវាអន្តរាគមន៍** សម្រាប់ដោះស្រាយបញ្ហាជូនសាធារណជន។

**ក្រុមអធិការកិច្ច និងត្រួតពិនិត្យ** មានមុខនាទីជាអ្នកតាមដានត្រួតពិនិត្យលើសកម្មភាពទាំងឡាយរបស់មន្ត្រីភ្នាក់ងាររាជការទាំងអស់របស់ក្រសួង ទាំងពួកនៅរដ្ឋបាលកណ្ដាល និងទាំងពួកនៅតាមខេត្ត/ក្រុង។ អធិការកិច្ច និងការត្រួតពិនិត្យ ត្រូវធ្វើទាំងលើ**ផ្នែកបច្ចេកទេស** ទាំងលើ**ផ្នែកហិរញ្ញវត្ថុ**។ ក្រុមនេះត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការប្រធានស្ថាប័ន។ **ក្រុមពួកទីប្រឹក្សា** សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងផ្ដល់យោបល់លើគម្រោងការផ្សេងៗ មុននឹងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការធ្វើការសម្រេច។

ក្រុមនេះ ជួនកាលជាអង្គការ ដូចជាក្រុមប្រឹក្សាអ្នកច្បាប់ជាដើមជួនកាលជា**បុគ្គលឯកត្តភូត** ធ្វើការអមរាជរដ្ឋាភិបាល ហើយអ្នកខ្លះយកប្រាក់ខែពីថវិកាជាតិអ្នកខ្លះទៀតជាទីប្រឹក្សាក្នុងគម្រោងជំនួយ

អន្តរជាតិទទួលប្រាក់កម្រៃពីមូលនិធិអន្តរជាតិ ដូចជា “ **យូអ៊ិនឌីភី**” (**UNDP**)“ **អេ ឌី ប៊ី**” (**ADB**)ជាដើម ។ល។

### ៣-**រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ**

ដូចយើងធ្លាប់បាននិយាយពីមុនរួចមកហើយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលដែនដីទើបតែអនុម័ត។ យើងទើបនឹងឃើញបាន **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០១ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០១។ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យថា ស្របនឹងរដ្ឋធម្មនុញ្ញ ហើយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កែប្រែដល់ឆ្នាំ១៩៩៩ចែងថា:“ *ទឹកដីព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់។*

### ៤-**លំដាប់ថ្នាក់រាជធានី/ខេត្ត**

មាត្រា២ នៃព្រះរាជក្រមលេខ នស/រកម/២៩៨/០៣ ចុះថ្ងៃទី១០ខែកុម្ភៈឆ្នាំ១៩៩៨ស្តីពីហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ចែងថា៖ ” ខេត្ត ក្រុង គឺជានីតិបុគ្គលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិសាធារណៈ” ។

” ខេត្ត ក្រុង បំពេញសមត្ថកិច្ចនានាដែលច្បាប់អនុញ្ញាតមានថវិកានិងមានទ្រព្យសម្បត្តិទាំងឡាយដែលកំណត់ដោយច្បាប់នេះ” ។

មាត្រា៤ បញ្ជាក់ថា ៖ ” អភិបាលខេត្ត ក្រុង គឺជាតំណាងនៃរដ្ឋបាលកណ្តាលនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន” ។

មាត្រា៣ចែងថា៖“ ខេត្ត ក្រុងត្រូវគ្រប់គ្រងដោយអភិបាលមួយ រូប និងអភិបាលរងមួយចំនួនជាជំនួយការនៅក្នុងលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់” ។

មាត្រា៣ ចែងថា ៖ “ ខេត្តក្រុងត្រូវគ្រប់គ្រងដោយអភិបាលមួយរូប និងអភិបាលរងមួយចំនួនជាជំនួយការនៅក្នុងលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់” ។ ឃ្លានេះធ្វើឱ្យប្រកាសលេខ៣១ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត-ក្រុង ដែលខុសច្បាប់នេះ រឹតតែខុសច្បាប់ទៅទៀត ប៉ុន្តែគេនៅអនុវត្តដល់សព្វថ្ងៃនេះនៅឡើយ។ មណ្ឌលដែនដីខេត្ត-ក្រុង ជាមណ្ឌលរដ្ឋបាលវិសហមជ្ឈការផងដែរ ពីព្រោះមានប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល។ អភិបាលខេត្ត-រាជធានី តែងតាំងដោយ**ព្រះរាជក្រឹត្យ**។

### ៤-១-លំដាប់ថ្នាក់ក្រុង-ស្រុក-ខណ្ឌ

អភិបាលស្រុក និងអភិបាលខ័ណ្ឌ ត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ហើយត្រូវនៅក្រោមឱវាទផ្ទាល់របស់អភិបាលខេត្តក្រុង។ អភិបាលខេត្តក្រុងអាចធ្វើប្រតិភូកម្មអំណាចឱ្យអភិបាលស្រុកខ័ណ្ឌបានតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់។ ប៉ុន្តែ ដោយមិនទាន់មានច្បាប់គេមានតែប្រកាសខុសច្បាប់របស់ក្រសួងមហាផ្ទៃលេខ៣១ប្រ.ក នោះប៉ុណ្ណោះសម្រាប់អនុវត្តទាំងខុសច្បាប់( ប្រការ៧ )បន្តទៀត

ក្រសួងមហាផ្ទៃមានច្បាប់បង្កើតក្រសួងនៅក្នុងឆ្នាំ១៩៩៦ គួរណាស់តែធ្វើនិយ័តភាពឱ្យបានឆាប់រហ័ស ហើយឈប់ប្រើអនុក្រឹត្យលេខ១៦ អនក្រ និងប្រកាសរបស់ក្រសួងមហាផ្ទៃទាំងឡាយដែលអនុវត្តអនុក្រឹត្យនេះ។ នៅពេលណាមួយដែលមានបញ្ហាកើតឡើងមេធាវី ដើម្បីការពារកូនក្តី អាចសុំឱ្យតុលាការបដិសេធរាល់សេចក្តីសម្រេចរដ្ឋបាលដែលយោងទៅលើអនុក្រឹត្យ និងប្រកាសទាំងអស់នេះដែលខុសច្បាប់។

**៤-២-លំដាប់ថ្នាក់ឃុំ -សង្កាត់**

នៅមុនពេលមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ឆ្នាំ២០០១នេះ ឃុំសង្កាត់គ្រាន់តែជាមណ្ឌលរដ្ឋបាលរបស់រដ្ឋថ្នាក់មូលដ្ឋានកម្រិតតូចបំផុត។ ពេលនោះ**មេឃុំ ចៅសង្កាត់** ជាភ្នាក់ងារសាធារណៈរបស់រដ្ឋតែងតាំងដោយអំណាចរបស់រដ្ឋគឺថា ដោយ**ដីកាខេត្ត-ក្រុង** តាមសំណើរបស់អភិបាលស្រុក-ខ័ណ្ឌ។ ដល់ច្បាប់នេះចូលជាធរមានឃុំ-សង្កាត់ នឹងក្លាយទៅជាមណ្ឌលរដ្ឋបាលវិសហមជ្ឈការផង និងជាមណ្ឌលរដ្ឋបាលវិមជ្ឈការផង។ នៅពេលច្បាប់នេះចូលជាធរមានឃុំ-សង្កាត់នឹងក្លាយទៅជាមណ្ឌលរដ្ឋបាលវិសហមជ្ឈការផង និងជាមណ្ឌលរដ្ឋបាលវិមជ្ឈការផង។

ជាសន្និដ្ឋានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុ-ជាមានការកែទម្រង់ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងហេដ្ឋារចនាសម្ព័ន្ធរឹងនិងទាំងហិរញ្ញវត្ថុសាធារណៈ ដោយធ្វើយ៉ាងណាឲ្យលទ្ធផលការងារកាន់តែខិតជិតប្រជាពលរដ្ឋ និងទទួលបានប្រសិទ្ធភាពការងារកាន់តែ

ឬល្អប្រសើរ។ ជាមួយគ្នានេះ ការកសាងសមត្ថភាពការងារដល់មន្ត្រីរាជការ និងមន្ត្រីទទួលអាណត្តិពីប្រជាពលរដ្ឋពីមួយថ្ងៃទៅមួយថ្ងៃក៏កាន់តែល្អប្រសើរទៀតផងដែរ។ ដូចជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តែងតែត្រូវហ្វឹកហ្វឺនជាប្រចាំដើម្បីពួកគាត់អាចរៀបចំអនុវត្តផែនការការងារបានត្រឹមត្រូវតាមរយៈការងារវាយមូលនិធិដោយដេញថ្លៃ និងការមានធ្វើសវនកម្មត្រឹមត្រូវទៅតាមច្បាប់បញ្ញត្តិ ជាដើម។

# ជំពូកទី៥

# សហគ្រាសសាធារណៈ

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១- អ្វីទៅជាគ្រឹះសាធារណៈ*

*២- ក្រុមហ៊ុនរដ្ឋ*

*៣- ក្រុមហ៊ុនចម្រុះ*

*៤- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច*

*៥- ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល*

*៦- ការត្រួតពិនិត្យសហគ្រាសាធារណៈ*

*៧- សេចក្តីសន្និដ្ឋាន*

## ១-អ្វីទៅជាសហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ដែលមានបេសកកម្មបង្កលក្ខណៈអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។

ការបង្កើតសហគ្រាសសាធារណៈ ជាចំណែកមួយនៃប្រតិបត្តិការរបស់រដ្ឋនៅក្នុងក្របខណ្ឌសេដ្ឋកិច្ចជាតិ ដើម្បីរួមចំណែកការពារនិងថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច ក្នុងគោលដៅឱ្យមានចីរភាពនៃការអភិវឌ្ឍ។

គេក៏អាចសម្គាល់បានដែរថា សហគ្រាសសាធារណៈ ធ្វើសកម្មភាពសេដ្ឋកិច្ចដែលស្ថិតក្រោមបរិយាកាសប្រកួតប្រជែង និងក្រោមឥទ្ធិពលនៃទីផ្សារក្នុងគោលបំណងពង្រីក និងទាញយក (ប្រាក់ចំណេញ) ផលប្រយោជន៍អំពីសកម្មភាពរបស់ខ្លួនរួមមានការលក់សម្ភារៈ ឬសេវាកម្មជាដើម។ សហគ្រាសសាធារណៈមានស្វ័យភាពក្នុងការគ្រប់គ្រងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងស្ថិតក្រោមរបបនីតិរួមចំពោះពន្ធ និងអាករ លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយ ច្បាប់។ យោងតាមមាត្រា២នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសារណៈបានចែងថា៖ «សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។» សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម

កិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ សហគ្រាសសាធារណៈមានបីទម្រង់គឺ៖

១-ក្រុមហ៊ុនរដ្ឋ

២-ក្រុមហ៊ុនចម្រុះ

៣-គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

## ២-ក្រុមហ៊ុនរដ្ឋ

ជាក្រុមហ៊ុនដែលដើមទុនជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ ដែលដើមទុនដំបូង ឬការកែប្រែភាគទុននោះជាក្រោយ ត្រូវបានអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុនិងច្បាប់ហិរញ្ញវត្ថុ។ ក្រុមហ៊ុនរដ្ឋត្រូវបង្កើតដោយអនុក្រឹត្យតាមការស្នើរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ នៅក្នុងអនុក្រឹត្យនោះ គេនឹងកំណត់យ៉ាងច្បាស់អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល។

ទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនរដ្ឋ ត្រូវបានទទួលខុសត្រូវរៀបចំឡើងដោយ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ដោយមានចែងនូវ៖

លក្ខខន្តិកៈនៃការបង្កើតក្រុមហ៊ុនរដ្ឋដោយពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការកំណត់ចំនួនទឹកប្រាក់ និង

ប្រភេទនៃភាគទុន ការរៀបចំរដ្ឋបាលនិងហិរញ្ញវត្ថុ វិធាន និងការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន។

-ចាត់ចែងចុះឈ្មោះក្រុមហ៊ុនរដ្ឋនោះក្នុងបញ្ជីពាណិជ្ជកម្ម

-បំពេញទម្រង់បែបបទនានាតាមគោលការណ៍នៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។

**២-១-ប្រភពគតិយុត្ត**

**២-១-១-ព្រះរាជក្រម**

ព្រះរាជក្រមលេខជស/រកម០៦៩៦/០៣ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦។

**២-១-២-អនុក្រឹត្យ**

អនុក្រឹត្យលេខ៤១អនក្រ.បកស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី៦ខែសីហាឆ្នាំ១៩៩៧។

**២-១-៣-អនុក្រឹត្យ**

អនុក្រឹត្យលេខ៤២អនក្រ.បកស្តីពីស្នងការគណនីសហគ្រាសសាធារណៈ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧។

**២-១-៤-អនុក្រឹត្យ**

អនុក្រឹត្យលេខ៣៨អនក្រ ស្តីពីបែបបទ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥។

## ២-១-៥-ប្រកាស

ប្រកាសលេខ៩៩៧សហវ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី២៥ខែធ្នូ ឆ្នាំ១៩៩៧។

## ២-១-៦-សារាចរណែនាំ

សារាចរណែនាំលេខ០០៥សហវ. ទរ ស្តីពីអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅ សហគ្រាសសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧។

## ២-៣-ការបង្កើត

ត្រូវបង្កើតដោយអនុក្រឹត្យតាមការស្នើរួមគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល(មាត្រា៣១នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

## ២-៣-១-លក្ខន្តិកៈ

ត្រូវរៀបចំឡើងដោយក្រសួងអាណាព្យាបាលបច្ចេកទេសសហការជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា២៩ អនុក្រឹត្យលេខ៤១ អនក្រ.បក ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧)។

## ២-៣-២-របបគតិយុត្ត

អនុវត្តតាមច្បាប់ឯកជន (មាត្រា៣៤ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**២-៣-៣-សកម្មភាព**

ធ្វើសកម្មភាពពាណិជ្ជកម្ម (មាត្រា៣២ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)

**២-៣-៤-ដើមទុន**

ដើមទុនទាំងអស់ជារបស់រដ្ឋ (មាត្រា៣០ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)

**២-៣-៥-អាណាព្យាបាល**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស)(មាត្រា៣១ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**២-៣-៦-សមាសភាព**

សមាសភាពមិនលើសពី៧រូប (តំណាងរដ្ឋមន្ត្រីអាណាព្យាបាល តំណាងនិយោជិត...)។

**២-៣-៧-ក្រុមប្រឹក្សាភិបាល**

សមាសភាពមិនលើសពី៧រូប (តំណាងរដ្ឋមន្ត្រី អាណាព្យាបាល តំណាងនិយោជិត...)

**២-៣-៨-អង្គការប្រតិបត្តិ**

ប្រធានអគ្គនាយក ឬអគ្គនាយកត្រូវ តែងតាំងដោយអនុក្រឹត្យស្នើដោយរដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស(មាត្រា ៣៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**២-៣-៩-លទ្ធកម្ម**

គ្រប់ការធ្វើលទ្ធកម្មត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដែលមានកំណត់ក្នុងប្រកាសលេខ៩៩៧សហវស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧។

**២-៣-១០-សវនការគណនី**

ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស (នីតិបុគ្គល បរទេសតំណាងដោយរូបវន្តបុគ្គលសញ្ជាតិជាខ្មែរ) ត្រូវជ្រើសរើសពីក្នុង ចំណោមអ្នកមានលក្ខខណ្ឌកំណត់ក្នុងច្បាប់ ដែលទទួលស្គាល់ដោយរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ហើយត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់អាណត្តិ៣ឆ្នាំ ដែលមានភារកិច្ចផ្ទៀងផ្ទាត់តម្លៃទឹកប្រាក់តួលេខឯកសារគណនេយ្យ ធ្វើរបាយការណ៍តុល្យការ។ល។ (អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការសវនការគណនីសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧)។

**២-៣-១១-ការត្រួតពិនិត្យ**

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានតែងតាំង និងបញ្ឈប់ពីមុខងារដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់អាណត្តិ៥ឆ្នាំ ដើម្បីត្រួតពិនិត្យសេដ្ឋកិច្ច (មាត្រា២០ និង២២ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**២-៣-១២-ឯកជនភាវូបនីយកម្ម**

អាចត្រូវបានធ្វើឯកជនភាវូបនីយកម្មនូវកម្មសិទ្ធិទ្រព្យសកម្មសាធារណៈដូចជា៖

-សហគ្រាសសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម

-ការចូលរួមភាគហ៊ុនសាធារណៈក្នុងមូលធននៃក្រុហ៊ុនសេដ្ឋកិច្ចចម្រុះ

-សកម្មភាពសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម រាល់ទ្រព្យសកម្មរូបិយ

អរូបិយ ឬហិរញ្ញវត្ថុស្ថិតក្នុងកម្មសិទ្ធិសាធារណៈ ឬជាកម្មសិទ្ធិរបស់សមូហភាពសាធាណៈ។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗនៃក្រុមហ៊ុនរដ្ឋ៖

-កំពង់ផែស្វយ័តក្រុងព្រះសីហនុ(ក.ស.ស)ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសាធារណៈការនិងដឹកជញ្ជូន និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រុមហ៊ុនហ្គ្រីនត្រេដ(ក.ហ.ត)មានភារកិច្ចធ្វើពាណិជ្ជកម្ម និងសេវាកម្ម ទៅលើមុខទំនិញស្បៀង និងម្ហូបអាហារជាមូលដ្ឋានដោយផ្ទាល់នៅក្នុងក្របខណ្ឌក្នុង និងក្រៅប្រទេស។ ក.ហ.ត ត្រូវបានរួមបញ្ចូលដោយក្រុមហ៊ុនរបស់រដ្ឋចំនួន៤គឺ៖ ក្រុមហ៊ុនស្បៀងកម្ពុជា ក្រុមហ៊ុនសម្ភារបរិក្ខារក្រុមហ៊ុនប្រមូលទិញ និងក្រុមហ៊ុនដឹកជញ្ជូនពាណិជ្ជកម្ម "កាំត្រង់" ហើយស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងពាណិជ្ជកម្ម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមហ៊ុនសំភារៈកសិកម្ម (ក.ហ.ស.ក) មានភារកិច្ច នាំចូលទិញ លក់សម្ភារៈកសិកម្ម ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៣-ក្រុមហ៊ុនចម្រុះ

ក្រុមហ៊ុនចម្រុះគឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬរូបវន្តបុគ្គលឯកជន និងនិតិបុគ្គលរដ្ឋ ឬអាចនិយាយដោយខ្លីថា ជាក្រុមហ៊ុនកាន់កាប់រួមរវាងរដ្ឋ និងឯកជន។ ប៉ុន្តែ ឱ្យតែភាគកម្មសាធារណៈលើសពី ៥១ នៃភាគទុនសរុប ឬនៃសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះនោះត្រូវបានចាត់ទុកថាជាសហគ្រាសសាធារណៈ។ ក្នុងកិច្ចការស្រាវជ្រាវនេះ "ភាគកម្មសាធារណៈ" មានន័យថា "ភាគទុនដែលកាន់កាប់ដោយរដ្ឋ" ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកកាន់កាប់ផ្នែករដ្ឋបាលនៃភាគកម្មសាធារណៈនេះ។

ចំពោះក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះត្រូវមានវត្តមានរបស់ **តំណាងរបស់រដ្ឋនៃក្រុមហ៊ុនចម្រុះ** ដែលតែងតាំងដោយអនុក្រឹត្យតាមការស្នើសុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **តំណាងរបស់ក្រុមហ៊ុនរដ្ឋ** ដែលត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់

ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយមានការឯកភាពក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លក្ខខណ្ឌនៃការជ្រើសរើស**តំណាងរបស់រដ្ឋនៃក្រុមហ៊ុនចម្រុះ**ដូចគ្នានឹងលក្ខខណ្ឌនៃការជ្រើសរើសតំណាងក្រុមហ៊ុនរដ្ឋ និងគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ចដែរ គឺត្រូវផ្អែកលើគុណសម្បត្តិនានាដែលយើងបានលើកឡើងខាងលើ។

**៣-១-ប្រភពគតិយុត្ត**

ក-ព្រះរាជក្រមលេខជស/រកម០៦៩៦/០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦។

ខ-អនុក្រឹត្យលេខ ៤១ អនក្រ.បកស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧។

គ-អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការស្នងការគណនីសហគ្រាសសាធារណៈ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧។

ឃ-អនុក្រឹត្យ លេខ៣៨ អនក្រ ស្តីពីបែបបទឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥។

ង-ប្រកាសលេខ៩៩៧ សហវ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧។

ច-សារាចរណែនាំលេខ០០៥សហវ.ទរ ស្តីពីអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧។

**៣-២-ការបង្កើត**

បង្កើតតាមច្បាប់ក្រុមហ៊ុនពាណិជ្ជកម្ម(ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម) (មាត្រា៣៨នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ) ចាត់ទុកក្រុមហ៊ុនចម្រុះជាសហគ្រាសសាធារណៈ លុះត្រាតែក្រុមហ៊ុនចម្រុះនោះរដ្ឋមានភាគកម្មលើសពី៥១ ភាគរយ។

**៣-៣-លក្ខន្តិកៈ**

រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលបច្ចេកទេសនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការព្រមព្រៀងជាមួយដៃគូឯកជនត្រូវរៀបចំអនាគតលក្ខន្តិកៈក្រុមហ៊ុន។

**៣-៤-របបគតិយុត្ត**

អនុវត្តតាមច្បាប់ឯកជន(មាត្រា៣៨ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៣-៥-សកម្មភាព**

ធ្វើសកម្មភាពពាណិជ្ជកម្ម(មាត្រា៣៨ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)

**៣-៦-ដើមទុន**

ដើមទុនដែលរដ្ឋមានលើសពី៥១% (មាត្រា៣៨ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៣-៧-អាណាព្យាបាល**

ក្រសួង ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរ៉ាប់រងរដ្ឋបាល លើភាគកម្មសាធារណៈ(មាត្រា៣៩ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៣-៨-ក្រុមប្រឹក្សាភិបាល**

សមាសភាពតំណាងឱ្យរដ្ឋមន្ត្រីអាណាព្យាបាលតំណាងឱ្យក្រុមហ៊ុន និងតំណាងឱ្យម្ចាស់ភាគហ៊ុន ជាដើម។

**៣-៩-អង្គការប្រតិបត្តិ**

ប្រធានអគ្គនាយក ឬអគ្គនាយកត្រូវតែងតាំងដោយអនុក្រឹត្យរបស់រដ្ឋមន្ត្រី អាណាព្យាបាលបច្ចេកទេស(មាតិកា ៤១ នៃសារាចរណែនាំលេខ០០៥សហវ.ទរ ស្តីពីអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧)

**៣-១០-លទ្ធកម្ម**

គ្រប់ការធ្វើលទ្ធកម្មត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដែលមានកំណត់ក្នុងប្រកាសលេខ៩៩៧សហវស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧។

**៣-១១-សវនការគណនី**

ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស(នីតិបុគ្គលបរទេសតំណាងដោយរូបវន្តបុគ្គលសញ្ជាតិជាខ្មែរ) ត្រូវជ្រើសរើសពីក្នុងចំណោមអ្នកមានលក្ខខណ្ឌកំណត់ក្នុងច្បាប់ដែលទទួលស្គាល់ដោយរដ្ឋមន្ត្រី និងក្រសួងយុត្តិធម៌ ហើយត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់

អាណត្តិ៣ឆ្នាំ ដែលមានភារកិច្ចផ្ទៀងផ្ទាត់តម្លៃទឹកប្រាក់តួលេខ ឯកសារគណនេយ្យធ្វើរបាយការណ៍តុល្យការ។ល។ (អនុក្រឹត្យលេខ៤២ អនក្រ.បកស្ដីពីការស្នងការគណនី សហគ្រាសសាធារណៈ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧)។

### ៣-១២-ការត្រួតពិនិត្យ

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានតែងតាំង និងបញ្ឈប់ពីមុខងារដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អាណត្តិ៥ឆ្នាំដើម្បីត្រួតពិនិត្យសេដ្ឋកិច្ច(មាត្រា២០ និង២២ ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)

### ៣-១៣-ឯកជនភាវូបនីយកម្ម

អាចត្រូវបានធ្វើឯកជនភាវូបនីយកម្មនូវកម្មសិទ្ធិទ្រព្យសកម្មសាធារណៈដូចជា៖ សហគ្រាសសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មការចូលរួមភាគហ៊ុនសាធារណៈក្នុងមូលធន នៃក្រុហ៊ុនសាជ្ជកិច្ចចម្រុះ។ សកម្មភាពសាធារណៈដែលមានលក្ខណៈឧស្សាហកម្មពាណិជ្ជកម្មរាល់ទ្រព្យសកម្មរូបិយ អរូបិយ ឬហិរញ្ញវត្ថុ ស្ថិតក្នុងកម្មសិទ្ធិសាធារណៈ ឬជាកម្មសិទ្ធិរបស់សមូហភាពសាធារណៈ។

លក្ខណៈពិសេសនៃក្រុមហ៊ុនចម្រុះនោះ រាល់ពេលមានមហាសន្និបាតម្ដងៗ គឺត្រូវមានវត្តមាន **អាណត្តិគោហកៈពិសេស**មួយរូបតំណាងរដ្ឋដែលមានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃសហគ្រាសនោះ មានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហា

សន្និបាតសាមញ្ញនិងវិសាមញ្ញ និងមានសិទ្ធិបោះឆ្នោតក្នុងនាមភាគីរដ្ឋ។ អាណត្តិគោហកៈពិសេសត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជ្រើសរើសចេញពីមន្ត្រីរាជការដែលកំពុងបម្រើការយ៉ាងតិច០៥ឆ្នាំ។ មុនពេលចូលរួមមហាសន្និបាតក្រុមហ៊ុនចម្រុះ អាណត្តិគោហកៈពិសេសត្រូវសុំយោបល់ណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសិន ដើម្បីធានាថាការសម្រេចចិត្តបោះឆ្នោតក្នុងនាមភាគីរដ្ឋក្នុងមហាសន្និបាត ដែលការពារប្រយោជន៍រដ្ឋត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវបំផុត។ យើងអាចក្រឡេកមើលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាជាឧទាហរណ៍មួយសម្រាប់ក្រុមហ៊ុនចម្រុះដែលមិត្តនិស្សិតអាចស្វែងយល់បន្ថែមបាន។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានតួនាទីផ្តល់សេវាចុះបញ្ជីក្រុមហ៊ុនសេវាជួញដូរមូលបត្រ ផាត់ទាត់ និងទូទាត់ ព្រមទាំងរក្សាទុកមូលបត្រ។ មាន ៥៥%នៃភាគហ៊ុនសរុបត្រូវបានកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយភាគហ៊ុនដែលនៅសល់ កាន់កាប់ដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េដែលជាប្រតិបត្តិករទីផ្សារមូលបត្រដ៏ល្បីល្បាញនៃសាធារណរដ្ឋកូរ៉េ។

### ៤-គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ ដែលផលិតអ្វីវ៉ាន់ឬធ្វើសេវាសម្រាប់ទីផ្សារនិងត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង

អាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ អនុក្រឹត្យមានចែងអំពីភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។

យោងតាមមាត្រា២៧ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដើម្បីឲ្យគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច មានដំណើរការទៅមុខបានគឺត្រូវពឹងផ្អែកទាំងស្រុងទៅលើរដ្ឋ ពោលគឺដើមទុនទាំងអស់ជារបស់រដ្ឋ។ ដូច្នេះគ្រឹះស្ថានសាធារណៈទាំងអស់តែងតែមានបេសកកម្មរបស់ខ្លួនក្នុងការបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលជាអតិថិជនរបស់ខ្លួន ប៉ុន្តែការផលិតអីវ៉ាន់ ឬធ្វើសេវាសម្រាប់ទីផ្សារនោះ ទាមទារឱ្យមានផលចំណេញណាមួយត្រឡប់មកវិញ។

អគ្គនាយក គឺជាអ្នកដឹកនាំគ្រឹះស្ថានសាធារណៈ ដែលមានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាលផងជាអគ្គនាយកផង ប៉ុន្តែតួនាទីទាំងពីរត្រូវតែញែកដាច់ពីគ្នា ហើយក្រុមប្រឹក្សាភិបាលអាចត្រួតពិនិត្យលើការបំពេញការងាររបស់អគ្គនាយករូបនោះ។ អគ្គនាយករូបនោះត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាជ្ញាព្យាបាលនៃគ្រឹះស្ថានសាធារណៈនោះ។ចំណែកសមាជិកផ្សេងទៀតនៃក្រុមប្រឹក្សាភិបាលជាតំណាងដែលស្នើដោយក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាជ្ញាព្យាបាលជាមួយនឹងលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ។ សូមក្រឡេកមើលឧទាហរណ៍

ដាក់ស្តែងនៃការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាប(រ.ស.ស) ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច។

នៅជាប់ជាមួយទ្រឹស្តីខាងលើ គេមិនភ្លេចសោះឡើយពាក្យថាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ សញ្ញាណនេះបង្កើតឡើងដោយនីតិរដ្ឋបាលបារាំង ដែលច្បាប់ខ្មែរយកមកប្រើសព្វថ្ងៃនេះ។ គោលបំណងគឺចង់ឲ្យប្រសិទ្ធភាពខ្ពស់ ចំពោះការបម្រើសេវាកម្មសាធារណៈមួយចំនួនដែលទាមទារឲ្យមានបច្ចេកទេសពិសេស ឬឲ្យមានការចាត់ចែងការងារបានឆាប់រហ័ស ទាន់ពេលវេលា ដែលបែបបទរដ្ឋបាលធម្មតាមិនអាចអនុវត្តកើត[117]។ នៅប្រទេសបារាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានបង្កើតឡើងដោយច្បាប់រដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៩៥៨ កែប្រែដល់ឆ្នាំ២០០០ មាត្រា៣៤។ ប៉ុន្តែគេអនុញ្ញាតបង្កើតអនុប្រភេទ (sous-catégorie)នៃគ្រឹះស្ថានសាធារណៈបានដោយបទបញ្ជារបស់អាជ្ញាធររដ្ឋបាលនៃអំណាចកណ្តាល ឬអំណាចវិមជ្ឈការ[118]។

១-សកម្មភាព៖ មានបេសកកម្មផលិត ផ្គត់ផ្គង់ និងចែកចាយទឹកស្អាតសម្រាប់ប្រើប្រាស់ជាទូទៅនៃសាធារណជននៅទីរួមខេត្តសៀមរៀប និងទីប្រជុំជនជុំវិញទីរួមខេត្ត។

២-ដើមទុន៖ ដើមទុនដំបូងរបស់ រ.ស.ស ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច

---

[117] សាយ បូរី៖ រដ្ឋបាលទូទៅ ឆ្នាំ២០០១ ទំព័រ៤១១

[118] ឯកសារដដែល

និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

៣-អាណាព្យាបាល៖ រ.ស.ស ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤-ក្រុមប្រឹក្សាភិបាល៖ សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។ រីឯតំណាងនិយោជិតត្រូវបានជ្រើសតាំងដោយមានការបោះឆ្នោតក្នុងចំណោមនិយោជិតរបស់រ.ស.ស។

**៤-១-ប្រភពគតិយុត្ត**

១-ព្រះរាជក្រមលេខ ជស/រកម០៦៩៦/០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦។

២-អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧។

៣-អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការស្នងការគណនីសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧។

៤-អនុក្រឹត្យ លេខ៣៨ អនក្រ ស្តីពីបែបបទឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥។

៥-ប្រកាសលេខ៩៩៧ សហវ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធាណៈ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧

៦-សារាចរណែនាំលេខ០០៥សហវ.ទរ ស្តីពីអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅ សហគ្រាសសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៧។

**៤-២-ការបង្កើត**

ត្រូវបង្កើតដោយអនុក្រឹត្យតាមការស្នើរួមគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល(មាត្រា២៧នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-៣-លក្ខន្តិកៈ**

ត្រូវរៀបចំឡើងដោយក្រសួងអាណាព្យាបាលបច្ចេកទេសសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា២៤ អនុក្រឹត្យលេខ៤១ អនក្រ.បក ស្តីពីការអនុវត្តព្រះរាជក្រម លក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧)។

**៤-៤-របបគតិយុត្ត**

អនុវត្តតាមច្បាប់សាធារណៈ(មាត្រា២៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-៥-សកម្មភាព**

ផលិតផលិតផលរ៉ាន់ ឬធ្វើសេវាសម្រាប់ទីផ្សារ (មាត្រា២៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-៦-ដើមទុន**

ដើមទុនទាំងអស់ជារបស់រដ្ឋ(មាត្រា២៧ ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-៧-អាណាព្យាបាល**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល (មាត្រា២៧ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-៨-ក្រុមប្រឹក្សាភិបាល**

សមាសភាពមិនលើសពី៧រូប(តំណាងរដ្ឋមន្ត្រីអាណាព្យាបាលតំណាងនិយោជិត...)។

**៤-៩-អង្គការប្រតិបត្តិ**

ប្រធានអគ្គនាយក ឬអគ្គនាយកត្រូវតែងតាំងដោអនុក្រឹត្យរបស់រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស(មាត្រា២៩ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ)។

**៤-១០-លទ្ធកម្ម**

គ្រប់ការធ្វើលទ្ធកម្មត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដែលមានកំណត់ក្នុងប្រកាសលេខ៩៩៧សហវស្ដីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧។

**៤-១១-ស្នងការគណនី**

ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស(នីតិបុគ្គលបរទេសតំណាងដោយរូបវន្តបុគ្គលសញ្ជាតិជាខ្មែរ) ត្រូវ

ជ្រើសរើសពីក្នុងចំណោមអ្នកមានលក្ខខណ្ឌកំណត់ក្នុងច្បាប់ ដែលទទួលស្គាល់ដោយរដ្ឋមន្ត្រី និងក្រសួងយុត្តិធម៌ ហើយត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់អាណត្តិ៣ឆ្នាំ ដែលនភារកិច្ចផ្ទៀងផ្ទាត់តម្លៃទឹកប្រាក់ តួលេខ ឯកសារគណនេយ្យ ធ្វើរបាយការណ៍តុល្យការ ។ល។ (អនុក្រឹត្យលេខ៤២អនក្រ.បក ស្តីពីការស្ទង់ការគណនីសហគ្រាសសាធារណៈ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧)។

### ៤-១២-ការត្រួតពិនិត្យ

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានតែងតាំង និងបញ្ឈប់ពីមុខងារដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់អាណត្តិ៥ឆ្នាំដើម្បីត្រួតពិនិត្យសេដ្ឋកិច្ច(មាត្រា២០ និង២២ ច្បាប់ស្តីពីលក្ខណ្តិកៈទូទៅសហគ្រាសសាធារណៈ)។

### ៤-១៣-ឯកជងភាវូនីយកម្ម

អាចត្រូវបានធ្វើឯកជនភាវូបនីយកម្មនូវកម្មសិទ្ធិទ្រព្យសកម្មសាធារណៈដូចជា៖ សហគ្រាសសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម។

### ៤-១៤-ឯកជងភាវូនីយកម្ម

អាចត្រូវបានធ្វើឯកជនភាវូបនីយកម្មនូវកម្មសិទ្ធិទ្រព្យសកម្មសាធារណៈដូចជា៖

-សហគ្រាសសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម។

-ការចូលរួមភាគហ៊ុនសាធារណៈ ក្នុងមូលធននៃក្រុហ៊ុនសេដ្ឋកិច្ចចម្រុះសកម្មភាពសាធារណៈដែលមានលក្ខណៈឧស្សាហកម្មពាណិជ្ជកម្ម។

-រាល់ទ្រព្យសកម្មរូបិយ អរូបិយ ឬហិរញ្ញវត្ថុស្ថិតក្នុងកម្មសិទ្ធិសាធារណៈ ឬជាកម្មសិទ្ធិរបស់សមូហភាពសាធារណៈ។

## ៥-ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល

អង្គការដឹកនាំខ្ពស់បំផុតនៅក្នុងសហគ្រាសសាធារណៈ ត្រូវបានគេហៅថា "ក្រុមប្រឹក្សាភិបាល" ដែលក្រុមនេះមានសមាជិកមិនលើសពី៧រូបឡើយដោយត្រូវបំពេញមុខងារប្រកបដោយស្វ័យភាពបរិបូរណ៍។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈទាំងអស់ត្រូវមានមួយអាសនៈសម្រាប់តំណាងនិយោជិតដែលត្រូវបានរើសចេញពីនិយោជិតទាំងអស់ និងដែលត្រូវបានបោះឆ្នោតដោយនិយោជិតទាំងអស់ដូចគ្នា។ ក្រុមប្រឹក្សាភិបាលមានភារកិច្ចកំណត់ទិសដៅនិងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាសព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការប្រព្រឹត្តិទៅនៃសហគ្រាស រួមមានការសម្រេចគម្រោងអភិវឌ្ឍសហគ្រាស

-វាយតម្លៃលទ្ធផលការងារ និងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត

-អនុម័តគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅការវិនិយោគនិងសេមាហិរញ្ញប្បទាន

-អនុម័តតុល្យការ និង គណនីគ្រប់គ្រង -កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងបៀវត្សរ៍។

-អនុម័តផែនការលទ្ធកម្ម។ ក្នុងរយៈពេលមិនលើសពី១៥ថ្ងៃនៃថ្ងៃដែលកំណត់ក្រុមប្រឹក្សានៃសហគ្រាសសាធារណៈត្រូវបញ្ជូនឯកសារនានាស្តីពីបច្ចុប្បន្នភាព និងសេចក្តីសម្រេចនៃសហគ្រាសសាធារណៈរបស់ខ្លួនទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ ឯកសារទាំងនោះមាន៖

-កំណត់ហេតុក្រុមប្រឹក្សាភិបាល។

-ថវិកាសម្រាប់ប្រព្រឹត្តទៅ និងកាតវិនិយោគ របាយការណ៍ស្តីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ។

-របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលមានសិទ្ធិជំទាស់លើខ្លឹមសារណាមួយក្នុងឯកសារពាក់ព័ន្ធខាងលើក្នុងករណីចាំបាច់ហើយត្រូវផ្តល់ព័ត៌មាននានានៃការជំទាស់នោះដល់ក្រុមប្រឹក្សាភិបាលវិញ ហើយក្នុងប្រសិនបើ ក្រុមប្រឹក្សាភិបាលមិនឯកភាពលើការជំទាស់នោះក្រុមប្រឹក្សាត្រូវប្រាប់ពីហេតុផលរបស់ខ្លួន ហើយក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលវិញជាបន្ទាន់។

-គណនីទាំងឡាយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមអ្នកជំនាញ

គណនេយ្យតាមលក្ខខណ្ឌនិងបែបបទ។ ចំណែកលទ្ធកម្មត្រូវធ្វើឡើងតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធាននៃការដេញថ្លៃ ការអនុវត្ត និងការត្រួតពិនិត្យត្រូវកំណត់ដោយអនុក្រឹត្យ[119]។

## ៦-ការត្រួតពិនិត្យសហគ្រាសសាធារណៈ

ដើម្បីធានាថា សេចក្ដីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ អនុលោមតាមរាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ចសហគ្រាសសាធារណៈរបស់ខ្លួនតាមរយៈមន្ត្រីត្រួតពិនិត្យរបស់រដ្ឋដែលត្រូវបានតែងតាំងនិងបញ្ឈប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដើម្បីឱ្យការត្រួតពិនិត្យនោះមានភាពសមស្រប និងមានគុណភាព មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវតែជាម្នាក់ក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបាននិងកំពុងបំពេញការងារ សាធារណៈយ៉ាងតិច៥ឆ្នាំ។ ជាមួយនឹងសមត្ថភាព និងបទពិសោធន៍ការងារទាំងនេះ ទើបមន្ត្រីត្រួតពិនិត្យរដ្ឋមានគុណសម្បត្តិគ្រប់គ្រាន់អាចត្រួតពិនិត្យសហគ្រាសសាធារណៈទៅលើ[120]៖

[119] ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ឆ្នាំ២០១៥ មាត្រា ១៩

[120] ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ឆ្នាំ២០១៥ មាត្រា ១៩

-ការបំពេញកាតព្វកិច្ចសាធារណៈដែលមានចែងនៅក្នុងច្បាប់ និងបទបញ្ញាជាធរមាន

-ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

-ការតាមដានការប្រព្រឹត្តទៅ និងការវិវឌ្ឍរបស់សហគ្រាស

-ប្រក្រតីភាពនៃសកម្មភាពទាំងឡាយដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ។ ការត្រួតពិនិត្យពីមន្ត្រីត្រួតពិនិត្យរដ្ឋទៅលើសហគ្រាសសាធារណៈគឺជាសកម្មភាពចាំបាច់ ហេតុនេះហើយទើបមន្ត្រីត្រួតពិនិត្យត្រូវបានអញ្ជើញចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាភិបាលយ៉ាងទៀងទាត់ហើយពួកគេក៏មានសិទ្ធិស្វែងយល់ និងស្នើសុំឯកសារ បញ្ជី គ្រប់ប្រភេទទាក់ទងនឹងបញ្ហាដែលមានចែងក្នុងរបៀបវារៈព្រមទាំងមានសិទ្ធិផ្តល់យោបល់ ប្រសិនបើជាយល់ឃើញថា ការសម្រេចរបស់ក្រុមប្រឹក្សាភិបាលពុំត្រូវនឹងលក្ខខណ្ឌ ឬគោលដៅរបស់សហគ្រាស។

ដើម្បីឱ្យការជំទាស់នោះមានប្រសិទ្ធភាព មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរបញ្ជូនទៅកាន់ក្រុមប្រឹក្សាភិបាលក្រោយប្រជុំ០៣ ថ្ងៃ (គិតតែថ្ងៃធ្វើការ) និងរាយការណ៍បន្ទាន់ទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាលនៃសហគ្រាសសាធារណៈនោះ។ ក្នុងរយៈពេល០៤ថ្ងៃ បន្ទាប់ពីការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ បើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យា បាលនៃសហគ្រាសសាធារណៈនោះពុំបានចេញបញ្ញាឱ្យលុប

ចោល ឬកែប្រែសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនោះទេ មានន័យថាសេចក្តីសម្រេចនោះបានការ និងអាចយកទៅអនុវត្តបាន។

## ៧-សេចក្តីសន្និដ្ឋាន

ក្នុងការសិក្សាជំនាញរដ្ឋបាលសាធារណៈ យើងគប្បីយល់ថា ដើម្បីគ្រប់គ្រងរដ្ឋបាលសាធារណៈឱ្យកាន់តែមានភាពល្អប្រសើរឡើង រដ្ឋាភិបាលបានផ្ទេរអំណាចពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិ ដែលយើងហៅថា វិមជ្ឈការ។ គួរបញ្ជាក់ផងដែរថា វិមជ្ឈការចែកចេញជាពីរគឺ វិមជ្ឈការរដ្ឋបាល និង វិមជ្ឈការបច្ចេកទេស ឬដែលយើងស្គាល់ថាសហគ្រាសសាធារណៈ។ សហគ្រាសសាធារណៈមាន៣ទម្រង់គឺ ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចម្រុះ និងគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច។ តំណាងរបស់រដ្ឋក្នុងក្រុមប្រឹក្សានៃសហគ្រាសសាធារណៈទាំង៣ទម្រង់ទទួលខុសត្រូវទាំងស្រុងដោយខ្លួនឯង លើផ្នែកព្រហ្មទណ្ឌ ប៉ុន្តែមិនមែនផ្នែករដ្ឋប្បវេណីឡើយ ដោយរដ្ឋ ឬក្រុមហ៊ុនចម្រុះ ឬគ្រឹះស្ថានសាធារណៈ ជាអ្នកទទួលខុសត្រូវជំនួស ពីព្រោះការសម្រេចចិត្តដែលធ្វើឡើងដែលនាំឱ្យមានផលប៉ះពាល់ផ្នែករដ្ឋប្បវេណី ដើម្បីប្រយោជន៍សហគ្រាសប៉ុណ្ណោះ ដូច្នេះរដ្ឋមានតួនាទីទទួលខុសត្រូវរួមទាំងការដោះស្រាយបំណុលជាដើម។ មុនពេលបីឆ្នាំ បន្ទាប់ពីឈប់ធ្វើជាតំណាងរបស់រដ្ឋក្នុងក្រុមប្រឹក្សានៃក្រុមហ៊ុនរដ្ឋ ឬក្រុមហ៊ុនចម្រុះ ឬគ្រឹះស្ថានសាធារណៈ តំណាងរបស់រដ្ឋពុំអនុញ្ញាតឱ្យធ្វើការនៅសហគ្រាសសាធារណៈចាស់នោះឡើយលុះត្រាតែមានការអនុញ្ញាតពិសេសពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ជំពូកទី៦

# សញ្ញាណទូទៅនៃលទ្ធកម្មសាធារណៈ

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១-សញ្ញាណទូទៅនៃលទ្ធកម្មសាធារណៈ*

*២- ប្រសិទ្ធភាពនៃការគ្រប់គ្រងការធ្វើលទ្ធកម្ម*

*៣- របនាសម្ព័ន្ធលទ្ធកម្មសាធារណៈ*

*៤- ប្រភេទនៃលទ្ធកម្មសាធារណៈ*

*៥- សេចក្ដីសន្និដ្ឋាន*

## ១-សញ្ញាណទូទៅនៃលទ្ធកម្មសាធារណៈ

### ១-១-និយមន័យ

លទ្ធកម្ម - ជាការទិញ ជួល ឬទទួលបាននូវទំនិញ សំណង់ស៊ីវិល និងសេវាកម្ម។ លទ្ធកម្មសាធារណៈ ប្រព្រឹត្តទៅដោយប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈ ស្របតាមច្បាប់ និងបទប្បញ្ញត្តិ និងនីតិវិធីរបស់ប្រទេស ឬភ្នាក់ងារផ្ដល់ជំនួយណាមួយ។

លទ្ធកម្មឯកជន - ការធ្វើលទ្ធកម្មដោយក្រុមហ៊ុនឯកជន ឬដោយបុគ្គល។

ការធ្វើលទ្ធកម្មមានគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការផ្គត់ផ្គង់ ការផ្គត់ផ្គង់សេវាកម្ម និងការផ្គត់ផ្គង់សេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃនិងភាពទាន់ពេលវេលា ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈ ឯកភាពមួយនៅព្រះរាជាណាចក្រកម្ពុជា។ ការធ្វើលទ្ធកម្ម មានវិសាលភាពអនុវត្តចំពោះគ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពធនធាន លើកលែងតែកិច្ចលទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍដែលត្រូវអនុវត្តតាមគោលការណ៍ណែនាំនិងនីតិវិធីដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីគោលការណ៍ណែនាំ និងនីតិវិធីលទ្ធកម្មណាមួយផ្សេងទេ ដំណើរការលទ្ធកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់។ លទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិ និងសន្តិសុខសាធារណៈ ដែល

ត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី។ការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋដែលត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដោយឡែក[121]។

-លទ្ធកម្ម ៖ សំដៅដល់ការទិញទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រ ដែលមានចែងក្នុងច្បាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-កិច្ចការលទ្ធកម្ម៖ សំដៅដល់ដំណើរការលទ្ធកម្ម ចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។

-លទ្ធកម្មសាធារណៈ ៖ សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័នរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័ត អង្គភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជនសាធារណៈ។

-ស្ថាប័នអនុវត្តលទ្ធកម្ម ៖សំដៅក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហរិញ្ញវត្ថុដទៃទៀត និងដៃគូរឯកសាធារណៈ ដែលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

---

[121] ព្រះរាជក្រម នស/រកម/០១១២/០០៤ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ ជំពូកទី១ មាត្រាទី១២ និង ទី៣ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលអនុម័ត។

-អង្គភាពថវិកា ៖ សំដៅអង្គភាព ដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវ និងមានភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារក្នុងការរៀបចំ និងគ្រប់គ្រងថវិកាព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធកម្មនៃការអនុវត្តសកម្មភាពការងារនិងការអនុវត្តថវិកាដោយខ្លួនឯងស្របតាមគោលការណ៍និងនិតិវិធីរបស់ក្រសួងស្ថាប័ន។

-ទំនិញ ៖ សំដៅដល់វត្ថុ រឹង ឧស្ម័ន ដែលមានតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ចដូចជាគ្រឿងចក្រឧបករណ៍សម្ភារៈ បរិក្ខារ គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗរួមទាំងអគ្គិសនីផងដែរ។

-សំណង់៖សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការងារសាងសង់ការងារជួសជុលការធ្វើឡើងជាថ្មី ការដំឡើង ការជីកការបូម និងការងារប្រហាក់ប្រហែលដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារនិងបច្ចេកវិទ្យា។

-សេវាកម្ម ៖ សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមនុស្សគ្រឿងបរិក្ខារ ឬបច្ចេកវិទ្យា ដែលនាំមកនូវប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និងសេវាទីប្រឹក្សាទេ។

-សេវាទីប្រឹក្សា៖សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សា ឯកត្តជនដែលពាក់ព័ន្ធនឹងគម្រោងណាមួយ ឬសម្រាប់ការពង្រឹងពង្រីកស្ថាប័ន ឬបង្កើនសមត្ថភាព។

-ទីប្រឹក្សា៖ សំដៅដល់ទីប្រឹក្សាឯកត្តជន ឬក្រុមហ៊ុនទីប្រឹក្សាដែលមានមុខរបរផ្តល់សេវាផ្នែកបញ្ញា[122] ឬចំណេះពិសោធន៍។

## ២-ប្រសិទ្ធភាពនៃការគ្រប់គ្រងការធ្វើលទ្ធកម្ម

### ក-ប្រសិទ្ធភាពនៃប្រព័ន្ធលទ្ធកម្ម

-តម្លាភាព

-គណនេយ្យភាព

-ប្រសិទ្ធភាព

-សន្សំសំចៃ

-សុចរិតភាព

-ប្រកួតប្រជែង

-ចំណេះដឹង និងគ្រប់គ្រងព័ត៌មាន

-ការគ្រប់គ្រង ធនធានមនុស្ស

-ទម្រង់បែបបទការងាររដ្ឋបាលជាក់លាក់

[122] ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៣៨១សហវ ប្រកចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ (ឯកឧត្តម គាត ឈន់) ទំព័រលេខ២ និងលេខ៣)

**ក-១-តម្លាភាព**

គឺជាវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់ស្ថាប័នលទ្ធកម្ម ដោយត្រូវផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយទំនាក់ទំនងទាំងអស់ដែលអាចធ្វើទៅបាន ហើយត្រូវអនុវត្តក្នុងលក្ខណៈបើកចំហ និងមានភាពច្បាស់លាស់ ដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់យល់ដឹងអំពីដំណើរការ និងនីតិវិធីលទ្ធកម្ម ហើយត្រូវផ្សព្វផ្សាយឱ្យទូលំទូលាយព័ត៌មាននៃនានានៃការដេញថ្លៃ។ គ្រប់ករណី និងគ្រប់កាលៈទេសៈទាំងអស់។ កិច្ចលទ្ធកម្មត្រូវធ្វើឡើងស្របតាមឯកសារដេញថ្លៃ និងកិច្ចសន្យាដែលមានលក្ខណៈស្តង់ដារ ហើយលទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។ គ្រប់ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មត្រូវកកត់ត្រាឱ្យបានច្បាស់លាស់ និងរក្សាទុកនូវកំណត់ត្រា និងឯកសារពាក់ព័ន្ធឱ្យបានគង់វង្សព្រមទាំងផ្តល់លទ្ធភាពដល់សាធារណជន និងអ្នកពាក់ព័ន្ធនានាអាចទទួលបាននូវឯកសារទាំងនេះ ប្រសិនបើមានតម្រូវការ។

**ក-២--គណនេយ្យភាព**

រាល់តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ច្បាស់លាស់ ហើយត្រូវទទួលខុសត្រូវ និងប្រព័ន្ធរបាយការណ៍សម្រាប់កិច្ចលទ្ធកម្ម ហើយមន្ត្រីពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្មត្រូវមានការយល់ដឹងអំពីការទទួលខុសត្រូវ និងប្រព័ន្ធរបាយការណ៍។

**ក-៣-ប្រសិទ្ធភាព**

កិច្ចដំណើរការលទ្ធកម្មត្រូវធ្វើឡើងស្របតាមច្បាប់ វិធាន និង

បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ឬឯកជនដែលមានជាធរមាន ហើយរាល់កិច្ចលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ឬសេវាទីប្រឹក្សា ត្រូវផ្អែកតាមឯកសារដេញថ្លៃ និងឯកសារពិគ្រោះថ្លៃ និងឯកសារស្ទង់តម្លៃត្រឹមត្រូវ ជាពិសេស ចំពោះលក្ខណៈបច្ចេកទេស ស្តង់ដារគុណភាព និងបរិមាណពិតប្រាកដ។ កិច្ចការលទ្ធកម្មត្រូវធ្វើឡើងតាមពេលវេលាកំណត់ និងមានប្រសិទ្ធភាពស្របតាមផែនការលទ្ធកម្ម។

**ក-៤-សន្សំសំចៃ**

ស្ថាប័នលទ្ធកម្មត្រូវខិតខំធ្វើកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមតម្រូវការចាំបាច់ តាមពេលវេលា និងក្នុងតម្លៃសមស្រប។គុណភាពនៃទំនិញ សំណង់ និងសេវាកម្ម ឬសេវាទីប្រឹក្សា ត្រូវឆ្លើយតបនឹងលក្ខណៈបច្ចេកទេសស្តង់ដារ និងកម្រិតតម្លៃ ដើម្បីធានាដល់ការសន្សំសំចៃ កត្តាមួយចំនួនដែលត្រូវពិចារណា រួមមានដូចជា តម្លៃដាក់ដេញថ្លៃ ផលប៉ះពាល់លើបរិស្ថាន ហានិភ័យក្នុងការអនុវត្តកិច្ចសន្យាដោយសារអ្នកដេញថ្លៃពុំមានបទពិសោធន៍ឬធនធានគ្រប់គ្រាន់ដែលអាចបំពេញបាននូវការអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ភាពសមស្របនៃទំនិញ សំណង់ ឬសេវាកម្ម អាយុកាលប្រើប្រាស់នៃទំនិញសំណង់ ឬសេវាកម្ម ការចំណាយសម្រាប់ប្រតិបត្តិការ ការថែទាំ និងការផ្តល់សេវារយៈពេលប្រគល់ទទួលថ្លៃចំណាយដឹកជញ្ជូនបន្តថ្លៃចំណាយក្នុងការស្តុកទុកពេលវេលាចំណាយសម្រាប់ធ្វើកិច្ចលទ្ធកម្ម។

**ក-៥-សុចរិតភាព**

កិច្ចដំណើរការលទ្ធកម្មត្រូវធ្វើឡើងប្រកបដោយភាពត្រឹមត្រូវ

ភាពស្មោះត្រង់ និងមានក្រមសីលធម៌ ដោយបង្ហាញនូវភាពទៀងត្រង់ក្នុងកម្រិតខ្ពស់បំផុត ដើម្បីជានាដល់ផលប្រយោជន៍សាធារណៈហើយគ្រប់អ្នកពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការលទ្ធកម្មមិនត្រូវពាក់ព័ន្ធជាមួយនឹងអំពើពុករលួយ អំពើឃុបឃិត អំពើបន្លំ ឬអំពើបង្ខិតបង្ខំឡើយ។ រាល់បុគ្គលដែលពាក់ព័ន្ធនឹងដំណើរការដេញថ្លៃ ត្រូវប្រកាស និងបង្ហាញឱ្យបានដឹងជាមុនអំពីទំនាស់ផលប្រយោជន៍ជាក់ស្តែង មុនពេលចូលរួមក្នុងការវាយតម្លៃសំណើដេញថ្លៃ ឬសំណើពិគ្រោះថ្លៃ ឬសំណើស្នងតម្លៃ។

**ក-៦-ភាពប្រកួតប្រជែង**

អ្នកដេញថ្លៃត្រូវមានចំនួនជាអតិបរមាចូលរួមក្នុងដំណើរការដេញថ្លៃ កិច្ចលទ្ធកម្មត្រូវបានធ្វើឡើងតាមរយៈការដេញថ្លៃ ដែលមានលក្ខណៈប្រកួតប្រជែងជាសាធារណៈ លើកលែងតែករណីដែលបានកំណត់ក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ហើយកិច្ចដំណើរការលទ្ធកម្មត្រូវធានាឱ្យមានការប្រកួតប្រជែងប្រកបដោយសមភាពក្នុងចំណោមអ្នកចូលរួមដេញថ្លៃ និងត្រូវធានាថា គ្មានអ្នកដេញថ្លៃណាម្នាក់មានឥទ្ធិពលទៅលើលទ្ធផលនៃការដេញថ្លៃ[123]។

**ក-៧-ចំណេះដឹង និងគ្រប់គ្រងព័ត៌មាន**

ដំណើរការលទ្ធកម្មមួយដែលប្រកបដោយចំណេះដឹង និង

---

[123] សេចក្តីណែនាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ០០២ សហវ អលសា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទំព័រ ២ដល់ទំព័រ ៤

ព័ត៌មានបានសេចក្ដីថា ជាដំណើរការនៃការដេញថ្លៃមួយដែលតាំងពីពេលចាប់ផ្ដើមរហូតដល់ទីបញ្ចប់ភាគីពាក់ព័ន្ធ និងដៃគូចូលរួមបានដឹងបានឮ និងទទួលបានព័ត៌មានទូលំទូលាយបានគ្រប់ជ្រុងជ្រោយនៃដំណើរការទាំងមូលដោយគ្មានការសង្ស័យ ឬមន្ទិលថា ដំណើរការទាំងមូលនេះមានពុធត្បុត ឬចរិកលាក់បាំងអ្វីមួយជាប្រយោជន៍ភាគីទាំងពីរ( អ្នករៀបចំ និងអ្នកដេញថ្លៃបាន )មានប្រយោជន៍ពីដំណើរការនេះ។

**ក-៨-ការគ្រប់គ្រង ធនធានមនុស្ស**

រាល់ដំណើរនៃការដេញថ្លៃធនធានមនុស្សជាកត្តាសំខាន់បំផុត។ គ្រប់នីតិវិធីដេញថ្លៃសុទ្ធតែត្រូវដំណើរបានដោយច្បាប់ និងបទបញ្ញាផ្សេងៗ។ ការអវត្តមាននៃនីតិវិធីណាមួយនៃដំណើរការដេញថ្លៃជាអំពើខុសច្បាប់ ហើយអាចកម្មវត្ថុនៃការបដិសេសធន៍នៃបញ្ចប់លទ្ធកម្មទាំងអស់។

**ក-៩-ទម្រង់បែបបទការងាររដ្ឋបាលជាក់លាក់**

លទ្ធកម្មមួយដែលលេចជារូបរាងបានត្រូវដំណើរតាមបែបបទរដ្ឋបាលមួយប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ។ ការប្រាសចាកពីបែបបទរដ្ឋបាលនៃនីតិវិធីទាំងឡាយដែលបានកំណត់នៅក្នុងការណែនាំនិងផែនការលទ្ធកម្មនឹងត្រូវបានផ្សព្វ-ផ្សាយយ៉ាងទូលំទូលាយហើយ ធានាថារាល់កិច្ចលទ្ធកម្មទាំងអស់ជាលទ្ធផលនៃការជឿទុកចិត្តបាន។

**ខ-ជំហានក្នុងការធ្វើលទ្ធកម្មសាធារណៈ**

-រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ

-អនុម័តលើគម្រោងលទ្ធកម្មសាធារណៈជាផ្លូវការ

-អនុវត្ត និង ដំណើរការលើគម្រោងលទ្ធកម្មសាធារណៈ

-រៀបចំប្រព័ន្ធតាមដានការងារលទ្ធកម្មជាប្រចាំ

-រៀបចំ និងគ្រប់គ្រងកិច្ចសន្យា

-ការកត់ត្រា និងតម្កល់ឯកសារ-កាលប្បវត្តិ។

**គ-រចនាសម្ព័ន្ធគណៈកម្មាធិការការលទ្ធកម្ម**

យោងតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលអនុម័តឲ្យប្រើប្រាស់កាលពីឆ្នាំ២០១២ បានបញ្ជាក់ថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ និងមានសិទ្ធិអំណាចរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ ព្រមទាំងអនុវត្តសិទ្ធិអំណាចដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងៗដូចមានរៀបរាប់លើចំណុចខាងលើ។

នាយកដ្ឋានលទ្ធកម្មសាថារណៈ ដែលជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានតម្លើងមកជាអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈដែលស្ថិតនៅក្នុងចំណុះរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដដែល។ ផ្អែកតាមច្បាប់នេះដដែលទៀតសោត គណៈកម្មាធិការកំណត់បុរេលក្ខណសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យាដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈពីឆ្នាំ២០០៦ ត្រូវប្តូរឈ្មោះទៅជាគណៈកម្មាធិការលទ្ធកម្ម ហើយប្រធានស្ថាប័ន ជា

ប្រធានគណៈកម្មាធិការលទ្ធកម្ម[124]។ ក្នុងឆ្នាំ២០១៥ អនុលោមតាមមាត្រា៩នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងប្រកាសលេខ២៤៩ សហវ. ប្រក ចុះថ្ងៃទី៣ខែមីនាឆ្នាំ២០១៥ក្រុមលទ្ធកម្មត្រូវបានបង្កើត និងដំណើរការអនុវត្តកិច្ចលទ្ធកម្មនៅគ្រប់អង្គភាពថវិកាដែលបានទទួលសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ[125]។ បច្ចុប្បន្ន ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្តតាមបែបវិសហមជ្ឈការលទ្ធកម្ម។ ក្នុងន័យនេះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានពីរកម្រិតគឺកិច្ចលទ្ធកម្មសាធារណៈ ដែលពិនិត្យសម្រេចដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្ទាល់ និងកិច្ចលទ្ធកម្មសាធារណៈ ដែលតម្រូវឱ្យមានការពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ របាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានីខេត្តត្រូវបានរៀបចំ និងបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណែក របាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបូកសរុប រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយឡែករបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំរបស់

---

[124] ព្រឹត្តិបត្រស្ថិតិលទ្ធកម្មសាធារណៈ(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)៖ ឆ្នាំ២០១៩ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ទំព័រ៤។

[125] សូមរកមើលប្រកាស២៤៩ សហវ ប្រក ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

មន្ទីរជំនាញរាជធានី ខេត្ត ត្រូវបានរៀបចំ និងបញ្ជូនទៅអង្គភាពលទ្ធកម្មរបស់សាមីក្រសួង ស្ថាប័នដើម្បីបូកសរុប រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណែកឯរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំ និងបញ្ជូនផ្ទាល់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដើម្បីជានាការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅដោយរលូនប្រកប ដោយតម្លាភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលាព្រមទាំងធានាបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលបានបង្កើតអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម[126] ។ អនុក្រឹត្យនេះ បានកំណត់យន្តការដឹកនាំ និងគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងស្ថាប័នអនុវត្តលទ្ធកម្ម។ ដូចបានរៀបរាប់ខាងលើស្ថាប័នអនុវត្តលទ្ធកម្មត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយដើម្បីដឹកនាំ គ្រប់គ្រង ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឲ្យស្របតាមគោលការណ៍ វិធាន វិធីសាស្ត្រ និងនីតិវិធី ដែលត្រូវបាន

---

[126] អនុក្រឹត្យលេខ១៣ អនក្រ.បក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាព លទ្ធកម្ម ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។

កំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ។ ដូចគ្នាដែរ ស្ថាប័នអនុវត្តលទ្ធកម្មនីមួយៗក៏ត្រូវបង្កើតអង្គភាពលទ្ធកម្មមួយ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្រប ដើម្បីទទួលខុសត្រូវរាល់កិច្ចលទ្ធកម្មសាធារណៈ។ រចនាសម្ព័ន្ធនេះត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌទូទាំងប្រទេស ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប៉ុន្តែលំហូរការងាររបស់ថ្នាក់ជាតិមានលក្ខណៈខុសប្លែកគ្នាមួយចំនួនពីថ្នាក់ជាតិ។

**រចនាសម្ព័ន្ធស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ**




### ឃ.គណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាការធិការលទ្ធកម្ម ផ្តុំទៅដោយសមាសភាពដូចជា ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម អនុប្រធាន ឬថ្នាក់ដឹកនាំ នៃស្ថាប័នអនុវត្តលទ្ធកម្ម ប្រធាន និង/ឬ អនុប្រធាន នៃអង្គភាពទទួលបន្ទុកកិច្ចការ

ហិរញ្ញវត្ថុដែលអាចជាអគ្គលេខាធិការដ្ឋានអគ្គនាយកដ្ឋាននាយកដ្ឋាន ឬ ការិយាល័យ និងប្រធានអង្គភាពលទ្ធកម្ម។ គណៈកម្មាធិការលទ្ធកម្ម អាចមានតំណាងអង្គភាពបច្ចេកទេសពាក់ព័ន្ធមុខសញ្ញាលទ្ធកម្ម ធ្វើជាសមាជិកចំពោះកិច្ចដោយពេញច្បាប់ អាស្រ័យទៅតាមគម្រោងនីមួយៗ។ អាស្រ័យហេតុនេះហើយ សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការលទ្ធកម្មត្រូវបានកំណត់ច្បាស់លាស់ និងតែងតាំងដោយប្រកាស សេចក្តីសម្រេច ឬដីការរបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។ គណៈកម្មាធិការលទ្ធកម្មមានភារកិច្ច[127] ជាសារវ័ន្តដូចខាងក្រោម៖

-ពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលរៀបចំដោយអង្គភាពលទ្ធកម្មមុននឹងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច

-ត្រួតពិនិត្យ និងណែនាំអង្គភាពលទ្ធកម្មឲ្យអនុវត្តតាមផែនការ លទ្ធកម្មឱ្យបានត្រឹមត្រូវ

-ពិនិត្យ វាយតម្លៃ និងកំណត់បុរេលក្ខណសម្បត្តិ ចំពោះកិច្ចលទ្ធកម្ម ដែលមានលក្ខណៈស្មុគស្មាញ

-ពិនិត្យឡើងវិញ លើទំហំទឹកប្រាក់នៃកញ្ចប់លទ្ធកម្មនីមួយៗ ដោយផ្ទៀងផ្ទាត់ជាមួយផែនការលទ្ធកម្ម មុននឹងចាប់ផ្តើមដំណើរការ

---

[127] អនុក្រឹត្យលេខ១៣ អនក្រ.បក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។

លទ្ធកម្ម

-ពិនិត្យ និងសម្រេច លើឯកសារដេញថ្លៃ ដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន ឬសម្រេចបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងផ្តល់ទិដ្ឋិការចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្នង់តម្លៃ ឬចរចាថ្លៃ

-ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា

-ត្រួតពិនិត្យ និងវាយតម្លៃលើលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ មុនការសម្រេចប្រគល់កិច្ចសន្យា ឬបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចចំពោះកិច្ចលទ្ធកម្ម ដែលត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅមុនការសម្រេចប្រគល់កិច្ចសន្យា

-ជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់

-ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ

-គ្រប់គ្រង និងតាមដានការអនុវត្តកិច្ចសន្យា

-អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមសង្កេតការណ៍គ្រប់ដំណាក់កាល នៃកិច្ចលទ្ធកម្មសាធារណៈលើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា

-ពិនិត្យ និងដោះស្រាយ បណ្តឹងពាក់ព័ន្ធកិច្ចលទ្ធកម្ម តាម

សមត្ថកិច្ចរបស់ខ្លួន

-រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ង-អង្គភាពលទ្ធកម្ម**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតអង្គភាពលទ្ធកម្មមួយ ដោយប្រកាស សេចក្តីសម្រេច ឬ ដីកា ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ព្រមទាំងមានសិទ្ធិអំណាចសមស្រប ដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ អង្គភាពលទ្ធកម្មនេះ មានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់ និងជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម។ សម្រាប់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ការបង្កើតអង្គភាពលទ្ធកម្ម ត្រូវធ្វើឡើងដោយអង្គភាពប្រតិបត្តិដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាភិបាល។ អង្គភាពលទ្ធកម្មនេះ ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានចំនួនពីររូបយ៉ាងច្រើនជាជំនួយការ។ ប្រធានអង្គភាពលទ្ធកម្ម មិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ។ ចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃ

ទៀត ប្រធានអង្គភាពលទ្ធកម្មមានឋានៈក្រោមអនុប្រធាននាយកដ្ឋាន តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល និងបទបញ្ជាផ្ទៃក្នុងរបស់ ធរមាន។

ប្រធានអង្គភាពលទ្ធកម្ម ត្រូវមានមានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬ ផ្នែកហិរញ្ញវត្ថុ រួមទាំងមានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច៣ឆ្នាំ និងធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លក្ខខណ្ឌនេះមិនគ្រប់គ្រាន់ទេ ប្រធានអង្គភាពលទ្ធកម្មគួររាប់បញ្ចូលចំពោះអ្នកមានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រផងដែរពីព្រោះថា ភាគច្រើននៃកិច្ចការនេះជាកិច្ចសន្យាមិនមែនជាជំនាញផ្នែកហិរញ្ញវត្ថុ ឬសេដ្ឋកិច្ចមួយមុខនោះទេ។

អង្គភាពលទ្ធកម្មបំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្មដោយមានភារកិច្ច[128]ជាសារវន្តដូចខាងក្រោម៖

-រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬ ផែនការលទ្ធកម្មកែតម្រូវក្នុងករណីចាំបាច់

-រៀបចំឯកសារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង

[128] អនុក្រឹត្យលេខ១៣ អនក្រ.បក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥

ហិរញ្ញវត្ថុ

-រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីការដេញថ្លៃ

-លក់ ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងការដេញថ្លៃ

-ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ

-រៀបចំ និងគ្រប់គ្រងសំណើដេញថ្លៃ រួមទាំងឯកសារពាក់ព័ន្ធដែលបានទទួលប្រកបដោយភាពត្រឹមត្រូវ សុវត្ថិភាព មុនពេលបើកសំណើដេញថ្លៃ

-រៀបចំបើកសំណើដេញថ្លៃជាសាធារណៈ ដោយមានការត្រួតពិនិត្យពីគណៈកម្មាធិការលទ្ធកម្ម

-រៀបចំរបាយការណ៍ឬកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្នង់តម្លៃ ឬចរចាថ្លៃ

-សម្របសម្រួលការវាយតម្លៃលើលក្ខណៈបច្ចេកទេសនៃសំណើដេញថ្លៃ

-ឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើរដេញថ្លៃ

-រៀបចំលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា ដល់អ្នកដេញថ្លៃឈ្នះ និងចម្លងជូនអ្នកដេញថ្លៃចាញ់ទាំងអស់

-រៀបចំការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ

-រៀបចំសេចក្តីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យាដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត

-តាមដានការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា

-រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។

**ច-ប្រភេទនៃលទ្ធកម្មសាធារណៈ**

លទ្ធកម្មសាធារណៈចែកចេញជាបួនប្រភេទធំៗរួមមាន៖

-ប្រភេទទី១ ៖ លទ្ធកម្មទំនិញ

-ប្រភេទទី២ ៖ លទ្ធកម្មសំណង់

-ប្រភេទទី៣ ៖ លទ្ធកម្មសេវាកម្មទីប្រឹក្សា

-ប្រភេទទី៤ ៖ លទ្ធកម្មសេវាមិនមែនសេវាទីប្រឹក្សា

**១-លទ្ធកម្មទំនិញ និងលទ្ធកម្មសំណង់**

**១-១-សញ្ញាណទូទៅ**

អង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្ម ត្រូវប្រមូលផ្តុំនូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកា តាមប្រភេទលទ្ធកម្ម ទំនិញ សំណង់ ឬលទ្ធកម្មសេវាកម្មមិនមែនទីប្រឹក្សា។ បន្ទាប់ពីទទួលបានទិន្នន័យនៃតម្រូវការប្រើប្រាស់ប្រចាំឆ្នាំដែលបានមកពីអង្គភាពប្រើប្រាស់ នៃស្ថាប័នអនុវត្តលទ្ធកម្ម មានដូចជា ស្ថាប័នជាតិ ថ្នាក់

ក្រោមជាតិ ឬសហគ្រាសសាធារណៈជាដើមនោះ អង្គភាពលទ្ធកម្ម ឬក្រុមការងារលទ្ធកម្មរបស់ស្ថាប័ននីមួយៗ ត្រូវសិក្សាអំពីតម្រូវការលក្ខណៈបច្ចេកទេស ទំនិញ សំណង់ សេវាកម្ម និងកត្តាចាំបាច់នានានៃមុខសញ្ញាលទ្ធកម្មនីមួយៗ ដើម្បីរៀបចំឡូត៍លទ្ធកម្ម និងកញ្ចប់លទ្ធកម្ម។

ឡូត៍លទ្ធកម្ម គឺជាការប្រមូលផ្តុំបញ្ចូលជាក្រុមតែមួយនូវតម្រូវការទំនិញ សំណង់ សេវាកម្ម ដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឲ្យការងារតែមួយ ដូចជា គ្រឿងសង្ហារិម សម្ភារៈការិយាល័យឬប្រេងឥន្ធនៈ សម្រាប់ទំនិញ ឬការសាងសង់តូចតាចមួយចំនួនដែលស្ថិតនៅជិតៗគ្នាជាដើម។

រីឯកញ្ចប់លទ្ធកម្ម ជាការប្រមូលផ្តុំបញ្ចូលគ្នា នូវឡូត៍លទ្ធកម្មដែលមានលក្ខណៈដូចគ្នាឬស្រដៀងគ្នាសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើកដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង និងចំណេញពេលវេលាព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយ។ ទាក់ទងនឹងការរៀបចំប្រមូលផ្តុំជាឡូត៍លទ្ធកម្ម និងកញ្ចប់លទ្ធកម្មនេះ ច្បាប់មិនអនុញ្ញាតឲ្យមានការបំបែកគម្រោងទៅជាគម្រោងតូចៗ[129] ដើម្បីបញ្ចៀសការដេញថ្លៃជាសាធារណៈនោះទេ ដែលវាបំពានដល់វិធីសាស្ត្រលទ្ធកម្ម ឬតម្រូវតាមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាឡើយ។ ទំនិញដូចជាឧបករណ៍ការិយាល័យ គ្រឿង

[129] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២ មាត្រា៣៣ ទំព័រ១០

សង្ហារឹម រថយន្ត ឬបោះពុម្ពសៀវភៅ។ល។ ការរៀបចំត្រូវផ្អែកលើកត្តាមួយចំនួនដូចខាងក្រោម៖

-តម្លៃជាកត្តាចម្បង

-មិនសូវមានការចរចា

-ការដេញថ្លៃគឺត្រូវបើកជាសាធារណៈ

-ការប្រកួតប្រជែងមានលក្ខណៈបើកទូលាយ

-សេវាមិនមែនជាសេវាទីប្រឹក្សា សេវាដូចជាដឹកខ្ចង សេវាថែទាំឧបករណ៍។

**១.២. នីតិវិធីលទ្ធកម្ម(Procurement procedures)**

ចំពោះលទ្ធកម្មទំនិញ សំណង់ សេវាមិនមែនសេវាទីប្រឹក្សា មានវិធីសាស្ត្រ៤ធំៗ ដែលត្រូវប្រើលើកលែងករណីពិសេស ដែលចាំបាច់ត្រូវប្រើវិធីសាស្ត្រលទ្ធកម្មដោយឡែក ត្រូវសុំការសម្រេចជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធីសាស្ត្រ៤ធំៗ រួមមាន៖

-ការដេញថ្លៃប្រកួតប្រជែងលក្ខណៈអន្តរជាតិ (International Competition Bidding)

-ការដេញថ្លៃប្រកួតប្រជែងលក្ខណៈជាតិ (National Competition Bidding)

-ការពិគ្រោះថ្លៃ (Shopping with advertisement)

-ស្ទង់តម្លៃ (Shopping without advertisement)

-ចំពោះករណីពិសេសរបស់លទ្ធកម្មទំនិញ សំណង់ សេវាមិនមែនសេវាទីប្រឹក្សា រួមមាន៖

-ការចុះកិច្ចសន្យាផ្ទាល់ (Direct Contracting)

-ការដេញថ្លៃលក្ខណៈអន្តរជាតិមានកម្រិត (Limited International Bidding)

-ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នអនុវត្តលទ្ធកម្ម (Procurement Agent)

-លទ្ធកម្មភាគកម្មសហគមន៍ (Community Participant in Procurement) ។

### ១.៣. ដំណើរការនៃការដេញថ្លៃ (Bidding Process)

-វាយតម្លៃពីតម្រូវការ

-ជ្រើសរើសនីតិវិធីលទ្ធកម្ម

-រៀបចំឯកសារដេញថ្លៃ

-ផ្សព្វផ្សាយជាសាធារណៈ

-ទទួល និង បើកការដេញថ្លៃ

-វាយតម្លៃឯកសារដេញថ្លៃ

-ការសម្រេចប្រគល់កិច្ចសន្យា

-ការគ្រប់គ្រងកិច្ចសន្យា

-ការទទួល និង ត្រួតពិនិត្យ

-ការទូទាត់ ។

### ១.៤. នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម

អង្គភាពលទ្ធកម្ម ត្រូវអនុវត្តកិច្ចលទ្ធកម្ម ស្របតាមផែនការលទ្ធកម្ម និងឯកសារដេញថ្លៃ ដែលបានទទួលទិដ្ឋាការយល់ព្រមរួច

ហើយ។ វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១១ មាត្រា១២ និងមាត្រា១៣ នៃច្បាប់លទ្ធកម្មសាធារណៈ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងសាធារណៈ[130] ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើស អ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយបើកចំហចំពោះគ្រប់អ្នកដេញថ្លៃក្នុងស្រុក និងអន្តរជាតិ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់ និងដែលត្រូវជំរុញឲ្យប្រើក្នុងកិច្ចលទ្ធកម្មសាធារណៈ។

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងរួមមាន៖

ក-ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិៈ វិធីសាស្ត្រនេះត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានទឹកប្រាក់កម្រិតធំ និងមានលក្ខណៈបច្ចេកទេសខ្ពស់។

ខ-ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុកៈ វិធីសាស្ត្រនេះត្រូវប្រើក្នុងករណីដែលមានផលិតផល ផលិតកម្ម សេវាកម្ម ឬសមត្ថភាពសាងសង់ក្នុងស្រុកគ្រប់គ្រាន់។

<u>វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត</u>[131]

ជាវិធីសាស្ត្រលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ រួមមាន៖

---

[130] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២ មាត្រា១១ ទំព័រ៥

[131] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២ មាត្រា១២ ទំព័រ៥

ក-ការដេញថ្លៃមានកម្រិត ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មគន្លឹះមានលក្ខណៈបច្ចេកទេសស្មុគស្មាញមិនអាចរៀបចំបច្ចេកទេសទុកជាមុន និងមានអ្នកដេញថ្លៃតិចតួចដែលមានសមត្ថភាព វិធីសាស្ត្រនេះ តម្រូវឲ្យមានការធ្វើបុរេលក្ខណសម្បត្តិ។

ខ-ការពិគ្រោះថ្លៃ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មមានរួចជាស្រេច នៅលើទីផ្សារក្នុងស្រុក និងមានទឹកប្រាក់មធ្យម។

គ-ការស្នង់តម្លៃជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញអ្នកទទួលការសំណង់ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើនៅពេលមុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារងស្រុក និងមានទឹកប្រាក់ទាប។

<u>វិធីសាស្ត្រលទ្ធកម្មដោយឡែក[132]</u> ត្រូវប្រើសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយមិនមានការដេញថ្លៃ។ វិធីសាស្ត្រនេះ អាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វិធីសាស្ត្រលទ្ធកម្មដោយឡែក រួមមាន៖

---

[132] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០១២ មាត្រា១៣ ទំព័រ៦

ក-ការចុះកិច្ចសន្យាផ្ទាល់ ជាវិធីសាស្ត្រលទ្ធកម្ម ដែលតម្រូវឲ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម៖

-មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ

-មុខសញ្ញាលទ្ធកម្មដែលត្រូវបានដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈម្តងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់ និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២

-ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២ មិនទទួលបានជោគជ័យ

-តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឲ្យប្រើវិធីសាស្ត្រផ្សេងទៀតបានសម្រាប់គោលបំណងសិក្សាស្រាវជ្រាវដកបទពិសោធ ឬអភិវឌ្ឍ។

ខ-ការបន្តចុះកិច្ចសន្យា ជាវិធីសាស្ត្រលទ្ធកម្ម ដែលតម្រូវឲ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈដូចខាង ក្រោម

-មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ

-ស្ថិតក្នុងអំឡុងពេលមិនលើសពី ៦(ប្រាំមួយ) ខែ បន្ទាប់ពី

កិច្ចសន្យាដើមចូលជាធរមាន និងស្ថិតនៅក្នុងឆ្នាំថវិកាតែមួយ

-តម្លៃឯកតាស្មើ ឬ ទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម និង

-តម្លៃសរុបមិនលើសពី២៥(ម្ភៃប្រាំ) ភាគរយនៃតម្លៃកិច្ចសន្យាដើម។

គ-ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ជាវិធីសាស្ត្រលទ្ធកម្ម ដែលតម្រូវឲ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយនឹងអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋ ដែលមានធនធានគ្រឿងចក្រ ឧបករណ៍ សម្ភារៈបរិក្ខា និងកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា។

ឃ-ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ ជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវបានប្រើសំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កម្លាំងពលកម្មចំណេះដឹងនិងសម្ភារៈ ក្នុងស្រុកសម្រាប់ចូលរួមក្នុងការអភិវឌ្ឍសហគមន៍។

**១.៥-ដំណើរការនៃការដេញថ្លៃ**

អង្គភាពលទ្ធកម្ម នៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ផ្សព្វផ្សាយ ដើម្បីជ្រើសរើសអ្នកដេញថ្លៃ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ[133] ត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោមៈ

---

[133] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២ មាត្រា៣៨ ទំព័រ១១។

-ការពណ៌នាអំពីប្រភេទ និងបរិមាណទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្ម

-ឈ្មោះ អាសយដ្ឋាន អ៊ីមែល ទូរស័ព្ទ និងទូរសាររបស់អង្គភាពលទ្ធកម្ម

-វិធីសាស្រ្តលទ្ធកម្ម ដែលត្រូវអនុវត្ត

-លក្ខខណ្ឌតម្រូវនានា នៃលក្ខណសម្បត្តិ ឬបុរេលក្ខណសម្បត្តិ

-កាលបរិច្ឆេទលក់ ទទួល និងបើកឯកសារដេញថ្លៃ ឬឯកសារកំណត់បុរេលក្ខណសម្បត្តិ

-ការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

អង្គភាពលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈនេះដោយបញ្ជាក់ពីលក្ខខណ្ឌតម្រូវ និងលក្ខណវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឲ្យបានច្បាស់លាស់សម្រាប់ដាក់ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្មពិនិត្យ និងចុះហត្ថលេខា។ ចំពោះកិច្ចលទ្ធកម្ម ដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃពីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ[134]។ កិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនគ្របដណ្តប់លើកិច្ចលទ្ធកម្ម ដែលអនុវត្តដោយឃុំសង្កាត់ឡើយ។

សេចក្តីជូនដំណឹងស្តីពីបុរេលក្ខណសម្បត្តិ ការដេញថ្លៃ និងសេចក្តីកែសម្រួលនានាត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្មសាធារណៈ និងតាមសារព័ត៌មាន ហើយត្រូវបិទផ្សាយនៅលើក្តារបិទផ្សាយព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។ ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃណាមួយអំពីឯកសារដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ។ ក្នុងករណីចាំបាច់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃ ដែលបានទទួលឯកសារដេញថ្លៃមកចូលរួម។

អង្គភាពលទ្ធកម្មត្រូវទទួលចុះបញ្ជី និងរៀបចំរក្សាទុកសំណើដេញថ្លៃដែលដាក់ក្នុងស្រោមសំបុត្របិទភ្ជិតនៅកន្លែងមានសុវត្ថិភាព ដោយមិនត្រូវប៉ះពាល់ឲ្យខូចទម្រង់ដើមនៃស្រោមសំបុត្រដាក់សំណើដេញថ្លៃនោះទេ មុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ។ រាល់សំណើដេញថ្លៃត្រូវភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការដេញថ្លៃ

---

[134] មើល ប្រកាស០១០ សហវ.ប្រក ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩។

លើកលែងតែសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្តង់តម្លៃ។ ប្រាក់កក់ធានាការដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សំណើដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ។ ព័ត៌មានសំខាន់ៗ នៃសំណើដេញថ្លៃអស់ ត្រូវប្រកាសនៅចំពោះមុខអ្នកចូលរួមបើកសំណើដេញថ្លៃ និងត្រូវកត់ត្រាក្នុងកំណត់ហេតុបើកសំណើដេញថ្លៃ រួចចម្លងជូនគ្រប់អ្នកដេញថ្លៃ និងអ្នកចូលរួមបើកសំណើដេញថ្លៃទាំងអស់។ ប្រសិនបើក្នុងដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មមិនត្រូវបើកសំណើដេញថ្លៃទាំងនោះឡើយ ហើយត្រូវបញ្ជូនត្រឡប់ ឬរំសាយអង្គប្រជុំដោយប្រកាសប្រាប់ទៅឲ្យអ្នកដេញថ្លៃវិញអំពោះមូលហេតុច្បាប់។ ក្នុងករណីដែលដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបីមែន ឬពុំទទួលបានសំណើដេញថ្លៃ ឬពុំមានសំណើដេញថ្លៃណាមួយឆ្លើយតបនឹងលក្ខខណ្ឌនៃការដេញថ្លៃនោះ ត្រូវដំណើរការដេញថ្លៃឡើងវិញ។ ក្នុងដំណើរការដេញថ្លៃឡើងវិញ ទោះបីទទួលបានសំណើដេញថ្លៃចំនួនប៉ុន្មានក៏ដោយ ក៏ត្រូវតែដំណើរការបើកសំណើដេញថ្លៃទាំងនោះតាមកាលបរិច្ឆេទកំណត់។ គណៈកម្មាធិការលទ្ធកម្មត្រូវពិនិត្យវាយតម្លៃលើសំណើដេញថ្លៃទាំងអស់ជាសម្ងាត់។ លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យដែលមានចែងក្នុងឯកសារដេញថ្លៃ ព័ត៌មានប្តឹងជំទាស់ និងកំណត់ហេតុបើកសំណើដេញថ្លៃគឺជាមូល

ដ្ឋានសម្រាប់វាយតម្លៃប្រគល់កិច្ចសន្យា។ លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនមានចែងក្នុងឯកសារដេញថ្លៃ មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ក្នុងការវាយតម្លៃឡើយ។ នីតិវិធីវាយតម្លៃលើសំណើដេញថ្លៃ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មុននឹងចាប់ផ្តើមត្រួតពិនិត្យ និងវាយតម្លៃលើសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មនីមួយៗ សមាជិកគណៈកម្មាធិការលទ្ធកម្ម ដែលត្រូវចូលរួមវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មដូចមានចែងក្នុងជំពូកទី ១១ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈនេះ។ បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។ចំពោះកិច្ចលទ្ធកម្ម ដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចលទ្ធកម្ម ដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើកលែងតែកិច្ចលទ្ធកម្ម ដែលអនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ប្រសិនបើមិនមានការជំទាស់តវ៉ាណាមួយក្នុងរយៈពេល១០(ដប់)

ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា អង្គភាពលទ្ធកម្មត្រូវស្នើឲ្យអ្នកដេញថ្លៃឈ្នះផ្តល់នូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងត្រូវរៀបចំកិច្ចសន្យាលទ្ធកម្មដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់នេះ។ ការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកដេញថ្លៃឈ្នះ។ ក្នុងករណីដែលកិច្ចលទ្ធកម្មត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចសន្យាលទ្ធកម្ម ត្រូវមានការចុះហត្ថលេខាបញ្ជាក់ការយល់ព្រមបន្ថែមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចាត់ចែងគ្រប់គ្រងកិច្ចសន្យា ដើម្បីធានាឲ្យការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

**១.៦-រយៈពេលកំណត់សម្រាប់អនុវត្តកិច្ចលទ្ធកម្ម**

ការរៀបចំសម្រាប់អនុវត្តកិច្ចលទ្ធកម្ម[135] ត្រូវបានបែងចែកជាដំណាក់កាលៗ ហើយដំណាក់កាលនីមួយៗ មានរយៈពេលកំណត់ផ្សេងៗគ្នា ទៅតាមប្រភេទផ្សេងៗគ្នានៃវិធីសាស្ត្រលទ្ធកម្ម។

**១-៧-ដំណាក់កាលនៃការកំណត់បុរេលក្ខណសម្បត្តិ**

ដំណាក់កាលនេះ អាចប្រព្រឹត្តទៅបាន តែក្នុងករណីចាំបាច់

[135] ប្រកាស៨៥១ សហវ.ប្រក ស្តីពីការរៀបចំផែនការលទ្ធកម្ម ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៧ ជំពូក៧ កម្មវិធីការងារសម្រាប់អនុវត្តកិច្ចលទ្ធកម្ម និងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

ប៉ុណ្ណោះ និងមានរយៈពេលយ៉ាងយូរ៤៣ថ្ងៃ។ នៅក្នុងដំណាក់កាលនេះក្រុមលទ្ធកម្ម ធ្វើការរៀបចំឯកសារបុរេលក្ខណសម្បត្តិនានា និងធ្វើការពិនិត្យយល់ព្រមលើឯកសារទាំងនោះ។ ក្រៅពីនេះក្រុមលទ្ធកម្ម ធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការអញ្ជើញចូលរួមបុរេលក្ខណសម្បត្តិ និងបើកទទួលសំណើបុរេលក្ខណសម្បត្តិ ដើម្បីធ្វើការពិនិត្យ និងវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

### ១-៨-ដំណាក់កាលនៃការរៀបចំ ការពិនិត្យ និងការអនុម័តលើឯកសារដេញថ្លៃ

ដំណាក់កាលនេះ ក្រុមការងារលទ្ធកម្ម ធ្វើការរៀបចំឯកសារដេញថ្លៃ និងពិនិត្យយល់ព្រមលើឯកសារដេញថ្លៃ ព្រមទាំងផ្ដល់ទិដ្ឋាការ យល់ព្រមលើឯកសារដេញថ្លៃដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីការស្នើសុំ លើសសិទ្ធិសម្រេចនៃដែនកំណត់របស់ក្រសួងសាម៉ី។ ក្នុងដំណាក់កាលនេះ ប្រើប្រាស់ពេលវេលាពី៤ថ្ងៃទៅដល់១៣ថ្ងៃ អាស្រ័យលើទម្រង់នៃវិធីសាស្ត្រលទ្ធកម្ម ដែលយកមកប្រើប្រាស់។

### ១-៩-ដំណាក់កាលនៃការផ្សព្វផ្សាយ ការលក់ឯកសារដេញថ្លៃ

ក្នុងដំណាក់កាលនេះស្ថាប័នអនុវត្តលទ្ធកម្មធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការអញ្ជើញចូលរួមដេញថ្លៃ ការលក់ឯកសារដេញថ្លៃបើកទទួលយកសំណើដេញថ្លៃនិងធ្វើការបើកសំណើដេញថ្លៃ

នៅក្នុងដំណាក់កាលនេះ ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិប្រើប្រាស់រយៈ ពេលយូរជាងការដេញថ្លៃបែបផ្សេងៗ គឺប្រើប្រាស់រយៈពេល៦០ថ្ងៃ រីឯការស្ទង់តម្លៃ ប្រើប្រាស់រយៈពេលតិចជាងគេត្រឹម៧ថ្ងៃ ។

## ១-១០-ដំណាក់កាលនៃការវាយតម្លៃលើសំណើដេញថ្លៃ

ដំណាក់កាលវាយតម្លៃលើសំណើដេញថ្លៃ ជាដំណាក់កាលនៃការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃនាំមុខ រួចធ្វើការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ។ បន្ទាប់ពីត្រួតពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិរួចហើយ គណៈកម្មាធិការលទ្ធកម្ម ឬក្រុមលទ្ធកម្មធ្វើការពិនិត្យ និងធ្វើការសម្រេច។ ក្នុងករណីលើសសិទ្ធិសម្រេចត្រូវមានការត្រួតពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដំណាក់កាលនេះ ប្រើប្រាស់រយៈពេលពី៤ថ្ងៃទៅដល់២៥ថ្ងៃ។

## ១-១១-ដំណាក់កាលនៃការចុះកិច្ចសន្យា

បន្ទាប់ពីទទួលបានការវាយតម្លៃលើសំណើដេញថ្លៃរួច ក្រុមលទ្ធកម្មធ្វើការរៀបចំលិខិតជូនដំណឹងស្តីការសម្រេចប្រគល់កិច្ចសន្យា ដោះស្រាយការប្តឹងតវ៉ាផ្សេងៗ និងធ្វើការរៀបចំអញ្ជើញ ព្រាង និងចុះហត្ថលេខាលើកិច្ចសន្យា។ ដំណាក់កាលនេះ ប្រើប្រាស់រយៈពេលពី៤ថ្ងៃទៅដល់២៦ថ្ងៃ។

## ១-១២-ដំណាក់កាលនៃការគ្រប់គ្រងនិងការអនុវត្តកិច្ចសន្យា

ក្រុមលទ្ធកម្ម ក្នុងដំណាក់កាលនេះ ធ្វើការត្រួតពិនិត្យការអនុ

វត្តកិច្ចសន្យា ព្រមទាំងធ្វើការការប្រគល់ និងទទួលលើកិច្ចលទ្ធកម្ម ដោយជានាគុណភាព។ ការប្រគល់ទទួល ត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព លក្ខណៈបច្ចេកទេស និងស្របតាមពេលវេលា ដែលបានកំណត់ក្នុងកាលវិភាគប្រគល់ទទួល ដូចមានចែងក្នុងកិច្ចសន្យា និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់គណៈកម្មាការប្រគល់ទទួល។

**១-១៣-ដំណាក់កាលនៃការទូទាត់**

នៅក្នុងដំណាក់កាលនេះ បានបញ្ជាក់នូវកាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់ និងទូទាត់ទឹកប្រាក់ទៅតាមត្រីមាសនីមួយៗ។ យោងតាមប្រកា២៧ នៃប្រកាស្តីពីការរៀបចំផែនការលទ្ធកម្ម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការទូទាត់ ត្រូវបានកំណត់ក្នុងរយៈពេលយ៉ាងយូរ៤៥ថ្ងៃ បន្ទាប់ពីការប្រគល់ទទួល។

**១-១៤-ការចែកចាយឯកសារដេញថ្លៃ**

ឯកសារដេញថ្លៃ សំដៅលើឯកសារដេញថ្លៃ សម្រាប់ទំនិញ សំណង់ សេវាកម្មមិនមែនទីប្រឹក្សា។ ឯកសារដេញថ្លៃ ត្រូវផ្សព្វផ្សាយលើគេហទំព័រលទ្ធកម្មសាធារណៈ។ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ត្រូវរៀបចំឯកសារដេញថ្លៃឲ្យបានគ្រប់គ្រាន់ សម្រាប់លក់ជូនអ្នក ដែលមានបំណងចូលរួមដេញថ្លៃ។ បែបបទ និងការកំណត់ថ្លៃលក់ឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១-១៥-កម្រិតទឹកប្រាក់**

ការកំណត់លក្ខខណ្ឌ និងកម្រិតទឹកប្រាក់ និងនីតិវិធីសម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ គឺមានលក្ខណៈខុសប្លែកគ្នា ដូចបានរៀបរាប់នៅចំណុចខាងលើ។ តារាងខាងក្រោម គឺជាកម្រិតទឹកប្រាក់ ដែលចែងតាមប្រភេទលទ្ធកម្មនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រអនុវត្តវិធីសាស្ត្រលទ្ធកម្មនៅក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល[136]

| **វិធីសាស្ត្រ** | **កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម** | | |
|---|---|---|---|
| | **ទំនិញ** | **សំណង់** | **សេវាកម្ម** |
| ការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ(ដ.ប.អ) | ចាប់ពី ៥.០០០លានរៀលឡើង | ចាប់ពី ៦.០០០លានរៀលឡើង | ចាប់ពី ៤.០០០លានរៀលឡើង |
| ការដេញថ្លៃដោយប្រកួត | ចាប់ពី ១០០ លានរៀល | ចាប់ពី ១០០ លានរៀល | ចាប់ពី ១០០ លានរៀល |

[136] ប្រកាសលេខ១៨៦៦ សហវ ប្រ.ក ស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឧបសម្ព័ន្ធទី១។

| | | | |
|---|---|---|---|
| ប្រដែងក្នុងស្រុក(ដ.ប.ស) | ដល់ក្រោម ៥.០០០លានរៀល | ដល់ក្រោម ៦.០០០លានរៀល | ដល់ក្រោម ៤.០០០លានរៀល |
| ការដេញថ្លៃមានកម្រិត (ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ (ព.ថ) | ចាប់ពី ២០ លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ២០ លានរៀល ដល់ក្រោម ១០០លានរៀល | ចាប់ពី ២០ លានរៀល ដល់ក្រោម ១០០លានរៀល |
| ការស្ទង់តម្លៃ (ស.ត) | ក្រោម ២០ លានរៀល | ក្រោម ២០ លានរៀល | ក្រោម ២០ លានរៀល |
| លទ្ធកម្មដោយទ្បែក (ល.ឡ) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |

តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ[137]

| វិធីសាស្ត្រ | កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | **ទំនិញ** | **សំណង់** | **សេវាកម្ម** |
| ការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ(ដ.ប.អ) | ចាប់ពី ២.០០០លានរៀលឡើង | ចាប់ពី ២.៥០០លានរៀលឡើង | ចាប់ពី ១.៥០០លានរៀលឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក(ដ.ប.ស) | ចាប់ពី ១០០ លានរៀលដល់ក្រោម ២.០០០លានរៀល | ចាប់ពី ១០០ លានរៀលដល់ក្រោម ២.៥០០លានរៀល | ចាប់ពី ១០០ លានរៀលដល់ក្រោម ១.៥០០លានរៀល |
| ការដេញថ្លៃមានកម្រិត (ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ (ព.ថ) | ចាប់ពី ១០ លានរៀល | ចាប់ពី ២០ លានរៀល | ចាប់ពី ១០ លានរៀល |

[137] ប្រកាស ១៨៦៦ សហវ ប្រ.ក ស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មឆ្នាំ២០១៤ ឧបសម្ព័ន្ធទី២

| | | | |
|---|---|---|---|
| | ដល់ក្រោម ១០០លាន រៀល | ដល់ក្រោម ១០០លាន រៀល | ដល់ក្រោម ១០០លាន រៀល |
| ការស្ទង់តម្លៃ (ស.ត) | ក្រោម ១០ លានរៀល | ក្រោម ១០ លានរៀល | ក្រោម ១០ លានរៀល |
| លទ្ធកម្មដោយខ្សែក (ល.ខ្ស) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |

## ៣-លទ្ធកម្មសេវាទីប្រឹក្សា

### ៣-១-សញ្ញាណទូទៅ

ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជនដើម្បីផ្តល់សេវាឯកទេសសម្រាប់គ្រប់គ្រង គម្រោងអនុវត្តកិច្ចសន្យាឬផ្តល់យោបល់ជំនាញការងារពង្រឹងពង្រីកស្ថាប័នឬបង្កើមសមត្ថភាព។ ក្រុមហ៊ុនទីប្រឹក្សាត្រូវបានជ្រើសរើសនៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ។ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវផ្អែកលើសំណើបច្ចេកទេស និងសំណើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សានីមួយៗ។

ទីប្រឹក្សាឯកត្តជន ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណ

សម្បត្តិរបស់ទីប្រឹក្សាសម្រាប់ផ្ដល់សេវាជូនស្ថាប័នអនុវត្តលទ្ធកម្ម[138]។

សេវាទីប្រឹក្សា ជាទូទៅមានរយៈពេល និងទំហំការងារកំណត់ច្បាស់ ហើយសេវាកម្មនេះជាទូទៅមានលក្ខណៈជាជំនាញវិជ្ជាជីវៈ សេវាពិគ្រោះយោបល់ ការសិក្សាគោលនយោបាយការបង្កើតយុទ្ធសាស្ត្រ ការបណ្ដុះបណ្ដាល ការវិភាគផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.២ នីតិវិធីលទ្ធកម្ម

នីតិវិធីលទ្ធកម្មក្រុមហ៊ុនទីប្រឹក្សា និង ទីប្រឹក្សាឯកត្តជន រួមមាន[139] ៖

-ការជ្រើសរើសផ្អែកលើគុណភាព : វិធីសាស្ត្រនេះ ត្រូវបានគេប្រើនៅពេលដែលគុណភាព គឺជាការពិចារសំខាន់បំផុតក្នុងដំណើរការជ្រើសរើស ។ការផ្សព្វផ្សព្វផ្សាតអំពីតម្រូវការជ្រើសរើសត្រូវប្រកាស ទាំងនៅក្នុងស្រុក និងក្រៅស្រុក ហើយត្រូវធ្វើបញ្ជីជ្រើសរើសខ្លីពីក្នុងចំណោមក្រុមហ៊ុននានាដែលមានចំណាប់អារម្មណ៍។ បន្ទាប់មកទីប្រឹក្សាទាំងអស់ត្រូវបានស្នើសុំឱ្យដាក់សំណើបច្ចេកទេសហើយសំណើនីមួយៗត្រូវបានចាត់លំដាប់ថ្នាក់ផ្អែកតាមពិន្ទុបច្ចេកទេសដោយផ្ទៀងផ្ទាត់ជាមួយនឹងលក្ខណៈវិនិច្ឆ័យ ដែលចែងនៅក្នុងសំណើ

---

[138] ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២

[139] សៀវភៅលទ្ធកម្ម ស្ដីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្ដី ពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៣៨១ សហវ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

ផ្តល់សេវាទីប្រឹក្សា។ ក្រុមហ៊ុនដែលមានពិន្ទុបច្ចេកទេសខ្ពស់បំផុត ត្រូវបានអញ្ជើញមុនគេមកចរចាប្រគល់កិច្ចសន្យា ដោយផ្អែកលើ សំណើបច្ចេកទេស និងសំណើហិរញ្ញវត្ថុ។ វិធីសាស្ត្រនេះប្រើសមស្រ មតែ ការសិក្សាអំពីសេដ្ឋកិច្ចក្នុងស្រុក ឬអំពីផ្នែកនានា ការសិក្សាអំពី លទ្ធភាពពហុផ្នែកការបង្កើតរោងចក្រដែលកាត់បន្ថយកាកសំណល់ គ្រោះថ្នាក់ ឬផែនការមេសម្រាប់អភិវឌ្ឍន៍ទីក្រុង ឬកំណែទម្រង់ផ្នែក ហិរញ្ញវត្ថុ។ ទី២ ការងារដែលមានផលប៉ះពាល់ខ្លាំង ហើយគោល បំណងរបស់វា គឺតម្រូវឱ្យមានជំនាញការប្រសើរបំផុត ឧទាហរណ៍ដូច ជា ការសិក្សាអំពីលទ្ធភាព និងរៀបចំផែនការកសាងហេដ្ឋារចនាស ម្ព័ន្ធធំៗ ដូចជាទំនប់ទឹក ការសិក្សា ពីគោលនយោបាយដែលជា សារ សំខាន់ដល់ប្រទេសជាតិ ការសក្សាអំពីការគ្រប់គ្រងរបស់ក្រសួង និង ស្ថាប័នធំៗរបស់រាជរដ្ឋាភិបាល។

-ការជ្រើសរើសផ្អែកលើគុណភាព និងថ្លៃ :

-ការជ្រើសរើសផ្អែកលើគុណភាព និងថ្លៃអន្តរជាតិ គឺត្រូវ ផ្សព្វផ្សាយអំពីតម្រូវការ។ ជ្រើសរើសក្នុងស្រុក និងអន្តរជាតិ ហើយ ក▯រវ▯យតម្លៃធ្វើឡើងដោយកំណត់ពិន្ទុផ្នែកបច្ចេកទេស(សំណើ បច្ចេកទេស) រួចហើយទៅពិនិត្យលើពិន្ទុផ្នែកហិរញ្ញវត្ថុតាមក្រោយ។ ជាទូទៅ Ratio នៃការវាយតម្លៃសំណើទាំងពីរនោះគឺ ៨០:២០ ( បច្ចេកទេស ៨០ ពិន្ទុ និង ហិរញ្ញវត្ថុ ២០ពិន្ទុ ) ។ ក្រោយពីវាយតម្លៃ

បច្ចេកទេសគុណភាពបានចប់ និងទទួលបានលិខិតមិនយល់ទាស់ពីក្រសួងសេដ្ឋកិច្ច ឬដៃគូអភិវឌ្ឍន៍ ត្រូវបើកប្រជុំជាសាធារណៈ ដោយអញ្ជើញតំណាងក្រុមហ៊ុនមកចូលរួម រួចប្រកាសពីពិន្ទុបច្ចេកទេស ហើយបើកសំណើហិរញ្ញវត្ថុ និងកំណត់ពិន្ទុលើសំណើហិរញ្ញវត្ថុនៃគម្រោងនីមួយៗ។ ក្រុមហ៊ុនណាដែលមានពិន្ទុបច្ចេកទេសខ្ពស់បំផុត និងត្រូវមកចរចាប្រគល់កិច្ចសន្យាមុនគេ ដោយផ្អែកលើសំណើបច្ចេកទេស និងសំណើហិរញ្ញវត្ថុ។

ការជ្រើសរើសផ្អែកលើគុណភាព និងថ្លៃក្នុងស្រុក ប្រើសម្រាប់គ្រប់លទ្ធកម្មសេវាកម្មទីប្រឹក្សាដែលមានទឹកប្រាក់ស្ថិតនៅក្រោម កម្រិតបានកំណត់របស់ក្រសួងសេដ្ឋកិច្ចហើយនៅពេលធ្វើបញ្ជីជំរើស គឺធ្វើបញ្ជីទីប្រឹក្សាក្នុងស្រុកតែប៉ុណ្ណោះ។ វិធីសាស្ត្រនេះដូចគ្នានឹងវិធីសាស្ត្រ ការជ្រើសរើសផ្អែកលើគុណភាព និងថ្លៃអន្តរជាតិ ខុសតែវិធីសាស្ត្រប្រើប្រាស់គំរូឯកសារដេញថ្លៃក្នុងស្រុក ហើយការប្រកាសការផ្សព្វផ្សាយតែនៅក្នុងស្រុកប៉ុណ្ណោះ។

-ការជ្រើសរើសផ្អែកលើថវិកាកំណត់ : វិធីសាស្ត្រនេះប្រើសម្រាប់ការងារធម្មតាដែលបានកំណត់ថវិកា និងទិសដៅច្បាស់លាស់ ការផ្សព្វផ្សាយពីតម្រូវការ ត្រូវធ្វើឡើងទាំងក្នុងស្រុក និងអន្តរជាតិ។ សំណើដេញថ្លៃ ត្រូវប្រាប់អោយដឹងពីថវិកាដែលមានរួចក្រុមហ៊ុនត្រូវដាក់សំណើបច្ចេកទេសតម្រូវតាមថវិកាដែលមាននោះ។ បន្ទាប់ពីការ

វាយតម្លៃសំណើបច្ចេកទេស ដូចវិធីសាស្ត្រដូចគ្នាទៅនឹងការជ្រើសរើសផ្អែកលើគុណភាព និងថ្លៃអន្តរជាតិដែរ។ ក្រុមហ៊ុនដែលដាក់សំណើលើសពីចំនួនថវិកាដែលមានត្រូវបដិសេធ។ ចំណែកឯក្រុមហ៊ុនដែលបានពិន្ទុខ្ពស់បំផុតលើសំណើបច្ចេកទេស ហើយសំណើហិរញ្ញវត្ថុស្ថិតនៅក្នុងកំរិតថវិកាដែលមានត្រូវបានអញ្ជើញមកចរចាដើម្បីចុះកិច្ចសន្យា។

-ការជ្រើសរើសផ្អែកលើថ្លៃទាបបំផុតៈ វិធីសាស្ត្រនេះសមស្របតែសេវាទីប្រឹក្សា ដែលមានលក្ខណៈបទដ្ឋាន និងមានការរៀបចំបានល្អដូចជាសវនកម្ម និងការងារវិសកម្មដែលមិនស្មុគស្មាញ ដោយផ្អែកលើការប្រកួតប្រជែងថ្លៃ ឬសម្រាប់សេវាទីប្រឹក្សាដែលមានលក្ខណៈជាស្តង់ដាររួមស្តង់ដារវិជ្ជាជីវៈហើយលក្ខណៈសម្បត្តិរបស់ទីប្រឹក្សាអាចត្រូវបានរំពឹងទុកថានឹងផ្តល់សេវាមានគុណភាពប្រហាក់ប្រហែលគ្នា។ វិធីសាស្ត្រនោះគឺសំណើដេញថ្លៃត្រូវបានកំណត់ពិន្ទុទាបបំផុតលើបច្ចេកទេស បន្ទាប់មកបដិសេដលើសំណើណាដែលមានពិន្ទុបច្ចេកទេសមិនដល់ពិន្ទុទាបបំផុត។ សំណើបច្ចេកទេសដែលស្ថិតក្នុងកម្រិតទាបបំផុត ត្រូវបានយកមកពិនិត្យមើលសំណើហិរញ្ញវត្ថុទៀតមុនពេលផ្តល់ ឬចរចាប្រគល់កិច្ចសន្យា។

-ការជ្រើសរើសផ្អែកលើការចរចាផ្ទាល់ : វិធីសាស្ត្រនេះប្រើប្រាស់តែក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះរួមមាន ៖

-ការងារបន្តពីការងារមុន ដែលត្រូវបានអនុវត្តដោយទីប្រឹក្សា

-ករណីបន្ទាន់បំផុតដែលត្រូវឱ្យមានការឆ្លើយតបភ្លាមៗ

-ករណីមានតែទីប្រឹក្សាម្នាក់ប៉ុណ្ណោះដែលមានសម្ថភាព និង បទពិសោធន៍

-ការជ្រើសរើសផ្អែកលើលក្ខណសម្បត្តិ : វិធីសាស្ត្រនេះប្រើប្រាស់សម្រាប់ការ ជ្រើសរើសទីប្រឹក្សាឯកត្តជនតែប៉ុណ្ណោះ។

ការជ្រើសរើសតាមវិធីសាស្ត្រនេះត្រូវផ្អែកលើចំណេះដឹងកម្រិត ជំនាញវិជ្ជាជីវៈ បទពិសោធន៍ ហើយសម្រាប់តែការងារតូចៗ និងងាយៗ មានទឹកប្រាក់នៅក្រោមកម្រិតកំណត់ ហើយផ្សព្វផ្សាយពីតម្រូវការត្រូវធ្វើទាំងនៅក្នុងស្រុក និងអន្តរជាតិ។ ទីប្រឹក្សាណាដែលមានលក្ខណៈសម្បត្តិប្រសើរជាងគេនឹងត្រូវបានចរចាប្រគល់ កិច្ចសន្យា។

**៣-៣-ដំណើរការនៃការជ្រើសរើសសេវាទីប្រឹក្សា** [140]

**៣-៣-ក-**ការរៀបចំឯកសារដេញថ្លៃ ៖ អង្គភាពលទ្ធកម្ម ត្រូវផ្ទៀងផ្ទាត់សញ្ញាលទ្ធកម្មឡើងវិញដើម្បីជានាមុខសញ្ញាលទ្ធកម្មដែលបានស្នើឡើងមាននៅក្នុងផែនការលទ្ធកម្ម និងថវិកាប្រចាំឆ្នាំ។ ស្នើសុំ

---

[140] សៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៣៨១ សហវ ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

ទិដ្ឋាការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើឯកសារ ដេញថ្លៃ នៅពេលណា ដែលតម្រូវឲ្យមាន។

**៣-៣-ខ-**ការជូនដំណឹងស្ដីពីការដេញថ្លៃសេវាទីប្រឹក្សា ៖ ការផ្សព្វផ្សាយសេចក្ដីជូនដំណឹងត្រូវមានលក្ខណៈទូលំទូលាយ តាមរយៈគេហទំព័រ បញ្ជរព័ត៌មាន ឬតាមគេហទំព័រលទ្ធកម្មសាធារណសារព័ត៌មាន និងមធ្យោបាយផ្សេងៗទៀត។ ផ្ដល់ការឆ្លើយតបជាលាយល័ក្ខណ៍អក្សរដែលបានស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរ ហើយក្នុងករណីចាំបាច់ត្រូវរៀបចំនូវកិច្ចប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណើផ្ដល់សេវាទីប្រឹក្សាដើម្បីឆ្លើយបំភ្លឺ ដោយត្រូវអញ្ជើញទីប្រឹក្សាទាំងអស់ដែល បានទទួលឯកសារដេញថ្លៃសេវាទីប្រឹក្សាចូលរួម។

**៣-៣-គ-**ការទទួល និងការរក្សាទទួលទុកសំណើផ្ដល់សេវាទីប្រឹក្សា៖ សំណើរបស់ទីប្រឹក្សាត្រូវទទួលតាមកាលបរិច្ឆេទកំណត់ដូចមាននៅក្នុងសេចក្ដីជូនដំណឹងហើយរក្សាទុកសំណើផ្ដល់សេវាទីប្រឹក្សានៅទីមានសុវត្ថិភាពរហូតដល់ថ្ងៃបើកសំណើផ្ដល់ទីប្រឹក្សា។ ករណីដែលសំណើបច្ចេកទេសបានទទួលក្រោយកាលបរិច្ឆេទឈប់ទទួលសំណើ គណៈកម្មកាធិការលទ្ធកម្មរបស់ក្រសួង សាមី ឬក្រុងស្រុក ខណ្ឌ មិនត្រូវបើកមើលឡើយ ហើយត្រូវបញ្ជូនសំណើបច្ចេកទេសទាំងនោះទៅម្ចាស់ដើមវិញ។

**៣-៣-ឃ-**ការបើកសំណើផ្តល់សេវាទីប្រឹក្សា ៖ គណៈកម្មាធិការលទ្ធកម្មរបស់អង្គភាពលទ្ធកម្មអញ្ជើញទីប្រឹក្សាដែលបានដាក់សំណើផ្តល់សេវាទីប្រឹក្សា និងអ្នកពាក់ព័ន្ធដ៏ទៃទៀត ដើម្បីបើកសំណើបន្ទាប់ពីឈប់ទទួលសំណើ រួចធ្វើកំណត់ហេតុបើកសំណើផ្តល់សេវាទីប្រឹក្សា។ កិច្ចប្រជុំបើកសំណើបច្ចេកទេសគឺជាកិច្ចប្រជុំសាធារណៈ ហើយអាចដំណើរ ការបានលុះត្រាតែមានសមាជិកគណៈកម្មាធិការលទ្ធកម្មចូលរួមលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

**៣-៣-ង-**ការវាយតម្លៃសំណើផ្តល់សេវាទីប្រឹក្សា ៖ ការវាយតម្លៃសំណើផ្តល់ទីប្រឹក្សា ឬសំណើបច្ចេកទេស គឺដើម្បីកំណត់រកសំណើណាមួយដែលឆ្លើយតបទៅនឹងលក្ខណៈបច្ចេកទេសដែលបានកំណត់នៅក្នុងឯកសារដេញថ្លៃសេវាទីប្រឹក្សា។ កិច្ចប្រជុំវាយតម្លៃសំណើបច្ចេកទេសគឺជាកិច្ចប្រជុំសម្ងាត់ ហើយអង្គភាពលទ្ធកម្មត្រូវរៀបចំតារាងទិន្ន័យវាយតម្លៃនៃសំណើបច្ចេកទេសនីមួយៗ និងផ្តល់តារាងនោះជូនគ្រប់សមាជិកគណៈកម្មការធិការលទ្ធកម្មវាយតម្លៃសំណើដោយឯករាជ្យ ដាច់ដោយឡែកពីគ្នា ទៅតាមថេរវេលាកំណត់ (បត់បែនទៅតាមទិដ្ឋភាពបច្ចេកទេសនៃសំណើសាមញ្ញ ឬស្មុគ-ស្មាញ)។ ចំពោះការវាយតម្លៃសំណើហិរញ្ញវត្ថុ ក៏ជាកិច្ចប្រជុំសម្ងាត់ និង តម្រូវអោយមានការចូលរួម (សមាជិកគណៈកម្មាធិការលទ្ធកម្ម)

ចំនួនពាក់កណ្តាល។ ការវាយតម្លៃលើសំណើហិរញ្ញវត្ថុនេះផងដែរ គណៈកម្មាធិការលទ្ធកម្មត្រូវ ៖

-ពិនិត្យផ្ទៀងផ្ទាត់តួលេខនៅក្នុងសំណើហិរញ្ញវត្ថុ ជាមួយនឹងសំណើបច្ចេកទេស

-ពិនិត្យផ្ទៀងផ្ទាត់លេខគណិត និងកែតម្រូវកំហុសឆ្គងលេខគណិត។

ក្នុងករណីដែលវិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃត្រូវបានប្រើសំណើហិរញ្ញវត្ថុដែលមានតម្លៃទាបជាងនឹងត្រូវទទួលបានពិន្ទុ១០០ ហើយសំណើហិរញ្ញវត្ថុផ្សេងៗទៀតត្រូវគណនាទៅតាមការកំណត់នៅក្នុងឯកសារដេញថ្លៃសេវាទីប្រឹក្សា។

គណៈកម្មាធិការលទ្ធកម្ម ត្រូវបូកសរុបពិន្ទុបច្ចេកទេស និងពិន្ទុហិរញ្ញវត្ថុបញ្ចូលគ្នា ហើយបន្ទាប់មកអញ្ជើញ ទីប្រឹក្សាដែលបានពិន្ទុសរុបខ្ពស់ជាងគេ (ពិន្ទុបច្ចេកទេស និងពិន្ទុហិរញ្ញវត្ថុ) ដើម្បីចរចាអំពីកិច្ចសន្យា។

ក្នុងករណីដែលវិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ត្រូវបានប្រើគណៈកម្មាធិការលទ្ធកម្មត្រូវជ្រើសរើសទីប្រឹក្សាដែលបានដាក់សំណើហិរញ្ញវត្ថុដែលមានតម្លៃទាបជាងគេ និងស្ថិតក្នុងកម្រិតទឹកប្រាក់ដែលបានកម្រិតទុក និងសំណើបច្ចេកទេសដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ ដើម្បីអញ្ជើញមកចរចាអំពីកិច្ចសន្យា។

ក្នុងករណីដែលវិធីសាស្ត្រជ្រើសរើសផ្អែកលើថ្លៃទាបបំផុតត្រូវបានប្រើគណៈកម្មាធិការលទ្ធកម្មត្រូវជ្រើសរើសទីប្រឹក្សាដែលបានដាក់សំណើហិរញ្ញវត្ថុដែលមានតម្លៃទាបជាងគេ ក្នុងចំណោមទីប្រឹក្សាដែលមានពិន្ទុបច្ចេកទេសក្នុងកម្រិតពិន្ទុដែលអាចទទួលយកបាន ដើម្បីអញ្ជើញមកចរចាអំពីកិច្ចសន្យា។

១-ការប្រគល់កិច្ចសន្យា ៖ អង្គភាពលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅឲ្យទីប្រឹក្សាដែលបានជ្រើសរើសដោយចម្លងជូនទៅគ្រប់ទីប្រឹក្សាផ្សេងៗទៀតដែលបានដាក់សំណើផ្តល់សេវាទីប្រឹក្សាតែមិនបានទទួលជោគជ័យ និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងទុកក្នុងរយៈពេល១០ថ្ងៃ (ថ្ងៃធ្វើការ) ដើម្បីឲ្យទីប្រឹក្សាទាំងនោះធ្វើការចោទសួរពីមូលហេតុ ដែលសំណើផ្តល់សេវាទីប្រឹក្សារបស់ខ្លួនមិនទទួលបានជោគជ័យ។ ប្រសិនបើទីប្រឹក្សាឈ្នះបដិសេធមិនទទួលយកសន្យានៅក្នុងអំឡុងពេលនៃសុពលភាពសំណើផ្តល់សេវាទីប្រឹក្សា ត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

២-ការចុះកិច្ចសន្យា ៖ ប្រសិនបើពុំមានការតវ៉ា ការចុះហត្ថលេខាលើកិច្ចសន្យាអាចធ្វើឡើងក្រោយដប់ថ្ងៃ(ថ្ងៃធ្វើការ)។ ការធ្វើកិច្ចសន្យាត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្ម និងទីប្រឹក្សាដែលឈ្នះលើសំណើទីប្រឹក្សា។ ក្នុងករណីដែលកិច្ចលទ្ធកម្មត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកិច្ចសន្យាលទ្ធកម្ម

ត្រូវមានការចុះហត្ថលេខាបញ្ជាក់ការយល់ព្រមបន្ថែមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកសារកិច្ចសន្យារួមមាន៖ លក្ខខណ្ឌនៃកិច្ចសន្យា លក្ខខណ្ឌការងារ សំណើបច្ចេកទេស សំណើហិរញ្ញវត្ថុ ប្រតិទិនការងារ សេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យានិងឯកសារផ្សេងៗទៀត (បើចាំបាច់)។ សម្រាប់កិច្ចសន្យាទំហំធំដែលត្រូវបានផ្សព្វផ្សាយជាអន្តរជាតិត្រូវបានរៀបចំធ្វើការចរចាជាមួយក្រុមហ៊ុនទីប្រឹក្សាដែលបានជ្រើសរើស ហើយរយៈពេលនៃការចរចាមានរយៈពេលចំនួន២ទៅ៥ថ្ងៃនៃថ្ងៃធ្វើការ។ចំពោះកិច្ចសន្យាជាមួយទីប្រឹក្សាឯកត្តជនតម្រូវឲ្យដាក់ប្រវត្តិរូបអាសយដ្ឋាន គណនីធនាគាររបស់ទីប្រឹក្សា ដើម្បីម្ចាស់គម្រោងបញ្ជូនសេចក្តីព្រាងកិច្ចសន្យាតាមរយៈអ៊ីម៉េលទៅទីប្រឹក្សាដើម្បីពិនិត្យ និងយល់ព្រម។

៣-ការត្រួតពិនិត្យ និងការគ្រប់គ្រងកិច្ចសន្យាសេវាទីប្រឹក្សា

កិច្ចសន្យាសេវាទីប្រឹក្សាអាចបញ្ជាក់ពីការទូទាត់ដោយផ្អែកលើមូលដ្ឋានពេលវេលា លទ្ធផលការងារ ថ្លៃឈ្នួល តម្លៃឯកតា ឬកម្រៃជើងសារ។ ដូច្នេះសកម្មភាពត្រួតពិនិត្យ និងគ្រប់គ្រងកិច្ចសន្យា ត្រូវផ្អែកលើលក្ខខណ្ឌជាក់លាក់នៃកិច្ចសន្យានីមួយៗ។ ការត្រួតពិនិត្យនេះត្រូវបានធ្វើឡើងដើម្បីធានាឲ្យបានថា កម្រិតសេវាកម្មត្រូវបានធានា ហើយលទ្ធផលការងារត្រូវបានដាក់ស្នើមកពិនិត្យ ឬបញ្ចប់សព្វ

គ្រប់ទាន់ពេលកំណត់ ហើយអនុវត្តបានយ៉ាយរហ័ស និងមានប្រសិទ្ធភាព។

**៣-៤-កម្រិតទឹកប្រាក់ក្នុងលទ្ធកម្មសេវាទីប្រឹក្សា** [141]

យោងតាមប្រកាសស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម លេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៤ បានកំណត់ថា វិធីសាស្ត្រដេញថ្លៃលទ្ធកម្មសេវាទីប្រឹក្សា ចាប់ពី៤,០០០លានរៀលឡើងទៅ ត្រូវជាការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងចាប់ពី១០០លានរៀលដល់ក្រោម ៤,០០០ លានរៀល ត្រូវជាការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក។

**៣-៥-លទ្ធកម្មមិនត្រឹមត្រូវ** ( Misprocurement )

លទ្ធកម្មមិនត្រឹមត្រូវ កើតឡើងនៅពេលណាទំនិញ សំណង់ ឬការជ្រើសរើសទីប្រឹក្សា ត្រូវបានប្រព្រឹត្តឡើងដោយប្រើប្រាស់នីតិវិធីផ្ទុយទៅនឹងនីតិវិធីដែលព្រមព្រាងនៅក្នុងកិច្ចព្រមព្រាងកម្ចី និងបញ្ជាក់នៅក្នុងផែនការលទ្ធកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិមិនទូទាត់ជូន និងកាត់ចោលកញ្ចប់ថវិកាទាំងឡាយណាដែលទាក់ទងនឹងកញ្ចប់លទ្ធកម្មដែលមិនត្រឹមត្រូវ។

រូបភាពនៃលទ្ធកម្មមិនត្រឹមត្រូវ [142] ៖

---

[141] ប្រកាសស្តីពី ការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម លេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៤

[142] Procurement Manual Volume I បោះពុម្ពដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១២។

- ❖ អំពើពុករលួយ៖ ការផ្តល់ជូន ឬទទួលអ្វីមួយដែលមានតម្លៃ ទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងមន្ត្រីសាធារណៈ ដើម្បីទទួលផលប្រយោជន៍ ឬអាទិភាពនៅក្នុងកិច្ចលទ្ធកម្ម។
- ❖ អំពើបោកប្រាស់៖ ផ្តល់ព័ត៌មានមិនពិត ឬបិទបាំងព័ត៌មាន។
- ❖ អំពើស៊ុមគ្រលំ៖ ការរៀបចំជាមុន ឬស៊ុមគ្រលំជាមួយអ្នកដេញថ្លៃដទៃ ដើម្បីកំណត់តម្លៃ និងកាត់បន្ថយភាពប្រកួតប្រជែង។

អំពើគំរាមកំហែង៖គំរាមកំហែងដោយផ្ទាល់ឬដោយប្រយោលដើម្បីទទួលបានផលប្រយោជន៍

## ៤-ការពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ពិនិត្យមុន vs. ពិនិត្យក្រោយ**

**ពិនិត្យមុន៖**

-ធ្វើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើដំណាក់កាលទាំងអស់នៃកិច្ចលទ្ធកម្ម

-កំណត់ដោយ “ ការកំណត់តម្លៃ” និងនីតិវិធីលទ្ធកម្មដែលប្រើ

ប្រាស់

-ប្រើប្រាស់សម្រាប់កិច្ចលទ្ធកម្មដែលមានតម្លៃខ្ពស់ និងស្មុគស្មាញ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ “ សេចក្តីយល់ព្រម”

តាមរយៈលិខិតមិនជំទាស់

**ពិនិត្យក្រោយ៖**

-ធ្វើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជារឿយៗ តាមពេលវេលាកំណត់ ក្រោយពេលកិច្ចលទ្ធកម្មត្រូវបានបញ្ចប់

-ប្រើប្រាស់សម្រាប់កិច្ចលទ្ធកម្មដែលមានតម្លៃទាប និងមិនស្មុគស្មាញ

## ៥-សេចក្តីសន្និដ្ឋាន

ជារួម ការធ្វើលទ្ធកម្មប្រកបដោយប្រសិទ្ធភាព និងការគោរពនីតិវិធីត្រឹមត្រូវនៅតាមស្ថាប័នរដ្ឋក្តី ឯកជនក្តីសុទ្ធតែជាប្រព័ន្ធការងារមួយដែលឆ្ពោះទៅរកគណនេយ្យភាព ការទទួលខុសត្រូវ សន្សំសំចៃ និងជំរុញឲ្យអភិបាលកិច្ចនៃស្ថាប័នទាំងនោះទទួលបានជោគជ័យ និងការជឿទុកចិត្តបាន។ ម្យ៉ាងវិញទៀត ដំណើរការនេះក៏ជាកត្តាមួយជំរុញឲ្យគុណភាពទំនិញ និងសមិទ្ធផលការងារទទួលបានគួរជាទីពេញចិត្តដែរ។ គ្រប់ស្ថាប័នទាំងអស់ និយាយដោយឡែក ស្ថាប័នរដ្ឋបច្ចុប្បន្នបាននិងកំពុងធ្វើការកែទម្រង់លើវិស័យហិរញ្ញវត្ថុសាធារណៈយ៉ាងត្រឹមត្រូវជាបណ្តើរៗក្នុងន័យធ្វើយ៉ាងណាឲ្យដំណើរការងារទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបានការគាំទ្រកាន់តែច្រើនឡើងៗពីប្រជារាស្ត្រ ជាពិសេសដៃគូអភិវឌ្ឍនានា។

# ជំពូកទី៧

# សវនកម្ម

*សម្រាប់ជំពូកនេះ នឹងបរិយាយអំពីចំណុចសំខាន់ៗដូចក្រោម៖*

*១- ទិដ្ឋភាពទូទៅនៃសវនកម្ម*

*២- ប្រភេទនៃសវនករ*

*៣- សវនករផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង*

*៤- សវនករផ្ទៃក្រៅ និងសវនកម្មផ្ទៃក្រៅ*

## ១-ទិដ្ឋភាពទូទៅនៃសវនកម្ម

នៅប្រទេសកម្ពុជា និយាយដោយឡែក អាជ្ញាធរជាតិសវនកម្ម ជាស្ថាប័នសវនកម្មកំពូលដែលពុំធ្លាប់មានតាំងពីជំនាន់មុនៗមក។ ស្ថាប័ននេះបានរួមចំណែកយ៉ាងសកម្មក្នុងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលសំដៅឈានទៅសម្រេចបាននូវគោលនយោបាយ អភិបាលកិច្ចល្អ ការអភិវឌ្ឍដោយចីរភាព សមធម៌ និងកាត់បន្ថយភាព

ក្រីក្រ[143]។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ បណ្តាស្ថាប័នគ្រប់គ្រងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះរួមមាន៖ ក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី ខេត្ត ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករ គ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកចំណេញ និងសហ-គ្រាសវិនិយោគឯកជនផង[144]។ នេះជាយន្តការមួយដើម្បីទាក់ទាញដល់ការជឿជាក់របស់វិនិយោគិនជាតិ និងអន្តរជាតិ ក៏ដូចជាភ្នាក់ងារផ្តល់ជំនួយ និងដៃគូអភិវឌ្ឍនានារបស់កម្ពុជា ជាពិសេសរវាងអ្នកនយោបាយ មន្ត្រីរាជការ និងប្រជាពលរដ្ឋខ្មែរទូទៅ។ សវនកម្ម ជាយន្តការសកលដ៏មានសក្តានុពលបំផុតដែលជំរុញឲ្យការអភិវឌ្ឍទាំងវិស័យសាធារណៈនិងឯកជនបានប្រើប្រាស់ជាម៉ែត្រសម្រាប់វាស់ស្ទង់មួយដ៏មានប្រសិទ្ធភាពបំផុតលើសកម្មភាពប្រព្រឹត្តរបស់ប្រតិបត្តិករនានាដើម្បីឲ្យមានការទទួលខុសត្រូវ និងទទួលយកបាន។

[143] ជួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ១។
[144] ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០០ មាត្រា២។

### ក-និយមន័យ

ជាដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយប្រមូលយក និងវាយតម្លៃលើវត្ថុតាងទាំងឡាយតាមគោលបំណងដែលបានណត់ទុក និងដោយអនុលោមទៅតាមការជានាអះអាងពីសកម្មភាព និងព្រឹត្តិការណ៍សេដ្ឋកិច្ចនានាទៅតាមកម្រិតមួយដែលមានភាពសុីចង្វាក់ទៅវិញទៅមករវាងការអះអាងនោះ និងលក្ខណៈវិនិច្ឆ័យដែលត្រូវបានបង្កើតឡើងសម្រាប់បកស្រាយលទ្ធផលទាំងនោះផ្តល់ដល់អ្នកប្រើប្រាស់។ ម៉្យាងទៀតសវនកម្ម គឺជាការត្រួតពិនិត្យឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ និងធ្វើការបញ្ជាក់ ឬបញ្ចេញយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ។

ក្នុងន័យនេះ អង្គភាពមានន័យថា ជាស្ថាប័នធ្វើសកម្មភាពសំដៅរកប្រាក់ចំណេញ ឬស្ថាប័នធ្វើសកម្មភាពមិនសំដៅរកប្រាក់ចំណេញ[145]។

និយាយតាមន័យទូលាយ សវនកម្ម គឺជាសេវាដែលរៀបចំឡើងដើម្បីឆែកឆេរប្រមូលភស្តុតាង វាយតម្លៃលើរបាយការណ៍ ដែលរៀបចំឡើងដោយគណនេយ្យករ។

គណនេយ្យ គឺជាដំណើរការកត់ត្រា ធ្វើចំណាត់ថ្នាក់ និងសង្ខេបព្រឹត្តិការណ៍សេដ្ឋកិច្ចតាមលក្ខណៈឡូសុិក( Logic )មួយក្នុងគោលបំណងដើម្បីផ្តល់ព័ត៌មានហិរញ្ញវត្ថុសម្រាប់ធ្វការសម្រេចចិត្ត។

---

[145] ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ២

សវនកម្ម ព័ត៌មានដែលបានកត់ត្រា ឆ្លុះបញ្ចាំងត្រឹមត្រូវជាមួយព្រឹត្តិការណ៍សេដ្ឋកិច្ចដែលកើតឡើងក្នុងអំឡុងពេលការិយបរិច្ឆេទ[146]។ សវនកម្មកើតចេញពីពាក្យថា Audio មានន័យថា Listening ឬ Listener ។ សវនកម្ម គឺជាដំណើរការដែលក្នុងនោះបញ្ជីការគណនេយ្យប្រចាំឆ្នាំរបស់ផ្នែកសាធារណៈ និងផ្នែកឯកជនត្រូវតម្រូវឲ្យមានការត្រួតពិនិត្យផ្ទៃក្រៅ ដើម្បីផ្តល់នូវការធានាដោយឯករាជ្យថាតើបញ្ជីគណនេយ្យទាំងនោះ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារវិជ្ជាជីវៈ និងស្តង់ដារគតិតយុត្តពាក់ព័ន្ធឬទេ និងត្រូវផ្តល់មតិពិត និងត្រឹមត្រូវលើកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពរងសវនកម្ម។ បច្ចុប្បន្ននេះពាក្យ សវនកម្ម ត្រូវបានគេប្រើជាទូទៅ និងមានន័យថា ការត្រួតពិនិត្យដោយលម្អិត និងពិនិត្យឡើងវិញនូវប្រព័ន្ធដំណើរការ និងទិន្នផល។ ដូច្នេះនិយមន័យសវនកម្មត្រូវបានកំណត់ថា ជាដំណើរការដោយប្រព័ន្ធក្នុងការប្រមូល និងវាយតម្លៃដោយមិនលម្អៀងនូវភស្តុតាងសវនកម្មលើការអះអាងអំពីព្រឹត្តិការណ៍ និងសកម្មភាពនៃសេដ្ឋកិច្ចដើម្បីបញ្ជាក់ឲ្យឃើញពីកម្រិតឆ្លើយតបរវាងការអះអាងរបស់អ្នកគ្រប់គ្រង និងលក្ខណៈវិនិច្ឆ័យបង្កើតឡើង ហើយចុងក្រោយផ្សព្វផ្សាយលទ្ធផលនេះទៅអ្នកប្រើប្រាស់ដែលពាក់ព័ន្ធ។

---

[146] ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៣

**ខ-គោលបំណងនៃការធ្វើសវនកម្ម**

-ដើម្បីធ្វើឲ្យប្រសើរនូវការទទួលខុសត្រូវ និងការគ្រប់គ្រងវិស័យសាធារណៈដោយបន្ថែមតម្លៃតាមរយៈកម្មវិធីទទួលផលល្អសម្រាប់សវនកម្ម និងផលិតផលពាក់ព័ន្ធដូចជា ការណែនាំ។

-ដើម្បីជួយអ្នកតំណាងរាស្ត្រក្នុងការអនុវត្តការត្រួតពិនិត្យផ្នែកច្បាប់ឲ្យមានប្រសិទ្ធភាព។

**គ-កំណត់បញ្ហា**

ដើម្បីកំណត់បញ្ហាលើការធ្វើសវនកម្មឲ្យមានតម្លាភាព ប្រសិទ្ធភាព ប្រសិទ្ធផលខ្ពស់នោះ តើយើងត្រូវអនុវត្តយុទ្ធសាស្ត្រការធ្វើសវនកម្មបែបណា?

**ឃ-គោលបំណងនៃការធ្វើសវនកម្ម**

គោលបំណងនៃមេរៀននេះ ចង់ឲ្យនិស្សិតបានយល់ដឹងពីច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងការធ្វើសវនកម្ម។

-អ្វីទៅហៅថា សវនកម្ម(Auditing) ?

-សវនកម្មមានផលប្រយោជន៍អ្វីខ្លះដល់អង្គភាពរងសវកម្ម

-ការធ្វើសវនកម្មនៅក្នុងប្រទេសកម្ពុជាផ្អែកតាមស្តង់ដារអន្តរជាតិដែរឬទេ?

-ការធ្វើសវនកម្មរួមចំណែកក្នុងការកាត់បន្ថយថវិកាជាតិដែរឬទេ? ម្យ៉ាងទៀតជួយផ្តល់ឲ្យនិស្សិតយល់ដឹងពីសារសំខាន់ពីការធ្វើសវនកម្ម និងសវនកម្មជួយអ្វីខ្លះដល់អង្គភាពរបស់ពួកគេ។ ក្រៅពីនេះ ជាពិសេសគឺចង់ផ្តល់ឲ្យនិស្សិតដែលមានបំណងចង់ក្លាយជា

សវនករនាពេលអនាគត។

**ង-គម្រោងនៃការធ្វើសវនកម្ម**

ដើម្បីធ្វើសវនកម្មគឺសវនករត្រូវមានគម្រោងការឲ្យបានច្បាស់លាស់ក្នុងការធ្វើសវនកម្មលើអង្គភាពរងសវនកម្ម។ សវនករត្រូវកំណត់ឲ្យបានច្បាស់នូវបញ្ហាដែលត្រូវសិក្សាស្រាវជ្រាវ ដូចជា៖

-ប្រធានបទសវនកម្ម

-គោលបំណង វិសាលភាព និងដែនកំណត់សវនកម្ម

-អង្គភាពរងសវនកម្ម និងអង្គភាពពាក់ព័ន្ធ

-រយៈពេលសវនកម្ម។

**ច-ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ជាទូទៅការសិក្សាស្រាវជ្រាវ សុទ្ធតែមានដែនកំណត់របស់វាច្បាស់លាស់ទាំងអស់។ ម្យ៉ាងទៀតដោយសារការស្រាវជ្រាវមានរយៈពេលខ្លីដូច្នេះដើម្បីឲ្យការសិក្សាស្រាវជ្រាវបានស៊ីជម្រៅទៅលើប្រធានបទដែលបានកំណត់នោះ សវនករមិនបានធ្វើការសិក្សាទៅលើផ្នែកផ្សេងៗទៀតដូចជា ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងគណនេយ្យ ឬក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការដែលមានឥទ្ធិពលទៅលើប្រតិបត្តិការនោះទេ។ ពោលគឺសវនករសិក្សាផ្តោតទៅលើប្រធានបទដែលក្រុមសវនករបានកំណត់ និងឯកសារពាក់ព័ន្ធក្នុងាការធ្វើសវនកម្មតែប៉ុណ្ណោះ។

**ឆ-វិធីសាស្ត្រនៃការស្រាវជ្រាវ**

គោលបំណងសំខាន់នៃការស្រាវជ្រាវ និងចងក្រងនេះ គឺចង់

ស្វែងយល់ឲ្យបានច្បាស់អំពីនីតិវិធី ការរៀបចំរបាយការណ៍ និងហានិភ័យ ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម។ ដូច្នេះដើម្បីឲ្យសម្រេចបាននូវគោលបំណងខាងលើនោះ ក្រុមស្រាវជ្រាវត្រូវការនូវប្រភពទិន្នន័យមួយចំនួនជាសំខាន់ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយ-ការណ៍សវនកម្ម។

**២-ប្រភេទនៃសវនករ** ( Types of Auditor )

សវនករមានច្រើនប្រភេទ ប៉ុន្តែត្រូវបានសង្ខេបតែបីប្រភេទដូចតទៅ៖

-សវនករផ្ទៃក្នុង (Internal Auditor )

-សវនករផ្ទៃក្នុង ( External Auditor )

-សវនកររដ្ឋាភិបាល ( Government Auditor )

**២-ក-សវនករផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង** ( Internal Auditor and Audit )

សវនករផ្ទៃក្នុង គឺជាសវនករបម្រើការឲ្យក្រុមហ៊ុន ស្ថាប័ន ឬអង្គភាពរបស់រដ្ឋាភិបាលនិងតាមអង្គភាពផ្សេងៗ។ សវនករផ្ទៃក្នុងត្រូវតែឯករាជ្យ មិនលម្អៀង និងអនុវត្តការងារសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មផ្ទៃក្នុងដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានសវនកម្មផ្ទៃក្នុងនៅសហរដ្ឋអាមេរិក។ ចំពោះសវនកម្មផ្ទៃក្នុងរបស់រដ្ឋាភិបាលត្រូវអនុវត្តការងារដោយអនុលោមទៅតាមស្តង់ដារវិជ្ជាជីវៈ

សវនកម្មផ្ទៃក្នុងដែលចេញផ្សាយដោយរដ្ឋាភិបាល ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញ[147]នៃព្រះរាជាណាចក្រកម្ពុជា។

**២-ខ-និយមន័យ**

សវនករផ្ទៃក្នុង បង្កើតឡើងដោយអង្គភាពមានមុខងារវាយតម្លៃ និងពិនិត្យសកម្មភាពដោយឯករាជ្យ និងផ្តល់សេវាកម្មដល់អង្គភាពនោះវិញ។

**២-គ-គោលបំណង**

សវនករផ្ទៃក្នុងនេះ គឺដើម្បីជួយដល់សមាជិកនៃអង្គភាពឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ សវនកម្មផ្ទៃក្នុង ផ្តល់ឲ្យអង្គភាពនូវការវិភាគ ការវាយតម្លៃ អនុសាសន៍ ការប្រឹក្សា និងការងារដែលពាក់ព័ន្ធនឹងសកម្មភាពត្រួតពិនិត្យឡើងវិញ។

**២-ឃ-តួនាទី**

-ពិនិត្យឡើងវិញលើកម្មវិធី ឬកិច្ចប្រតិបត្តិការថាតើលទ្ធផលនានាមានសង្គតភាពជាមួយគោលដៅដែលបង្កើតឡើងឬទេ?

-ពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងដែលបានបង្កើតឡើងដើម្បីធានាការអនុលោមតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និងកិច្ចសន្យានានា។

-ពិនិត្យឡើងវិញលើភាពអាចទុកចិត្តបាន និងភាពសុច្ចរិតនៃព័ត៌មានហិរញ្ញវត្ថុ ប្រតិបត្តិការ និង មធ្យោបាយប្រើប្រាស់ដើម្បីកំណត់

---

[147] ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៤

ឲ្យឃើញ វាស់វែង ចាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មាននេះ។

-វាយតម្លៃអំពីប្រសិទ្ធភាព ការទទួលផលល្អនៃធនធានដែលបានប្រើប្រាស់។

-កំណត់ឲ្យបានច្បាស់លាស់នូវចំណុចបញ្ហា និងគោលនយោបាយសម្រាប់សកម្មភាពកែលម្អមុនពេលបញ្ហានានាកើតឡើងដែលអាចនាំឲ្យប៉ះពាល់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការ។

-ជំរុញការផ្សព្វផ្សាយជាចំហ និងបង្កើតទំនាក់ទំនងជាវិជ្ជមានក្នុងចំណោមសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្រៅ បុគ្គលិក អ្នកគ្រប់គ្រង និងគណៈកម្មការសវនកម្ម[148]។ ការធ្វើសវនកម្មផ្ទៃក្នុង សកម្មត្រូវអនុលោមទាំងស្រុងទៅតាមច្បាប់ (Compliance Audit) ឬបទបញ្ជាសេចក្តីណែនាំដែលបានចែងឬកំណត់ទុករួចហើយ។

ជាមួយគ្នានេះ យើងក៏មានការត្រួតពិនិត្យទៅលើកិច្ចប្រតិបត្តិការ (Performance Audit or Operation Audit)ផងដែរ។ ទោះបីយ៉ាងណាក៏ដោយការត្រួតពិនិត្យ ឬការធ្វើសវនកម្មត្រូវផ្អែកលើស្មារតីនៃសន្សំសំចៃ(Economy) ប្រសិទ្ធភាពការងារ (Effectiveness) និងប្រសិទ្ធផល(Efficiency) ដែលនេះជាទ្រឹស្តីដ៏មានប្រជាប្រិយភាព (3E )របស់លោកស្រី ម៉ាហ្គារ៉េត ថាចឈ័រ(Margaret Thatcher) និងទ្រឹស្តី(4E)rbsសហរដ្ឋអាមេរិក ពោលគឺ សន្សំសំចៃ(Economy) ប្រសិទ្ធភាពការងារ (Effectiveness) និងប្រសិទ្ធផល(Efficiency)

---

148 ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៥

ហើយបន្ថែម E= Embrace មួយទៀត។ ជាមួយនឹង គោលការខាងលើ សវនកម្មផ្ទៃក្នុងក៏មានការត្រួតពិនិត្យធ្វើឡើងម្តងម្កាលផងដែរ សកម្មភាពនេះ កើតមានឡើងនៅពេលដែលមានបទបញ្ជារបស់ថ្នាក់លើដើម្បីត្រួតពិនិត្យខាងហិរញ្ញវត្ថុ( Financial adit ) តែម្តង។

**៣-សវនករផ្ទៃក្រៅ**( External Audit )

សវនករផ្ទៃក្រៅ ជាសវនករឯករាជ្យមិនស្ថិតនៅក្រោមអង្គភាព ក្រសួង ស្ថាប័នណាឡើយ។ សវនកម្មផ្ទៃក្រៅភាគច្រើនអនុវត្តភាគច្រើនអនុវត្តលើការត្រួតពិនិត្យលើ៖

-សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ( Financial Statement Audit)

-សវនកម្មលើប្រតិបត្តិការ ( Operational/ Management Audit)

-សវនកម្មលើការអនុលោមតាមច្បាប់ និងលិខិតបទដ្ឋាន ( Compliance Audit )

**៣-១-សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** ( Financial Statement Audit )

ចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនករត្រូវធ្វើការវិភាគលើប្រតិបត្តិការ និងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ដែលកំពុងធ្វើសវនកម្មនោះថាតើរបាយការណ៍ទាំងនោះអនុលោមតាម ស្តង់ដារគណនេយ្យដែលអាចទទួលយកបានដែរ ឬទេ[149] ?

---

[149] ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៥

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ គឺជាការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពរងសវនកម្មជាមួយគោលបំណងចម្បង ហើយរកឲ្យឃើញថា តើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវតាមស្ថានភាពហិរញ្ញវត្ថុ លទ្ធផលប្រតិបត្តិការ និងចលនាសាច់ប្រាក់ ដោយអនុលោមតាមគោលការណ៍គណនេយ្យដែលអាចទទួលយកបានជាទូទៅដែរឬទេ? ចំណែកសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុផ្នែកសាធារណៈ មានភាពស្មុគស្មាញជាងការអនុវត្តលើផ្នែកឯកជន។ ភាពស្មុគស្មាញផ្នែកសាធារណៈ គឺការទំនាក់ទំនងតាមឋានានុក្រមនៃអង្គភាពរងសវនកម្មនៅគ្រប់កម្រិត ដែលដាក់បន្ទុកការលំបាកផ្នែកគំនិត និងវិធីសាស្ត្ររបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ ការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុ គួរតែត្រូវបានអនុវត្តឲ្យដល់កម្រិតមួយដែលមូលដ្ឋានសនិទានត្រូវបានទទួលដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុ។ វិធីសាស្ត្រ និងបច្ចេកទេសនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ អាស្រ័យទៅតាមកម្រិតទំហំនៃលក្ខណៈវិសាលភាព និងគោលបំណងសវនកម្ម និងពឹងផ្អែកផងដែរទៅលើចំណេះដឹង និងការវិនិច្ឆ័យរបស់សវនករ។ សវនករត្រូវការវិភាគឲ្យបានលម្អិតលើរបាយការណ៍ហិរញ្ញវត្ថុ និងធានាថា៖

**៣-១-១**-របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យដែលអាចទទួលយកបានជាទូទៅ

**៣-១-២**-របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាមួយការពិចារណាដោយយកចិត្តទុកដាក់គ្រប់កាលៈទេសៈនៃអង្គភាពសវនកម្ម។

**៣-១-៣**-ការបោះផ្សាយរបាយការណ៍ត្រូវបង្ហាញឲ្យបានគ្រប់គ្រាន់នូវធាតុនៃរបាយការណ៍ហិរញ្ញវត្ថុ

**៣-១-៤**-ធាតុផ្សេងៗនៃរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃ វាស់វែង និងបង្ហាញយ៉ាងត្រឹមត្រូវ។

**៣-១-៥-សវនកម្មលើប្រតិបត្តិការ** ( Operational/ Management Audit)

សវនកម្មលើប្រតិបត្តិការ ជាការវាយតម្លៃលើភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ធនធានសាធារណៈ។ សវនករវិភាគលើភាពសន្សំសំចៃ និងប្រសិទ្ធភាពតម្រូវការ និងការប្រើប្រាស់ធនធានរួមវិភាគលើប្រសិទ្ធផល។ សវនកម្មក៏ពិនិត្យផងដែរលើភាពត្រឹមត្រូវនៃដំណើរការ និងសមិទ្ធផលដែលសម្រេចបាន។ សវនកម្មលើប្រតិបត្តិការអាស្រ័យទៅលើវិសាលភាព និងលក្ខណៈសវនកម្មជាសំខាន់។ សវនកម្មអាចផ្តោតទៅលើសំណួរថាតើធនធានត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវដែរឬទេ ឬផ្តោតទៅលើការវាយតម្លៃនៃផលប៉ះពាល់គោលនយោបាយ និងកម្មវិធីនានា[150]។

សវនកម្មលើប្រតិបត្តិការ គឺជាសវនកម្មលើការសន្សំសំចៃ

---

[150] ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៦

(Economy) ប្រសិទ្ធភាព(Effectiveness) ប្រសិទ្ធផល (Efficiency) ដែលជាមួយគ្នានេះអង្គភាពសវនកម្មត្រូវប្រើប្រាស់ធនធានសម្រាប់អនុវត្តការទទួលខុសត្រូវរបស់ខ្លួន។

**៣-១-៦-សវនកម្មលើការអនុលោមតាមច្បាប់ និងលិខិតបទដ្ឋាន** (Compliance Audit)

សវនកម្មលើការអនុលោមតាមច្បាប់គឺជាការត្រួតពិនិត្យដើម្បីបញ្ជាក់លើភាពស្របច្បាប់នៃប្រតិបត្តិការរបស់អង្គភាពរងសវនកម្ម ដោយផ្តោយទៅលើរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច ការអនុវត្តកម្មវិធី និងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

សវនករមានលក្ខណៈសំខាន់ជាពិសេសចំពោះអ្នកធ្វើការសម្រេចចិត្តដោយចង់ដឹងថាតើច្បាប់ និងបទប្បញ្ញត្តិទាំងឡាយត្រូវបានប្រតិបត្តិដែរ ឬទេ ហើយតើការអនុវត្តទាំងនោះសម្រេចបានលទ្ធផលដូចបានគ្រោងទុកឬទេ ហើយក្នុងករណីមិនបានដូចការគ្រោងទុកនោះ តើត្រូវមានវិធានការអ្វីខ្លះដែលត្រូវដាក់ចេញ។

ជាមួយប្រភេទនៃសវនកម្ម ក៏មានដែរដែរ សវនកម្មរដ្ឋាភិបាល គោលការនៃការធ្វើសវនកម្ម ការរៀបចំផែនការធ្វើសវនកម្ម ការអនុវត្តការងារធ្វើសវនកម្ម ការរៀបចំរបាយការណ៍សវនកម្ម និងចុងក្រោយការតាមដានការអនុវត្ត អនុសាសន៍នៃសវនកម្មទាំងមូលតែម្តង។ ដោយឃើថា ការសិក្សារបស់យើងជាការការលើកឡើងអំពីគោលបំណងរួមនៃការសិក្សាមុខវិជ្ជារដ្ឋបាលសាធារណៈនេះ តើត្រូវការ

យល់ដឹងអំពីអ្វីខ្លះតែប៉ុណ្ណោះ។ យើងដឹងថា ដើម្បីស្វែងយល់ឲ្យស៊ីជម្រៅលើមុខវិជ្ជានីមួយៗ យើងនឹងសិក្សាដោយឡែកយ៉ាងលម្អិត។

សវនកម្មមានការប្រែប្រួលទៅប្រភេទផ្សេងៗគ្នា ដូចជា៖

**៣-១-៧-សវនកម្មស៊ើបអង្កេត( Forensic or Investigation Audit)**

ជាសវនកម្មដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ ស៊ើបអង្កេតលើករណីដែលមិនបានកំណត់ទុកជាមុន ហើយវាបានធ្វើឲ្យមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ពីសវនករក្នុងការកំណត់ពីសុពលភាពចោទប្រកាន់លើកំហុសឆ្គង និងការធ្វើខុសក្នុងផ្នែកហិរញ្ញវត្ថុផ្សេងៗ។

**៣-១-៨-សវនកម្មលើបរិស្ថាន( Environment Audit)**

សវនកម្មប្រភេទនេះ គឺវាយតម្លៃលើទឹកស្អាត កាកសំណល់ការបំពុល ការប្រែប្រួល អាកាសធាតុ និងការធ្វើឲ្យចុះខ្សោយស្រទាប់អូនសូន។ល។

**៣-១-៩-សវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា( Information Technology Audit )**

គឺជាដំណើរការប្រមូល និងវាយតម្លៃភស្តុតាងដើម្បីកំណត់ថាតើប្រព័ន្ធកុំព្យូទ័របានរៀបចំ ដើម្បីថែរក្សាសុច្ចរិតភាពនៃព័ត៌មាន និងការពារទ្រព្យសម្បត្តិព្រមទាំងធ្វើឲ្យគោលដៅរបស់អង្គភាពសម្រេចនូវលទ្ធផលល្អ ហើយប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធភាព។

ជារួម គ្រប់ដំណើរការនៃការធ្វើសវនកម្ម ទោះបីស្ថាប័នសាធារណៈក្តី និងឯកជនក្តី វាជាតម្រុយនៃការពង្រឹងការទទួលខុសត្រូវរបស់មន្ត្រី និងបុគ្គលិក ភ្នាក់ងារប្រតិបត្តិការការងារទាំងអស់។ ក្នុងន័យនេះ សវនករត្រូវតែដើរតួរជាអ្នកឯករាជ្យមួយរយភាគរយ បំពេញការងារប្រកបដោយវិជ្ជាជីវៈ ទោះបីកាលៈទេសៈណាមួយ ឬក្រោមសំពាធបុគ្គលណាម្នាក់ក៏ដោយ។ ស្ថាប័នមួយដែលមានមន្ត្រី ឬភ្នាក់ងារធ្វើការប្រកបដោយវិជ្ជាជីវៈមានការទទួលខុសត្រូវសកម្ម ជាភ័ព្វសំណាងធំនៃស្ថាប័ននោះហើយ។

## ៤-សេចក្តីសន្និដ្ឋាន

ជាថ្មីម្តងទៀត ស្ថាប័នសវនកម្មបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ដើម្បីចូលរួមពង្រឹងប្រសិទ្ធភាពការងារដឹកនាំ ក៏ដូចជាការជំរុញឲ្យមានតម្លាភាព យុត្តិធម៌ និងការជឿទុកចិត្តពីសាធារណជននៅក្នុងសង្គមកម្ពុជាទាំងបច្ចុប្បន្ន និងថ្ងៃអនាគត។ រាល់ការងារទាំងឡាយដែលមិនបានត្រួតពិនិត្យមិនអាចសន្មតថា ការងារនោះមានការទទួលខុសត្រូវយ៉ាងណានោះទេ ផ្ទុយទៅវិញ ការត្រួតពិនិត្យដើម្បីឈានទៅដល់ការដាក់ទណ្ឌកម្ម ការលើកទឹកចិត្ត ការសរសើរ ឬការផ្តល់រង្វាន់ និងតម្លើងឋានន្តរស័ក្តិ គឺជាវិធីមួយដ៏ល្អដើម្បីពង្រឹងឲ្យស្ថាប័នអនុវត្តកាន់តែមានការកក់ក្តៅ និងសុវត្ថិភាពការងារ។

# ឯកសារយោង

## ១-ព្រះរាជក្រម និងច្បាប់

-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-ព្រះរាជក្រមលេខជស/រកម០៦៩៦/០៣ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅសហគ្រាសសាធាណៈចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦។

-ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០១២

## ២-អនុក្រឹត្យ

-អនុក្រឹត្យលេខ១៣ អនក្រ.បក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥

-អនុក្រឹត្យលេខ៤១អនក្រ.បកស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧

-អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការស្នងការគណនីសហគ្រាសសាធារណៈ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧

-អនុក្រឹត្យស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាបជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧។

-អនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនសម្ភារៈកសិកម្ម លេខ១២ អនក្រ.កប ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩

-អនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនហ្វ្រីនត្រេដ លេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ១៩៩៨

-អនុក្រឹត្យស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨

-អនុក្រឹត្យលេខ៤១ អនក្រ.បក ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧

**៣-ប្រកាស និងសារាចរណ៍**

-ប្រកាស០១០សហវ.ប្រកស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធាណៈ ឆ្នាំ២០១៩

-ប្រកាសលេខ៨៥១សហវ.ប្រក ស្តីពីការរៀបចំផែនការលទ្ធកម្ម ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧

-ប្រកាសលេខ២៤៩ សហវប្រក ស្តីពី ការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

-ប្រកាស១៨៦៦សហវប្រ.កស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម ឆ្នាំ២០១៤

-ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ៣៨១សហវប្រកចុះថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០១០

-ប្រកាសលេខ៩៩៧សហវ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធាណៈ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧

-សារាចរណែនាំលេខ០០៥សហវ.ទរ ស្តីពីអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅសហគ្រាសសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧

**៤-សៀវភៅ**

-មេធាវី អ៊ីវ ប៉ូលី៖ នីតិក្រុមហ៊ុន ឆ្នាំ២០០៨

-ដួង កណ្ណារ៉ា៖ ទ្រឹស្តី និងអនុវត្តសវនកម្ម ឆ្នាំសិក្សា២០០៦-២០០៧

## ៥-ស្ថាប័ន

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ សេចក្តីណែនាំលេខ០០២ សហវ អលសា ចុះថ្ងៃទី២៨ ខែ មករា ឆ្នាំ២០១៤

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ Procurement Manual Volume I ឆ្នាំ២០១២

-ព្រឹត្តិបត្រស្ថិតិលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០

## ៦-គេហទំព័រ

-https://senate.gov.kh/about-senate/senate-history/

-https://km.wikipedia.org/wiki/

-https://www.nec.gov.kh/khmer/

-គេហទំព័រផ្សារមូលបត្រកម្ពុជា csx.com.kh

## អំពីអ្នកនិពន្ធ



លោក សេង ប៊ុនធឿន កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧២ នៅភូមិសមរលាវ ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។ លោកបានចូលសិក្សាបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅសាលាកម្រិតសិក្សាទី១ (បឋមសិក្សា) សមរលាវ ក្នុងឆ្នាំ១៩៨១ សាលាមធ្យមសិក្សាកម្រិត១(ឱប្ញូម) ព្រៃល្វា(ទីរួមស្រុកព្រៃកប្បាស)ក្នុងឆ្នាំ១៩៨៥។ លោកត្រូវបានបងជីទូតមួយនាំយកទៅឲ្យរៀននៅសាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការនៃវិទ្យាល័យតាកែវ (បច្ចុប្បន្នវិទ្យាល័យ ជាស៊ីម តាកែវ) ពីឆ្នាំ១៩៨៨ដល់ឆ្នាំ១៩៩២ដើម្បីសិក្សាយកសញ្ញាបត្រមធ្យមសិក្សាកម្រិត២(BACII)។ លោកជានិស្សិតអាហារូបករណ៍ ហើយទទួលបានបរិញ្ញាបត្រ នីតិសាស្ត្រ ពីមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (បច្ចុប្បន្នសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) នាឆ្នាំ១៩៩៨ និងនៅឆ្នាំ២០០១ ទទួលបានបរិញ្ញាបត្រ ប្រវត្តិវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឆ្នាំ២០០៤ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយនៅឆ្នាំ២០០៩ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែក អប់រំវិធីសាស្ត្របង្រៀនភាសាអង់គ្លេស (MEd-TESOL) ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាដដែល។ នៅឆ្នាំ២០១២ លោកទទួលបានសញ្ញាបត្របណ្ឌិតទស្សនៈវិជ្ជាផ្នែកនីតិសាស្ត្រ (PhD in Law) ពីរាជបណ្ឌិត្យសភាកម្ពុជា។

មុខជំនាញសិក្សាវគ្គខ្លីៗជាច្រើនដែលលោកបានសិក្សា ជាពិសេស វិជ្ជាជីវៈសារព័ត៌មាន (Professional Journalism) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឧបត្ថម្ភដោយមូលនិធិអាស៊ី (Asia Foundation)។ ធ្លាប់បានឧនសម្បទានៅថ្ងៃ១១រោច ខែចេត្រ ឆ្នាំម្សាញ់ ត្រីស័ក ព.ស២៥៤៥ ត្រូវនឹងថ្ងៃទី៨ ខែមេសា គ.ស២០០២។

ចំពោះបទពិសោធន៍ការងារ លោកធ្លាប់បម្រើការងារជាជំនួយការឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជានាយកខុទ្ទកាល័យ ជាគ្រូបង្រៀននៅតាមអង្គការ និងគ្រឹះស្ថានឧត្តមសិក្សានានា ក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន លោកជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងជាសមាជិកសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា។

សៀវភៅនេះបានរៀបចំឡើងដោយអនុលោមទាំងស្រុងតាមកម្មវិធីសិក្សានៃគ្រឹះស្ថានសិក្សាផ្ទាល់។ ដោយសារតែមុខវិជ្ជារដ្ឋបាលសាធារណៈ ជាមុខវិជ្ជាមួយតម្រូវឲ្យអ្នកសិក្សាស្គាល់នូវគោលការណ៍សំខាន់ៗមានជាអាទិ៍ៈរបៀបដឹកនាំ របៀបគ្រប់គ្រង ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខភាព អនាម័យ ការអភិវឌ្ឍទាំងអស់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។

*គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ*

*ក្រសួងអប់រំ យុវជន និងកីឡា*

*មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍*

រក្សាសិទ្ធិគ្រប់យ៉ាង

2021

ISBN 978999-63-810-2-7